# ឯកសហាស្សរាត្រី

# មួយពាន់មួយយប់



# រឿងឯកសហស្សរាត្រី(១)

# ឬមួយពាន់មួយយប់

## (ជារឿងអារ៉ាប់)

តាមពង្សាវតារស្តេចអំពីបុរាណ ក្នុងដែនពែរ្ស៊ី ដែលបានផ្សាយព្រះរាជអាណាខេត្ត ទៅក្នុងស្រុកឥណ្ឌា និងនានាប្រទេស ដែលនៅក្នុងរាជោវាទ នៃស្តេចស្រុកពែរ្ស៊ីព្រមទាំងបរិវេណ ដែលនៅខាងនាយទន្លេគង្គា ដរាបដល់ទល់នឹងស្រុកចិន នោះបានសេចក្តីថាក្នុងកាលជាយូរង្វែងមកហើយ មានស្តេច១អង្គ គ្រងរាជ្យ ក្នុងនគរពែរ្ស៊ីប្រកបដោយសុចរិតយុត្តិធម៌ បច្ចាមិត្រ គ្រប់ទិសានុទិសក៏រអាខ្លបខ្លាចនូវបុញ្ញរិទ្ធិ ហេតុអំពីទ្រង់បានបង្អាត់បង្ហឹកសេនាទាហាន បម្រុងចាំការពារព្រះមហានគរជានិច្ចឥតមានធ្វេសប្រហែសមួយវេលា។

ក្នុងរជ្ជកាលនោះ គ្រឿងឧបភោគបរិភោគចម្រើនសម្បូរហូរហៀរ ឥតមានខ្វះចន្លោះ របស់អ្វីដែលមនុស្សលោកត្រូវការប្រើក្នុងជាន់នោះ។ ព្រះមហាក្សត្រអង្គនេះ មានព្រះរាជបុត្រា២ព្រះអង្គបុត្រច្បងទ្រង់នាមថា សារ្យា ប្រកបដោយរូបឆោមនិងសតិបញ្ញាឥតមាន

---

១- ពាក្យថាឯកសហស្សរាត្រីជាភាសាសំស្ក្រឹត ប្រែថា “មួយពាន់មួយយប់” បានជាខ្ញុំយកមកប្រើក្នុងទីនេះព្រោះយល់ឃើញថាមានសម្លេងពីរោះជាងពាក្យខ្មែរ ។

ល្បៀងអំពីព្រះបិតា ឯព្រះរាជកុមារដែលជាអនុជទ្រង់នាមថា សាសី-ណង់ ក៏មានលក្ខណៈមិនឃ្លាតឆ្ងាយប៉ុន្មានពីព្រះរៀម ។

លុះគ្រងរាជ្យសម្បត្តិតមកជាយូរអង្វែងឆ្នាំ ស្តេចក៏ទីវង្គតទៅ ទើបព្រះកុមារ សារ្យាជារាជបុត្រច្បងគ្រងជាតំណាតព្រះរាជវង្សមក ឯព្រះកុមារ សាសីណង់ គ្មានចំណែកអ្វីក្នុងរាជសម្បត្តិនោះឡើយ ព្រោះច្បាប់សម្រាប់ព្រះនគរមិនត្រូវឱ្យបាន ទ្រង់ក៏ចិញ្ចឹមជីវិតនៅជាប្រក្រតីហាក់ដូចជាជនធម្មតាដូច្នោះឥតមានច្រណែនឫស្យា ដល់ភ័ព្វសំណាងស្តេចព្រះរៀមឡើយ ព្រះហឫទ័យប្រាថ្នាឱ្យតែព្រះរៀមសប្បាយក្នុងរាជសម្បត្តិប៉ុណ្ណោះ។ ព្រះបាទសារ្យាកាលណាបានឃើញអធ្យា-ស្រ័យ ដ៏ប្រសើររបស់ព្រះអនុជក៏ទ្រង់មានសេចក្តីប្រតិពទ្ធហើយទ្រង់ព្រះតិរិះ នឹងចែកព្រះនគរឱ្យព្រះអនុជគ្រងផង ទើបទ្រង់ប្រគល់ក្រុងតារតារីឱ្យព្រះអនុជ កាលណាបានទទួលយករាជបរិវេណនោះ ក៏តាំងព្រះរាជនិវេសន៍នៅនាតំបន់សាមារក័ណ្ឌ ។

ស្តេចទាំងពីរព្រះអង្គនេះ គ្រងរាជបានដល់ទៅ១០ឆ្នាំមិនដែលបានយាងទៅមករកគ្នា លុះសម័យ១ព្រះបាទសារ្យាភ្នកព្រះទ័យចង់ជួបនឹងព្រះអនុជ ក៏បានចាត់រាជទូតឱ្យទៅអញ្ជើញព្រះបាទសាសីណង់ដ៏ជាព្រះអនុជមកវេលានោះប្រើអគ្គមហាសេនាឱ្យនាំសកលយោធាសមនឹងរាជសក្តានុភាពទៅហែហម ។ លុះរាជទូតទៅទៀបដល់ជិតក្រុងសាមារក័ណ្ឌ ព្រះបាទសាសីណង់ទ្រង់បានជ្រាបសេចក្តីក៏នាំ

អស់សេនាសេនីយ៍សព្វមុខមន្ត្រី ចេញទៅទទួលដោយរួសរាន់ ហើយដណ្ដឹងសួរនូវសុខទុក្ខនៃសម្ដេចព្រះរៀមជាដើម ឯអគ្គមហាសេនាដ៏ជារាជទូតក៏ថ្វាយសេចក្ដីដោយអណ្ដាប់ដរាបដល់អវសាន ទើបក្រាបទូលរឿងដែលខ្លួនទទួលកិច្ចការនាំមក លុះព្រះបាទសាសីណង់បានជ្រាបរឿងច្បាស់សព្វគ្រប់ ក៏មានព្រះបន្ទូល តបនឹងអគ្គរាជទូតវិញថា "ម្នាលអគ្គរាជទូត តាមសេចក្ដីដែលអ្នកព័ណ៌នានោះ ឃើញថាសម្ដេចព្រះជេដ្ឋាមានសេចក្ដីរលឹកនឹកដល់យើងជាខ្លាំង ហេតុនេះយើងមានអំណរពន់ពេកណាស់ ព្រោះសមនឹងគំនិតដែលយើងបានគិតជាយូរហើយ បើដូច្នោះយើងនឹងលើករេហ៍ពលទៅថ្វាយបង្គំដោយរួសរាន់ក្នុងនគរនេះឥតមានចលាចលទេ យើងនឹងរៀបដំណើរឱ្យស្រេចក្នុងរវាង១០ ថ្ងៃដើម្បីនឹងទៅជាមួយនឹងអ្នក វេលានេះសូមអ្នកបោះបារាំភាក់នៅក្រៅក្រុងសិន ខ្ញុំនឹងត្រឡប់ទៅចាត់ការឱ្យរៀបស្បៀងអាហារនាំមកលៀងអ្នកមួយអន្លើ ដោយរេហ៍ពលទាំងអស់ឱ្យបានគ្រប់គ្រាន់បរិបូណ៌" មានព្រះបន្ទូលតែប៉ុណ្ណោះ ក៏នាំសេនាសេនីយ៍សព្វមុខមន្ត្រីចូលទៅក្នុងព្រះរាជនិវេសន៍ ហើយទ្រង់ចាត់ឱ្យនាំស្បៀងអាហារនឹងវត្ថុផ្សេងៗ ដើម្បីជារង្វាន់ដល់យោធាមាត្យគ្រប់ៗគ្នាសុទ្ធសឹងតែជារបស់មានតម្លៃ។

ទើបព្រះបាទសាសីណង់ ទ្រង់ម៉ីម្នាឱ្យសម្រេចកិច្ចការជាប្រញាប់ឱ្យហើយស្រេច ហើយទ្រង់បានតាំងក្រុមជំនុំឱ្យកាន់កាប់នគរ នៅ

វេលា ដែលទ្រង់ព្រះរាជដំណើរទៅបានចាត់សេនាបតីម្នាក់ដែលមាន សតិបញ្ញាមុតមាំជាអធិបតីនៃក្រុមជំនុំនោះ ចាត់ការក្នុងព្រះនគរ រួចស្រេចកាលណាទ្រង់ក៏ផ្ដាំលាព្រះអគ្គមហេសី ហើយលើកសេកល យោធាចេញចាកវាំងជ័យក្នុងវេលារសៀលត្រជាក់ទៅប្រថាប់ក្នុងបារាំ ព្រះពន្លានៅប្របបារាំអគ្គមហាសេនាដ៏ជារាជទូតព្រះបាទសារ្យា ។ ទ្រង់គង់សន្ទនាជាមួយនឹងអគ្គរាជទូតដរាបដល់ពាក់កណ្ដាលអធ្រាត្រ ទ្រង់ភ្នកព្រះហឫទ័យរឭកដល់ព្រះអគ្គមហេសី ក៏ស្ដេចត្រឡប់ចូលទៅ ក្នុងរាជនិវេសន៏វិញតែ១ ព្រះអង្គឯងក្នុងរាត្រីនោះ ឯព្រះអគ្គមហេសី គិតស្មានថាព្រះស្វាមីមិនត្រឡប់មកវិញទេ ក៏នាំប្រុសសហាយម្នាក់ ដែលជាមហាតលិកទៅរួមវេណីជាមួយ ហើយដេកលក់ទាំងពីរអ្នក តាំងពីបឋមយាមមក ។

ព្រះបាទសាសីណង់ស្ដេចមកដល់កាលណា ក៏យាងព្រះបាទ ថ្នម១ចូលទៅ ដើម្បីធ្វើកុំឱ្យព្រះអគ្គមហេសីភ្ញាក់នឹងព្រះអង្គ ព្រោះ ទ្រង់ស្មានថា ព្រះទេវីមានព្រះហឫទ័យស្មោះត្រង់ លុះយាងចូលទៅ ដល់ក្រឡាព្រះបន្ទំទ្រង់ទតទៅឃើញព្រះអគ្គទេពី កំពុងផ្ទឹឱបប្រុស សហាយនៅលើព្រះទែន ក៏ទ្រង់ស្លុតព្រះហឫទ័យ ហើយទ្រង់ប្រតិស្ថាន ជញ្ជីងមួយស្របក់ ដើម្បីសង្កេតឱ្យច្បាស់ក្រែងព្រឹលព្រះនេត្រទេដឹង លុះបានមួយស្របក់ទៅ ទ្រង់ឈ្វេងយល់ថា មិនមែនជាស្រមៃទេ ទើប ទ្រង់ពិចារណាថា "ឱអនិច្ចា ! កម្មអើយកម្មខ្លួនអញមិនទាន់ចេញផុត



ស្រឡះពីក្រុងសាមារក័ណ្ឌនៅឡើយ វាហ៊ានក្បត់ចិត្តអញដល់ម៉្លេះ អញមិនត្រូវបង្អង់ទោស មេចង្រៃកាឡកណ្ណីនេះឡើយ ខ្លួនអញជាស្ដេចគួរឱ្យផ្ដន្ទាបទល្មើស ដែលកើតក្នុងអាណាខេត្តអញ ខ្លួនអញជាស្វាមីត្រូវអញផ្ទាល់ឱ្យសមនឹងទោស ។ គិតតែប៉ុណ្ណោះហើយ ក៏ហូតព្រះខ័នយាងចូលទៅជិតប្រហារសហាយ ទាំងពីរកំពុងដេកលក់ដល់នូវមរណៈក្នុងវេលានោះស្រេចហើយ ទ្រង់ក៏ទាញយកម្ដងមួយទៅទម្លាក់ចោលក្នុងជ្រោះដែលជីកជុំវាំង » ។

ស្រេចហើយកាលណា ទ្រង់ក៏ចេញពីព្រះរាជវាំងដោយស្ងាត់ៗទៅវិញយាងចូលទៅក្នុងបារាំព្រះពន្លាដើមឥតប្រាប់អ្នកឯណាឱ្យដឹងអំពីរឿងនេះឡើយ ហើយទ្រង់បង្គាប់ឱ្យលើករេហ៍ពលទៅក្នុងរាត្រីនោះ អស់សេនាយោធាក៏ម្ទីម្ទាប្រជុំកងទាហាន ហើយប្រគុំតូរ្យតន្ត្រីផ្លុំត្រែស័ង្ខពួកងរំពង ទើបត្រាច់ពនេចរតតាមមាគ៌ាទៅកាលនោះ ព្រះបាទសាសីណង់ទ្រង់មានបរិវិតក្កជាអនេកដោយទ្រង់រំពឹងនឹកដល់រឿងព្រះអគ្គមហេសី ព្រះឱរាចង្អៀតចង្អល់ជានិច្ច តែមួយព្រះអង្គឯង ។

លុះទ្រង់យាងទៀបដល់ក្រុង ស៊ុលតង់[១] សារ្យាជាជេដ្ឋាស្ដេចចេញមកទទួលមួយអន្លើដោយសេវកាមាត្យជាច្រើន ហើយនៅវេលាដែលបានជួបក្រស័ត្រទាំងពីរអង្គក៏ចុះពីខ្នងអស្សតរ ស្ទុះចូលទៅគំនាប់

១- ពាក្យស៊ុលតង់ជាពាក្យ អារ៉ាប់ ប្រែថាស្ដេច បើជាអគ្គមហេសីហៅថា ស្រីស៊ុលតាន ។

ថ្លែងសេចក្តីប្រាស្រ័យកាន់គ្នា ហើយក៏ប្រកៀកប្រឱបតាមដោយសេចក្តី រលឹកដែលខានឃើញគ្នាជាយូរឆ្នាំ លុះបានស្រាកស្រាន្តព្រះហឫទ័យ ក៏ស្តេចឡើងអាជានេយ្យយាងចូលទៅក្នុងព្រះរាជវាំង ព្រមទាំងសេនា យោធាហែហមមុខក្រោយ លុះដល់ព្រះរាជដំណាក់ហើយ ស៊ុលតង់ សារ្យាក៏នាំព្រះអនុជាធិរាជទៅប្រថាប់ក្នុងដំណាក់មួយ ទន្ទឹមគ្នា នឹងដំណាក់ព្រះអង្គដែលមានសួនច្បារមួយឃ្លាំងនៅកណ្តាលជាកន្លែង សម្រាប់រៀបធ្វើពិធីបុណ្យផ្សេងៗ ហើយមានទាំងប្រដាប់ប្រដាឥត មានខ្វះអ្វីផង ។

កាលណាបានប្រគល់ ដំណាក់ថ្វាយព្រះអនុជរួចហើយ ស៊ុលតង់ សារ្យាក៏ស្តេចទៅកាន់ទីដទៃ ដើម្បីឱ្យព្រះអនុជាធិរាជចូលស្រង់គង្គា លុះព្រះអនុជបានស្រង់នឹងតែងព្រះអង្គស្រេច ទើបស្តេចមកជួបវិញ គង់សន្ទនាអំពីកិច្ចការផ្សេងៗ នូវសេចក្តីសុខទុក្ខក្នុងរវាង ដែលឃ្លាត ចេញពីគ្នាជាយូរអង្វែងឆ្នាំ នាកណ្តាលមន្ត្រីដែលអង្គុយគាល់ ដោយ ជុំវិញ។ ដល់ពេលសោយ ក្រស័ត្រទាំងពីរព្រះអង្គក៏ទ្រង់សោយជាមួយ គ្នា សោយស្រេចវេលាណា ក៏គង់សន្ទនាតទៀត ដរាបរាត្រីស្ងាត់ ទើប ព្រះបាទសារ្យាលាព្រះអនុជទៅ ដើម្បីឱ្យព្រះអនុជបានសម្រាកព្រះ កាយពល ។

ព្រះបាទសាសីណង់ក៏យាងចូលក្នុងក្រឡាព្រះបន្ទំ ដើម្បីសំងំ ផ្ទំក្នុងវេលានោះ ក្នុងពេលដែលសម្តេចព្រះជេដ្ឋាគង់សន្ទនាជាមួយ

ហាក់ដូចជាបានរយាលស្បើយ នូវសេចក្ដីវិតក្កនោះខ្លះ តែលុះវេលាដែលសំងំតែមួយព្រះអង្គឯងបន្តិចទៅ សេចក្ដីវិតក្កនោះក៏ច្រឡោតឡើង នាំឱ្យកើតរសាប់រសល់ឈឺឆ្អៀបព្រោះព្រះហឫទ័យ ប្រវត្តិតែទៅរឿងព្រះអគ្គជាយាទុច្ចរិត ប្រៀបបីដូចជាគោដែលត្រូវគេចាក់ដោយជន្លួញ បានសេចក្ដីឈឺចាប់យ៉ាងណា ឬសេចក្ដីក្ដៅផ្សាដោយស្រ្ដីក៏ឈឺចាប់យ៉ាងដូច្នោះ ម្ល៉ោះហើយទ្រង់ក្រោកចេញពីក្រឡាព្រះបន្ទំគង់តម្រង់កាយសញ្ជឹងតែមួយព្រះអង្គអស់រាត្រីនោះ ទ្រង់មានព្រះភក្ត្រសៅហ្មង ដោយអំណាចទុក្ខជាខ្លាំង ។ ឯស៊ុលតង់សារ្យាសម្គាល់ឃើញ ថាព្រះអនុជមិនសប្បាយដូច្នោះទ្រង់ព្រះតំរិះថា (ចុះប្អូនអញមានរឿងអ្វីកើតទុក្ខ អផ្សុកដោយហេតុយ៉ាងណា នរណាធ្វើឱ្យអាក់អន់ ឬមួយតូចចិត្តថាអញរៀបទទួលមិនគួរសម តែតាមអញធៀបមើលទៅឃើញថាការដែលអញរៀបទទួលនេះគួរ និងស័ក្ដិប្អូនសំឡាញ់អញណាស់ហើយ ឥតមានទាស់ឆ្គងត្រង់ណាទេ ឬមួយជាមានសេចក្ដីព្រួយរឭកដល់នគរនឹងដល់អគ្គមហេសី ប្រសិនបើដូច្នេះត្រូវអញឱ្យរបស់ប៉ុន្មាន ដែលអញបម្រុងនឹងឱ្យដល់ប្អូនអញ ដើម្បីបើមានប្រាថ្នានឹងវិលទៅនគរវេលាណាក៏ទៅបាន មិនទើសទាល់ព្រោះហេតុមិនហ៊ានលាអញទៅ លុះព្រឹកឡើងទ្រង់ក៏ចាត់ឱ្យនាំដង្វាយផ្សេងៗ យកមកព្រះរាជទានសុទ្ធ សឹងតែវត្ថុដ៏មានតម្លៃ រកបានដោយក្រដែលមានក្នុងប្រទេសនោះ។ រួចទ្រង់ចាត់ឱ្យធ្វើបុណ្យមានលេងល្បែងប្លែក ដើម្បី

ជាទីកំសាន្តដល់ព្រះអនុជ ប៉ុន្តែព្រះអនុជឥតមានស្រាកសេចក្តីវិតក្ក នោះឡើយរឹងរឹតតែទ្វេទុក្ខឡើងទៀត ។

មានថ្ងៃមួយព្រះបាទសារ្យា បានចាត់យោធាដើម្បីចេញទៅបណ្តេញសត្វព្រៃចម្ងាយពីរថ្ងៃ ពីទីក្រុងហើយនាំព្រះអនុជទៅក្រសាលជាមួយផង ប៉ុន្តែក្នុងវេលានោះព្រះអនុជសុំខាន ទូលថាមានប្រឈួននឹងទៅក្រសាលមិនបាន ព្រះជេដ្ឋាក៏មិនហ៊ានបង្ខំ បណ្តោយឱ្យព្រះអនុជនៅជាសុខក្នុងព្រះរាជវាំង ហើយស្តេចចេញទៅតែមួយព្រះអង្គឯងមួយអន្លើដោយសេនាទាហាន ។ ឯព្រះបាទសាសឺណង់គង់នៅក្នុងព្រះដំណាក់តែឯង ហើយសញ្ជឹងសញ្ជប់នៅបង្អួចដែលឆ្ពោះទៅសួនច្បារដ៏មានដើមឈើធំៗ ជាច្រើនមានបក្សីគ្រប់យ៉ាង ។ តាំងទ្រនំនៅជានិច្ចក្នុងទីនោះ ហើយស្រែកយំទ្រហឹងស៊ានតាមភាសាវាទីទៃៗ គួរជាទីសប្បាយដល់មនុស្សដែលគ្មានទុក្ខ ប៉ុន្តែឯព្រះបាទសាសឺណង់ ក៏គ្មានសេចក្តីស្បើយក្នុងព្រះឱរា រួចពីសម្លឹងមើលព្រឹក្សាលតាវល្លិក្នុងសួនច្បារ ងើបព្រះភក្ត្រាទតឡើងទៅលើមេឃ ហើយពោលត្អូញត្អែរពីកម្មអកុសលនឹងភ័ព្វសំណាងអាក្រក់ដែលផ្តល់មក ។

ក្នុងវេលានោះទ្រង់ឆ្មៀងព្រះនេត្រទត ត្រង់ទៅទ្វារសម្ងាត់នៃប្រាសាទព្រះជេដ្ឋា ស្រាប់តែឃើញទ្វារនោះបើកឡើងហើយឃើញស្ត្រី ២០ នាក់ចេញមក ឃើញអគ្គទេវី នៃព្រះជេដ្ឋានៅកណ្តាលស្ត្រីទាំងនោះ ។ រីព្រះនាងគិតស្មានថា ស៊ុលតង់សាសឺណង់ចេញទៅជាមួយនឹង

ស្វាមីទើបនាំស្រីស្នំទាំងនោះឆ្ពោះទៅកាន់ដំណាក់ ដែលស្តេចសាសីណង់គង់តែស្ត្រីទាំងអស់សុទ្ធតែគ្របមុខមិនឱ្យឃើញ តាមទំនៀមស្រុក លុះមកជិតដំណាក់កាលណា ក៏បើកមុខឡើងទាំងអស់គ្នា ឯស្តេចសាសីណង់ពួននៅក្បែរបង្អួចលបមើលមិនឱ្យស្រីទាំងនោះឃើញ ។ កាលណាបើកមុខហើយ ស្ត្រីទាំងនោះក៏ដោះអាវវែងខាងក្រៅនៅសល់តែអាវខ្លីជាន់ក្នុងព្រះបាទសាសីណង់មានសេចក្តីឆ្ងល់ណាស់ ព្រោះឃើញក្នុងចំណោមនោះមានមនុស្សប្រុសខ្មៅ១០នាក់ ដែលទ្រង់ស្មានថា ជាស្ត្រីទាំងអស់ ហើយប្រុសទាំងនោះកៀកស្ត្រីមួយម្នាក់ៗ ដែលជាសហាយរបស់ខ្លួន ឯចំណែកព្រះអគ្គទេវីក៏មិននៅឥតគូដែរ យូរបន្តិចដោះអាវហើយទះដៃផ្ទួងៗ ស្រែកហៅថា "មាសូទៗ" ក្នុងគ្រានោះឃើញប្រុសខ្មៅម្នាក់ទៀតចុះពីលើដើមឈើ ហើយរត់ទៅឱបព្រះរាជទេពី ។

កិរិយាដែលបុរសនឹងស្ត្រីទាំងនេះ ប្រព្រឹត្តក្នុងវេលានោះខ្ញុំមិនអាចនឹងពោលឱ្យសព្វគ្រប់ទៅបានឡើយ ដោយច្បាប់កេរ្តិ៍ខ្មាសមិនអនុញ្ញាតឱ្យ ហើយជាការដែលគេតែងតែដឹងគ្រប់គ្នា គ្រាន់តែថាក្នុងវេលានោះ ព្រះបាទសាសីណង់បានសង្កេតឃើញច្បាស់គ្រប់ស្ថានហើយមកគិតថា "សម្តេចព្រះរៀមមិនមែនមានអកុសលតិចជាងទ្រង់ឡើយ សេចក្តីតម្រេកក្នុងកាមគុណរបស់សហាយទាំងនេះ សម្តែងនៅក្នុងទីដដែល ដរាបដល់ពាក់កណ្តាលអធ្រាត្រ ទើបនាំគ្នាចុះងូតទឹក

ស្រះក្នុងសួនច្បារនោះទាំងអស់គ្នា ស្រេចហើយកាលណា ក៏ស្នៀកពាក់នាំគ្នាចូលទៅក្នុងដំណាក់តាមទ្វារដដែលនោះវិញ ឯចំណែកមាសូទដែលជាសហាយរបស់ព្រះអគ្គទេវី ជាមនុស្សខាងក្រៅក៏ចេញទៅតាមកន្លែងដដែលដែលបានចូលមក " ។

កាលទ្រង់បានទស្សនាការអំពើទាំងនេះ ច្បាស់នឹងព្រះនេត្រហើយក៏មកឈ្វេងក្នុងព្រះហឫទ័យថាអញ "គិតពេញជាខុសសោះដែលស្មានថាក្នុងលោកនេះ មានតែខ្លួនអញមួយជាមនុស្សឥតភព្វជាងគេ អកុសលនេះធ្លាក់លើច្រើនប្រុសដែលមានភរិយាបានជាថាដូច្នេះព្រោះឃើញថាអម្បាលដល់ ស៊ុលតង់ បងអញជាមហាក្សត្រធំបំផុតក្នុងលោកម្ដេចក៏ទ្រង់ជៀសអកុសលនេះមិនផុត ឯខ្លួនអញនេះសោតជាមនុស្សទន់ខ្សោយណាស់ បានជាបណ្ដោយឱ្យទុក្ខមកញាំញីបាន ចាប់ដើមពីពេលនេះតទៅ អញមិនត្រូវបើកឱកាសទុក្ខមកជ្រៀតជ្រកនៅបាន" លុះទ្រង់ព្រះចិន្ដាដូច្នេះហើយ សេចក្ដីវិតក្កទាំងប៉ុន្មាន ដែលមានក្នុងព្រះឱរាក៏រសាយបាត់អស់ សោយក្រយាស្ងោយក៏មានឱជារសព្រះកាណ៌ក៏ទទួលសណ្ដាប់នូវភ្លេងមហោស្រពដែលលេងថ្វាយ ព្រោះតាំងពីទ្រង់យាងចេញពីក្រុងសាមារកណ្ឌមក ទ្រង់មិនដែលបានសោយដោយមានឱជារសដូច្នេះ ហើយទ្រង់មិនដែលបានក្រសាលនឹងមហោស្រពសោះ ។

ថ្ងៃក្រោយមកទៀត សេចក្ដីតម្រេកក៏រឹតតែកើតមានក្នុងព្រះ

អង្គ លុះបានជ្រាបជាព្រះជេដ្ឋាត្រឡប់មកពីប្រពាតព្រៃ ក៏ស្ដេចចេញទៅគាល់ដោយរួសរាយរាក់ទាក់។ ដើមឡើយ ស៊ុលតង់សារ្យាមិនបានជាពិនិត្យដល់ហេតុដែលនាំឱ្យព្រះអនុជប្រែប្រួល ទ្រង់មានបន្ទូលតែអំពីស្ដាយមិនបានព្រះអនុជទៅក្រសាលជាមួយ ហើយព្រះអនុជមិនទាន់ទាំងបានឆ្លើយតបថាដូចម្ដេច ទ្រង់មានបន្ទូលទៀតអំពីសេចក្ដីសប្បាយក្នុងការប្រពាតព្រៃ អំពីចាប់សត្វម្រឹគផ្សេងៗបានជាច្រើន។ ខណៈនោះព្រះបាទសាសឺណង់ទ្រង់ស្ដាប់ព្រះរៀមលុះចប់សេចក្ដីហើយ ដោយទ្រង់គ្មានទុក្ខអ្វីក្នុងព្រះអង្គ ទ្រង់ក៏ព័ណ៌នាតបទៅព្រះរៀមដោយការរួសរាយអំពីរឿងផ្សេងៗ តាមដែលទ្រង់នឹកឃើញក្នុងវេលានោះ ។

ឯស៊ុលតង់សារ្យា គិតស្មានថា ព្រះអនុជនៅមានទុក្ខដូចដែលក៏ភ្ញាក់ស្មារតី វេលាដែលឃើញភក្ត្រាព្រះអនុជស្រុះស្រួល ហើយរួសរាយទើបទ្រង់មានព្រះរាជឱង្ការទៅកាន់ព្រះអនុជថា "ប្អូន ! បងសូមអរគុណដល់ព្រះជាម្ចាស់ ដែលបានផ្លាស់ប្រែកិរិយាប្អូនក្នុងពេលដែលបងមិននៅបងមានសេចក្ដីអំណរហួសប្រមាណ ដែលបានឃើញប្អូនបានសេចក្ដីរីករាយដូច្នេះ ប៉ុន្តែបងសូមសួរប្អូនបន្តិច សូមឱ្យប្អូនអនុញ្ញាតតបសេចក្ដីដែលបងសួរទាំងប៉ុន្មាន" ព្រះអនុជតបទៅវិញថាទូលព្រះបង្គំជាខ្ញុំមិនអាចនឹងរាំងរាព្រះជេដ្ឋាទេ បើព្រះជេដ្ឋាសព្វព្រះហឫទ័យសួរពីរឿងអ្វីទូលបង្គំ នឹងសូមឆ្លើយថ្វាយគួរនឹងការ សូមព្រះជេដ្ឋាសួរមកចុះ ទូលបង្គំជាខ្ញុំចង់ដឹងរឿងដែលព្រះអង្គសួរដែរ ព្រះ

បាទសារ្យាមានបន្ទូលសួរថា "តាំងពីប្អូនចូលមក ដល់ទីក្រុងបងវេលាណាបងសម្គាល់ឃើញប្អូនស្រងូតស្រងាត់ជានិច្ច បងខំធ្វើឱ្យប្អូនរសាយនូវសេចក្តីស្រងូតស្រងាត់នោះ គ្រប់បែបយ៉ាងតែមិនបានការអ្វីសោះ ហើយបងគិតឃើញថា ដែលប្អូនកើតទុក្ខនេះ គឺបណ្តាលមកអំពីការដែលប្អូនបោះបង់ចោលនគរ ឯសេចក្តីស្រងូតស្រងាត់នេះប្រហែលកើតអំពីសេចក្តីស្នេហាដល់អគ្គជាយា ព្រោះវេលាដែលប្អូនរើសអគ្គ-មហេសីនោះ គឺរើសយកស្ត្រីដែលប្រកបដោយលក្ខណៈរូបឆោម ហើយបងស្មានថាអគ្គមហេសីប្អូននេះហើយ ជាដើមឫសនៃសេចក្តីវិតក្ករបស់ប្អូន ប៉ុន្តែមិនដឹងជាគំនិតដែលបងគិតឃើញនេះត្រូវឬខុសព្រោះតែបងគិតឃើញដូច្នេះហើយបានជាបង យល់ថាមិនត្រូវឱ្យប្អូនទើសទាល់មិនហ៊ានលាបង បងរៀបរបស់ទាំងប៉ុន្មានដែលបម្រុងនឹងថ្វាយប្អូនយកទៅថ្វាយ ដើម្បីឱ្យប្អូនចង់វិលទៅនគរវេលាណាក៏បាន ប្អូនក៏នៅតែស្រងូតស្រងាត់ព្រះភ័ក្ត្រដដែល លុះបងត្រឡប់មកពីចាប់សត្វនេះស្រាប់តែឃើញកិរិយាប្អូនផ្លាស់ទៅជារីករាយបាត់កើតទុក្ខវិញ ហេតុនេះ សូមឱ្យប្អូនប្រាប់បងដោយត្រង់ ចុះហេតុអ្វីបានជាប្អូនស្រងូតស្រងាត់? ហើយចុះហេតុអ្វីបានជារីករាយឡើងវិញ?"

កាលណាចប់សេចក្តីខាងលើនេះ ព្រះបាទសាសីណង់ជាប្អូនសញ្ជឹងស្ងៀមនៅមួយស្របក់ដូចជារកនឹកសេចក្តីនឹងឆ្លើយតបទៅវិញទើបឆ្លើយទូលថា "ព្រះអង្គជាស៊ុលតង់របស់ទូលបង្គំ ជាម្ចាស់លើ

សិរសាទូលបង្គំ ប៉ុន្តែក្នុងវេលានេះ សូមព្រះអង្គទ្រង់អនុញ្ញាតកុំឱ្យទូលបង្គំជាខ្ញុំឆ្លើយ" ព្រះបាទសារ្យាមានបន្ទូលតទៅទៀតថា ត្រូវតែប្អូន និយាយប្រាប់បងខានមិនបាន ព្រោះបងបានសូមអនុញ្ញាតជាស្រេច ហើយឯព្រះបាទសាសីណង់ស្មៀមមិនបាន ក៏មានបន្ទូលថា "បើព្រះជេដ្ឋា ទទូចសួរទូលបង្គំដូច្នេះទូលបង្គំនឹងថ្វាយសេចក្តី" ទើបអធិប្បាយតាំងអំពីព្រះអគ្គមហេសីផិតក្បត់ ដរាបដល់ចប់រឿង ហើយទូលទៅព្រះរៀមថា "នេះហើយជាដើមហេតុដែលនាំឱ្យទូលព្រះបង្គំជាខ្ញុំស្រងូតស្រងាត់សូមទ្រង់ជ្រាប" វេលានោះស៊ុលតង់សារ្យាតបទៅវិញថា រឿងដែលប្អូននិយាយនេះជារឿងអព្វមង្គលសមនឹងប្អូនផ្តន្ទាមនុស្សក្បត់ដល់ទីនេះគ្មានអ្នកណាឯណាបន្ទោសប្អូនឡើយ ព្រោះបានធ្វើសមនឹងបទល្មើសនោះណាស់ បងប្រាប់ប្អូនដោយត្រង់ចុះ ប្រសិនបើខ្លួនបងវិញប្រហែលជាធ្វើលើសប្អូនទៅទៀត គឺថាជីវិតស្ត្រីម្នាក់មិនធួនទេ ត្រូវសម្លាប់យ៉ាងតិច ១០០០នាក់ទើបធួន នឹងកំហឹងបង វេលានេះបងអស់សន្ទិះសង្ស័យហើយ ព្រោះដឹងថាទុក្ខប្អូនមានដើមកំណើតមាំពន់ប្រមាណណាស់ តាមដោយបងស្មានឃើញ ថាមនុស្សក្នុងលោកនេះគ្មាននរណាមួយអភព្វជាងប្អូនទេ រឿងដូច្នេះមានលើតែប្អូនម្នាក់ឯងគ្មាននរណាមានរឿងហេតុដូច្នេះឡើយ ប៉ុន្តែត្រូវតែរលឹកដល់គុណព្រះជាម្ចាស់ដែលលោកបានធ្វើឱ្យប្អូនមានសេចក្តីរីករាយឡើងវិញ តែដោយបងជឿជាក់ថា ក្នុងវេលានេះប្អូនអស់សេចក្តីវិតក្ក ស្រឡះពីខ្លួនហើយ

ត្រូវតែប្អូនប្រាប់រឿងដែលនាំឱ្យប្អូនបាត់ទុក្ខនេះ ឱ្យបងដឹងផង តើបណ្ដាលមកពីហេតុអ្វី?

សេចក្ដីសួរលើកទី ២ នេះនាំឱ្យព្រះបាទសាសីណង់រួញអល់ឯកលើសរឿងដំបូង ព្រោះរឿងនេះមានទាក់ទាមដល់ព្រះរៀម "ប៉ុន្តែនឹងទប់មិននិយាយមិនបាន ព្រោះព្រះរៀមបង្ខំជាពន់ពេកណាស់។ មុននឹងចាប់ផ្ដើមរឿងឡើង ទ្រង់ទូលព្រះរៀមថា បើព្រះជេដ្ឋាសព្វព្រះហឫទ័យ ទូលព្រះបង្គំជាខ្ញុំនឹងទទួលតាមតែទូលព្រះបង្គំពិភាល់ក្នុងចិត្តថា ក្រែងទទួលតាមព្រះរាជតម្រាស់ទៅ នាំឱ្យកើតទោសដល់ព្រះអង្គដោយរឿងនេះ ព្រោះព្រះអង្គបង្ខំឱ្យទូលព្រះបង្គំថ្វាយសេចក្ដីដែលទូលព្រះបង្គំនាំឱ្យខ្ញុំប្រែចិត្តកើតមានរីករាយឡើងវិញ" វេលានោះព្រះបាទសារ្យាឆ្លើយកាត់ថា "មិនអីទេ ! រឿងដែលប្អូននិយាយនោះនាំឱ្យរឹតតែចង់ស្ដាប់ទៅទៀត " ចូរប្អូននិយាយឱ្យឆាប់ទៅរឿងអ្វីក៏ដោយឱ្យតែពិត តាមការដែលកើតឡើង កាលណាអាក់ខានពុំបាន ព្រះបាទសាសីណង់ក៏ព័ណ៌នាតាំងអំពីដែលបានឃើញមនុស្សខ្មៅ១ ក្លែងភេទជាស្ត្រីអំពីកាមរាគរបស់ព្រះអគ្គទេវីនឹង បណ្ដាស្រីស្នំក្រមការទាំងប៉ុន្មានព្រមទាំងមាសូទដែលជាសហាយរបស់ព្រះអគ្គមហេសីនៃព្រះរៀម ទ្រង់សារស័ព្ទតាមដែលបានឃើញគ្រប់ស្ថាន ឥតមានភ្លេចកន្លែងណា ចប់រឿងហើយ ទ្រង់ទូលព្រះរៀមតទៅថា "នៅវេលាដែលបានឃើញអំពើអាក្រក់នេះ ទូលបង្គំពិចារណាថា ស្ត្រីទាំងអស់តែងតែដូច្នេះ តែ

កាលណាបាក់ចិត្តទៅខាងណា មិនអាចនឹងទប់ចិត្តវិញបាន លុះគិតឃើញដូច្នេះហើយ ទូលបង្គំសន្និដ្ឋានថា បុរសណាតែជាប់ទុកចិត្តទៅលើកិរិយាមារយាទរបស់ស្ត្រីណាហើយ បុរសនោះគេហៅថាជាមនុស្សខ្សោបខ្សោយ ជាមនុស្សមានសភាពទន់ដុនដាប ទូលបង្គំពិចារណាឃើញហេតុជាច្រើនទៅទៀត បានជាខំកាត់ចិត្តលះបង់នូវសេចក្តីវិតក្កស្រងូតស្រងាត់ចេញ លុះដល់បានសម្រេចដូចសេចក្តីប្រាថ្នា ប្រសិនបើព្រះជដ្ឋាជឿរឿងដែលទូលបង្គំប្រារព្ធនេះ សូមទ្រង់យកតម្រាប់តាមដែលទូលបង្គំបានធ្វើនោះ ឃើញជាការស្រួលល្អ"។

ឯស៊ុលតង់សារ្យារវេលាដែលបានទ្រង់ព្រះសណ្តាប់នូវវាចានៃព្រះអនុជទាំងប៉ុន្មានហើយ ក៏ទ្រង់ឥតជឿព្រះអនុជបន្តិចសោះ ព្រះហឫទ័យចង់ខ្វាល់នឹងព្រះអនុជវិញផងហើយមានបន្ទូលថា "ពាក្យដែលប្អូននិយាយនេះជាពាក្យមិនពិតទេ ព្រះអគ្គមហេសីបងមិនអាចនឹងប្រព្រឹត្តអំពើលាមកក្បត់បងដូច្នេះឡើយ បងជឿប្អូនលុះតែបងបានឃើញច្បាស់នឹងភ្នែកបង ប្រហែលជាប្អូនភាន់ច្រឡំទេដឹង? ដោយរឿងនេះ ជារឿងធំត្រូវបងចាំបញ្ជាក់នឹងភ្នែកបងឱ្យច្បាស់សិន" វេលានោះ ព្រះបាទសាសីណង់ទូលតបវិញថា ប្រសិនបើព្រះជេដ្ឋាចង់ច្បាស់នោះ ជាការងាយណាស់ ព្រះអង្គធ្វើជាចេញទៅចាប់សត្វម្តងទៀតជាមួយនឹងទូលបង្គំជាខ្ញុំ នាំទាំងនាហ្មឺនសព្វមុខមន្ត្រីរបស់ព្រះអង្គនឹងរបស់ទូលបង្គំជាខ្ញុំទៅទាំងអស់គ្នា លុះយើងទៅប្រថាប់ក្នុងព្រះពន្លា

នៅក្រៅក្រុងហើយ យើងត្រឡប់មកវិញតែ២នាក់ ចូលមកពួននៅក្នុងដំណាក់ដែលទូលបង្គំជាខ្ញុំនៅ ទូលបង្គំជាខ្ញុំថាប្រាកដជាព្រឹកស្អែកទ្រង់នឹងបានឃើញដូចកាលដែលទូលបង្គំជាខ្ញុំឃើញមិនខាន " ព្រះបាទសារ្យាក៏ទ្រង់យល់ព្រមតាម ហើយបានចាត់ការឱ្យទៅសង់ព្រះពន្លានៅកន្លែងមួយក្នុងព្រៃដែលបានសម្រេចទុក ។

ថ្ងៃក្រោយតពីនោះមក ក្សត្រទាំង២យាងចេញមួយអន្លើ ដោយសេវកាមាត្យជាច្រើន លុះបានដល់ទីព្រះពន្លាហើយទ្រង់ចូលសម្រាកព្រះកាយក្នុងទីនោះដរាបដល់រាត្រីស្ងាត់ ទ្រង់ត្រាស់ហៅអគ្គមហាសេនាមកផ្ដាំឱ្យនៅថែទាំព្រះពន្លា ហាមផ្ដាច់មិនឱ្យមនុស្សណាចូលដល់ក្រឡាបន្ទំ តែទ្រង់មិនបានប្រាប់អំពីសេចក្ដីប្រាថ្នារបស់ទ្រង់ឡើយ ផ្ដាំស្រេចហើយ ទ្រង់ឡើងគង់លើអាជានេយ្យជាមួយនឹងព្រះអនុជាធិរាជយាងត្រឡប់ចូលមកក្នុងនគរវិញ ប្រថាប់ក្នុងដំណាក់ដែលព្រះបាទសាសីណង់សម្រាកនៅ ហើយក៏ផ្ទំទាំងពីរព្រះអង្គនៅទីនោះ លុះវេលាព្រឹកឡើងទ្រង់យាងទាំងពីរព្រះអង្គទៅគង់នៅព្រះកៅវតា ទ្រង់គង់ក្រសាលយកសន្ទើមនៅទីបង្អួចដោយក្នុងវេលានោះព្រះអាទិត្យមិនទាន់រះនៅឡើយ តែទ្រង់ឆ្មៀងព្រះនេត្រញយ១ នៅទីទ្វារតូចនោះតែមួយស្របក់ទើបឃើញទ្វារនោះរបើកឡើង ហើយឃើញព្រះអគ្គ-មហេសីចេញមកព្រមដោយស្រីស្នំក្រមការ នឹងមនុស្សខ្មៅ ១០នាក់នោះ ហើយឃើញទាំងស្រែកហៅឈ្មោះមាសូទ ដែលជាសហាយ

របស់ព្រះអគ្គទេវីផង ។ ស៊ុលតង់សារ្យាបានឃើញ ហេតុភេទជាក់ស្តែងទាំងអស់ឥតមានខុសអំពីព្រះអនុជទូលទ្រង់ ក៏មានសេចក្តីអៀនខ្មាសជាខ្លាំង អំពីទុក្ខធំដែលធ្លាក់លើព្រះអង្គហើយ ទ្រង់ស្រែកថ្ងូរញថា ឱព្រះម្ចាស់ថ្លៃអើយ ខ្ញុំហួសចិត្តណាស់អកុសលអ្វីម្ល៉េះ អម្បាលដល់អគ្គមហេសីនៃមហាក្សត្រមានឫទ្ធានុភាពដូចយ៉ាងខ្ញុំនេះ គង់ប្រព្រឹត្តអំពើលាមកដូច្នេះបាន បើយ៉ាងនេះតើមានក្សត្រណាក្រៅអំពីខ្ញុំ នឹងអួតអាងថាខ្លួនប្រកបដោយសុខនិរទុក្ខទៅបាន? រួចទ្រង់ស្ទុះទៅឱបព្រះអនុជហើយមានបន្ទូលថា "នែប្អូន ! យើងទាំងពីរនាក់ត្រូវកុំនៅក្នុងព្រះនគរយើងនេះ គ្មានមនុស្សបញ្ជោរនិងក្បត់ទាំងអស់ត្រូវយើងទៅពឹងពាក់លាក់ខ្លួន ក្នុងប្រទេសដទៃកុំឱ្យមានអ្នកណាដឹងស្គាល់យើង ព្រះបាទសាសឹណង់មិនព្រមតាម តែទ្រង់មិនអាចទទឹងនឹងព្រះរៀមទើបទ្រង់ទូលតបទៅវិញ បពិត្រព្រះជេដ្ឋាប្អូនឥតមានទទឹងទាស់អ្វីនឹងព្រះហឫទ័យទេ ប៉ុន្តែសូមឱ្យព្រះអង្គសន្យានឹងទូលបង្គំថា យើងត្រូវត្រឡប់មកនគរវិញ កាលណាបើយើងបានឃើញមនុស្សដែលមានអកុសលក្រាស់ជាងយើងទៅទៀត ព្រះបាទសារ្យាឆ្លើយតបថាមិនអីទេ បងនឹងសន្យាឱ្យ តែបងស្មានមើលទៅច្បាស់ជាគ្មានអ្នកឯណាមួយជាមនុស្សអកុសលជាងយើងទេ ព្រះបាទសាសឹណង់ទូលវិញថាទូលបង្គំជាខ្ញុំមិនស្មានដូចព្រះអង្គទេ ទូលបង្គំស្មានថាប្រហែលជាយើងទៅមិនឆ្ងាយប៉ុន្មាន គង់បានប្រទះមនុស្សអកុសលមួយមិនខាន លុះ

សន្ទនាដូច្នេះស្រេចហើយក្សត្រទាំងពីរលបចេញពីព្រះរាជវាំងទៅឥតមានឱ្យនរណាដឹង ហើយត្រាច់តាមផ្លូវដទៃផ្សេងពីផ្លូវដែលយាងចូលមកកាត់ព្រៃព្រឹក្សាជរាបដល់ពេលព្រលប់ ក៏ឈប់ផ្ទំក្នុងព្រៃស្ងាត់នោះមួយយប់ លុះអរុណរះឡើងជាថ្មីក៏ទ្រង់រាជដំណើរតទៅទៀត លុះដល់មាត់ឆ្នេរសមុទ្រមានរុក្ខជាតិធំៗ ត្រសុំសាខាប្រកបដោយម្លប់ត្រជាក់ ទ្រង់ក៏សម្រាកព្រះកាយព្ធដ៏ទីនោះទាំងពីរព្រះអង្គ ប្រាប់ទុកគ្នាតែអំពីរឿងរាជទេវីចិត្តក្បត់នោះ ។

ទើបតែសម្រាកបានមួយស្របក់ក្នុងទីនោះ ស្រាប់តែឮសព្ទសម្រែកទ្រហឹងរំពងក្នុងកណ្ដាលសមុទ្រគួរឱ្យតក់ស្លុត ដោយសម្លេងនោះជាខ្លាំង យូរបន្តិចលេចផុសជាផ្សែងខ្មៅកួចត្របាញ់ពីក្នុងទឹកឡើងខ្ពស់ទៅលើអាកាសវេហាស៍ ក្សត្រទាំងពីរអង្គឃើញដូច្នេះ ក៏រឹតតែភាន់ភាំងស្មារតី ដោយមិនជ្រាបហេតុ ហើយទ្រង់ក៏ស្ទុះស្រវាឡើងលើមែកឈើសំងំពួនទាំងពីរព្រះអង្គ លបមើលទៅឃើញផ្សែងខ្មៅនោះកាន់ តែជិតមកៗដល់ត្រើយសមុទ្រ។

គឺមានអារក្សទឹកមួយដែលជាសត្រូវនឹងមនុស្ស អារក្សនោះខ្លួនខ្មៅ មុខក្រញៀវក្រញូវមាឌធំកម្ពស់ចុងត្នោតលៃ ទូលហឹបកែវមួយលើក្បាល។ ហឹបនោះមានចាក់សោគ្រប់ ទាំង៤មុមទូលដើរឡើងតាមមាត់សមុទ្រសំដៅមកត្រង់កន្លែងដែល ស្ដេចបងប្អូនពួននៅហើយក៏ដាក់ហឹបចុះក្រោមដើមឈើនោះ ។

ឯស្តេចទាំងពីរអង្គមានសេចក្តីតក់ស្លុតស្ទើរនឹងបាត់ស្មារតីរំពឹងក្នុងព្រះអង្គថា នឹងដល់នូវសេចក្តីមរណៈហើយ អារក្សដាក់ខ្លួនអង្គុយចុះប្របហីប ហើយក៏ទាញកូនសោពីចង្កេះចាក់ហីបនោះ បើកយកស្ត្រីម្នាក់ពីក្នុងហីបមក ស្ត្រីនោះប្រដាប់កាយដោយគ្រឿងអលង្ការណ៍យ៉ាងឆើតរកអ្វីផ្ទឹមមិនបាន មានរូបឆោមសក្តិសមរាងកាយគួរជាទីសម្រើបដល់បុរសទាំងពួង អារក្សដាក់ស្ត្រីឱ្យអង្គុយជិតខ្លួនហើយថ្នាក់ថ្នមបបោសអង្អែលលួងលោមដោយពាក្យផ្អែមថា "ម្នាលប្អូនសំឡាញ់ដ៏ប្រកបដោយនរលក្ខណ៍ឥតខ្ចោះរបស់បង បងនឹងរកស្ត្រីណាក្នុងលោកនេះមកផ្ទឹមឱ្យប្រហែលនឹងប្អូនគ្មាន តាំងពីបងបានលួចយកប្អូនមកពីកណ្តាលប្រជុំជន ដែលប្អូនកំពុងរៀបអាពាហ៍ពិពាហ៍ ដរាបមកដល់ថ្ងៃនេះ បងឥតមានឃ្មើសចិត្តអ្វីនឹងប្អូនឡើយ បងរឹតតែស្រឡាញ់ច្រើនឡើងៗ វេលានេះសូមប្អូនអនុញ្ញាតឱ្យបងកើយលើភ្លៅបន្តិចព្រោះបងងងុយដេកណាស់ ថាដូច្នេះហើយក៏ប្រះខ្លួនដេកកើយលើភ្លៅនាងនោះទៅ សណ្តូកជើងស្ដូកដល់មាត់សមុទ្រ ហើយស្រមុកខ្ទ័រព្រៃលក់នៅទីនោះ" ។

ឯភរិយាជូនជាងើយមើលទៅចុងឈើ ក៏ប្រទះឃើញក្សត្រទាំង២ ហើយបោយដៃហៅឱ្យលបចុះមក ស្តេចទាំង២ឃើញដូច្នោះក៏ភិតភ័យទ្វេឡើង សំពះអង្វរពីលើមកថាមិនហ៊ានចុះមកទេ ស្ត្រីនោះរំកិលជើងចេញពីក្បាលអារក្សបានហើយ ក្រោកឈរឡើងកំហែងឱ្យប

ថា ចុះមកឱ្យឆាប់ហើយចូលមកឯខ្ញុំ ស្ដេចទាំងពីរឆ្លើយអង្វរមកវិញថា មិនហ៊ានចុះមកទេ ព្រោះខ្លាចអារក្សណាស់។ នាងនោះក៏កំហែងទៅទៀតថា "ចុះមកឱ្យឆាប់ បើខឹរឹងរូស ខ្ញុំនឹងដាស់អារក្សទឹកឱ្យសម្លាប់ឥឡូវ" ។ ស្ដេចទាំង២មានសេចក្ដីភ័យ តក្កមានឹងអារក្សពេកណាស់ ក៏ចុះមក ដោយប្រយ័ត្នថ្នមមិនឱ្យឮសូរឡើយ ក្រែងអារក្សភ្ញាក់ ។ លុះចុះមកដល់ដីវេលាណា ស្ត្រីនោះស្ទុះ ទៅចាប់ទាញដៃទាំងពីរអង្គនាំទៅក្រោមដើមឈើមួយឆ្ងាយពីនោះបន្តិច ហើយបង្ខំឱ្យធ្វើនូវមេថុនកម្ម។ ដើមឡើយក្សត្រទាំងពីរមិនព្រមលុះនាងនោះកំហែងបន្លាចដោយប្រការផ្សេងៗ ទើបធ្វើឱ្យសម្រេចតាមប្រាថ្នាទៅ ។ លុះនាងនោះបានឃើញស្ដេចទាំងពីរមានចិញ្ចៀនមួយម្នាក់នៅម្រាមក៏និយាយសុំចិញ្ចៀននោះត្រាតែបាន ហើយទាញយកខ្សែមួយពីក្នុងប្រអប់ដែលដាក់ក្នុងអាវចេញមក។ នៅខ្សែនោះមានចិញ្ចៀនឯទៀតជាច្រើនបែប នាងនោះសួរទៅស្ដេចបងប្អូនថា "អ្នកបានដឹងរឿងចិញ្ចៀនទាំងនេះឬទេ? ស្ដេចទាំងពីរឆ្លើយតបថា យើងមិនដឹងរឿងអ្វីទេ សូមឱ្យនាងអធិប្បាយប្រាប់យើងឱ្យដឹងចុះ នាងក៏ប្រាប់ថា ចិញ្ចៀនទាំងនេះសុទ្ធតែជារបស់ប្រុសដែលបានធ្វើសេវនកិច្ចជាមួយនឹងខ្ញុំ គឺចិញ្ចៀនមួយប្រុសមួយ ទាំងអស់បានចិញ្ចៀន ៩៨ ហើយខ្ញុំបានសុំមកទុកជាទីរលឹករបស់ខ្ញុំ ដែលខ្ញុំសុំរបស់អ្នកនេះ ដើម្បីយកមកទុកជាទីរលឹកដូច្នេះដែរ បំពេញឱ្យបានគ្រប់ ១០០" ។ តាំងពីអារក្សយកខ្ញុំមកទល់

នឹងថ្ងៃនេះ ខ្ញុំមានសហាយ ១០០នាក់ ហើយៗ អារក្សនេះប្រយ័ត្នខ្ញុំជាទីបំផុត មិនដែលឃ្លាតទៅទីឯណាឆ្ងាយចោលខ្ញុំទេ ដូចអ្នកឃើញច្បាស់នឹងភ្នែកស្រាប់ វាទុកខ្ញុំតែក្នុងហឹប លាក់ដល់បាតសមុទ្រប្រយ័ត្នយ៉ាងនេះ ខ្ញុំគង់តែផិតវាបាន ត្រូវឱ្យអ្នកដឹងប្រាកដថា តែកាលណាស្ត្រីផ្ទៀងចិត្តទៅលើអ្វីហើយគ្មានប្ដីណាឬសហាយណាទៅការពារទប់ឈ្នះឡើយ ជាតិប្រុសត្រូវកុំខាខាំងឬបង្ខំចិត្តស្រី ត្រូវបណ្ដោយតាមការវិញល្អជាង ។ សេចក្ដីដែលបើកបណ្ដោយនេះហើយជាឧបាយដ៏សំខាន់ដើម្បីឱ្យស្ត្រីដើរត្រឹមត្រូវតាមគន្លងស្រី ប្រាប់តែប៉ុណ្ណោះ ក៏យកខ្សែដោតចិញ្ចៀនទាំងពីរបញ្ចូល ជាមួយគ្នានឹងចិញ្ចៀនមុនៗ ទើបដើរចូលទៅអង្គុយជិតប្ដីលើកក្បាល ដាក់ឱ្យកើយលើភ្លៅដូចដើមវិញ បក់ដៃឱ្យស្ដេចទាំងពីរគេចខ្លួនទៅ។

ឯស្ដេចបងប្អូនក៏ដើរតាមផ្លូវដដែល ឆ្ពោះទៅនគរវិញ។ លុះដើរឆ្ងាយបន្តិចពីទីនោះទៅ ល្មមមើលផុតកន្ទុយភ្នែក ស៊ុលតង់សារ្យាមានបន្ទូលទៅនឹងអនុជថា “នែប្អូន ! អ្នកយល់ដូចម្ដេចរឿងអម្បាញ់មិញនេះ តើអារក្សនោះវាគិតស្មានថាខ្លួនវាមានភរិយាស្លូតត្រង់តាមគន្លងធម៌ឬទេ? ប្អូនជឿជាក់ថាគ្មានអ្វីស្មើនឹងពុតស្ត្រីដែរឬទេ?” វេលានោះ ព្រះអនុជទូលតបវិញថា “ទូលបង្គំជាខ្ញុំជឿប្រាកដដូច្នេះណាស់ សូមឱ្យព្រះអង្គសន្និដ្ឋានថា អារក្សនោះគួរថ្កូញគួរថ្ងូរច្រើនជាងយើងទាំងពីរនាក់ ព្រោះខ្លួនវាជាអ្នកឥតភ័ព្វជាអ្នកអកុសលជាងយើងច្រើនណាស់ បើដូច្នេះគួរយើងវិលទៅកាន់នគរយើងវិញ ព្រោះយើងបាន

ឃើញហេតុដែលយើងដើរនេះហើយ យើងត្រូវយល់ថាគ្មានអ្វីឃាត់ខាំងមិនឱ្យយើងយកភរិយាទៀត ។ ចំណែកទូលបង្គំជាខ្ញុំនោះ នឹងធ្វើតាមគំនិតដែលបានគិតទុកស្រេចយូរហើយក្នុងរឿងនេះ គំនិតនោះព្រះអង្គគង់នឹងជ្រាបទៅថ្ងៃក្រោយ ទូលបង្គំប្រាកដក្នុងចិត្តថាវេលាណាព្រះអង្គបានជ្រាបព្រះអង្គមុខជានឹងធ្វើតាមទូលបង្គំមិនខាន ស៊ុលតង់សារ្យា ក៏ព្រមតាមព្រះអនុជក្នុងវេលានោះ ហើយស្តេចត្រឡប់ទាំងពីរអង្គ ឆ្ពោះទៅព្រះពន្លាដែលអគ្គមហាសេនានៅចាំក្នុងព្រៃស្តេចទាំងពីរ យាងទៅដល់វេលាព្រលប់នៅថ្ងៃទី៣ គឺថ្ងៃដែលទ្រង់ចេញទៅពីព្រះពន្លានោះ ។

ឯអគ្គមហាសេនានឹងអាមាត្យទាំងឡាយ ដែលនៅក្នុងទីនោះលុះបានដឹងថាស្តេចទាំងពីរយាងចូលមកវិញហើយ ក៏ព្រមព្រៀងជួបជុំគ្នាចូលទៅថ្វាយបង្គំគាល់ទាំងពីរព្រះអង្គទទួលដោយសេចក្តីករុណាលុះសាកសួរកិច្ចការផ្សេងៗស្រេចហើយ ទើបត្រាស់បង្គាប់ទៅអគ្គមហាសេនាឱ្យរៀបភ្ញុំរេហ៏ពល ត្រឡប់ចូលទៅព្រះបរមរាជវាំងវិញព្រោះព្រះអង្គមិនចង់នៅក្រសាលតទៅឡើយហើយក៏ទ្រង់ឡើង អាជានេយ្យសីហនាទចូលដល់ព្រះរាជវាំងក្នុងរាត្រីនោះ ។

**ចប់ភាគទី១ តែប៉ុណ្ណេះ**

**រឿងក្នុងភាគទី២ កាន់តែចម្លែកណាស់ទៅទៀត**

**សូមអញ្ជើញមើលតទៅកុំខាន ។**

# ឯកសហាស្សរាត្រី

# ឬមួយពាន់មួយយប់

## (ភាគទី២)

លុះយាងចូលទៅក្នុងព្រះរាជដំណាក់ វេលាណាស្ដេចសារ្យា ក៏ស្ទុះចូលទៅក្នុងបន្ទប់ព្រះអគ្គមហេសី ហើយទ្រង់ព្រះបញ្ជាឱ្យចាប់នាងចង ប្រគល់ដល់ដៃអគ្គមហាសេនាឱ្យយកទៅប្រហារជីវិតបង់ក្នុងវេលានោះ ឥតប្រាប់ឱ្យដឹងរឿងដែលខុសឆ្គងអ្វីសោះ ។

អគ្គមហាសេនា ក៏ទទួលព្រះរាជអាជ្ញាទៅសម្រេចឃាតកម្មទៅ រីព្រះមហាក្សត្រ ដោយទ្រង់ព្រះពិរោធខ្លាំងក៏ចាប់ព្រះសែងថ្លាប្រហារនូវស្ត្រីទាំងប៉ុន្មាន ដែលជាស្រីស្នំក្រមការព្រះអគ្គមហេសីដោយព្រះហស្តព្រះអង្គឯង លុះផ្ដន្ទាទោសរួចហើយ ទ្រង់ឈ្វេងយល់ថាៈ អំណើះតទៅនឹងជ្រើសរើសរកស្ត្រីម្នាក់ឱ្យបានត្រឹមត្រូវតាមគន្លង-ធម៌គ្មាន ទើបទ្រង់ព្រះតិរិះថា នឹងយកស្ត្រីមករួមសង្វាសតែមួយយប់ម្នាក់ រួចយកទៅប្រហារជីវិតបង់នៅក្នុងវេលាព្រឹកឡើង ដល់បានកម្រិតព្រះរាជកំណត់ច្បាស់ជាស្រេចដូច្នោះហើយ ទ្រង់ប្ដេជ្ញាថា នឹងចាប់ធ្វើនៅវេលាដែលព្រះអនុជាធិរាជត្រឡប់ទៅនគរវិញ ឯស្ដេចសាសីណង់មិនបានគង់នៅយូរប៉ុន្មាន ក៏លាព្រះជេដ្ឋាវិលត្រឡប់ទៅ

ក្រុងសាមារក័ណ្ឌដោយរួសរាន់ នាំគ្រឿងបណ្ណាការជាដង្វាយដែលព្រះរៀម ព្រះរាជទានទៅជាមួយផង ។

លុះស្តេចសាសឺណង់យាងចេញផុតទៅ សុលតង់សារ្យាទ្រង់បង្គាប់អគ្គមហាសេនាឱ្យនាំស្ត្រីម្នាក់ ដែលជាកូនសេនាទាហានសក្តិខ្ពស់ម្នាក់មកថ្វាយទ្រង់រួមប្រវេណី នឹងស្ត្រីនោះតែមួយយប់ដល់វេលាព្រឹកឡើងឱ្យយកទៅប្រហារជីវិតបង់ ហើយក្នុងយប់ក្រោយឱ្យយកម្នាក់មកថ្វាយទៀត។ អគ្គមហាសេនាដោយខ្លាចស៊ុលត្រង់ណាស់ ក៏ទទួលស្តាប់ហើយធ្វើតាមទៅ លុះយប់ក្រោយនាំយកបុត្រីសេនាទាហានជាន់ទាបទៅថ្វាយ ហើយព្រឹកស្អែកឱ្យយកទៅសម្លាប់ចោលទៀត រួចពីនោះមកដល់វេនស្ត្រីដែលជាកូនរាស្ត្រអ្នកមានមុខនៅក្នុងក្រុង ស្តេចឱ្យយកទៅប្រហារជីវិតគ្រប់តែស្ត្រីឥតមានលោះមួយណាឡើយ ។

ដំណឹងនេះ មិនបាត់ស្ងាត់ក៏បែកសាយទូទៅពេញទាំងក្រុងឮសូរស័ព្ទសម្រែកនឹងស័ព្ទត្អូញត្អែរទ្រហឹងអឹងកង ជួនកាលឃើញឪពុកស្រែកទ្រហោយំបោកខ្លួនប្រាណដោយស្តាយកូន ដែលគេសម្លាប់ ជួន-កាលឮសូរសេចក្តីត្អូញត្អែររបស់ម្តាយ ដែលមានកូនស្រីភិតភ័យក្រែងកូនត្រូវព្រះរាជអាជ្ញាដែរ តាំងអំពីដើមរៀងមកបណ្តារាស្ត្រតែងពោលសរសើរថ្វាយសាធុការពរ ដល់ស៊ុលតង់គ្រប់កន្លែងចាប់ដើមពីនោះមក ឮតែសម្លេងប្រទេចផ្តាសាដល់ស្តេចនោះវិញ ។

អគ្គមហាសេនាមានបុត្រី ២នាក់ នាងបងឈ្មោះ សែរ៉ាសាដ[១] ឯនាងប្អូនឈ្មោះឌីណារសាដ[២] ធីតាទាំងពីរនេះមានរូបឆោមល្អដូចគ្នា ប៉ុន្តែនាងបងមានសេចក្តីក្លាហានជាង ហើយប្រកបដោយសតិបញ្ញាឆ្លៀវឆ្លាសហួសភេទជាស្ត្រីភាព ប្រកបដោយសេចក្តីឧស្សាហ៍ព្យាយាមរៀនសូត្រក្បួនខ្នាតជាច្រើន ហើយចាំអស់រឿងរ៉ាវដែលបានមើលទាំងប៉ុន្មាន នាងបានសិក្សាសព្វវិជ្ជាផ្សេងៗ មានក្បួនវិជ្ជាសារពើដែលឥតរូបវិជ្ជាពេទ្យ ពង្សាវតារ នឹងក្បាច់រចនាជាដើម ។ ចំណែកខាងកាព្យឃ្លោងក៏ប៉ិនប្រសប់ចំណាន ដូចជាពូកកវីយ៉ាងពូកែក្នុងជាន់នោះក្រៅពិនេះ នាងមានរូបឆោមលោមពណ៌ប្រកបដោយនរលក្ខណ៍គ្រប់ប្រការទាំងឫកពាមារយាទក៏ត្រឹមត្រូវតាមបែបបទឥតឆ្គង ។ បិតាស្រឡាញ់បុត្រីពន់ពេកណាស់ មានកាលសម័យមួយកំពុងតែអង្គុយនិយាយគ្នាលេងនាងនិយាយទៅកាន់អាពុកថាបពិត្របិតាខ្ញុំមានប្រាថ្នា នឹងសុំអនុញ្ញាតធ្វើកិច្ចមួយ សូមឱ្យលោកអាពុកអនុញ្ញាតឱ្យនាងខ្ញុំកុំខាន ។ វេលានោះអគ្គមហាសេនាឆ្លើយតបទៅវិញថា អាពុកឥតរាំងដល់សេចក្តីប្រាថ្នារបស់កូនទេ បើសេចក្តីអនុញ្ញាតដែលកូនសុំនោះ ត្រឹមត្រូវតាមគន្លងច្បាប់ល្មមអាពុកបើកឱ្យបាននាងឆ្លើយថា ដែលលោកពុកថាឱ្យ

---

១- សែរ៉ាសាដ ជាពាក្យអារ៉ាប់ប្រែថា "កូនព្រះចន្ទ្រ" ពាក្យនេះ សរសេរជាអក្សរខ្មែរមិនចំទេ ។

២- ឌីណារសាដ ប្រែថា "ល្អដូចមាស" ដាក់ជាអក្សរខ្មែរមិនចំដូចគ្នា ។

ត្រឹមត្រូវតាមគន្លងធម៌នោះ ខ្ញុំយល់ឃើញថាមិនជាត្រូវពេញប៉ុន្មាន តែថាលោកអាពុកអាចនឹងសន្និដ្ឋានពិចារណាទៅបានតាមទំនងហេតុ ដែលបណ្ដាលឱ្យខ្ញុំសុំនេះ គឺខ្ញុំមានបំណងនឹងបំបាត់នូវអំពើបាប ដែលមហាក្សត្រតែងប្រព្រឹត្តលើត្រកូលនីមួយៗក្នុងក្រុងនេះ គឺខ្ញុំមានបំណងនឹងបំបាត់នូវសេចក្ដីភិតភ័យតក់ស្លុតសេចក្ដីតូញ ថ្ងូររបស់មនុស្សដែលមានបុត្រីទាំងប៉ុន្មាន កុំឱ្យមានទៅទៀត វេលានោះអគ្គមហារសេនាតបទៅវិញថា ម្នាលកូន ! សម្ដីដែលកូនពោលមកនេះពេញជាមហាប្រសើរហើយ តែថារោគដែលកូនចង់យកឱសថ ទៅដាក់នេះអាពុកស្មានថាហាក់ដូចជាគ្មានថ្នាំណាទប់ទល់ការពារបានឡើយ បើដូច្នេះតើកូនគិតដូចម្ដេចឱ្យបានសម្រេចតាមសេចក្ដីប្រាថ្នានាងឆ្លើយទៅវិញថា រាល់តែយប់លោកអាពុកនាំស្ត្រីម្នាក់ៗទៅថ្វាយស្ដេច សេចក្ដីនេះខ្ញុំអង្វរសូមឱ្យលោកអាពុកនាំខ្លួនខ្ញុំទៅថ្វាយស្ដេចចុះ កាលបានស្ដាប់ពាក្យគួរសៀម គួរខ្លាចរបស់កូនដូច្នេះហើយ អគ្គមហាសេនាក៏ស្រែកកាត់ដោយសេចក្ដីក្រោធថា “ឱម្ចាស់ថ្លៃអើយ ! ជួយស្ដាប់ខ្ញុំមើលចុះ កូនឯងរលត់សតិហើយឬអីបានជាហ៊ាននិយាយសុំគ្រោះអាក្រក់មកដាក់ខ្លួនដូច្នេះចុះ កូនមិនដឹងទេឬ? ស្ដេចបានប្ដេជ្ញាថានឹងផ្ដុំជាមួយនឹងស្រីម្នាក់តែមួយយប់ហើយយកទៅកាប់សម្លាប់ មិនដែលបណ្ដោយឱ្យហួសកំណត់ ម្ដេចក៏បានជាចង់ឱ្យអាពុកនាំកូនទៅថ្វាយស្ដេចដូច្នោះ កូនគិតឱ្យសព្វទៅមើល បើទុកជាកូនចេះផ្ដាប់ ត្រូវបែបបទយ៉ាងណា

ក៏ជាការឥតប្រយោជន៍នឹងខាខាំងឱ្យឈ្នះ សេចក្ដីប្ដេជ្ញារបស់ស្ដេចមិនបានឡើយ ” នាងឆ្លើយតបទៅវិញថា “ខ្ញុំបានដឹងច្បាស់ហើយគ្រោះកាចទាំងនោះ ប៉ុន្តែខ្ញុំឥតរំភើបអ្វីនឹងគ្រោះទាំងនោះទេ បើជាខ្ញុំស្លាប់ក៏សេចក្ដីស្លាប់របស់ខ្ញុំនោះជាមង្គលប្រសើរដែរ” បើប្រសិនជាខ្ញុំធ្វើទៅហើយបានសម្រេចដូចសេចក្ដីប្រាថ្នាវិញ ខ្ញុំនឹងមានគុណបំណាច់យ៉ាងធំលើព្រះនគរ ។ អគ្គមហាសេនាឆ្លើយតបទៅវិញថា “ទេៗកូនកុំថាដូច្នោះ បើទុកជាកូនចេះថាដូចម្ដេចទៀត ដើម្បីឱ្យអាពុកព្រមនាំកូនទៅចូលក្នុងសេចក្ដីវិនាសនោះ ក៏កុំឱ្យគិតស្មានថា អាពុកនឹងអនុញ្ញាតឱ្យសោះឡើយ កាលណាបើស្ដេចប្រើអាពុកឱ្យនាំកូនយកទៅសម្លាប់នោះឱ្យអាពុកធ្វើម្ដេច គឺត្រូវតែអាពុកទទួលតាមព្រះរាជអាជ្ញាខានមិនបានចូរកូនរំពឹងគិតឱ្យជ្រៅទៅមើល កាលដែលអាពុកយកអាវុធទៅសម្លាប់កូនខ្លួននោះគួរឬ? ឱកូន ! បើកូនមិនខ្លាចស្លាប់ក៏ហើយទៅចុះតែត្រូវឱ្យកូនខ្លាចថា ហេតុនេះ នឹងនាំឱ្យអាពុកមានទុក្ខដល់ស្លាប់ខ្លួនវិញ នៅវេលាដែលអាពុកឃើញដៃប្រឡាក់ដោយឈាមកូនឯង នាងឆ្លើយតបវិញថា “ខ្ញុំសូមអង្វរលោកអាពុកម្ដងទៀត សូមឱ្យអនុញ្ញាតឱ្យខ្ញុំកុំខាន ” អគ្គមហាសេនានិយាយ តឹងសម្លេងឡើងថាសេចក្ដីចចេសរបស់ឯងនាំឱ្យអញខឹងជាខ្លាំង ចុះហេតុអ្វីបានជានៅសុខមិនចង់ទៅចង់ស្លាប់វិញ នរណាក៏ដោយ បើមិនបានពិចារណាឱ្យជ្រៅក្នុងការអន្តរាយនឹងអាចដកខ្លួនឱ្យផុតមិនបាន ទាំងនេះសុទ្ធតែឥត

ប្រយោជន៍សោះហើយ និងមានគ្រោះអាក្រក់ដល់ខ្លួនផង អញក្រែង ខ្លួនឯងនេះដូចជារឿងសត្វលាមួយ ដែលចង់ឱ្យគេបានសុខស្រួល ទៅ ជាបានទុក្ខមកលើខ្លួនវិញ ។ នាងសួរថា តើទុក្ខដែលធ្លាក់លើខ្លួនសត្វ លានោះដូចម្តេចខ្លះ? អគ្គមហាសេនាឆ្លើយប្រាប់ថា ឯរឿងលានេះចូរ ឯងប្រុងស្តាប់ចុះ... ។

## រឿងសត្វលា១ សត្វគោ១ និងអ្នកត្បូងស្រម្នាក់

មាននាយពាណិជម្នាក់ ប្រកបដោយភោគសម្បទបានសង់ផ្ទះ ជាច្រើនខ្នងនៅស្រុកស្រែ ហើយបានចិញ្ចឹមសត្វស្រុកជាច្រើន មាន សម័យមួយ នាយពាណិជបាននាំប្រពន្ធកូនទៅត្រួតមើលស្រូវអង្ករ នៅទីផ្ទះមួយ ឯនាយពាណិជមានវិជ្ជាមួយដ៏សំខាន់ គឺចេះស្តាប់ភាសា សត្វទាំងអស់ ប៉ុន្តែស្តាប់បានតែម្នាក់ឯង និងនិយាយប្រាប់អ្នកដទៃ មិនបានតែនិយាយទៅនឹងមានអន្តរាយដល់ជីវិតខ្លួន ។

នៅទីក្រោលមួយ គេតែងដាក់សត្វលា និងគោជាមួយគ្នា ។ ថ្ងៃមួយ វេលាដែលនាយពាណិជកំពុងតែអង្គុយលេងប្របក្រោលនោះ ដើម្បីមើលកូនតូចៗ ដែលលេងជាមួយគ្នា ស្រាប់តែឮគោនិយាយទៅ លាថា ម្នាលបងលាជាសត្វឥតទុក្ខ សព្វថ្ងៃនេះ តាមខ្ញុំរំពឹងមើលទៅ ឃើញថា បងឯងពេញជាមានភ័ព្វមហាស្រណុក ព្រោះគេឱ្យបងឯង ធ្វើការតិចណាស់ មានមនុស្សថែទាំបងឯង ហើយដុសលាងសំអាត



ជានិច្ច ឱ្យស៊ីសុទ្ធតែស្រូវយ៉ាងស្អាតគ្មានសំដីមួយគ្រាប់លាយសោះ នឹងឱ្យផឹកតែទឹកយ៉ាងថ្លាត្រជាក់ ។ ការនឿយបំផុតរបស់បងឯងនោះ គឺគ្រាន់តែឱ្យម្ចាស់ជិះបន្តិចៗប៉ុណ្ណោះវេលាដែលគាត់មានដំណើរទៅណាមកណា ហើយបើម្ចាស់មិនត្រូវការទេ បងឯងនៅសម្រាន្តជាសុខឥតព្រួយបារម្ភអ្វីសោះ។ ឯចំណែកមុខងាររបស់ខ្ញុំវិញ ឃើញប្លែកគ្នាពន់ពេក ពេលវេលាខ្ញុំក៏ខុសគ្នាពីបងឯងឆ្ងាយទូលាយណាស់មិនទាន់រំលងអធ្រាត្រទៅប៉ុន្មាន គេយកខ្ញុំទៅបញ្ចូលនឹមនង្គ័ល ហើយបរទៅភ្ជួររាស់ដីទាំងយប់នោះ លុះព្រឹកឡើងទាល់ល្ងាចទៅទៀត ឥតឱ្យឈប់ឈរសម្រាកកម្លាំង ខ្ញុំហត់ស្ទើរតែនឹងដាច់ខ្យល់ ឯអ្នកភ្ជួរដែលនៅក្បែរគួថជានិច្ច មិនបង្អង់វាយគួថខ្ញុំឡើយ ដោយខ្ញុំប្រឹងទាញនង្គ័លរនាស់ខ្លាំងណាស់ទៅ ស្បែកកខ្ញុំក៏របកទាំងដុំៗ។ ដល់ព្រលប់ខ្ញុំត្រឡប់ចូលមកក្រោលវិញ គេយកចំបើងដោយទាំងដីធ្លី សំរាមសំរោចមកឱ្យខ្ញុំស៊ី ខ្ញុំក៏អត់ធ្មត់ខំប្រឹងស៊ីត្រាតែឆ្អែតទៅ ហើយត្រូវប្រះខ្លួនដេកលើអាចម៍លើនោមខ្ញុំជានិច្ច ព្រោះគ្មានកន្លែងផ្សេងសម្រាប់ដេក បើដូច្នេះតើខ្ញុំច្រណែននឹងភ័ព្វសំណាងបងឯងគួរឬទេ ?

វេលានោះ សត្វលាមិនឆ្លើយកាត់គោថា ដូចម្តេច? បណ្តោយឱ្យគោនិយាយលុះអស់សេចក្តីទើបលាឆ្លើយតបទៅថា "ម្នាលគោ ពាក្យដែលឯងនិយាយត្អូញត្អែរទាំងប៉ុន្មាន សុទ្ធតែពិតទាំងអស់ឥតមានបំភ្លើសឡើយ ប៉ុន្តែបានជាដូច្នេះ ព្រោះឯងឆ្កួតខ្លួនឯង នឹងបន្ទោស

អ្នកឯណា ក៏មិនបានឯងធ្វើស្លូតពេក បណ្តោយឱ្យគេដឹកនាំទៅតាមត្រូវការឥតមានរឹងរូសអ្វីបន្តិចសោះ ដែលឯងនឿយព្រួយលំបាកទាំងម្ល៉េះ តើឯងបានប្រយោជន៍អ្វីខ្លះដែរឬទេ? ឯងខំប្រឹងធ្វើការស្ទើរស្លាប់ខ្លួន ដើម្បីប្រយោជន៍ដល់មនុស្សដែលគ្មានគិតដល់សេចក្តីនឿយហត់របស់ឯងសោះ ប្រសិនបើឯងមានសេចក្តីក្លាហានស្មើនឹងកម្លាំងរបស់ឯង នោះគេមិនអាចធ្វើឯងដូច្នេះឡើយ ហេតុអ្វីបានជាវេលាដែលគេដឹកឯងទៅបញ្ចូលនឹមឯងមិនទំរន់កុំទៅដោយស្រួលហើយឯងមិនស្ទុះទៅគំរាមនឹងស្នែងរបស់ឯងធ្វើជាខឹងតន្រ្តំដី? ហេតុអ្វីបានជាមិនស្រែករោទ៍ឱ្យលាន់លឺខ្លាំងឡើង? អញឃើញថាឯងមានគ្រឿងបង្ការគ្រប់គ្រាន់ល្មមធ្វើឱ្យគេខ្លាចបាន ប៉ុន្តែឯងមិនប្រើប្រដាប់នោះសោះ កាលណាបើគេយកស្មៅស្ងួតមកឱ្យស៊ីត្រូវឯងកុំស៊ីគ្រាន់តែហិត១ ហើយដើរចេញទៅ បើឯងតាមដំបូន្មានអញនេះ ឯងនឹងបានសុខស្រួលមិនខាន ហើយឯងនឹងអរគុណដល់អញមិនលែងឡើយ» ។

វេលានោះ គោទទួលយកដំបូន្មាន អរគុណនឹងសត្វលាជាអនេកប្រការ ហើយមានវាចាថា ចាប់ផ្តើមតាំងពីថ្ងៃនេះទៅ ខ្ញុំនឹងធ្វើតាមពាក្យប្រដៅរបស់បងឯងមិនខាន ឱ្យបងឯងចាំមើលខ្ញុំចុះ ។ គោនិងលានិយាយគ្នាតែប៉ុណ្ណោះក៏ស្ងៀមទៅ ។ ឯនាយពាណិជ្ជបានស្តាប់សត្វទាំងពីរចាំឥតមានភ្លេចមួយម៉ាត់ ។

លុះព្រឹកឡើង អ្នកភ្ជួរស្រែភ្ជាក់ពីព្រលឹមដឹកគោយកទៅទឹម

តាមធម្មតា ឯគោដែលចាំដឹបូន្មានលាជានិច្ច ក៏ធ្វើកាចក្នុងថ្ងៃនោះយ៉ាងគ្រាន់បើ ដល់ពេលព្រលប់វេលាដែលគេយកទៅបញ្ចូលក្រោល ហើយយកខ្សែទៅចង ក៏មិនបណ្ដោយឱ្យចងតាមទម្លាប់ប្រឹង ត្រវីស្ទែងស្រែករោទ៍កញ្ច្រោលស្ទុះថយក្រោយ ហើយបន្ទាបក្បាលចុះធ្វើអាការៈចង់បុះអ្នកនោះ តាមពាក្យដែលសត្វលាបញ្ឆេះទាំងអស់ លុះព្រឹកស្អែកឡើងទៀត អ្នកភ្ជួរស្រែក៏ទៅពីព្រលឹម ដើម្បីនាំយកទៅទឹមទៀត វេលាដែលដើរទៅដល់ឃើញចំបើងដែលដាក់ឱ្យស៊ីពីល្ងាចសល់នៅទាំងអស់ ហើយឃើញគោដេកជើងត្រង់ស្លូក ដកង្ហើម ដង្ហក់មិនដូចប្រក្រតី ក៏ស្មានថាជាគោមានជំងឺ អ្នកភ្ជួរស្រែអាណិតគោណាស់ ក៏ខាននាំទៅទឹម ទើបយកសេចក្ដីទៅជម្រាបដល់នាយពាណិជថាគោឈឺ ។

នាយពាណិជកាលបានឮដូច្នោះហើយក៏យល់ឃើញថា គោនោះធ្វើតាមពាក្យដែលសត្វលាបញ្ឆេះពិត ។ ដើម្បីនឹងដាក់ទណ្ឌកម្មដល់សត្វលា ក៏ប្រាប់ទៅអ្នកភ្ជួរស្រែថា "អឺ បើគោឈឺ ត្រូវឯងយកលាទៅទឹមជាជំនួសវិញ បើទឹមហើយត្រូវឯងប្រើវាឱ្យនឿយ ធ្វើឱ្យលំបាកយ៉ាងច្រើន កុំប្រណីឡើយ" អ្នកភ្ជួរទទួលបង្គាប់ ហើយនាំយកលាទៅទឹមជំនួសក្នុងថ្ងៃនោះ ឯសត្វលាក៏សោយទុក្ខវេទនាពន់ប្រមាណ ដោយខ្លួនមិនធ្លាប់ធ្វើការដូច្នេះផង នឹងដោយគេវាយឥតត្រាប្រណីផង ។

ឯចំណែកគោក៏បានសេចក្ដីសុខស្រួល នៅថ្ងៃនោះមហិមាស៊ីស្មៅទាំងប៉ុន្មានដែលគេបានដាក់ឱ្យ ហើយដេកសម្រាកកំលាំងតាំងពីព្រលឹមដល់ព្រលប់ ទើបរំពឹងក្នុងចិត្តថា "អញធ្វើតាមពាក្យប្រដៅរបស់លាទៅ ឃើញស្រួលមែនហើយ ក៏ឱ្យពរដល់លាជាច្រើន" ។ លុះឃើញលាត្រឡប់មកពីស្រែវិញក៏និយាយសរសើរ នឹងអរគុណ តែវេលានោះលាមិនចេញស្ដីមួយម៉ាត់ ដោយតូចចិត្តខ្លាំងអំពីគេប្រើហើយធ្វើបាបពេញមួយថ្ងៃ ។ លាគិតតែក្នុងចិត្តថា "ការនេះ មកពីអញមិនបានគិតឱ្យជ្រៅម្យ៉ាង និងមកពីអញធ្វេសប្រហែសម្យ៉ាងបានជាអកុសលធ្លាក់លើខ្លួនអញដូច្នេះ កាលពីដើមខ្លួនអញបានសុខស្រួលសប្បាយ ជាទីបំផុត ចង់ធ្វើដូចម្ដេចក៏បានតាមចិត្តអញទាំងអស់ ឥឡូវមកពីកំហុសរបស់អញបានជាអញធ្លាក់ខ្លួនដល់ទីនេះ បើនៅស្ងៀមមិនគិតរកឧបាយអ្វីកែខ្លួនទេ អញមុខជាខូចការធំមិនខាន" គិតដូច្នេះ ហើយក៏ផ្ដួលខ្លួនដេកដូចជាស្លាប់ក្បែរស្នាចស្រូវនោះទៅ ព្រោះអស់កម្លាំងស្ទើរនឹងផុតដង្ហើម ដោយខំទាញនង្គ័លតាំងពីព្រលឹម លុះពេលព្រលប់ ។

អគ្គមហាសេនានិយាយដល់សេចក្ដីត្រង់នេះ ក៏បែរទៅប្រាប់នាងសែរ៉ាសាដថាៈ "នែកូន ! គំនិតកូនឯងដូចសត្វលាដូច្នោះ គឺសេចក្ដីចំណង់របស់កូនឯងនាំឱ្យអន្តរាយខ្លួន" ដោយមិនបានគិតឱ្យជ្រៅបុរាណថា "កុំឱ្យយកកទៅលអន្ទាក់ ចូរកូនជឿអាពុកចុះ នៅផ្ទះឱ្យស្ងៀមទៅកុំរករឿងចង់ស្លាប់ដូចគេ" ។ នាងឆ្លើយតបថា "លោកអាពុក

រឿងដែលលោកអាពុកយកមកធ្វើជាឧទាហរណ៍ពន្យល់ខ្ញុំនោះ មិនអាចនឹងទប់ទល់សេចក្ដីប្រាថ្នារបស់ខ្ញុំ ឱ្យប្រែប្រួលទៅទៀតបានឡើយ កាលណាបើលោកអាពុកព្រមនាំខ្ញុំទៅថ្វាយស្ដេច ទើបខ្ញុំសុខចិត្តលែងរំអុកលោកអាពុកទៅទៀត" ។ អគ្គមហាសេនាលុះឃើញបុត្រីចចេសទទូចសុំដូច្នោះ ក៏ប្រាប់ទៅទៀតថា "អើបើឯងមិនព្រមផ្លាស់គំនិតអាក្រក់នេះចេញទេ ត្រូវអញធ្វើឯងបន្តិចឱ្យដូចជានាយពាណិជធ្វើបំបាត់ចំណង់ប្រពន្ធនៅខាងចុងរឿង ដែលនិទានអម្បាញ់មិញនេះ ចូរឯងប្រុងស្ដាប់ចុះ" អគ្គមហាសេនាចាប់រឿងទៅទៀតថា :

ឯនាយពាណិជកាលបានដឹងថាលា មានសេចក្ដីទុក្ខវេទនាខ្លាំងដូច្នោះហើយ ក៏នឹកចង់ដឹងរឿងលានឹងគោ តើវានិយាយគ្នាដូចម្ដេចទៀត លុះរួចបាយល្ងាចហើយ នាយពាណិជនាំប្រពន្ធកូនដើរទៅលេងក្នុងវេលាយប់ខែភ្លឺច្បាស់ ក៏ទៅឈរជិតក្រោលសត្វនោះស្រាប់តែឮលាសួរទៅគោថា "ម្នាលគោសំឡាញ់អើយ ! ឯងនឹងគិតធ្វើដូចម្ដេចទៅទៀតដល់គេយកស្មៅមកឱ្យឯងស៊ីព្រឹកស្អែកនេះ? គោឆ្លើយតបថា ខ្ញុំនឹងធ្វើដូចជាបងឯងប្រដៅពីម្សិលមិញដូច្នោះទៀត ដំបូងខ្ញុំត្រូវថយឱ្យឆ្ងាយរួចខ្ញុំគ្រវីស្នែងចូល ខ្ញុំធ្វើពុតជាឈឺ ហើយស្រែករោទ៍ឱ្យឮខ្លាំងឡើង" វេលានោះលាឆ្លើយកាត់ថា : "នែសំឡាញ់ការនេះឃើញជាមិនស្រួលទេអញហាមឯងឱ្យហើយ ចូរឯងស្ដាប់អញ ត្រូវឯងកុំធ្វើដូច្នោះទៀត តែខំធ្វើនឹងអន្តរាយដល់ខ្លួនមិនខាន ព្រោះវេលាដែល

អញដើរមកចូលក្រោល ដល់កណ្ដាលផ្លូវអញឮម្ចាស់ យើងនិយាយការមួយ អញស្ដាប់ហើយភ័យតក់ស្លុតរន្ធត់ជួសឯងណាស់” គោសួរថា “បងឯងឮដូចម្ដេច? កុំលាក់នឹងខ្ញុំអាណិតប្រាប់ខ្ញុំផង” លាឆ្លើយប្រាប់ថា “អញបានឮម្ចាស់យើងនិយាយនឹងអ្នកភ្ជួរថា បើគោវាឈឺមិនស៊ីស្មៅហើយក្រោកមិនរួចដូច្នោះ វេលាព្រឹកស្អែកត្រូវឯង យកទៅសម្លាប់ហើយចែកចាយសាច់ដល់អ្នកកំសត់ទុគ៌តទៅ ឯស្បែកវាដែលមានប្រយោជន៍នោះ ត្រូវឯងប្រគល់ឱ្យទៅជាងសម្លាប់ស្បែក ត្រូវឯងទៅហៅអ្នកពិឃាតសត្វមកកុំខាន” លាប្រាប់បន្ថែមទៅគោទៀតថា “ដែលអញបានឮមកគឺយ៉ាងនេះ ហើយអញមិនចង់ឱ្យឯង អន្តរាយជីវិតព្រោះអញអាណិតស្រឡាញ់ឯងបានជាអញមកប្រាប់ ឯងវេលាព្រឹកស្អែកឡើង បើគេយកស្មៅមកឱ្យ ត្រូវឯងក្រោកឡើងយ៉ាងរហ័សហើយស្ទុះទៅរកស្មៅនោះ ធ្វើដូច្នេះម្ចាស់យើងនឹងសម្គាល់ឃើញថាឯងជាពិតប្រាកដ ហើយគាត់ក៏លែងឱ្យសម្លាប់ទៅវិញ អញប្រាប់ឯងតែប៉ុណ្ណេះ បើឯងធ្វើខុសពីនេះ មិនតាមដំបូន្មានអញទេ ឯងកុំបន្ទោសថាអញចិត្តអាក្រក់ ” ។

ឯគោ លុះបានស្ដាប់លានិយាយរឿងប្រាប់សព្វគ្រប់ហើយ ក៏ស្រយុតចិត្តភិតភ័យមហិមា ខ្លាចអន្តរាយរកអ្វីប្រៀបមិនបាន ហើយបន្លឺនូវសម្រែកជាកិរិយាត្អូញថ្ងូរគ្រប់ប្រការ តាមភាសាខ្លួនក្នុងវេលានោះ ។

នាយពាណិជបានឮសត្វទាំងពីរ ចរចាគ្នាទៅវិញទៅមក ដូច្នេះហើយ ក៏អស់សំណើចតែម្នាក់ឯងក្នុងទីនោះ ភរិយាដែលអង្គុយនៅជាមួយ ក៏កើតងឿងឆ្ងល់ទើបដណ្ដឹងសួរទៅស្វាមីថា "អ្នកសើចអ្វីខ្លាំងម៉្លេះ ចូរប្រាប់ខ្ញុំឱ្យដឹង ខ្ញុំនឹងសើចជាមួយផង" ប្ដីឆ្លើយប្រាប់ថា "នាងគ្រាន់តែស្ដាប់បងសើចក៏បានហើយ កុំចាំបាច់ចង់ដឹងរឿងរ៉ាវអ្វី" ប្រពន្ធថា "ទេ ! ខ្ញុំមិនព្រម ខ្ញុំចង់តែដឹងដើមទងអំពីសំណើចរបស់អ្នក សូមប្រាប់ខ្ញុំទើបខ្ញុំសុខចិត្ត" ប្ដីប្រាប់ទៀតថា "បងនឹងបំពេញចំណង់របស់នាងមិនបានទេ នាងគ្រាន់តែដឹងថា ដែលបងសើចនោះ គឺសើចនឹងពាក្យដែលលានឹងគោនិយាយគ្នា តែប៉ុណ្ណេះបានហើយ ឯដំណើររឿងរ៉ាវ ដែលវាថាដូចម្ដេចៗនោះ បងប្រាប់មិនបានទេ ព្រោះជាការស្ងាត់កំបាំងរបស់បង" ប្រពន្ធឆ្លើយថា "នរណាហាមមិនឱ្យអ្នកនិយាយរឿងស្ងាត់កំបាំងនោះប្រាប់ខ្ញុំ " ប្ដីប្រាប់ថា "បើបងប្រាប់នាងទៅជីវិតបងនឹងអន្តរាយក្នុងវេលានេះមិនខាន" ប្រពន្ធឆ្លើយថា "អ្នកឯងកុហកខ្ញុំ ពាក្យដែលអ្នកនិយាយនេះមិនពិត បើអ្នកមិនព្រមប្រាប់ខ្ញុំឱ្យត្រង់ពីរឿង ដែលអ្នកសើចទេ ហើយមិនព្រមឱ្យខ្ញុំដឹងអំពីសត្វលានឹងគោនិយាយដូចម្ដេចទេ ខ្ញុំប្ដេជ្ញាចិត្តស្បថចំពោះព្រះដែលគង់នៅខាងលើថា យើងទាំងពីរនាក់ច្បាស់ជាមិនបានរស់នៅជាមួយគ្នាតទៅទៀតបាន" ថាតែប៉ុណ្ណោះ ក៏ស្ទុះចូលទៅក្នុងផ្ទះ ហើយអង្គុយក្នុងកៀនមួយស្រែកទ្រហោយំខ្សឹកខ្សួលលុះអស់រាត្រី ។ ឯប្ដីក៏ដេកតែម្នាក់ឯងក្នុង

វេលាយប់នោះ លុះព្រឹកឡើងឃើញភរិយាអាត្មានៅ តែខ្សឹកខ្សួល ក៏បន្ទោសថា “នាងធ្វើយ៉ាងនេះមិនត្រូវទេ យំសោក ព្រោះតែរឿងប៉ុណ្ណេះ ការនេះបើទុកជានាងបានដឹងទៅ ក៏គ្មានប្រយោជន៍អ្វីសោះ ឯចំណែកបងត្រូវតែលាក់ ព្រោះជាត្រណមយ៉ាងតឹងរបស់បងត្រូវនាងលែងគិតអំពីរឿងនេះទៀតទៅ” ប្រពន្ធឆ្លើយឡើងថា “ខ្ញុំនៅតែគិតលុះត្រាតែអ្នកនិយាយ ប្រាប់ខ្ញុំទើបខ្ញុំលែងយំ” ប្ដីនិយាយទៀតថា “បងបានប្រាប់នាងដោយច្បាស់លាស់ថា បើបងប្រាប់តាមចំណង់ឆ្កួតរបស់នាងនោះខ្លួនបងនឹងស្លាប់មិនខានម្ដេចក៏នៅតែមិនព្រមជឿ” ប្រពន្ធឆ្លើយទៀតថា “បើត្រូវស្លាប់ក៏ស្លាប់ទៅចុះ ស្រេចនូវសង្ខាររបស់ខ្លួននឹងឱ្យខ្ញុំសុខចិត្តលែងសួរលែងចង់ដឹងរឿងនោះខ្ញុំមិនលែងទេ” ប្ដីនិយាយតទៅទៀតថា “បើអញកែឯងមិនឡើង ឯងនៅតែចចេសចង់ស្លាប់ដូច្នេះតោងហៅកូនចៅឱ្យមកជួបជុំ ឱ្យបានទាន់ដង្ហើមមុនដែលឯងនឹងផុតខ្យល់ទៅ” ថាតែប៉ុណ្ណេះក៏ប្រើមនុស្សឱ្យទៅហៅកូនចៅមកជួបជុំ ហើយហៅ ទាំងអាពុកម្ដាយនឹងបងប្អូននាងនោះទាំងប៉ុន្មានមកផង លុះមកជួបជុំគ្នា ហើយនាយពាណិជក៏និយាយរឿងប្រាប់តាមដំណើរសព្វគ្រប់ឱ្យស្ដាប់ទាំងអស់គ្នា ក៏ចូលទៅលួងលោមនិយាយពន្យល់ដោយន័យផ្សេងៗ ដើម្បីឱ្យលះបង់គំនិតអាក្រក់នោះចោលចេញ តែនាងមិនព្រមទទួលស្ដាប់ពាក្យនោះឡើយ ។ ត្រូវការតែស្ដាប់រឿងនោះឱ្យបាន បើមិនបានស្ដាប់សុខចិត្តតែស្លាប់ ឯកូនទាំងប៉ុន្មាននាក់

ដែលឃើញម្ដាយមិនព្រមស្ដាប់ដូច្នោះ ហើយក៏ស្រែកយំទ្រហឹងអឹងកងក្នុងវេលានោះ ចំណែកនាយពាណិជ ក៏មិនដឹងគិតផ្លូវណាអង្គុយកើតទុក្ខម្នាក់ឯងនៅមាត់ទ្វារផ្ទះពិចារណា ថាគួរធ្លាយប្រាប់ទៅស៊ូស្លាប់ខ្លួនឯង ឬគួរកុំនិយាយបណ្ដោយឱ្យភរិយាអាត្មាស្លាប់វិញ គិតទៅគិតមកមិនដឹងជាត្រូវសម្រេចតាមគំនិតណាឡើយ ។

ឯនាយពាណិជបានចិញ្ចឹមមាន់ញី៥០ នឹងមាន់គក ១នៅក្នុងភូមិនោះ ហើយមានឆ្កែ១ សម្រាប់ការពារសត្វទាំងនោះផង វេលាដែលនាយពាណិជកំពុងតែអង្គុយគិតម្នាក់ឯង ដើម្បីរកឧបាយណាដែលស្រួលល្អស្រាប់តែឃើញឆ្កែស្ទុះទៅសង្គ្រប់មាន់គកដែលកំពុងជាន់ញី ហើយឮឆ្កែស្ដីទ្រគោះឱ្យមាន់ថា “អាគកឯងហៅពេញជាព្រើលគ្មានដឹងអ្វីសោះ អាឯងច្បាស់ជាព្រះលោកមិនឱ្យរស់នៅយូរប៉ុន្មានឡើយ ឯងគ្មានព្រួយបារម្ភទេឬ? បានជាឯងត្រេកត្រអាលការកាល់ញីតាមអំពើចិត្តដូច្នេះ ក្នុងថ្ងៃនេះ” វេលានោះមាន់គកស្ទុះលោតឡើងទៅលើគំនរឧសហើយស្រែកសួរទៅឆ្កែវិញ ដោយព្រងើយឥតភ័យថា “នែ៎បងសុនខ ខ្ញុំឆ្ងល់ណាស់ ហេតុអ្វីក៏ត្រូវតមក្នុងថ្ងៃនេះពីថ្ងៃមុនៗម្ដេចក៏មិនតមផង” ឆ្កែតបវិញថា “បើឯងមិនដឹងអញនឹងប្រាប់” នែអាគកចូរឯងដឹងថា ក្នុងថ្ងៃនេះម្ចាស់ស្រីគាត់ចង់ដឹងរឿងដែលម្ចាស់ប្រុសប្រាប់មិនបាន បើប្រាប់ទៅនឹងអន្តរាយដល់ជីវិតអញ ភ័យក្រែងម្ចាស់ប្រុសអត់ប្រាប់មិនបាន ព្រោះគាត់ស្រឡាញ់ម្ចាស់ស្រីពន់ពេក

ឯម្ចាស់ស្រីចចេសទទូចចង់ដឹងណាស់អង្វរយ៉ាងណាក៏មិនស្តាប់ ចេះតែអង្គុយយំទង្គឹះខ្សឹកខ្សួល ហើយអញឃើញម្ចាស់ប្រុសព្រួយចិត្តអាណិតប្រពន្ធគាត់ផង ស្តាយជីវិតខ្លួនផង ហេតុនេះបានជាយើងព្រួយបារម្ភទាំងអស់គ្នា មានតែឯងមួយគ្មានគិតដល់ទុក្ខគេសោះ ចេះតែរត់ដេញកាល់ញីលេងតាមទំនើងចិត្តឯង ។

ឯមាន់គកកាលបើបានឮឆ្កែស្តីបន្ទោសដូច្នោះហើយ ក៏ឆ្លើយតបថា "ម្នាលបងសុនខ ម្ចាស់យើងពេញជាខ្លៅណាស់ប្រពន្ធតែមួយប្រដៅឱ្យបានបទដូចចិត្តមិនបាន បងឯងមើលខ្ញុំវិញប្រពន្ធដល់ទៅ ៥០ ខ្ញុំប្រដៅឱ្យរបបទាំងអស់ តែមួយក៏មិនហ៊ានខ្ទើកឱ្យទើសចិត្តខ្ញុំ" ។ ម្ចាស់យើងល្ងង់ក្រៃលែង បើចង់ឱ្យបាត់ព្រួយចិត្តជាការងាយសោះ ឆ្កែស្រែកសួរថា "ឯងថាងាយ តើត្រូវឱ្យម្ចាស់យើងធ្វើដូចម្តេច មាន់គកឆ្លើយថា ត្រូវឱ្យម្ចាស់ប្រុសចូលទៅក្នុងបន្ទប់ ដែលម្ចាស់ស្រីនៅបិទទ្វារឱ្យជិតហើយយកដំបងមួយយ៉ាងធំល្មមទៅសំពងបាន ១០០ កុំប្រណីបើធ្វើដូច្នេះហើយខ្ញុំហ៊ានសន្យាថា ម្ចាស់ស្រីច្បាស់ជានៅស្ងៀមទៅវិញលែងចង់ដឹងរឿងរ៉ាវនោះទៀត វេលានោះនាយពាណិជស្តាប់មាន់និយាយស្មើរតែមិនផុតសេចក្តី ក៏ស្ទុះក្រោកយកដំបងមួយដើរចូលទៅ ឯប្រពន្ធដែលកំពុងតែខ្សឹកខ្សួលតាំងបិទទ្វារជិតនៅតែពីរនាក់ ក៏ពឹតសំពងអស់ទំហឹងឥតប្រណី" លុះត្រាតែនាងនោះអត់មិនបានស្រែកអង្វរថា "ប៉ុណ្ណឹងហើយៗ ម្ចាស់ប្តីអើយវាយប៉ុណ្ណឹងចុះ ខ្ញុំលែងសួរ

លែងចង់ដឹងទៀតហើយ" កាលណាឮប្រពន្ធស្រែកខ្លាំងសន្យាថា នឹងបោះបង់គំនិតចាស់ចោលដូច្នេះហើយ នាយពាណិជក៏ឈប់វាយស្មុះទៅបើកទ្វារឱ្យបងប្អូនកូនចៅទាំងអស់គ្នាចូល អ្នកទាំងអស់ក៏មានសេចក្ដីសោមនស្សក្នុងវេលានោះ ដោយបានឃើញនាងចុះសំរុងស្រួលទៅវិញទើបនិយាយសរសើរដល់ប្រាជ្ញានាយពាណិជចេះរកឧបាយមកកែបាន ។ លុះចប់រឿងនេះហើយ អគ្គមហាសេនាប្រាប់ទៅនាងសែរ៉ាសាដជាកូនថា "ឯងនេះ ក្រែងតែអញធ្វើឱ្យដូចជានាយពាណិជធ្វើប្រពន្ធ ទើបឯងបោះបង់សេចក្ដីចចេសនេះចេញបាន" ។

នាងសែរ៉ាសាដឆ្លើយតបវិញថា ខ្ញុំសូមលោកអាពុកអនុញ្ញាតទោសខ្ញុំម្ដងទៀត សុំឱ្យលោកអាពុកកុំយល់ថាការដែលខ្ញុំចចេសនេះជាការអាក្រក់ឡើយ ឯរឿងនាងប្រពន្ធពាណិជនោះ មិនអាចមកប្រៀបនឹងសេចក្ដីចំណង់របស់ខ្ញុំបានទេ ខ្ញុំនឹងនាំរឿងរ៉ាវជាច្រើន ដែលជាឧបាយនាំឱ្យលោកអាពុកលែងឃាត់ខ្ញុំក៏បាន តែថាជាការខាតពេលវេលា បើដូច្នេះខ្ញុំគ្រាន់តែជម្រាបលោកអាពុកថា ដែលលោកអាពុកឃាត់ខ្ញុំជាការឥតអំពើ បើទុកជាលោកអាពុកមិនព្រមអនុញ្ញាតឱ្យខ្ញុំគង់តែនឹងចចេសទៅឱ្យដល់ស្ដេចខ្លួនឯងមិនខាន ។

ឯអគ្គមហាសេនា កាលឃាត់កូនមិនបានដូច្នោះ ក៏ទៅទាំងខឹងចូលទៅគាល់ស៊ុលតង់សារៀា ហើយទូលថាល្ងាចនេះនឹងនាំនាង សែរ៉ា-សាដ ជាកូនមកថ្វាយ ។

កាលនោះ ស៊ុលតង់សារ្យា មានសេចក្តីឆ្ងល់អំពីកិរិយារបស់អគ្គមហាសេនា ទើបទ្រង់ត្រាស់សួរថា "ចុះហេតុអ្វីបានជាដាច់ចិត្តយកកូនបង្កើតមកឱ្យយើងដូច្នេះ" ។

មហាមាត្យក្រាបទូលថា "កូនទូលព្រះបង្គំជាខ្ញុំចង់មកខ្លួនវាឃាត់មិនស្តាប់ វាថាឥតស្មើបរួញរាអ្វីនឹងសេចក្តីស្លាប់ ដែលរង់ចាំនោះសោះឡើយ វាថាឱ្យតែបានបម្រើព្រះករុណាជាម្ចាស់មួយរាត្រីវាសុខចិត្តទទួលស្លាប់ឥតមានតូចចិត្ត" ស៊ុលតង់ឆ្លើយប្រាប់ថា អគ្គមហាសេនា បើដូច្នោះអ្នកកុំភ្លេចថ្ងៃស្អែកយើងនឹងប្រគល់នាងសែរ៉ាសាដឱ្យអ្នកយកទៅពិឃាតដោយដៃឯង ប្រសិនបើអ្នកមិនសំលាប់យើងនឹងសម្លាប់អ្នកឯងវិញ ដោយដៃយើងជាប្រាកដ អគ្គមហាសេនាទូលថា "សូមទ្រង់ព្រះមេត្តាប្រោស បើទុកជាទូលព្រះបង្គំអល់ឯក វេរាចិត្តយ៉ាងណាក៏មិនអាចនឹងកន្លងព្រះរាជអាជ្ញាបាន ទូលព្រះបង្គំត្រូវតែសម្រេចព្រះរាជតម្រាស់តាមធម្មតា ដែលធ្លាប់ធ្វើមកវេលានោះ ស៊ុលតង់សារ្យាព្រមទទួលហើយ ប្រាប់ទៅអគ្គមហាសេនាថា បុត្រីមកថ្វាយពេលណាក៏បានតាមចិត្ត ។

អគ្គមហាសេនាថ្វាយបង្គំលាចេញទៅ ហើយក៏ម្នីម្នាទៅប្រាប់នាងសែរ៉ាសាដបុត្រីគ្រប់ប្រការ នាងនោះមានចេក្តីសោមនស្សពន់ប្រមាណ ហាក់ដូចជាបានវត្ថុអ្វីយ៉ាងប្រសើរថ្លៃថ្លាក្នុងលោក នាងអរគុណនឹងអគ្គមហាសេនាជាអាពុកឥតគណនា ហើយលួងលោមបិតា

ដោយមធុរវាចាជាច្រើនប្រការ កុំឱ្យអាពុកព្រួយបារម្ភនឹងខ្លួននាង ត្រូវឱ្យចាំសប្បាយឱ្យអស់ពីចិត្តក្នុងគ្រានេះចុះ ។

រួចពីនោះនាងប្រុងប្រៀបរៀបចំខ្លួន ដើម្បីទៅគាល់ស៊ុលតង់មុននឹងទៅ នាងហៅនាងឌីណារសាដជាប្អូនមកនិយាយថា "នែអូន ! ក្នុងវេលានេះបងមានធុរៈម្យ៉ាងធំ បងសូមឱ្យអូនជួយបងបន្តិចកុំប្រកែកឡើយ" ល្ងាចនេះអាពុកយើងនឹងនាំបងទៅថ្វាយព្រះមហាក្សត្រ ដើម្បីធ្វើជាមហេសីកុំឱ្យអូនមានសេចក្ដីភ័យបារម្ភអ្វីសោះអូនចាំស្ដាប់បងនិយាយប្រាប់ឱ្យច្បាស់ការណ៍ កាលណាបងបានទៅដល់ចំពោះព្រះភ័ក្រ្តស៊ុលតង់នោះ បងនឹងសុំអនុញ្ញាតនាំអូនទៅដេកក្នុងបន្ទប់ ដែលជាក្រឡាព្រះបន្ទំជាមួយផង ដើម្បីឱ្យបងបានឃើញមុខអូន ហើយចរចាប្រស្រ័យនឹងគ្នាក្នុងយប់នេះ បើបងសុំអនុញ្ញាតដូច្នេះបាន ត្រូវអូនចាំសម្ដីបងកុំភ្លេច ថាវេលាព្រឹកស្អែកត្រូវអូនភ្ញាក់ពីព្រលឹមមុនថ្ងៃរះមួយម៉ោង ហើយដាស់បងដោយវាចាថាដូច្នេះ "អ្នកបង ! បើអ្នកបងមិនសម្រាន្តលក់ទេ សូមនិទានរឿងអ្វីមួយដ៏ពីរោះ ដែលអ្នកបងចេះឱ្យខ្ញុំស្ដាប់បន្តិចទំរាំតែថ្ងៃរះឡើង លុះអូននិយាយសុំដូច្នេះហើយ បងក៏ផ្ដើមនិយាយរឿងមួយភ្លាម បងសង្ឃឹមថា រឿងនេះអាចនឹងសង្គ្រោះបណ្ដាជនទាំងអស់គ្នា ឱ្យរួចពីសេចក្ដីក្ដៅក្រហាយបានជាប្រាកដ" ឯនាងឌីណារសាដក៏ព្រមទទួលធ្វើតាមពាក្យទាំងប៉ុន្មានដូចមានខាងលើនេះ ។

លុះដល់ពេលព្រលប់ អគ្គមហាសេនានាំបុត្រីចូលទៅថ្វាយ

ស៊ុលតង់ ហើយថ្វាយបង្គំលាទៅលំនៅអាត្មាវិញ។ ខណៈនោះស្តេចមានបន្ទូលប្រាប់នាងសែរ៉ាសាដឱ្យបើកមុខចេញ ហើយទ្រង់គយគន់សព្វសព៌ាង្គកាយ ឃើញនាងមានរូបឆោមប្រកបដោយនរលក្ខណ៍ក៏កើតសេចក្តីស្នេហាប្រតិពទ្ធពន់ប្រមាណ តែទ្រង់មានសេចក្តីសន្ទិះសង្កាក្នុងព្រះហឫទ័យ ដោយឃើញនាងនោះទង្គឹះខ្សឹកខ្សួល ទើបមានព្រះរាជឱង្ការត្រាស់សួរហេតុនៃសេចក្តីសោយសោកនោះ នាងក៏ក្រាបទូលថា "បពិត្រព្រះសម្មតិទេវាវង្ស បានជាខ្ញុំម្ចាស់ខ្សឹកខ្សួលនេះព្រោះខ្ញុំម្ចាស់ឃ្លាតពីប្អូនស្រីមួយ ដែលខ្ញុំម្ចាស់ស្រឡាញ់ពេញចិត្តក្រៃពេកហើយ នាងនោះក៏ស្រឡាញ់ខ្ញុំម្ចាស់ស្មើគ្នា ខ្ញុំម្ចាស់សូមព្រះរាជានុញ្ញាតឱ្យប្អូនខ្ញុំម្ចាស់មកនិទ្រាក្នុងបន្ទប់នេះជាមួយមួយយប់ផង ដើម្បីឱ្យខ្ញុំម្ចាស់បានឃើញមុខនឹងបានផ្តែផ្តាំលាស្លាប់ សូមព្រះអង្គកុំទ្រង់យល់ទាស់សេចក្តីសុំរបស់ខ្ញុំម្ចាស់នេះឡើយ ព្រោះខ្ញុំម្ចាស់បានរស់នៅតែក្នុងយប់នេះទៀតទេ"។ វេលានោះស៊ុលតង់សារ្យាទ្រង់បើកព្រះរាជានុញ្ញាតឱ្យហើយឱ្យទៅនាំខ្លួននាងឌីណារសាដមកក្នុងពេលនោះ លុះដល់ពេលផ្ទំស្តេចនាំនាងសែរ៉ាសាដឡើងលើគ្រែទេនអាសនៈយ៉ាងខ្ពស់តាមទម្លាប់មហាក្សត្រ នាងឌីណារសាដក៏នៅដេកលើគ្រែមួយខាងក្រោមដែលបានរៀបទុកក្នុងទីនោះ ។

លុះពេលទៀបភ្លឺ នាងឌីណារសាដក៏ក្រោកឡើងមុនម្នាតាមពាក្យបណ្តាំបង ហើយស្រែកសួរទៅបងថា "អ្នកបង ! បើមិនទាន់



សម្រាន្តលក់ទេ សូមនិទានរឿងអ្វីមួយដ៏ពីរោះដែលអ្នកបងចេះឱ្យប្អូនស្តាប់បន្តិចទម្រាំតែភ្លឺ ឱអ្នកបងអើយ ! ប្រហែលជាប្អូនបានស្តាប់រឿងពីរោះរបស់អ្នកបងតែម្តងនេះទៀតទេ” ។

ឯនាងសែរ៉ាសាដ មុននឹងឆ្លើយតបទៅប្អូន បានទូលសួរស៊ុល-តង់ថា “បពិត្រព្រះករុណាជាម្ចាស់ ខ្ញុំម្ចាស់សូមព្រះរាជទានបំពេញបំណងនាងឌីណារសាដជាប្អូនក្នុងវេលានេះ សូមទ្រង់ព្រះករុណាមេត្តាប្រោសអនុញ្ញាតចុះ” ស្តេចឆ្លើយតបថា “អើចូរនាងនិយាយចុះ” នាងស្រែកប្រាប់ប្អូនថាចាំស្តាប់ ហើយទូលទៅស៊ុលតង់សារ្យាឱ្យទ្រង់ ព្រះសណ្តាប់រឿងដែលនាងនឹងនិទានថ្វាយ ទើបនាងចាប់និយាយរឿងនោះឡើង ។

**ចប់ភាគទី២ តែប៉ុណ្ណេះ**

**រឿងក្នុងភាគទី៣ កាន់តែចម្លែកណាស់ទៅទៀត**

**សូមអញ្ជើញមើលតទៅកុំខាន ។**

# រឿងបងប្អូនស្រីពីរនាក់ ច្រណែននឹងប្អូនស្រីពៅ

ព្រះនាងសេហេរ៉ាសាធ ដោយពុំទាន់ដឹងច្បាស់ថា តើព្រះបាទស៊ុលតង់នឹងសម្លាប់នាង ឬក៏ទុកជីវិតនាងឱ្យគង់នៅ ក៏ចាប់និយាយរឿងថ្មីមួយទៀតទូលព្រះអង្គ ដើម្បីបន្ទប់ព្រះអង្គកុំឱ្យទ្រង់នឹកតែទៅការសម្លាប់ចោលពេក មានសេចក្ដីដូចតទៅនេះ ÷

បពិត្រព្រះករុណាថ្លៃវិសេស កាលដើមឡើយមានព្រះអង្គម្ចាស់ប្រទេសពែរ្សមួយព្រះអង្គព្រះនាមកូរូសា ។ ព្រះអង្គម្ចាស់អង្គនេះកំពុងចាប់ផ្ដើមចង់ដឹងកិច្ចការផ្សេងៗក្នុងលោក ប៉ុន្តែព្រះអង្គច្រើនសព្វព្រះទ័យយាងដើរផ្សងព្រេងតែនៅវេលាយប់ គឺទ្រង់ស្លៀកពាក់ក្លែងព្រះអង្គមាននាយទាហានជំនិតមួយតាមដង្ហែផង ស្លៀកពាក់ក្លែងខ្លួនដូចជាព្រះអង្គដែរ ។ វេលាមួយព្រះអង្គទ្រង់យាងកាត់តាមសង្កាត់នៃទីក្រុង ព្រះអង្គទ្រង់បានទតឃើញវត្ថុដ៏ចម្លែកៗជាច្រើន ដែលខ្ញុំម្ចាស់ពុំអាចយកមកនិទានទូលព្រះអង្គក្នុងល្ងាចនេះ ឱ្យបានចប់ទាំងអស់តែម្ដងទេ ប៉ុន្តែខ្ញុំសង្ឃឹមថា ព្រះអង្គនឹងទ្រង់បានព្រះសណ្ដាប់យ៉ាងរីករាយ នូវរឿងមួយដែលកើតឡើងនៅពេលដែលព្រះមហាក្សត្រអង្គនោះ យាងចេញទតទីក្រុងនៅគ្រាជាដំបូងបង្អស់ នៅពេលពីរ-បីថ្ងៃ

បន្ទាប់ពីព្រះអង្គបានទ្រង់ឡើងសោយរាជសម្បត្តិជំនួសបិតាព្រះអង្គ ដែលទ្រង់សោយទីវង្គតទៅក្នុងព្រះជន្មាយុដ៏ចាស់ជរាជាទីបំផុត។ បិតាព្រះអង្គម្ចាស់មុននឹងទ្រង់សោយទីវង្គតទៅ បានប្រគល់ដែនដីប្រទេសពៃរ្សីថ្វាយមកព្រះអង្គម្ចាស់ទុកជាមរតក ។

បន្ទាប់ពីពិធីធ្វើបុណ្យរាជាភិសេក នឹងបន្ទាប់ពីពិធីបូជាព្រះបរមសព ព្រះករុណាជាអម្ចាស់លើត្បូងមក ព្រះចៅកូរូសា ជាព្រះបាទស៊ុលតង់ថ្មី ដើម្បីនឹងបានជ្រាបនូវកិច្ចការផ្សេងៗផ្ទាល់ព្រះអង្គ ព្រះអង្គក៏យាងចេញពីព្រះបរមរាជវាំងជាមួយលោកនាយករដ្ឋមន្ត្រី ស្លៀកពាក់ក្លែងកាយដូចជាព្រះអង្គដែរ នៅវេលាល្ងាចមួយ ពេលម៉ោងពីរយប់។ លុះយាងទៅដល់ក្នុងសង្កាត់មួយដែលមានតែប្រជាជនតូចតាចរស់នៅ, ព្រះអង្គទ្រង់ព្រះសណ្តាប់ឮគេនិយាយគ្នាយ៉ាងខ្លាំងៗ ។ ព្រះអង្គក៏ទ្រង់យាងចូលទៅជិតផ្ទះដែលលេចឮសម្រែកនោះចេញមក. ។ រួចកាលបើព្រះអង្គទតតាមប្រហោងទ្វារទៅ ទ្រង់ក៏បានឃើញពន្លឺនឹងបងប្អូនស្រីបីនាក់អង្គុយនៅលើកៅអីវែង កំពុងជជែកគ្នាក្រោយពីញ៉ាំបាយរួចមក។ កាលបើព្រះអង្គបានព្រះសណ្តាប់សំដីស្ត្រីដែលចាស់ជាងគេទៅ ព្រះអង្គក៏ទ្រង់ជ្រាបថា ប្រធាននៃរឿងដែលគេជជែកគ្នានោះគឺ "សេចក្តីប្រាថ្នា" ។ នារីជាបងបង្អស់ពោលថា : "សេចក្តីប្រាថ្នារបស់អញគឺចង់បានអ្នកធ្វើនំប៉័ងថ្វាយព្រះរាជាធ្វើជាស្វាមី នៅពេលនោះអញនឹងស៊ីនំប៉័ងដ៏ឆ្ងាញ់នោះឱ្យឆ្អែតឆ្អន់ ដែលគេអាចហៅម្យ៉ាងទៀត

ថា នំប៉ុងព្រះបាទស៊ុលតង់" ។ ដូច្នេះ ចាំមើលតើមានបំណងអ្នកណាប្រសើរជាងអញទេ ។

- នារីជាប្អូនបន្ទាប់ក៏និយាយថា សេចក្ដីប្រាថ្នារបស់ខ្ញុំ គឺចង់បានចៅហ្វាយនៃនាយពិសេសព្រះរាជាធ្វើជាប្ដី នៅពេលនោះខ្ញុំនឹងញ៉ាំម្ហូបសាច់ឆ្ងាញ់ៗ ហើយដោយខ្ញុំជឿជាក់ថា នំប៉ុងព្រះបាទស៊ុលតង់នឹងមាននៅក្នុងប្រាសាទឥតខ្វះឡើយ ដូច្នេះ ខ្ញុំក៏នឹងបាននំប៉ុងញ៉ាំឥតខ្វះឡើយ ។ បងឃើញទេ សេចក្ដីប្រាថ្នារបស់ខ្ញុំប្រសើរជាងសេចក្ដីប្រាថ្នារបស់អ្នកបង ។

ចំណែកនាងពៅវិញ, ដែលមានរូបសម្បត្តិដ៏ល្អក្រៃលែង ហើយជាស្ត្រីប្រកបដោយគំនិតវៀងវៃជាងបងៗផង នាងបានពោលដូច្នេះថា "ចំណែកខ្ញុំ, ខ្ញុំមិនប្រាថ្នាអ្វីខ្ជីបន្តិចដូច្នេះទេ ខ្ញុំប្រាកដជាប្រាថ្នាឱ្យបានខ្ពស់ជាងនេះហើយ បំណាច់យើងខំជជែកពីសេចក្ដីប្រាថ្នា ។ ដូច្នេះខ្ញុំនឹងប្រាថ្នាឱ្យបានទៅជាមហេសីព្រះបាទស៊ុលតង់ ហើយសុំប្រាថ្នាឱ្យមានព្រះរាជបុត្រមួយ មានសក់មួយចំហៀងជាមាសមួយចំហៀងទៀតជាប្រាក់។ ហើយកាលណាវាយំ សូមឱ្យទឹកភ្នែកហូរចេញមកក្លាយទៅជាគជ់, ហើយនៅគ្រប់ពេលដែលវាញញឹម សូមឱ្យបបូរមាត់ក្រហមជាំនោះលេចចេញឡើងដូចជាផ្កាកូលាបកំពុងរីក ។

សេចក្ដីប្រាថ្នានៃបងប្អូនស្រីបីនាក់នោះ, ជាពិសេសសេចក្ដីប្រាថ្នារបស់នាងពៅ, បានធ្វើឱ្យព្រះបាទស៊ុលតង់ទ្រង់ចម្លែកក្នុងព្រះ

ទ័យណាស់ ហើយព្រះអង្គទ្រង់សម្រេចចព្រះទ័យថា និងបំពេញបំណង ស្រីទាំងបីនេះឱ្យបាន ។ ប៉ុន្តែព្រះអង្គឥតទ្រង់មានព្រះបន្ទូលប្រាប់ រឿងនោះឱ្យលោកនាយករដ្ឋមន្ត្រីដឹងទេ. ព្រះអង្គគ្រាន់តែផ្តាំឱ្យលោក នាយកឱ្យសម្គាល់ផ្ទះនោះឱ្យច្បាស់ ដើម្បីនឹងបង្គាប់ឱ្យគេមកនាំស្ត្រី ទាំងនោះទៅថ្វាយព្រះអង្គនៅថ្ងៃស្អែក ។

ស្អែកឡើង លោកនាយករដ្ឋមន្ត្រីក៏ធ្វើតាមព្រះរាជបញ្ជាព្រះ បាទស៊ុលតង់ ។ លោកបានបង្គាប់ឱ្យស្រីទាំងនោះស្លៀកពាក់យ៉ាងឆាប់ ជាទីបំផុត ដើម្បីនឹងចូលទៅគាល់ព្រះអង្គ ។ លោកឥតបាននិយាយ រឿងអ្វីប្រាប់ស្ត្រីទាំងនោះ ក្រៅពីថាព្រះករុណាត្រូវការចង់ជួបទេ ។ លោកនាយកក៏នាំកញ្ញាទាំងនោះ ចូលទៅថ្វាយបង្គំព្រះបាទស៊ុលតង់ ក្នុងព្រះបរមរាជវាំង ។ ព្រះបាទស៊ុលតង់ក៏មានព្រះបន្ទូលសួរទៅនារី ទាំងនោះថា : "នាងភ្លេចហើយឬនៅអំពីបំណងដែលនាងរាល់គ្នាបាន ប្រាថ្នាពីយប់ម្សិលមិញ? ចូរនាងនិយាយប្រាប់យើងមក. កុំលាក់នឹង យើងឱ្យសោះ ព្រោះយើងចង់ដឹង" ។

កាលបើបានឮព្រះរាជឱង្ការ ព្រះមហាក្សត្រដូច្នេះយុវតីទាំងបី ដែលមិនសូវជាបានយកចិត្តទុកដាក់នឹងការដែលខ្លួនបាននិយាយគ្នាមក នោះប៉ុន្មាន. ក៏ទៅជាបែបភាន់ភាំងក្នុងគំនិត ។ នាងឱនមុខចុះនៅ ស្ងៀមទាំងអស់គ្នា ចំណែកនាងពៅដែលមានការប្រាថ្នាខ្ពស់ជាងគេ ក៏ សម្តែងកិរិយាបែបប្លែកជាងគេបន្តិចដែរ ។ ព្រះបាទស៊ុលតង់ កាលបើ

ទ្រង់សង្កេតឃើញនារីទាំងអស់នៅស្ងៀម ព្រោះក្រែងនឹកអៀនខ្មាស នឹងព្រះអង្គ នឹងខ្លាចក្រែងព្រះអង្គទ្រង់អាក់អន់ព្រះទ័យ ក៏មានព្រះបន្ទូលបញ្ជាក់ថា : "សូមនាងកុំខ្លាចអ្វីឱ្យសោះ យើងមិនមែនហៅនាងមកដើម្បីធ្វើទុក្ខទោសអ្វីទេ ។ ប៉ុន្តែឥឡូវដោយយើងសម្គាល់ឃើញថា សំនួរដែលយើងសួរទៅនាងនោះ ទៅជាបានលទ្ធផលផ្ទុយនឹងបំណងយើងវិញ យើងក៏លែងត្រូវការសួរទៀតដែរ ព្រោះយើងដឹងបំណងនាងរៀងៗខ្លួនអស់ហើយ ។ ដូច្នេះនាងដែលប្រាថ្នាចង់បានយើងធ្វើជាស្វាមី នាងនឹងបានពេញចិត្តក្នុងថ្ងៃនោះពុំខាន ។ ចំណែកឯនាងពីរនាក់ឯណោះខ្ញុំនឹងរៀបចំការឱ្យជាមួយអ្នកធ្វើនំប៉័ងយើង នឹងជាមួយចៅហ្វាយនៃនាយពិសេសរបស់យើងជាការចាំបាច់" ។

កាលបើព្រះបាទស៊ុលតង់ ទ្រង់សម្តែងឆន្ទៈព្រះអង្គដូច្នេះរួច. នាងពៅ. ដើម្បីជាគំរូដល់នាងបងៗ ក៏ស្ទុះទៅឱបព្រះបាទស៊ុលតង់សម្តែងអំណរគុណដល់ព្រះអង្គ ។ នាងពោលថា : "បពិត្រព្រះករុណាថ្លៃវិសេស ពិតមែនតែព្រះអង្គទ្រង់បានជ្រាប នូវសេចក្តីប្រាថ្នារបស់ខ្ញុំម្ចាស់. ប៉ុន្តែសេចក្តីប្រាថ្នានេះ គ្រាន់តែជាការជជែកគ្នាលែងសប្បាយប៉ុណ្ណោះទេ. ខ្ញុំម្ចាស់មិនសមនឹងទទួលកិត្តិយសដែលព្រះអង្គទ្រង់បានព្រះរាជទានដល់ខ្ញុំម្ចាស់នេះសោះ ហើយខ្ញុំម្ចាស់សូមព្រះករុណាទ្រង់ព្រះរាជទានអភ័យទោសដល់ខ្ញុំម្ចាស់ផង ចំពោះអំពើឥតអៀនខ្មាសរបស់ខ្ញុំម្ចាស់នេះ" ។ នាងបងពីរនាក់ទៀត ក៏បម្រុងសុំទោសព្រះរាជា

ដូច្នេះដែរ ប៉ុន្តែព្រះអង្គទ្រង់មានព្រះបន្ទូលកាត់ថា "ទេ. ទេ. កុំនាំរីវរ អ្វីទៀត. សេចក្តីប្រាថ្នារបស់នាងម្នាក់ៗត្រូវតែបានសម្រេច" ។

ពិធីរៀបអាពាហ៍ពិពាហ៍ ក៏បានធ្វើឡើងដំណាលគ្នាក្នុងថ្ងៃនោះ ដូចដែលព្រះបាទស៊ុលតង់ទ្រង់មានព្រះបន្ទូលមែន ប៉ុន្តែមានការប្លែកគ្នាសម្បើមណាស់ ។ ការរៀបអាពាហ៍ពិពាហ៍នាងពៅប្រព្រឹត្តទៅដោយអធិកអធម ប្រកបដោយការសប្បាយគ្រប់បែបគ្រប់យ៉ាង សមជាពិធីរាជាភិសេកព្រះបាទស៊ុលតង់ នឹងព្រះនាងស៊ុលតានប្រទេសពែរ្ស៍មែនៗ ។ ចំណែកឯមង្គលការនាងបងពីរនាក់វិញ ក៏បានធ្វើឡើងតាមរបៀបធម្មតា សមទៅតាមឋានៈអ្នកធ្វើនំប៉័ង នឹងចៅហ្វាយនៃនាយពិសេសរបស់ព្រះរាជា ។

ចាប់តាំងពីពេលនោះមក នាងបងទាំងពីរនាក់យល់ឃើញថា ការរៀបអាពាហ៍ពិពាហ៍របស់ខ្លួន មានសភាពអន់ថយជាងប្អូនស្រីឆ្ងាយណាស់។ ដូច្នេះ មិនបានត្រេកអរនឹងសុភមង្គលរបស់ខ្លួន ដែលបានសម្រេចទៅតាមតែបំណងរបស់ខ្លួនរៀងៗខ្លួន មានតែពីចង់លើសសេចក្តីប្រាថ្នានោះទៀតផង នាងបងពីរនាក់បែរទៅជាកើតសេចក្តីច្រណែនមហិមានឹងប្អូនស្រីខ្លួន លែងសប្បាយលែងរីករាយអ្វីទាំងអស់។ ប៉ុន្តែ នាងពុំទាន់មានពេលជួបនិយាយគ្នាផ្ទាល់អំពីការយល់ឃើញរៀងៗខ្លួន ចំពោះការដែលព្រះបាទស៊ុលតង់ទ្រង់សព្វព្រះទ័យប្អូនស្រីខ្លួនជាងខ្លួនទៅវិញ. នាងបានជួបគ្នាតែនៅពេលរៀបចំខ្លួន ដើម្បី

រៀបការតែប៉ុណ្ណោះ ។ ប៉ុន្តែពីរបីថ្ងៃក្រោយមក នៅពេលដែលនាងបានជួបគ្នានៅកន្លែងមុជទឹកសាធារណៈមួយដែលនាងបានសន្មតគ្នាពីពេលមុននោះ, នាងបងបង្អស់ ក៏និយាយទៅកាន់ប្អូនបន្ទាប់ថា : "ម្ដេចទៅអូន, តើអូនយល់ឃើញដូចម្ដេចអំពីប្អូនស្រីយើង? តើជាស្រីល្អសមធ្វើមហេសីស្ដេចទេ?"

- ទេបង, នាងបន្ទាប់ឆ្លើយ, ខ្ញុំដូចជាពុំយល់សោះហើយក្នុងរឿងនេះ។ ខ្ញុំមើលពុំឃើញវាល្អត្រង់ណាសោះ ចុះហេតុអ្វីបានជាព្រះបាទស៊ុលតង់ទ្រង់ទតឃើញវាល្អ ហើយទ្រង់ស្រឡាញ់វាទៅវិញ ។ វានេះ ជាកូនក្មេងសោះ ហើយបងដឹងទេ តើបងឃើញវាយ៉ាងម៉េច ។ តើជាការត្រឹមត្រូវទេ ដែលព្រះបាទស៊ុលតង់មិនបានសម្លឹងមើលរូបបងឯងសិន, ព្រោះបងឯងមានទឹកមុខនៅក្មេងជាងអូន ហើយបងឯងនេះ សមនឹងឋានៈព្រះអង្គផង គួរណាស់តែព្រះអង្គរកយុត្តិធម៌ឱ្យបងឯង ក្នុងការដែលទ្រង់ទៅជាសព្វព្រះទ័យស្រឡាញ់វាទៅវិញនោះ ។

- ទេអូន, នាងបងចរចា, សូមកុំនិយាយពីបង បងឥតយល់ទាស់ទេ បើសិនជាព្រះបាទស៊ុលតង់ទ្រង់សព្វព្រះទ័យនឹងរូបអូន តែនេះព្រះអង្គទៅជាស្រឡាញ់មនុស្សក្រខ្វក់ទៅវិញ ជាហេតុគួរឱ្យបងកើតទុក្ខណាស់ ។ បងត្រូវតែសងសឹកវាឱ្យបាន ហើយអូនឯងក៏មានប្រយោជន៍ក្នុងរឿងនេះដូចបងដែរ ។ អាស្រ័យដោយហេតុនេះ, បងសូមឱ្យអូនពួតដៃជាមួយបង ដើម្បីនឹងបានគិតគូរគ្នាពីរឿងនេះ ដែល

មានប្រយោជន៍ស្មើគ្នានឹងដើម្បីជួយប្រាប់មធ្យោបាយណា ដែលប្អូនយល់ឃើញថាប្រសើរនោះ ប្រយោជន៍នឹងធ្វើបង្អាប់មុខវាឱ្យទាល់តែបាន ។

បន្ទាប់ពីការរួមគំនិតក្បត់ដ៏ចង្រៃនោះមក ស្រីបងប្អូនពីរនាក់ក៏បានជួបគ្នាជាញឹកញយ ហើយនៅគ្រប់ពេលវាជួបគ្នា វាគ្មានជំនុំរឿងអ្វីក្រៅពីរិះរកផ្លូវយ៉ាងណាដើម្បីបំផ្លាញសុភមង្គលព្រះនាងស៊ុលតានជាប្អូនបង្កើតនោះទេ ។ វាក៏បានរកឃើញមធ្យោបាយជាច្រើន ប៉ុន្តែដល់ជជែកគ្នាពីរឿងត្រូវប្រតិបត្តិការណ៍ទៅ ឃើញថាមានឧបសគ្គយ៉ាងសម្បើម លុះត្រាតែវាពុំហ៊ានប្រថុយយកមធ្យោបាយមួយណាមកអនុវត្តន៍ភ្លាមៗបាន ។ ដូច្នេះយូរៗម្តង គេឃើញស្រីបងប្អូនពីរនាក់ទៅលេងប្អូនស្រីដោយលាក់ពុតអាក្រក់គួរផ្តន្ទាទោស ហើយនៅពេលដែលវាទៅលេងប្អូននោះ វាធ្វើជាសម្តែងសេចក្តីរីករាយរាក់ទាក់ទៅរកប្អូនជាក្រៃលែងប្រយោជន៍ឱ្យប្អូនជឿថា វាជាបងទាំងពីរមានសេចក្តីសោមនស្សជាពន់ពេកណាស់ ដែលបានឃើញប្អូនស្រីបានឡើងឋានៈខ្ពង់ខ្ពស់យ៉ាងនេះ ។ ចំណែកឯព្រះនាងស៊ុលតានជាប្អូនវិញ, នាងបានទទួលបងទាំងពីរដោយភារកិច្ចធម្មតា ដែលប្អូនត្រូវតែមានដល់បង ព្រោះនាងជាស្ត្រីមិនចេះឆ្មើងកន្ទ្រើង ដោយអាងយសសក្តិ ហើយនាងនៅតែស្រឡាញ់បង ដោយភាពជិតស្និទ្ធដូចជាពីពេលមុនដដែល ។

ពីរបីខែបន្ទាប់ពីពេលរៀបអាពាហ៍ពិពាហ៍មក, ព្រះនាង

ស៊ុលតានក៏ទ្រង់មានគភ៌ ។ ព្រះបាទស៊ុលតង់ក៏ទ្រង់មានព្រះទ័យត្រេកអរជាពន់ពេក ។ ហើយដំណឹងដ៏រីករាយនេះ បន្ទាប់ពីបានលាន់ឮពាសពេញនៅក្នុងព្រះបរមរាជវាំង ក៏បានផ្សាយចេញលាន់ឮរហូតទៅដល់ក្នុងសង្កាត់នានា នៃរាជធានីប្រទេសពែរ្ស៍ ។ ស្រីជាបងទាំងពីរនាក់កាលបើបានឮដំណឹងនេះ ក៏បានចូលទៅសម្ដែងសេចក្ដីរីករាយដល់ប្អូនដែរ ។ ហើយនៅពេលនោះ, ស្រីទាំងពីរក៏បាននិយាយរំលឹកព្រះនាងស៊ុលតានអំពីការរកឆ្មប ដែលព្រះនាងមុខជានឹងត្រូវការ ដើម្បីនឹងជួយប្រសូតបុត្រនាង ហើយស្រីទាំងពីរនោះក៏បានអង្វរព្រះនាងថាសូមកុំឱ្យយកឆ្មបឯណាក្រៅពីនាងជាបងពីរនាក់នោះ ។

ព្រះនាងស៊ុលតាន ក៏មានបន្ទូលតបទៅវិញដោយសេចក្ដីគួរសមទៅថា : “អ្នកបងទាំងពីរ, បើសិនជាការជ្រើសរើសនេះ អាចសម្រេចចេញពីខ្លួនខ្ញុំផ្ទាល់បាននោះ ខ្ញុំគ្មានត្រូវការយកនរណាដទៃទៀតទេ ដូចអ្នកបងបានជ្រាបនូវចិត្តខ្ញុំស្រាប់ហើយៗ ខ្ញុំសូមអរគុណនឹងឆន្ទៈល្អនេះ ។ ប៉ុន្តែខ្ញុំពុំអាចសម្រេចការអ្វីផ្សេងៗជួសព្រះបាទស៊ុលតង់បានឡើយ ។ ហេតុនេះ សូមអ្នកបងជម្រាបប្ដីអ្នកបងឱ្យគាត់ពឹងពាក់រកសម្លាញ់គាត់ ដើម្បីចូលសុំសេចក្ដីអនុគ្រោះនេះពីព្រះបាទស៊ុលតង់ទៅ ហើយបើសិនជាព្រះអង្គទ្រង់សួរយោបល់ខ្ញុំពីរឿងនោះៗ សូមអ្នកបងជឿចុះថា, ខ្ញុំមិនត្រឹមតែអរគុណព្រះអង្គដែលទ្រង់សព្វព្រះរាជហឫទ័យសួររឿងនេះដល់ខ្ញុំផងទេ គឺខ្ញុំថែមទាំងអរគុណព្រះ

អង្គជាច្រើនទៀត បើសិនជាព្រះអង្គព្រមរើសយកអ្នកបងធ្វើជាឆ្មប ខ្ញុំនោះ" ។

ស្វាមីស្រីពីរនាក់ក៏ទទួចសុំពឹងពាក់ជននៅក្នុងព្រះបរមរាជវាំង ដែលជាអ្នកឧបត្ថម្ភខ្លួន ព្រមទាំងសូមអង្វរឱ្យគេជួយក្រាបទូលព្រះបាទស៊ុលតង់ សុំឱ្យព្រះអង្គរើសយកភរិយាខ្លួនធ្វើជាឆ្មបព្រះនាងក្នុងការប្រសូតបុត្រ ។ ឧបត្ថម្ភកជន ក៏បានខំជួយខ្នះខ្នែងក្នុងរឿងនេះយ៉ាងពេញទំហឹង លុះត្រាតែព្រះបាទស៊ុលតង់ ទ្រង់ព្រមទទួលយករឿងនោះទៅពិនិត្យ ។ នៅពេលមួយព្រះអង្គក៏ទ្រង់មានព្រះបន្ទូលនិយាយជាមួយនឹងព្រះនាងស៊ុលតានថា ព្រះអង្គយល់ថាព្រះជេដ្ឋភគនីថ្លៃ[១] សមយកធ្វើជាឆ្មបសម្រាប់ជួយប្រសូតបុត្រម្ចាស់អូនប្រសើរជាងឆ្មបដទៃទៀត ប៉ុន្តែព្រះអង្គពុំទាន់ហ៊ានតែងតាំងភ្លាម ព្រោះពុំទាន់បានទទួលសេចក្តីយល់ព្រមពីព្រះនាងជាមុនផង ។ ព្រះនាងស៊ុលតានរំភើបញាប់ញ័រនឹងសេចក្តីគោរព ដែលព្រះបាទស៊ុលតង់ទ្រង់មានមកលើខ្លួនដូច្នេះ ក៏មានព្រះសវនីយតបថាៈ "បពិត្រព្រះករុណាថ្លៃវិសេស ខ្ញុំម្ចាស់បានបម្រុងខ្លួនស្រេចជាមុនថានឹងធ្វើការអ្វីៗតាមតែព្រះរាជបញ្ជារបស់ព្រះអង្គ ។ ដូច្នេះដោយព្រះអង្គទ្រង់មានព្រះទ័យមេត្តាសណ្តោសនឹងរើសយកបងស្រីខ្ញុំម្ចាស់នោះៗ ខ្ញុំម្ចាស់សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅជាអនេកចំពោះព្រះអង្គ ព្រោះកាយវិការនេះបណ្តាល

---

(១) បងថ្លៃស្រី

មកតែពីសេចក្តីស្នេហារបស់ព្រះអង្គមកលើរូបខ្ញុំម្ចាស់តែប៉ុណ្ណោះ ។ ហើយខ្ញុំម្ចាស់សូមទូលព្រះអង្គដោយត្រង់ថា ខ្ញុំម្ចាស់មានសេចក្តីរីក-រាយជាក្រៃលែងនឹងទទួលបងខ្ញុំម្ចាស់ជាជាងអ្នកដទៃទៀត» ។

ព្រះបាទស៊ុលតង់ក្នុរូសាក៏តែងតាំងបងស្រីព្រះនាងស៊ុលតានពីរនាក់ឱ្យធ្វើជាឆ្មបព្រះនាង ។ ហើយចាប់តាំងពីពេលនោះមក ស្រីទាំងពីរក៏បានចូលនៅក្នុងព្រះបរមរាជវាំងយ៉ាងសប្បាយ ដោយវារកឃើញឱកាសល្អត្រូវតាមបំណងខ្លួន ដើម្បីប្រព្រឹត្តិអំពើកំណាចគួរឱ្យខ្ពើម ប្រឆាំងនឹងព្រះនាងស៊ុលតានជាប្អូន ។

ពេលប្រសូតបុត្រក៏បានមកដល់ ហើយនាងស៊ុលតានក៏បានប្រសូតព្រះអង្គម្ចាស់មួយមកល្អដូចជាពន្លឺថ្ងៃ ។ ប៉ុន្តែលម្អនឹងភាពទន់ខ្សោយនេះពុំអាចញ៉ាំងចិត្តស្រីឥតមេត្តានោះ ឱ្យទោទន់អាណិតព្រះរាជកុមារបន្តិចសោះឡើយ ។ វាបានយកក្រណាត់សំពត់រុំកូនង៉ែតនោះធ្វើបែបលេង១ រួចយកទៅដាក់ក្នុងកញ្ច្រែងមួយ បណ្តែតឱ្យរសាត់ទៅតាមប្រឡាយទឹក ដែលហូរកាត់តាមក្បែរដំណាក់ព្រះនាងស៊ុលតាន ទើបវាយកកូនឆ្កែតូចមួយមកដាក់នៅកន្លែងនោះ ហើយដើរនិយាយផ្សាយថា ព្រះនាងស៊ុលតានបានប្រសូតបុត្រមកជាសត្វឆ្កែ ។ ដំណឹងដ៏អពមង្គលនេះបានឮទៅដល់ព្រះបាទស៊ុលតង់ ហើយព្រះបាទស៊ុលតង់ក៏ទ្រង់តូចព្រះទ័យជាក្រៃលែងស្ទើរតែនឹងបណ្តាលឱ្យមានលទ្ធផលដ៏អាក្រក់ដល់ព្រះនាងមហេសី បើកុំតែបានលោកនាយករដ្ឋមន្ត្រីពោល

បំភ្លឺព្រះអង្គថា ព្រះអង្គពុំអាចចាត់ភាពចម្លែកដែលកើតមកពីធម្មជាតិនេះឱ្យព្រះនាងទទួលខុសត្រូវទេ ។

កញ្ច្រែងដែលគេបានដាក់ព្រះរាជកុមារបណ្តែតចោលនោះ បានរសាត់ទៅតាមប្រឡាយទឹក រហូតទៅដល់ខាងក្រៅកំពែងជញ្ជាំងដែលខណ្ឌដំណាក់ព្រះនាង ហើយចាប់តាំងពីទីនោះទៅ. កញ្ច្រែងក៏រសាត់កាត់តាមទីសួននានានៃប្រាសាទ ។ ដោយទេសកាលនាយតម្រួតសួនច្បារព្រះបាទស៊ុលតង់ ដែលជាមន្ត្រីមានបណ្តាសក្តិម្នាក់ ហើយដែលត្រូវគេស្រឡាញ់រាប់អានជាច្រើនបំផុត នៅក្នុងព្រះនគរ បានអញ្ជើញដើរលេងក្នុងសួនបណ្តោយតាមប្រឡាយទឹក ក៏បានប្រទះឃើញកញ្ច្រែងអណ្តែត ។ លោកក៏ស្រែកហៅអ្នកថែសួនច្បារ ហើយចង្អុលប្រាប់ទៅអ្នកនោះថា "ចូរឯងទៅឱ្យលឿន ហើយរើសយកកញ្ច្រែងនោះមកឱ្យខ្ញុំ ដើម្បីខ្ញុំពិនិត្យមើលតើមានវត្ថុអ្វីនៅក្នុងនោះ" ។ អ្នកថែសួនក៏ចេញទៅមួយរំពេច លុះទៅដល់គាត់ក៏ឈោងពីមាត់ប្រឡាយយកចបជីកថ្កក់ទាញកញ្ច្រែងនោះលើកឡើង ហើយយកទៅជូនចៅហ្វាយគាត់ ។

នាយតម្រួតសួនមានសេចក្តីភ្ញាក់ផ្អើលជាខ្លាំង កាលបើឃើញកូនង៉ែតមួយរុំក្រណាត់ដាក់ក្នុងកញ្ច្រែងនោះ ហើយកូនង៉ែតនោះ ពិតមែនតែនៅរស់ហើយគួរឱ្យចង់មើល ប៉ុន្តែលោកមើលទៅហាក់ដូចជាពុំសូវឃើញល្អប៉ុន្មាន ។ ជាឱកាសល្អ. នាយតម្រួតសួននោះមានប្រពន្ធជាយូរពេលក្រៃលណាស់មកហើយ ប៉ុន្តែទេវតាពុំទាន់បានដាក់ទាន

បុត្រមួយដល់លោកសោះ ។ ដូច្នេះ លោកក៏ឈប់ដើរលេង ហើយបង្គាប់ឱ្យអ្នកថែសួនកាន់កញ្ច្រែងនោះដើរមកតាមលោក ។ លុះលោកត្រឡប់មកដល់សណ្ឋាគារលោកវិញ ដែលមានផ្លូវចូលតាមសួនព្រះរាជវាំង លោកក៏ចូលទៅក្នុងបន្ទប់ប្រពន្ធលោកភ្លាម ហើយនិយាយថា "ឯងហើយ យើងពុំទាន់មានកូនមួយសោះ ឥឡូវទេវតាលោកបានដាក់ទានកូនឱ្យយើងមួយហើយ ។ ហេតុនេះចូរឯងរកមេដោះមួយឱ្យបានឆាប់មក ហើយចូរឯងមើលថែរក្សាកូននេះដូចជាកូនយើងបង្កើត ។ ខ្ញុំទទួលស្គាល់ថាជាកូនតាំងពីពេលនេះទៅ" ។ ប្រពន្ធក៏ទទួលយកកូនង៉ែតនោះដោយរីករាយ សម្តែងអាការៈឱ្យឃើញថា នាងចង់បានកូនមែន ។ នាយតម្រួតសួនមិនចង់និយាយរឿងនេះឱ្យវែងឆ្ងាយប្រាប់ប្រពន្ធទៀតទេ តែគាត់បាននឹកក្នុងចិត្តថា : "អញយល់ច្បាស់ថា កូននេះលេចចេញមកពីខាងទិសដំណាក់ព្រះនាងស៊ុលតាន ប៉ុន្តែការនេះមិនត្រូវមុខងារអញដើម្បីនឹងទៅពិនិត្យការអ្វីៗនៅកន្លែងនោះទេ ឬក៏ទៅបណ្តាលឱ្យមានចលាចលនៅក្នុងកន្លែង ដែលសេចក្តីស្ងប់ស្ងៀមត្រូវតែមានជាការចាំបាច់ឡើយ" ។

ឆ្នាំជាបន្ទាប់មក, ព្រះនាងស៊ុលតានក៏ប្រសូតព្រះរាជបុត្រមួយព្រះអង្គទៀត, ស្រីឆ្មបទាំងពីរក៏គ្មានចិត្តករុណាអ្វីបន្តិចដល់ព្រះអង្គម្ចាស់ខាងក្រោយនេះដែរ ។ វាបានយកកូនង៉ែតនោះដាក់កញ្ច្រែងបណ្តែតតាមប្រឡាយទឹកដូចជាលើកមុន រួចវាក៏ពោលក្លែងថា ព្រះ

នាងស៊ុលតានប្រសូតបុត្រមកជាសត្វឆ្មា ។ ជាសំណាងល្អរបស់កូនង៉ែតនោះ. នាយតម្រួតសួនបាននៅក្បែរប្រឡាយទឹកនោះទៀត. លោកក៏រើសយកកញ្ច្រែងឡើងពីទឹក រួចយកទៅឱ្យភរិយាលោក ដោយផ្តាំនឹងភរិយាថា សុំឱ្យមើលបីបាច់ថែរក្សាកូនខ្ចីនោះដូចជាកុមារមុនផង ។ នាងភរិយាក៏បានយកចិត្តទុកដាក់ចិញ្ចឹមបីបមកូនង៉ែតអភព្វ ដោយក្តីស្នេហាជាទីបំផុត ម្យ៉ាងបណ្តាលមកពីចិត្តរបស់គាត់ផ្ទាល់ ម្យ៉ាងដើម្បីឱ្យត្រូវតាមបណ្តាំស្វាមី ។

ព្រះបាទស៊ុលតង់ប្រទេសពែរ្ស៍ កាលបើទ្រង់ជ្រាបនូវដំណឹងខាងក្រោយនេះ. ក៏ទ្រង់អាក់អន់ព្រះទ័យលើសពីលើកមុនទៅទៀត ។ ព្រះអង្គទ្រង់សម្តែងអាការៈក្រោធទៅហើយ បើសិនជាការព្រមានរបស់លោកនាយករដ្ឋមន្ត្រីមិនបានជួយញ៉ាំងព្រះទ័យព្រះអង្គឱ្យស្ងាត់ស្ងៀមទៅវិញទេ ។

ទីបំផុត. នៅឆ្នាំទីបីព្រះនាងស៊ុលតាន ទ្រង់ប្រសូតព្រះរាជបុត្រមួយទៀត តែម្តងនេះជាក្សត្រី ។ ព្រះរាជកុមារីខាងក្រោយនេះក៏ទទួលវាសនាដូចជាព្រះរៀមមុនៗដែរ ។ ស្រីបងប្អូនពីរនាក់ ដែលបានកំណត់ក្នុងចិត្តជាស្រេចហើយថា នឹងឈប់ប្រព្រឹត្តអំពើអាក្រក់គួរឱ្យខ្ពើមនេះ លុះត្រាតែវាបានឃើញព្រះនាងស៊ុលតានប្អូនស្រីវាយ៉ាងហោចណាស់ក៏ខ្ចាត់ចេញពីព្រះបរមរាជវាំង. អាម៉ាសមុខរកអ្វីប្រៀបគ្មានដែរ. ក៏នៅតែប្រព្រឹត្តអំពើលាមកទៅលើកូនង៉ែតព្រះរាជាដដែល

ដោយដាក់បណ្តែតចោលតាមប្រឡាយទឹក ។ តែជាកុសលផលបុណ្យលោកជួយព្រះអង្គម្ចាស់ក្សត្រី ក៏ត្រូវបានលោកនាយតម្រួតសួនដដែលជួយស្រោចស្រង់ជីវិតផុតពីក្តីមរណៈទៀត ហើយបានទទួលការចិញ្ចឹមបីបាច់ពីលោក ដូចជាព្រះរៀមពីរនាក់មុនដែរ ។

បន្ទាប់ពីអំពើមនុស្សធមិនេះមក, ស្រីពីរនាក់ក៏បានប្រើមធ្យោបាយកុហកនឹងបោកប្រាសដូចជាលើកមុនទៀត ។ វាបានបង្ហាញឈើមួយដុំឱ្យគេឯងឃើញ ហើយនិយាយបង្កាច់ថា ព្រះនាងស៊ុលតានបានប្រសូតបុត្រមកជាដុំឈើ ហើយគឺជាឈើថ្មីម ដែលគេសង់នៅមាត់ផ្លូវចូលផែកប៉ាល់សម្រាប់ការពារនឹងខ្យល់រលក ។

ម្តងនេះ កាលបើព្រះបាទស៊ុលតង់ទ្រង់បានជ្រាបនូវដំណឹងចម្លែកខាងក្រោយបំផុតនេះ ព្រះអង្គពុំអាចទប់ពុំក្រោធបានទៀតឡើយ ។ ទើបព្រះអង្គមានព្រះបន្ទូលស្ទូរសីហនាទថាៈ "យីម៉េច, មិនស្រីចង្រៃមិនសមឋានៈអញនេះ បើសិនជាអញទុកឱ្យវារស់នៅក្នុងទីនេះ តទៅទៀត វាមុខជានឹងបង្កើតរបស់អាក្រក់ៗដាក់ពេញប្រាសាទអញទៅហើយឬ? ទេ, ការនេះមិនត្រូវឱ្យកើតមានបានទេ, វានេះជាស្រីចង្រៃអញត្រូវតែលាងគំរង់នេះ ឱ្យស្អាតចេញពីលោកនេះ" ។ ដូច្នេះ ព្រះអង្គក៏ទ្រង់ប្រកាសកាត់ទោសប្រហារជីវិត រួចក៏ទ្រង់បង្គាប់ទៅលោកនាយករដ្ឋមន្ត្រីឱ្យចាត់ការនេះឱ្យបានសម្រេច ។

លោកនាយករដ្ឋមន្ត្រីនិងជននៅក្នុងព្រះបរមរាជវាំង ដែលនៅ

ជួបជុំគ្នាក្នុងទីនោះ ក៏ឱនលុតជង្គង់សូមអង្វរព្រះអង្គដើម្បីសុំលប់ចោលសេចក្តីសម្រេចព្រះទ័យនោះ។ លោកនាយករដ្ឋមន្ត្រីក៏មានប្រសាសន៍ឡើងថា : “បពិត្រព្រះករុណាថ្លៃវិសេស, សូមព្រះតេជៈតំកល់លើត្បូង សូមល្អងធូលីប្រោសព្រះរាជទានអនុញ្ញាត ឱ្យទូលព្រះបង្គំនិយាយទូលព្រះអង្គបន្តិចថា ច្បាប់សម្រាប់ផ្តន្ទាទោសប្រហារជីវិតបានចែងឡើង ដើម្បីដាក់ទណ្ឌកម្មតែដល់ជនណាដែលបានប្រព្រឹត្តអំពើឧក្រិដ្ឋ រីឯការប្រសូតបុត្រនៃព្រះនាងស៊ុលតាន ពិតមែនជាការចម្លែកពុំដែលឃើញ ពុំដែលឮ ក៏ប៉ុន្តែមិនមែនជាអំពើឧក្រិដ្ឋទេ ។ តើអាងអ្វីដែលថា ឱ្យព្រះនាងត្រូវទទួលទោសក្នុងរឿងនេះ? មានស្រីឯទៀតជាច្រើនដែរដែលបានកើតបុត្រចម្លែកៗ ដូច្នេះហើយនឹងនៅតែមានដូច្នេះជារៀងរាល់ថ្ងៃទៀតផង ។ ស្ត្រីទាំងនោះត្រូវទទួលសេចក្តីឈឺចាប់ក្នុងចិត្តមែន ប៉ុន្តែស្រីទាំងនោះឥតដែលត្រូវមានទោសទេ ។ ព្រះករុណាថ្លៃវិសេសអាចបណ្តេញវាចេញឱ្យបាត់ពីព្រះភក្ត្រ ប៉ុន្តែត្រូវទុកជីវិតវា។ សេចក្តីទុក្ខព្រួយដែលវានឹងត្រូវទទួល លុះត្រាអស់មួយជីវិតវានោះ ដោយសារវាត្រូវបាត់បង់នូវសេចក្តីទទួលរាប់អានពីព្រះអង្គជាទារុណកម្មមួយដ៏សម្បើមណាស់ទៅហើយ” ។ ព្រះបាទស៊ុលតង់ប្រទេសពែរ្សក៏ទ្រង់នៅស្ងៀម ។ ហើយដោយហេតុថាព្រះអង្គទ្រង់យល់នូវការអយុត្តិធមិ ដែលព្រះអង្គទ្រង់បានប្រកាសផ្តន្ទាទោសប្រហារជីវិតព្រះនាងស៊ុលតានមកពីការប្រសូតបុត្រខុសគេ

នោះ ហើយទោះបីការនេះមិនមែនដូច្នោះក៏ដោយ ក៏ព្រះអង្គមិនត្រូវធ្វើយ៉ាងនេះដែរ ទើបព្រះអង្គមានព្រះបន្ទូលថា: "បើដូច្នេះត្រូវទុកវាឱ្យរស់នៅចុះ ប៉ុន្តែត្រូវផ្តន្ទាទោសវាជារាល់ថ្ងៃកុំខាន ។ ហេតុនេះត្រូវឱ្យគេសង់រានមួយនៅមាត់ផ្លូវចូលទៅក្នុងវិហារអ៊ីស្លាម ដែលធំជាងគេ ត្រូវមានបង្អួចមួយបើកចំហជានិច្ច រួចត្រូវយកមីស្រីចង្រៃនេះទៅឱ្យនៅក្នុងនោះ ឱ្យសំពត់អាវវាស្លៀកពាក់យ៉ាងក្រខ្វក់បំផុត ដើម្បីឱ្យពួកអ៊ីស្លាមម្នាក់ៗ ដែលត្រូវចូលទៅព្រះវិហារស្តោះទឹកមាត់ដាក់មុខវា នៅពេលដើរចូលទៅសូត្រធម៌ ។ ហើយបើសិនជាមាននរណាធ្វើល្មើសនឹងបញ្ញត្តិនេះ ខ្ញុំនឹងផ្តន្ទាទោសដូចស្រីទុរយសនេះដែរ ។ ដូច្នេះដើម្បីឱ្យការនេះត្រូវបានគេគោរព. ខ្ញុំសូមឱ្យលោកនាយកចាត់ការឱ្យមានមនុស្សចាំឃ្លាំមើលផង" ។

ព្រះសូរសៀង ដែលព្រះបាទស៊ុលតង់ទ្រង់ប្រកាសដាក់កំហិតដល់ព្រះនាងស៊ុលតាននេះ បានបិទមាត់លោកនាយករដ្ឋមន្ត្រីឱ្យនៅស្ងៀមឈឹង ។ លោកនាយកក៏រៀបចំចាត់ចែងការនេះ ជាហេតុឱ្យស្រីប្រច័ណ្ឌពីរនាក់ជាបងសប្បាយចិត្តជាក្រៃលែង ។ រានសម្រាប់ដេកក៏បានសង់រួចជាស្រេច ហើយនាងស៊ុលតានដែលមានសន្តានគួរឱ្យសន្តោសនោះ. ក៏ត្រូវគេនាំយកទៅដាក់នៅកន្លែងនោះ បន្ទាប់ពីពេលព្រះនាងយាងចេញពីកន្លែងប្រសូតបុត្រ តាមព្រះរាជបញ្ជាព្រះបាទស៊ុលតង់ ។ ហើយចាប់តាំងពីពេលនោះមក ព្រះនាងក៏ត្រូវទទួលអំពើដ៏ថោកទាប

មានការចំអកឡកឡឺយនិងការមើលងាយគ្រប់បែបគ្រប់យ៉ាងពីប្រជាជន គឺជាអំពើមួយដែលព្រះនាងពុំត្រូវទទួលរងសោះ ប៉ុន្តែនាងស៊ូខាំមាត់នៅស្ងៀមទ្រាំទទួលទោសនោះ ជាហេតុញ៉ាំងទឹកចិត្តជនដែលចេះរើកញែករកការខុសត្រូវម៉ត់ចត់ជាងជនសាមញ្ញឱ្យមានការស្ងើចសរសើរនិងអាណិតព្រះនាងជាច្រើន ។

សូមដំណាលពីព្រះអង្គម្ចាស់ពីរព្រះអង្គ និងព្រះអង្គម្ចាស់ក្សត្រីជាព្រះរាជបុត្រព្រះនាងម្តងវិញ. ព្រះអង្គទ្រង់បានទទួលការចិញ្ចឹមបីបាច់ពីសំណាក់លោកនាយតម្រួតសួន និងភរិយាលោកដោយសេចក្តីស្នេហាថ្នាក់ថ្នមវិស័យដូចមាតាបិតាព្រះអង្គបង្កើត ហើយសេចក្តីស្នេហានេះកាន់តែកើតមានធំឡើងៗជាលំដាប់ណា ដែលព្រះអង្គម្ចាស់ទាំងឡាយមានវ័យធំបន្តិចឡើងៗ និងតាមសញ្ញានៃឫកពាអានុភាពដែលលេចចេញឡើង ។ តាមការចំណាំនេះ គេសម្គាល់ឃើញថា ព្រះអង្គម្ចាស់ក្សត្រីទ្រង់បែបមានបញ្ញាវៀងវៃជាងព្រះរៀមទាំងពីរ ។ ក្រៅពីនេះ មាតាបិតាចិញ្ចឹមទ្រង់ស្រឡាញ់ព្រះអង្គម្ចាស់ក្សត្រីច្រើនជាងព្រះអង្គម្ចាស់បន្តិច ដោយមកពីព្រះអង្គម្ចាស់ក្សត្រីកាន់តែមានព្រះរូបល្អឡើងជារាល់ថ្ងៃ និងដោយព្រះនាងមានភាពទន់ភ្លន់និងចរិយាថ្លៃថ្នូរខុសពីក្មេងធម្មតា ព្រមទាំងមានទឹកព្រះភក្ត្រអាចប្រដូចបានតែទៅនឹងបុត្រនៃខត្តិយវង្សទាំងឡាយ ។ ដើម្បីសម្គាល់ព្រះអង្គម្ចាស់ទាំងពីរនោះតាមលំដាប់ថ្ងៃខែប្រសូតមក លោកនាយសួននិងភរិយាបានដាក់

ព្រះនាមព្រះអង្គម្ចាស់បងថា បាម៉ាន. ព្រះអង្គម្ចាស់ប្អូន ប៉ៃរិស (គឺជាព្រះនាមអតីតមហាក្សត្រប្រទេសពៃរ្យ៍) ។ ឯព្រះនាងក្សត្រីវិញ, គាត់បានថ្វាយព្រះនាមថាប៉ារីសាដ ដែលជាព្រះនាមដែលគេបានដាក់ថ្វាយព្រះមហេសី ឬព្រះអង្គម្ចាស់ក្សត្រីក្នុងប្រទេសជាច្រើនមកហើយ ។

កាលបើព្រះអង្គម្ចាស់ទាំងពីរមានព្រះវ័យចម្រើនធំល្មមហើយ, នាយតម្រួតសួនក៏បានរកគ្រូម្នាក់ឱ្យមកបង្រៀនព្រះរាជកុមារឱ្យរៀនមើលរៀនសរសេរ ។ ចំណែកឯព្រះរាជកុមារី ដែលព្រះអង្គចេះតែទៅអង្គុយស្តាប់គេរៀន ក៏កើតព្រះទ័យចង់រៀនមើលរៀនសរសេរនឹងគេដែរ ពិតមែនតែនៅក្មេងជាងព្រះកុមារទាំងពីរ ។ នាយតម្រួតសួនសប្បាយចិត្តនឹងចេតនាល្អនោះ ក៏សុំគ្រូនោះឱ្យព្រះនាងចូលរៀនជាមួយនឹងព្រះអង្គម្ចាស់ផង ។ មិនយូរប៉ុន្មានអាស្រ័យដោយព្រះនាងមានបញ្ញាវៀងវៃនិងមានចិត្តប្រណាំងប្រជែង, ព្រះនាងក៏មានការចេះចាំច្រើនជាងព្រះអង្គម្ចាស់ព្រះរៀម ។

ចាប់តាំងពីពេលនោះមក, ព្រះអង្គម្ចាស់ទាំងបីព្រះអង្គទ្រង់រៀនមុខវិជ្ជាខាងវិចិត្រសិល្ប៍ផ្សេងៗ នឹងគ្រូតែមួយជាមួយគ្នា ដូចជាភូមិសាស្ត្រ, កវីនិពន្ធន៍, ពង្សាវតារ និងវិទ្យាសាស្ត្រផ្សេងៗ ទោះវិទ្យាសាស្ត្រអាថិកំបាំងក៏ដោយ ។ ហើយដោយហេតុតែព្រះអង្គម្ចាស់ទាំងឡាយទ្រង់សិក្សាមុខវិជ្ជាទាំងនោះ ហាក់ដូចជាគ្មានឃើញលំបាកត្រង់កន្លែងណាសោះ ព្រះអង្គក៏ទ្រង់សិក្សាឆាប់ចេះចម្រើនជាទីបំផុត

លុះត្រាតែគ្រូទាំងឡាយមានសេចក្ដីងឿងឆ្ងល់ ហើយមិនយូរប៉ុន្មានគ្រូទាំងអស់ក៏លាន់មាត់ពោលបញ្ជាក់ដោយត្រង់ថា ព្រះអង្គម្ចាស់ទាំងឡាយទ្រង់បានសិក្សាមុខវិជ្ជាទាំងអស់ ចេះសព្វគ្រប់ជ្រៅជ្រះជាងលោកទៅទៀត ដូច្នេះលោកគ្មានអ្វីនឹងបង្រៀនព្រះអង្គម្ចាស់ទាំងបីព្រះអង្គនេះទៀតទេ ទោះតិចតួចក៏ដោយ ។ នៅពេលវិស្សមោកាល. ព្រះអង្គម្ចាស់ក្សត្រីទ្រង់រៀនវិជ្ជាភ្លេង. រៀនច្រៀងនិងរៀនលេងភ្លេងជាច្រើនមុខទៀត ។ កាលបើព្រះអង្គម្ចាស់ព្រះរៀមទៅរៀនជិះសេះ. ព្រះនាងក៏ទៅរៀនជិះសេះជាមួយដែរ លុះត្រាតែចេះគង់សេះ. ចេះបាញ់ធ្នូ ចោលដំបងចោលលំពែងយ៉ាងប៉ិនប្រសប់ដូចជាព្រះរៀមដែរ ព្រោះព្រះនាងមិនចង់ឱ្យព្រះរៀមចេះមុខវិជ្ជាអ្វីលើសព្រះនាងឡើយ ។ ហើយព្រះនាងទ្រង់តែងចេះវិជ្ជានីមួយៗថ្មីកជាងព្រះរៀមផង ។

នាយតម្រួតសួន ដែលមានទឹកចិត្តសប្បាយជាពន់ពេក ដោយបានឃើញកូនចិញ្ចឹមរបស់ខ្លួនមានការចម្រើនសព្វគ្រប់ទាំងអស់ ទាំងខាងរាងកាយក៏ដូចជាខាងចំណេះវិជ្ជាសមទៅនឹងការចំណាយដ៏ច្រើនដែលគាត់ធ្វើមក ដើម្បីអប់រំកូនគាត់ទាំងបី ។ ការចម្រើននេះបានកើនហួសពីការសង្ឃឹមរបស់គាត់ទៅទៀត ។ ដូច្នេះ គាត់ក៏ធ្វើការចំណាយម្ដងទៀត ដើម្បីសេចក្ដីស្នេហាដល់បុត្រចិញ្ចឹមនោះ ។ តាំងពីដើមមករហូតមកទល់នឹងពេលនេះ. នាយតម្រួតសួនតែងពេញចិត្តនឹងផ្ទះចាស់គាត់ ដែលតាំងនៅក្នុងកំពែងព្រះបរមរាជវាំងនេះណាស់

គាត់គ្មានសង់ផ្ទះនៅឯជនបទទៀតទេ ។ ប៉ុន្តែឥឡូវនេះ គាត់ទើបតែនឹងបានទិញផ្ទះមួយឆ្ងាយពីទីក្រុងបន្តិច ដោយមានទាំងដីទំនេរអាចភ្ជួរដាំដំណាំបានយ៉ាងធំផង. កន្លែងខ្លះជាវាលស្មៅ. កន្លែងខ្លះជាព្រៃឈើ។ ហើយដោយហេតុតែគាត់យល់ថា គេហស្ថាននោះមិនសូវល្អ. មិនសូវស្រួលនៅ គាត់ក៏សម្រុតចុះមកនៅទាបវិញ ។ ហើយគាត់ឥតសំចៃធនធាន ដើម្បីនឹងតុបតែងទីជុំវិញផ្ទះនោះឱ្យបានល្អឡើយ ។ គាត់តែងទៅកាន់ទីផ្ទះថ្មីនោះជារាល់ថ្ងៃ ដើម្បីតឿនកម្មករជាច្រើនដែលគាត់បានជួលមកនោះឱ្យខំធ្វើការឱ្យបានហើយឆាប់ ។ លុះគាត់ធ្វើបានបន្ទប់មួយសមល្មមនឹងគាត់ទៅនៅបាន គាត់បានទៅសម្រាកលេងនៅទីនោះអស់ពេលជាច្រើនថ្ងៃ នៅពេលដែលគាត់គ្មានកិច្ចការអ្វីនឹងបំពេញនៅឯទីសួន ។ ដោយសេចក្តីសង្វាតឱហាតរបស់គាត់ មិនយូរប៉ុន្មានក៏បានធ្វើផ្ទះនោះហើយ ហើយនៅពេលដែលគេរៀបចំផ្ទះលម្អដោយគ្រឿងតុទូ ដើម្បីឱ្យសមនឹងផ្ទះថ្មី។ គាត់បានទៅបង្គាប់ឱ្យគេកាប់ជម្រះសម្អាតទីសួនតាមគំនូរ ដែលគាត់បានព្រាយទុកជាស្រេចតាមរបៀបធម្មតាដែលគេ ធ្លាប់បានឃើញមកនៅប្រទេសពៃរ៉ូបណ្តាផ្ទះពួកគហបតីធំៗ។ ក្រៅពីនេះ គាត់បានធ្វើឧទ្យានមួយយ៉ាងធំមានរបងយ៉ាងមាំព័ទ្ធជុំវិញ ហើយនៅក្នុងឧទ្យាននោះ គាត់មានចិញ្ចឹមសត្វម្រឹគីម្រឹគាគ្រប់បែបគ្រប់យ៉ាង សម្លាប់ឱ្យព្រះអង្គម្ចាស់ក្សត្រីបរបាញ់លេងតាមពេលសព្វព្រះទ័យ ។

កាលបើផ្ទះគាត់បានសង់ហើយស្រេចទាំងអស់ សមនឹងនៅបានស្រួលហើយ. នាយតម្រួតស្ងួនក៏ចូលទៅក្រាបថ្វាយបង្គំព្រះបាទស៊ុលតង់ សុំព្រះរាជានុញ្ញាតឱ្យគាត់លាឈប់ពីតំណែងធ្វើការ ។ នៅពេលនោះ គាត់បាននិយាយទូលព្រះរាជាថា គាត់បានធ្វើការបម្រើព្រះរាជវាំងមកអស់ពេលយូរណាស់ហើយ ឥឡូវគាត់មានវ័យចាស់ជរាហើយពុំអាចធ្វើការបម្រើព្រះអង្គឱ្យបានជិតដល់ទៀតទេ រួចគាត់ក៏ថ្វាយពាក្យសុំលាឈប់នោះទៅព្រះមហាក្សត្រ ទើបថយចេញមក ។ ព្រះបាទស៊ុលតង់ក៏ទ្រង់ព្រះរាជទានឱ្យគាត់លាឈប់ពីតំណែងដោយរីក-រាយ ។ ព្រះអង្គទ្រង់សព្វព្រះទ័យនឹងមុខការគាត់នេះណាស់ តាំងតែពីនៅក្នុងរាជ្យបិតាព្រះអង្គ ក៏ដូចជាតាំងតែពីពេលដែលព្រះអង្គទ្រង់ឡើងសោយរាជ្យសម្បត្តិមកដែរ ។ មួយចំណែកទៀត ព្រះបាទស៊ុលតង់ទ្រង់មានព្រះបន្ទូលថា តើព្រះអង្គមានអ្វីនឹងជូនគាត់ជារង្វាន់ គាត់ក៏ឆ្លើយតបថា : "បពិត្រព្រះករុណាថ្លៃវិសេស ទូលព្រះបង្គំជាខ្ញុំមានសេចក្ដីឆ្អែតឆ្អន់ពេញចិត្តនឹងការធ្វើល្អ របស់ព្រះអង្គនិងបិតាព្រះអង្គណាស់ទៅហើយ ដូច្នេះទូលព្រះបង្គំជាខ្ញុំគ្មានត្រូវការអ្វីទៀត ក្រៅពីប្រាថ្នាសុំឱ្យបានស្លាប់ទៅ ដោយសេចក្ដីរីករាយដូច្នេះទៀត" ។ នាយតម្រួតស្ងួនក៏ថ្វាយបង្គំលា ព្រះបាទស៊ុលតង់ក្លូសារួចបន្ទាប់ពីនោះមកគាត់ក៏ទៅនៅផ្ទះថ្មី ជាមួយនឹងព្រះអង្គម្ចាស់បាម៉ាន. ព្រះអង្គម្ចាស់ប៉ែរីសនិងព្រះអង្គម្ចាស់ក្សត្រីបារីសាដ ។ ចំណែកប្រពន្ធគាត់វិញ, នាង

បានទទួលអនិច្ចកម្មចំនួនជាពីរបីឆ្នាំមកហើយ ។ លោកនាយកតម្រួតសួននេះទៀត. ក្រោយពីបានរស់នៅរួមសុខទុក្ខជាមួយនឹងបុត្រចិញ្ចឹមបានចំនួនជា ៥ ឬ៦ខែ ក៏ជំងឺទន់ហាន់បាននាំស្ដេចមច្ចុរាជមកផ្ដាច់ជីវិតគាត់ទៅទៀត ដោយឥតទុកពេលឱ្យគាត់បាននិយាយរឿងពិតពីរឿងកំណើតនៃបុត្រគាត់ ប្រាប់បុត្រគាត់ទាន់ឡើយ។ ការនេះគាត់បម្រុងនឹងនិយាយប្រាប់បុត្រគាត់ ព្រោះជាការចាំបាច់ដើម្បីបង្ហំព្រះអង្គម្ចាស់ទាំងឡាយឱ្យបន្ដការរស់នៅឱ្យបានប្រពៃ ដូចដែលបានធ្វើមកទល់សព្វថ្ងៃនេះ ឱ្យសមទៅតាមភាពនឹងឋានៈនិងឱ្យសមទៅតាមការអប់រំដែលគាត់បានខំខ្នះខ្នែង ហ្មិកហ្មឺនបង្ហាត់បង្ហាញទូន្មានអស់ពេលជាយូរមកហើយផង ។

ព្រះអង្គម្ចាស់បាម៉ាន ព្រះអង្គម្ចាស់ប៉ៃវិសព្រមទាំងព្រះអង្គម្ចាស់ក្សត្រីប៉ារីសាដ ដោយទ្រង់គ្មានស្គាល់បិតាឯណាក្រៅពីនាយតម្រួតសួន ក៏ទ្រង់សោកស្ដាយនាយតម្រួតសួនហាក់ដូចជាបិតាព្រះអង្គបង្កើតហើយព្រះអង្គទ្រង់បំពេញកិច្ចផ្សេងៗសព្វគ្រប់ទាំងអស់ក្នុងពេលបូជាសពនាយតម្រួតសួន សមទៅតាមសេចក្ដីស្នេហានិងសេចក្ដីកតញ្ញូដែលបុត្រត្រូវមានចំពោះមាតាបិតា ។ ដោយហេតុតែនាយតម្រួតសួនបានស្លាប់ទៅ. នៅសល់ទ្រព្យសម្បត្តិជាច្រើនទុកជូនបុត្រចិញ្ចឹមរបស់គាត់. ព្រះអង្គម្ចាស់ទាំងឡាយក៏ទ្រង់សព្វព្រះទ័យនឹងរបស់មរតកនេះណាស់ ហើយទ្រង់ក៏បន្តការរស់នៅជាមួយគ្នាដូច្នេះតរៀងទៅ. ឥតមានព្រះទ័យលោភលន់ចង់បានអ្វីទៀតឡើយ ។

ថ្ងៃមួយ. នៅពេលដែលព្រះអង្គម្ចាស់ព្រះរវៀមទាំងពីរយាង ទៅបរបាញ់. ហើយព្រះអង្គម្ចាស់ក្សត្រីទ្រង់នៅចាំផ្ទះមានស្រីអ្នកកាន់សាសនាអ៊ីស្លាមម្នាក់មានវ័យចាស់ណាស់ទៅហើយ បានដើរមកឈរនៅមាត់ទ្វារផ្ទះ ហើយអង្វរសុំឱ្យគេអនុញ្ញាតឱ្យគាត់ចូលសូត្រធម៌បន្តិច ព្រោះដល់ពេលត្រូវសូត្រធម៌ ។ គេក៏ទៅទូលសុំសេចក្តីអនុញ្ញាតពីព្រះនាងម្ចាស់ក្សត្រី ។ ព្រះអង្គម្ចាស់ក្សត្រីក៏បង្គាប់ឱ្យគេបើកទ្វារឱ្យស្រីនោះចូល ហើយបង្ហាញកន្លែងសូត្រធម៌គាត់ ដែលនាយតម្រួតសួនឥតធ្វេសប្រហែសបានធ្វើបន្តជាប់នឹងផ្ទះធំ ព្រោះទីនោះគ្មានព្រះវិហារអ៊ីស្លាម ។ ក្រៅពីនេះព្រះនាងទ្រង់មានសវនីយ៍បង្គាប់ដូច្នេះទៀតថា កាលបើស្រីអ្នកកាន់សាសនានោះសូត្រធម៌ចប់ហើយ ត្រូវនាំគាត់ដើរមើលផ្ទះនឹងទីសួន រួចហើយនាំគាត់មកជួបនឹងព្រះនាងបន្តិច ។

ស្ត្រីអ្នកកាន់ធម៌ក៏ដើរចូលទៅ. ហើយចូលទៅសូត្តធម៌ក្នុងកន្លែងដែលគេបានបង្ហាញគាត់ ។ លុះគាត់សូត្រធម៌ចប់ ភិលៀងម្ចាស់ក្សត្រីពីរនាក់. ដែលនៅឈរចាំគាត់ ក៏អញ្ជើញគាត់ឱ្យដើរមើលផ្ទះនឹងទីសួន។ គាត់ក៏យល់ព្រមតាម. ភិលៀងទាំងពីរក៏នាំជូនចាស់ដើរមើលផ្ទះពីបន្ទប់មួយទៅបន្ទប់មួយ. ហើយនៅគ្រប់បន្ទប់គាត់បានសម្លឹងមើលរបស់សព្វគ្រប់ទាំងអស់ ។ បន្ទាប់មកភិលៀងក៏នាំគាត់ចូលទៅក្នុងទីសួន. គាត់ក៏បានឃើញរបៀបតំនូវថ្មីប្លែក. គាត់ក៏ស្ងើចក្នុងចិត្ត. ហើយនិយាយថា អ្នកដែលបានគូរតំនូវឱ្យគេធ្វើនេះ ប្រាកដជាគ្រូសិល្ប៍

យ៉ាងចំណាន ។ នៅទីបំផុត, ស្រីអ្នកកាន់សាសនានោះក៏បានចូលទៅជួបនឹងព្រះអង្គម្ចាស់ក្សត្រី ដែលគង់នៅក្នុងបន្ទប់ទទួលភ្ញៀវ ។ បន្ទប់នេះមានលម្អនឹងគ្រឿងតុបតែងឆើតជាងបន្ទប់មុនៗ ដែលស្រីអ្នកកាន់ធមិបានឃើញ ។

កាលបើព្រះអង្គម្ចាស់ក្សត្រីបានឃើញស្ត្រីអ្នកកាន់សាសនាដើរចូលមកភ្លាម, ព្រះអង្គម្ចាស់ក៏មានសវនីយទៅកាន់ស្រីនោះភ្លាមថា : "ជីដូនថ្លៃ សូមជីដូនអញ្ជើញមកជិត, ហើយអញ្ជើញមកអង្គុយក្បែរខ្ញុំឯនេះ ។ ខ្ញុំមានសេចក្ដីត្រេកអរនិងសុភមង្គល ដែលឱកាសល្អបានផ្ដល់ឱ្យខ្ញុំមានពេលបាននិយាយសន្ទនាជាមួយមនុស្ស ដូចជាជីដូននេះ ដែលដែលបានដើរផ្លូវត្រូវផ្លូវល្អ ព្រោះបានប្រគល់ខ្លួនទាំងអស់ចំពោះព្រះអាទិទេព, ហើយដែលជនទាំងអស់ត្រូវតែយកតម្រាប់តាម បើសិនជាខ្លួនជាអ្នកប្រកបដោយគតិបណ្ឌិតមែន" ។

ស្ត្រីអ្នកកាន់សាសនាក៏អង្គុយនៅប្របេះខាងកៅអីវែង ប៉ុន្តែព្រះអង្គម្ចាស់ក្សត្រីមិនព្រមឱ្យគាត់អង្គុយដូច្នោះឡើយ ។ ព្រះនាងទ្រង់យាងក្រោកពីកន្លែង ហើយយាងទៅដឹកដៃគាត់ឱ្យអង្គុយជិតព្រះនាង, ត្រង់កន្លែងកិត្តិយស ។ ស្ត្រីអ្នកកាន់សាសនាក៏រំភើបញាប់ញ័រនឹងសេចក្ដីគួរសមនេះណាស់ ទើបគាត់និយាយថា : "អ្នកស្រី, ខ្ញុំមិនសមនឹងទទួលបដិសណ្ឋារកិច្ចដល់ទៅយ៉ាងនេះទេ ហើយដែលខ្ញុំគោរពធ្វើតាមអ្នកស្រីនេះ, ក៏ព្រោះតែអ្នកស្រីបានបង្គាប់មកខ្ញុំ និងដោយ

សារតែអ្នកស្រីជាចៅហ្វាយលើទីនេះផង" ។ កាលបើស្រីអ្នកកាន់សាសនាអង្គុយចុះ ហើយមុននឹងចាប់ពិភាក្សាគ្នាភិលៀងព្រះអង្គម្ចាស់ក្សត្រីម្នាក់បានលើកថាសតូចល្អមដាក់នំ, ផ្លែឈើក្នុងរដូវដំណាប់ផ្លែឈើ និងបង្អែមកំប៉ុងមកថ្វាយព្រះនាងនិងជូនដូនចាស់នោះ ។

ព្រះអង្គម្ចាស់ក្សត្រី ទ្រង់ចាប់យកនំមួយចានជូនទៅដូនចាស់ ហើយទ្រង់មានសវនីយថា : "ជីដូនថ្លៃ, សូមជីដូនទទួលយកពិសាទៅ រួចរើសយកផ្លែឈើណាដែលជីដូនពេញចិត្តពិសាទៀតទៅ" ។ ជីដូនប្រាកដជាត្រូវការទទួលទានហើយ បន្ទាប់ពីជីដូនបានធ្វើដំណើរមកដល់ទីនេះ ។ ដូចចាស់ក៏ឆ្លើយថា : "អ្នកស្រី, ខ្ញុំពុំដែលទម្លាប់ទទួល-ទានរបស់ដ៏ឆ្ងាញ់ៗដូច្នេះសោះ, ហើយបើសិនជាខ្ញុំទទួលទាន គឺមកពីខ្ញុំមិនហ៊ានប្រកែកនឹងទទួលយករបស់អ្វីៗដែលព្រះអាទិទេពលោកបានផ្ញើមកឱ្យខ្ញុំតាមដៃនៃអ្នកសប្បុរសដូចជាអ្នកស្រីនេះ ។

នៅពេលដែលដូនចាស់កំពុងទទួលទានរបស់ផ្សេងៗ ព្រះអង្គម្ចាស់ក្សត្រី ដែលកំពុងសោយរបស់ផ្សេងៗដែរ ដើម្បីកំដរដូនចាស់ បានមានសវនីយសួរទៅដូនចាស់ជាច្រើនអំពីការហាត់ពត់ចិត្តប្រព្រឹត្តតាមសាសនា ដែលគាត់បានប្រតិបត្តិមក និងអំពីរបៀបដែលគាត់រស់នៅ។ ដូនចាស់ក៏បានឆ្លើយតបទៅព្រះនាងក្សត្រីវិញ ដោយសេចក្ដីសុភាព។ លុះជជែកគ្នាពីនេះពីនោះបានបន្តិចទៅ, ព្រះអង្គម្ចាស់ក្សត្រីក៏សួរទៅដូនចាស់ថា តើគាត់យល់ឃើញដូចម្ដេចអំពីគេហស្ថានព្រះនាងនេះ ។

ស្រីអ្នកកាន់សាសនាក៏ឆ្លើយថា : “អ្នកស្រីផ្ទះនេះល្អណាស់មើលទៅគួរឱ្យសប្បាយ. មានគ្រឿងតាំងយ៉ាងល្អឆើត មើលទៅគ្មានឱ្យទាស់ត្រង់ណា។ ឯទីកន្លែងវិញគឺផ្ទះនេះបានសង់នៅលើកន្លែងត្រជាក់ត្រជុំកើតកាលវាលគុម្ពជាប្រាកដ ហើយគេពុំអាចរកសួនច្បារឯណាទៀតឱ្យបានសប្បាយជាងនេះបានឡើយ” ។ ប៉ុន្តែបើសិនជាអ្នកស្រីអនុញ្ញាតឱ្យខ្ញុំនិយាយឱ្យអស់កុំឱ្យមានសល់អ្វីនោះៗ ខ្ញុំសូមជម្រាបថាផ្ទះនេះនឹងទៅជាផ្ទះមួយល្អរកប្រៀបគ្មាន បើសិនជាអ្នកស្រីអាចរករបស់បីមុខ ដែលនៅខ្វះមកដាក់បំពេញទៀតបាន. នេះតាមយោបល់ខ្ញុំ ។

- ជីដូន ព្រះអង្គម្ចាស់ក្សត្រីបារីសាដមានសវនីយ. តើអ្វីខ្លះទៅរបស់បីមុខនោះ? សូមជីដូនមេត្តាប្រាប់ខ្ញុំមក ខ្ញុំសូមអង្វរដោយតាងនាមព្រះអាទិទេព ។ ខ្ញុំនឹងឥតសំចៃកម្លាំងឡើយ ដើម្បីនឹងរករបស់នោះឱ្យបាន. បើសិនជាអាចធ្វើកើត ។

- អ្នកស្រី. ដូនចាស់រៀបរាប់. របស់ទីមួយគឺបក្សាចេះនិយាយគឺជាបក្សាមួយចម្លែកឈ្មោះប៊ុលប៊ុលហីសារ ហើយប្រកបដោយលក្ខណៈចេះល្បួងហៅបក្សាបក្សីនៅទីជិតខាង ដែលកំពុងស្រែកឱ្យស្រែកតាមសម្រែកខ្លួន ។ របស់ទីពីរគឺដើមឈើចេះច្រៀង ដែលមានស្លឹកទាំងឡាយទុកដូចជាមាត់ ហើយអាចប្រគុំកើតជាភ្លេងមានសម្លេងប្លែកៗ. ហើយសម្លេងតន្ត្រីនេះឥតចេះឈប់សោះឡើយ ។ នៅទីបំផុត

របស់ទីបី គឺទឹកពណ៌លឿងដូចពណ៌មាស ហើយទឹកនេះ កាលបើគេយកទៅចាក់តែមួយដំណក់ចូលទៅក្នុងអាងទឹកមួយ ដែលទើបនឹងធ្វើហើយនៅក្នុងទីសួននេះ ឬនៅកន្លែងណាក៏ដោយនឹងរីកទំហំឡើងពេញអាង ហើយកើតរាងទៅជាកណ្ដាប់ស្រូវមួយដុះចេញឡើង ពីកណ្ដាលអាងនោះ ។ ទឹកផុះជាកណ្ដាប់ស្រូវនេះ តែងហូរបាញ់ឡើងលើ ហើយធ្លាក់ចុះទៅក្នុងអាងវិញឥតឈប់ឈរ ដោយឥតឱ្យហៀរទឹកចេញពីអាងនោះឡើយ ។

- អែយ៉ា ! ជីដូនថ្លៃ. ព្រះអង្គម្ចាស់ក្សត្រីទ្រង់ផ្ទះសម្រែក. តើខ្ញុំត្រូវដឹងគុណជីដូនយ៉ាងណាទៅ ដែលជីដូនបានប្រាប់វត្ថុនោះដល់ខ្ញុំ ! របស់ទាំងនេះគួរឱ្យខ្ញុំចង់ឃើញណាស់. ហើយខ្ញុំពុំដែលឮគេនិយាយសោះថា នៅក្នុងលោកនេះ មានរបស់ដ៏ចម្លែកអស្ចារ្យដូច្នេះឡើយ ។ ប៉ុន្តែ ដោយខ្ញុំជឿថាជីដូនប្រាកដជាស្គាល់ទីកន្លែងវត្ថុទាំងនោះហើយដូច្នេះ ខ្ញុំនឹងនៅចាំស្ដាប់ជីដូនមានប្រសាសន៍ប្រាប់ខ្ញុំពីរឿងនេះតទៅទៀត ។

ដើម្បីបំពេញសេចក្ដីត្រូវការរបស់ព្រះអង្គម្ចាស់ក្សត្រី ស្រីអ្នកកាន់សាសនាក៏ពោលថា : “អ្នកស្រី. ខ្ញុំនឹងទៅជាមនុស្សមិនសមនឹងត្រូវបានអ្នកស្រីទទួលឱ្យសំណាក់អាស្រ័យ ដោយសេចក្ដីសប្បុរសដូច្នេះទេ បើសិនជាខ្ញុំហើយប្រកែកមិនព្រមបំពេញសេចក្ដីត្រូវការដែលអ្នកស្រីប្រាថ្នាចង់ដឹង ។ ដូច្នេះ ខ្ញុំមានសេចក្ដីរីករាយនឹងជម្រាបអ្នកស្រីថា

វត្ថុបីមុខដែលខ្ញុំទើបតែនឹងនិយាយជំម្រាបអ្នកស្រីនោះ ស្ថិតនៅត្រង់កន្លែងជាមួយគ្នា ត្រង់ទីព្រំដែននៃព្រះរាជអាណាចក្រខាងទិសប្រទេសឥណ្ឌា ។ ផ្លូវដែលត្រូវទៅកាន់កន្លែងនោះ កាត់តាមមុខផ្ទះអ្នកស្រីនេះ ។ មនុស្សណាដែលអ្នកស្រីចាត់ឱ្យទៅកាន់កន្លែងនោះ ត្រូវដើរតែតាមផ្លូវនេះចំនួនម្ភៃថ្ងៃ ហើយនៅថ្ងៃទីម្ភៃមួយ អ្នកនោះឯងត្រូវសួរជនណាដែលខ្លួនបានជួបដំបូងបង្អស់ថា តើបក្សាចេះនិយាយ ដើមឈើចេះច្រៀង, នឹងទឹកពណ៌លឿងនៅឯណា? គេនឹងនិយាយប្រាប់ពុំខាន" ។ កាលបើនិយាយចប់ភ្លាម ដូនចាស់នោះក៏ក្រោកឡើង, ហើយក្រោយពីបានជម្រាបលាព្រះអង្គម្ចាស់ក្សត្រី, គាត់ក៏ថយចេញទៅបន្តដំណើរគាត់ទៅទៀត ។

ព្រះនាងប៉ារីសាដ មានព្រះទ័យកង្វល់រំពល់ជាក្រៃលែងនឹងរក្សាកត់ត្រាទុកកុំឱ្យមានភ្លេច នូវសេចក្ដីត្រូវការរបស់អ្នកស្រីកាន់សាសនាអ៊ីស្លាមអំពីរឿងបក្សាចេះនិយាយ, រុក្ខជាតិចេះច្រៀង, នឹងទឹកពណ៌លឿងនេះ ព្រោះព្រះនាងបានស្មានខុសថា ស្រីអ្នកកាន់សីលនឹងលាចេញពីទីនេះទៅ លុះណាតែបន្ទាប់ពីព្រះនាងបានសួរបញ្ជាក់គាត់ពីរឿងខាងលើនេះសព្វគ្រប់សិន ។ អាស្រ័យហេតុនេះ ព្រះនាងហាក់ដូចជាពុំអស់ក្នុងព្រះទ័យសោះ ដោយហេតុថា ការដែលព្រះនាងបានស្ដាប់ឮពីមាត់ស្រីអ្នកកាន់សីលទាំងប៉ុន្មាន ដូចជាពុំទាន់គ្រប់គ្រាន់សោះ ដើម្បីកុំឱ្យរងគ្រោះថ្នាក់ឥតអំពើ ដោយសារតែការធ្វើដំណើរ

ទៅគ្មានបានផលអ្វី ។ ព្រះនាងមិនមែនចង់ឱ្យគេរត់ទៅតាមគាត់ ដើម្បីហៅគាត់ឱ្យត្រឡប់មកវិញទេ, ប៉ុន្តែ ព្រះនាងខំតាំងស្មារតី ដើម្បីនឹកឱ្យឃើញទាំងអស់នៅការអ្វីៗទាំងប៉ុន្មាន ដែលព្រះអង្គបានឮ ហើយខំធ្វើយ៉ាងណាកុំឱ្យភ្លេចទៅវិញ ។ កាលបើព្រះនាងយល់ថា ព្រះនាងបានកត់ត្រាចំណាំចាំក្នុងព្រះទ័យឥតមានសល់សោះឡើយ, ព្រះនាងក៏ទ្រង់នឹកសង្ឃឹមយ៉ាងមាំថា នឹងបានឃើញការសប្បាយយ៉ាងអស្ចារ្យពុំខាន បើសិនជាព្រះនាងអាចរករបស់ដ៏អស្ចារ្យទាំងនោះបានដូចសេចក្ដីប្រាថ្នាមែន ។ ប៉ុន្តែឧបសគ្គដែលព្រះនាងទ្រង់យល់ដល់ក្នុងរឿងនោះនិងសេចក្ដីបារម្ភខ្លាចពុំបានសម្រេចតាមព្រះទ័យ បានធ្វើឱ្យព្រះនាងព្រួយព្រះចិន្ដាជាក្រៃលែង ។

ព្រះអង្គម្ចាស់ក្សត្រីប៉ារីសាដកំពុងតែឈ្លក់ព្រះទ័យក្នុងរឿងនេះស្រាប់តែព្រះអង្គម្ចាស់ ព្រះរៀមយាងត្រឡប់មកដល់ពីបរបាញ់សត្វវិញ ។ ព្រះអង្គម្ចាស់ទាំងពីរក៏យាងចូលទៅក្នុងបន្ទប់ទទួលភ្ញៀវ ហើយស្រាប់តែទតឃើញព្រះនាងមានទឹកព្រះភក្ត្រស្រពាប់ស្រពោនខុសពីប្រក្រតី, ព្រះនាងទ្រង់ឱនព្រះភក្ត្រចុះដូចជាកើតទុក្ខធំណាស់ ឥតងើបព្រះភក្ត្រឡើងបន្តិច គ្រាន់ជាសញ្ញាឱ្យដឹងថា ព្រះនាងបានទតឃើញព្រះអង្គដែរឡើយ ។ ព្រះអង្គម្ចាស់បាម៉ានក៏មានព្រះបន្ទូលថា៖ "ម្ចាស់អូន, តើសេចក្ដីសប្បាយរីករាយ ដែលធ្លាប់តែមានជាប់ជានិច្ចជាមួយម្ចាស់អូនឯង រហូតមកទល់នឹងសព្វថ្ងៃនេះ រត់ទៅឯណាទៅ? ម្ចាស់

អូនមិនស្រួលខ្លួនឬ? មានគ្រោះថ្នាក់អ្វីកើតមានដល់អូនឬ? មានគេប្រាប់រឿងអ្វីនាំឱ្យលំបាកចិត្តឬ? សូមម្ចាស់អូនប្រាប់មកយើង ជាព្រះរៀមកុំលាក់ឱ្យសោះ ដើម្បីឱ្យព្រះរៀមចូលរួមក្នុងរឿងនោះ ផង ហើយនឹងគិតរកឱសថមកដាក់ឱ្យត្រូវ. ឬមួយក៏ព្រះរៀមនឹងសងសឹកជំនួសម្ចាស់អូន បើសិនជានរណាហើយមានចិត្តព្រហើនប្រមាថមើលងាយមនុស្សដូចជាម្ចាស់អូននេះ ដែលគេត្រូវតែមានសេចក្ដីគោរព" ។

ព្រះអង្គម្ចាស់ក្សត្រីប៉ារីសាដ ក៏ទ្រង់គង់នៅស្ងៀមយ៉ាងយូរគ្មានមានព្រះសវនីយ៍ឆ្លើយតបនឹងព្រះរៀមថាដូចម្ដេចឡើយ ។ នៅទីបំផុត ព្រះនាងក៏ទ្រង់ងើបព្រះភក្ត្រឡើង ទតទៅព្រះរៀមទាំងពីរហើយទ្រង់អោនចុះវិញមួយរំពេច. បន្ទាប់ពីមានព្រះសវនីយ៍ទូលព្រះរៀមថា គ្មានរឿងអ្វីទេ ។

ព្រះអង្គម្ចាស់បាម៉ាន ក៏មានព្រះបន្ទូលតទៅទៀតថា : "ម្ចាស់អូន. ម្ចាស់អូនលាក់ការពិតនឹងព្រះរៀមហើយ ប្រាកដជាមានរឿងអ្វីពុំខាន ហើយជារឿងធំផង ។ វាមិនសមសោះនៅក្នុងរយៈពេលដ៏ខ្លីដែលព្រះរៀមបានបែកពីម្ចាស់អូនទៅមានកើតហេតុយ៉ាងធំ បើតាមព្រះរៀមបានសង្កេតឃើញអាកប្បកិរិយាម្ចាស់អូន. ហើយម្ចាស់អូនមានបន្ទូលបញ្ជាក់ថាគ្មានរឿងអ្វីទេ ។ ម្ចាស់អូនស្មានថា ព្រះរៀមមិនអភ័យទោសឱ្យម្ចាស់អូនឬ បើសិនជាចម្លើយម្ចាស់អូនបណ្ដាលឱ្យព្រះរៀមពុំសប្បាយចិត្ត ។ ដូច្នេះត្រូវម្ចាស់អូនកុំលាក់នឹងព្រះរៀម លុះត្រា

តែព្រះរៀមអាចសន្និដ្ឋានបានថា ម្ចាស់អូនចង់ឈប់ចងស្ពានមេត្រីនិងរស់នៅជាមួយគ្នាយ៉ាងស្និទ្ធស្នាលតទៅទៀតនោះ ដែលជាអំពើដែលយើងធ្លាប់មានមកទល់នឹងថ្ងៃនេះ ចាប់តាំងពីនៅជាកុមារភាពម្ល៉េះ" ។

ព្រះអង្គម្ចាស់ក្សត្រី ដែលគ្មានព្រះទ័យនឹងចង់ផ្តាច់ភាតរភាពជាមួយនឹងព្រះរៀមសោះ ក៏មានព្រះសវនីយ៍ឡើងថា : "កាលដែលម្ចាស់អូនបាននិយាយទូលព្រះរៀមថា ម្ចាស់អូនគ្មានរឿងអ្វីទេនោះៗ ម្ចាស់អូននិយាយចំពោះទៅនឹងខ្លួនព្រះរៀម មិនមែននិយាយចំពោះខ្លួនម្ចាស់អូនទេ ដែលយល់ថារឿងនេះជាការមានប្រយោជន៍ខ្លះ ។ ឥឡូវដោយម្ចាស់ព្រះរៀមទ្រង់ចុចទៅលើរឿងភាតរភាព និងការរួបរួមគ្នា ដែលជាទីស្រឡាញ់បំផុតរបស់ម្ចាស់អូននោះៗម្ចាស់អូននឹងនិយាយទូលព្រះរៀមអំពីរឿងនោះ ។ ម្ចាស់ព្រះរៀមក៏យល់ដូចជាម្ចាស់អូនដែរថា ផ្ទះនេះដែលជាកេរ្តិ៍បិតាយើងបានសង់ទុកឱ្យ មានតុបតែងលម្អដោយក្បាច់និងគ្រឿងសង្ហារិមហើយស្រេចសព្វគ្រប់ទាំងអស់គ្មានខ្វះចន្លោះត្រង់កន្លែងណាសោះ ប៉ុន្តែទើបតែនឹងមកដល់ថ្ងៃនេះ ខ្ញុំម្ចាស់ក៏បានដឹងថា ផ្ទះនេះមានខ្វះរបស់បីទៀត បើសិនជាបានរបស់នោះមក នោះផ្ទះនេះនឹងទៅជាល្អដាច់គេរកប្រៀបគ្មាន បណ្តាផ្ទះទាំងឡាយដែលសង់នៅទីជនបទដូចគ្នា ក្នុងលោកយើងនេះ។ របស់ទាំងបីនោះគឺបក្សាចេះនិយាយ, ដើមឈើចេះច្រៀង និងទឹកពណ៌លឿងដូច-ជាពណ៌មាស" ។

បន្ទាប់ពីបានមានសវនីយ៍ទូលព្រះរៀមអំពីវត្ថុល្អនោះ ព្រះអង្គម្ចាស់ក្សត្រីក៏ទ្រង់បន្ថែមថា ៖ "គឺអ្នកស្រីកាន់សាសនាអ៊ិស្លាមម្នាក់ដែលបានប្រាប់ម្ចាស់អូនអំពីរឿងនេះ អំពីទីកន្លែងដែលវត្ថុទាំងនោះស្ថិតនៅ ព្រមទាំងផ្លូវដែលទៅកាន់ទីនោះ ។ ម្ចាស់ព្រះរៀមប្រហែលជាយល់ឃើញថា របស់ទាំងនោះមិនជាមានសារៈសំខាន់ប៉ុន្មានទេ ដើម្បីយកមកតុបតែងផ្ទះយើងឱ្យបានល្អសព្វគ្រប់ ហើយអាចនៅតែល្អដាច់គេដរាប ព្រោះតែមានរបស់ថ្មីនេះមកបន្ថែមនោះទេ ។ ម្ចាស់អូនសូមទុកឱ្យព្រះរៀមយល់ឃើញយ៉ាងណាក៏យល់ចុះ ប៉ុន្តែ ម្ចាស់អូនពុំអាចនៅស្ងៀមមិននិយាយទូលព្រះរៀមបានឡើយថា ចំណែកម្ចាស់អូនៗយល់ថា របស់នោះជាការមានប្រយោជន៏ចាំបាច់ដល់ផ្ទះយើង ហើយម្ចាស់អូននឹងឥតសប្បាយចិត្តសោះឡើយ បើសិនជាម្ចាស់អូនពុំបានឃើញរបស់ទាំងនោះមកដាក់តាំងក្នុងទីនេះ ។ ដូច្នេះទោះព្រះរៀមយល់ថាគ្មានប្រយោជន៏ឬមានក៏ដោយ, ក៏ម្ចាស់អូនសូមឱ្យព្រះរៀមជួយឱ្យដំបូន្មាននិងជួយគិតមើលថា តើម្ចាស់អូនត្រូវចាត់នរណាឱ្យទៅរកយករបស់នោះឱ្យបាន ។

- ម្ចាស់អូន. ព្រះអង្គម្ចាស់បាម៉ានមានបន្ទូល គ្មានអ្វីដែលម្ចាស់អូនត្រូវការហើយៗម្ចាស់ព្រះរៀមឥតត្រូវការផងដែរនោះទេ ។ ដែលម្ចាស់ព្រះរៀមពោលនេះ ព្រោះឃើញម្ចាស់អូនមានការរវៀសរវៃក្នុងរឿងនេះពេក ដើម្បីឱ្យម្ចាស់បងចូលរួមក្នុងរឿងនេះផង ។ ប៉ុន្តែផ្ទុយ

អំពីគំនិតម្ចាស់អូនយល់ទៅវិញ. ម្ចាស់ព្រះរៀមក៏ចង់បានរបស់នោះដូចជាម្ចាស់អូនដែរ ព្រោះម្ចាស់ព្រះរៀមជឿជាក់ថា ម្ចាស់អូនក៏ឥតមានមនោសញ្ចេតនាប្លែកពីម្ចាស់បងដែរ ។ ដូច្នេះ គឺយើងទាំងពីរនាក់នេះហើយ ដែលត្រូវចេញទៅធ្វើការច្បាំងដណ្តើមរបស់នេះមកប្រើ ព្រោះម្ចាស់អូនបានហៅដូច្នេះ ហើយឱ្យសមនឹងតម្លៃវត្ថុដែលយើងត្រូវទៅរកនោះផង ។ ព្រះរៀមក៏សុំខ្លួនទៅរករបស់នោះ សូមម្ចាស់អូនគ្រាន់តែនិយាយប្រាប់ព្រះរៀមមកអំពីផ្លូវដែលត្រូវទៅ និងទីកន្លែងនៃរបស់នោះ ព្រះរៀមនឹងចេញដំណើរទៅមិនឱ្យយូរហួសពីថ្ងៃស្អែកនេះឡើយ ។

- ម្ចាស់ព្រះរៀម, ព្រះអង្គម្ចាស់ប៉ែរីសជាព្រះអនុជបន្ទាប់មានព្រះបន្ទូល, ម្ចាស់ព្រះរៀមជាចៅហ្វាយនិងជាទីពំនាក់ក្នុងទីនោះ, ដូច្នេះ មិនសមបើម្ចាស់ព្រះរៀមធ្វើដំណើរចេញចោលផ្ទះអស់ពេលយ៉ាងយូរដូច្នេះទេ មួយចំណែកទៀតខ្ញុំសូមអង្វរម្ចាស់ក្សត្រីទុកឱ្យខ្ញុំចេញទៅបំពេញបេសកកម្មនេះវិញ ព្រោះខ្ញុំក៏ចេះបំពេញករណីយកិច្ចមិនអន់ថយជាងម្ចាស់ព្រះរៀមប៉ុន្មានដែរ, ហើយកិច្ចការក្នុងផ្ទះយើងនឹងអាចស្ថិតនៅជាសណ្តាប់ធ្នាប់ដដែល ។

- ម្ចាស់អូន, ព្រះរៀមយល់ច្បាស់ហើយនូវសុឆន្ទៈរបស់ម្ចាស់អូន ហើយម្ចាស់អូនក៏អាចធ្វើដំណើរនេះបានដូចជាព្រះរៀមដែរ ប៉ុន្តែដោយការនេះបានសម្រេចរួចទៅហើយ ម្ចាស់ព្រះរៀមបានបម្រុងធ្វើ

ហើយនិងត្រូវតែធ្វើ ។ សូមព្រះអនុជគង់នៅជាមួយនឹងម្ចាស់ក្សត្រីអូនយើងទៅ ហើយព្រះរៀមឥតចាំបាច់ផ្ដែផ្ដាំអ្វីទៀតទេ" ។ បន្ទាប់ពីនោះមក, ព្រះអង្គម្ចាស់ព្រះរៀមទ្រង់បានខ្វល់ខ្វាយរៀបចំគ្រឿងប្រដាប់ធ្វើដំណើរ និងសាកសួរព័ត៌មានពីព្រះនាងឱ្យបានជ្រាបច្បាស់សព្វគ្រប់ ដើម្បីកុំឱ្យឃ្លាតចាកពីគោលបំណង ។

ស្អែកឡើងនៅពេលព្រលឹមធំ, ព្រះអង្គម្ចាស់បាម៉ានក៏បានឡើងគង់លើសេះរៀបចំធ្វើដំណើរយាងចេញទៅ ។ ព្រះអង្គម្ចាស់ប៉ែរីសនិងព្រះអង្គម្ចាស់ក្សត្រីបារីសាដ ដែលចង់ឃើញព្រះរៀមធ្វើដំណើរចេញទៅពេក ក៏ស្ទុះទៅឱបរឹតព្រះអង្គ រួចថ្វាយពរសូមព្រះរៀមធ្វើដំណើរទៅប្រកបដោយសេចក្ដីសុខសប្បាយ ។ ប៉ុន្តែនៅពេលនោះ, ព្រះអង្គម្ចាស់ក្សត្រីក៏ទ្រង់នឹកឃើញរឿងមួយ ទើបព្រះនាងមានសវនីយ៍ទៅកាន់ព្រះរៀមថា : "ម្ចាស់ព្រះរៀមម្ចាស់អូនឥតនឹកឃើញដល់គ្រោះថ្នាក់ ដែលអាចកើតមានក្នុងការធ្វើដំណើរនេះទេ តែថាតើនរណាមួយអាចដឹងថា ម្ចាស់អូនពិតជានឹងបានឃើញម្ចាស់ព្រះរៀមត្រឡប់មកវិញ? សូមម្ចាស់យាងចុះមកសិន, ម្ចាស់អូនសូមអង្វរ ហើយឈប់ធ្វើដំណើរទៅត្រឹមនេះចុះ ម្ចាស់អូនស៊ូរខានឃើញនឹងខានបានបក្សា ចេះនិយាយ ដើមឈើចេះច្រៀង និងទឹកពណ៌លឿងជាជាងនឹងនៅទន្ទឹងតែចាំមើលផ្លូវព្រះរៀមឥតឈប់ឈរ បារម្ភក្រែងតែមិនឃើញព្រះរៀមយាងត្រឡប់មកវិញដូច្នេះនោះ ។

- ព្រះអង្គម្ចាស់បាម៉ានមានព្រះបន្ទូលទាំងញញឹម ព្រោះឃើញម្ចាស់ក្សត្រីឆាប់ភ័យអ្វីម្ល៉េះយ៉ាងនេះថា ម្ចាស់ក្សត្រីអូន, ការសម្រេចចិត្តបានធ្វើរួចទៅហើយ ហើយបើសិនជាពេលនេះព្រះរៀមពុំបានធ្វើក៏គង់ពេលក្រោយព្រះរៀមនៅតែទទូចធ្វើឱ្យទាល់តែបានទៀតដែរ ។ ដូច្នោះសូមម្ចាស់ក្សត្រីអូនអនុញ្ញាតឱ្យម្ចាស់បងធ្វើទៅ ។ គ្រោះថ្នាក់ដែលម្ចាស់អូនបាននិយាយនោះកើតមានឡើងតែដល់ពួកអភព្វបុគ្គលទេ ។ ពិតមែនហើយ, ម្ចាស់ព្រះរៀមក៏អាចចាត់ចូលជាមួយពួកជនអភព្វនោះដែរ ប៉ុន្តែម្ចាស់ព្រះរៀមក៏អាចចាត់ចូលជាមួយនឹងពួកភព្វបុគ្គល ដែលមានចំនួនច្រើនជាងអភព្វបុគ្គល ។ ប៉ុន្តែដោយហេតុថាព្រឹត្តិការណ៍ទាំងឡាយមិនមែនសុទ្ធតែពិតប្រាកដនោះទេ ហើយម្ចាស់ព្រះរៀមក៏អាចស្លាប់បាន ក្នុងការធ្វើដំណើរនេះដែរ ដូច្នេះការដែលព្រះរៀមអាចធ្វើបាន គឺទុកកាំបិតនេះថ្វាយម្ចាស់ក្សត្រីអូន" ។

នៅពេលនោះព្រះអង្គម្ចាស់បាម៉ានក៏ដកយកកាំបិតស្នៀតព្រមទាំងស្រោមថ្វាយទៅព្រះអង្គម្ចាស់ក្សត្រី រួចមានព្រះបន្ទូលថា: "សូមម្ចាស់អូនទទួលយកទុក, ហើយយូរៗម្តង សូមម្ចាស់អូនដកកាំបិតនេះចេញពីស្រោមមើល បើសិនជាដកចេញពីស្រោមមកឃើញកាំបិតនេះស្អាតទេ នោះជាសញ្ញាឱ្យដឹងថា ព្រះរៀមទ្រង់មានព្រះជន្មនៅឡើយទេ ប៉ុន្តែបើសិនជាម្ចាស់អូនឃើញស្រក់ឈាមចេញពីមុខកាំបិត នោះជាសញ្ញាឱ្យដឹងថា ម្ចាស់បងអស់ព្រះជន្មហើយៗ សូមម្ចាស់អូនសូត្រធម៌ឧទ្ទិសបញ្ជូនទៅឱ្យផង ។



កាលបើព្រះអង្គម្ចាស់ក្សត្រីចារិសាដ អស់រឿងអ្វីនឹងសុំពីព្រះអង្គម្ចាស់បាម៉ានទៀតហើយ ព្រះអង្គម្ចាស់បាម៉ានក៏មានព្រះបន្ទូលលានាងនឹងព្រះអង្គម្ចាស់ប៉ៃរិស ជាលើកក្រោយបំផុត រួចឡើងគង់លើសេះយាងចេញទៅ ប្រកបដោយអាវុធ និងគ្រឿងបរិក្ខាសព្វគ្រប់ ។ ព្រះអង្គក៏ទ្រង់យាងត្រង់តាមផ្លូវគ្មានបែកងាកទៅខាងស្តាំ ឬខាងឆ្វេងឡើយ. ហើយនៅថ្ងៃទីម្ភៃមួយ. ព្រះអង្គទ្រង់ជួបនឹងតាចាស់ម្នាក់នៅក្បែរផ្លូវ មានរូបរាងអាក្រក់ស្គមស្គៃ ។ តាចាស់នោះអង្គុយនៅក្រោមដើមឈើមួយ ជិតផ្ទះស្បូវមួយ ដែលជាជម្រកសម្រាប់ការពារនឹងការប្រែប្រួលនៃធាតុអាកាស ។

តាចាស់នោះមានរោមចិញ្ចើម, សក់, ពុកមាត់, ពុកចង្កាដូចព្រិល ។ រោមចិញ្ចើមដុះធ្លាក់រហូតមកដល់ចុងច្រមុះ ពុកមាត់គ្របមាត់ជិត ពុកចង្កានិងសក់ធ្លាក់រហូតដល់ជើង ក្រចកដៃក្រចកជើងលូតវែងហួសប្រមាណ មានពាក់អ្វីរាងដូចជាមួកសំប៉ែតហាក់ដូចជាតាំងយូហើយយកកន្ទេលរុំធ្វើជាខោអាវ ។ តាចាស់នោះគឺជាអ្នកបួសក្នុងសាសនាអ៊ិស្លាម គាត់បានបែកចេញពីសង្គមមនុស្ស ដើម្បីទៅរកស្វែងធម៌តែម្នាក់ឯង អស់ពេលជាច្រើនឆ្នាំហើយៗបានធ្វើកិច្ចឧទ្ទិសខ្លួនចំពោះតែព្រះអាទិទេព ដើម្បីនៅទីបំផុតគាត់បានទៅកើតជាព្រះអាទិទេពដែរ ។

ព្រះអង្គម្ចាស់បាម៉ាន ដែលបានប្រុងព្រះអង្គតាំងតែពីព្រលឹម

ឱ្យតែបានជួបនរណាម្នាក់ ព្រះអង្គក៏នឹងអាលបានសួរអំពីទីកន្លែងដែល ព្រះអង្គប្រាថ្នានឹងយាងទៅនោះ លុះបានជួបតាចាស់នោះកាលណា ព្រះអង្គក៏ឈប់យាងចុះពីខ្នងសេះភ្លាម ព្រោះព្រះអង្គយល់ថា អ្នកនេះ ហើយដែលជាជនទីមួយដែលព្រះអង្គត្រូវសួរព័ត៌មាន ដើម្បីឱ្យត្រូវ តាមពាក្យឱ្យការ ដែលស្រីអ្នកកាន់សាសនាបានទូលព្រះអង្គម្ចាស់ ក្សត្រីមក ។ ព្រះអង្គម្ចាស់ក៏ទ្រង់ដឹកសេះយាងចូលទៅជិតតាចាស់ សម្តែងសេចក្តីគួរសំតាមទម្លាប់ រួចមានព្រះបន្ទូលថា : “លោកតាមាន ធម៌. ព្រះអាទិទេពបានទុកជីវិតលោកតាឱ្យនៅវែងណាស់ ហើយលោក ពេញចិត្តនឹងឱ្យលោកតានៅបំពេញសេចក្តីប្រាថ្នារបស់លោកតា ។

តាចាស់ក៏ឆ្លើយតបនឹងសំនួររបស់ព្រះអង្គម្ចាស់ ប៉ុន្តែព្រះអង្គ ម្ចាស់ឥតទ្រង់ស្តាប់បានមួយម៉ាត់ឡើយ ។ ដោយហេតុមកពីពុកមាត់ គាត់ដុះគ្របមាត់គាត់ជិត ហើយដោយព្រះអង្គម្ចាស់មិនចង់យាងចេញ ពីទីនោះតទៅទៀត ដោយឥតទាន់បានជ្រាបព័ត៌មាន ដែលព្រះអង្គ ត្រូវការចង់ដឹងនោះសោះ ព្រះអង្គក៏ហូតយកកន្ត្រៃដែលព្រះអង្គបាន ដាក់ជាប់ទៅជាមួយចេញមក រួចក្រោយពីបានយកសេះព្រះអង្គទៅ ចងនឹងមែកឈើមួយ. ព្រះអង្គក៏ទ្រង់មានព្រះបន្ទូលទៅកាន់តាចាស់ នោះថា : “លោកតាប្រកបដោយធម៌. ខ្ញុំត្រូវការនិយាយនឹងលោកតា បន្តិច. ប៉ុន្តែឧបសគ្គមកពីពុកមាត់លោកតា ធ្វើឱ្យខ្ញុំស្តាប់លោកតាមាន ប្រសាសន៍ថាដូចម្តេចពុំបានសោះ ដូច្នេះ ខ្ញុំសូមអង្វរលោកតាសុំឱ្យ

លោកតាអនុញ្ញាតឱ្យខ្ញុំកាត់ពុកមាត់នឹងរោមភ្នែកលោកតាចេញ ដែល ជារបស់ធ្វើឱ្យលោកតាមានរូបដូចជាខ្លាឃ្មុំ មិនមែនដូចមនុស្សទេ" ។

អ្នកបួសក៏ឥតយល់ទាស់នឹងបំណងព្រះអង្គម្ចាស់នេះទេ, គាត់ យល់ព្រមឱ្យព្រះអង្គម្ចាស់ធ្វើតាមបំណង ។ កាលបើព្រះអង្គម្ចាស់បាន កាត់ពុកមាត់ នឹងរោមចិញ្ចើមអ្នកបួសនោះរួចហើយ, ព្រះអង្គក៏ទ្រង់ ទតឃើញគាត់មានសាច់ឈាមនៅក្មេងសោះ, មិនមែនចាស់ដូចជាពី ពេលព្រះអង្គទតឃើញពីដំបូងសោះ ទើបព្រះអង្គមានព្រះបន្ទូលថា : "លោកតាប្រកបដោយធម៌, បើសិនជាខ្ញុំមានកញ្ចក់ឆ្លុះមុខជាប់មកជា មួយផង ខ្ញុំនឹងជូនឱ្យលោកតាឆ្លុះមើលខ្លួនលោកតា តើលោកតានៅ ក្មេងស្រស់យ៉ាងណា ។ ឥឡូវនេះ លោកតាទើបពេញជាមនុស្សដែល ពីពេលមុននេះ គ្មាននរណាមួយអាចសម្គាល់លោកតាថាជាអ្វីបាន ឡើយ" ។

ការនិយាយលួងលោមសរសើរខ្លះបញ្ឆោរខ្លះនេះ បានធ្វើឱ្យ អ្នកបួសញញឹមគោរពតបមកវិញ ហើយនិយាយថា : "លោកម្ចាស់, ទោះលោកម្ចាស់ជានរណាក៏ដោយ, ខ្ញុំត្រូវតែនឹកគុណចំពោះអំពើ ពិសេសដែលលោកម្ចាស់បានធ្វើដល់ខ្ញុំនេះ ។ ដូច្នេះខ្ញុំបានប្រុងខ្លួនជា ស្រេចនឹងបញ្ចេញភស្តុតាងនៃសេចក្ដីកតញ្ញូរបស់ខ្ញុំនេះ ដើម្បីបំពេញ កិច្ចអ្វីៗផ្សេង ដែលលោកត្រូវការឱ្យតែការនោះនៅក្រោមអំណាចខ្ញុំ នោះៗ លោកម្ចាស់មិនចាំបាច់អញ្ជើញចុះពីខ្នងសេះផង សេចក្ដីត្រូវ

ការនោះ នឹងបានសម្រេចភ្លាម ។ ហេតុនេះសូមលោកម្ចាស់មានប្រ-សាសន៍ប្រាប់ខ្ញុំមក តើលោកម្ចាស់ត្រូវការអ្វី. ខ្ញុំនឹងខំធ្វើបំពេញចិត្តលោកម្ចាស់ បើសិនជាខ្ញុំអាចធ្វើបាន ។

- លោកតាដ៏ចម្រើន. ព្រះអង្គម្ចាស់បាម៉ានមានព្រះបន្ទូល. ខ្ញុំមកពីទីឆ្ងាយណាស់ ហើយខ្ញុំមកនេះ ត្រូវការរកបក្សាចេះនិយាយ. ដើមឈើចេះច្រៀង និងទឹកពណ៌លឿង ។ ខ្ញុំដឹងថារបស់ទាំងបីមុខនេះស្ថិតនៅទីក្បែរកន្លែងនេះ ប៉ុន្តែខ្ញុំពុំស្គាល់កន្លែងពិតប្រាកដ. បើសិនជាលោកតាដឹង. ខ្ញុំសូមអង្វរមេត្តាបង្ហាញផ្លូវខ្ញុំបន្តិច. ដើម្បីកុំឱ្យខ្ញុំស្ទាក់ស្ទើរពុំដឹងទៅតាមផ្លូវណា ហើយនិងកុំឱ្យខ្ញុំខាតប្រយោជន៍ឥតអំពើបណ្ដាលមកពីការធ្វើដំណើរដ៏ឆ្ងាយនេះ ។

នៅពេលព្រះអង្គម្ចាស់កំពុងមានព្រះបន្ទូលដូច្នេះ ព្រះអង្គទ្រង់សង្កេតឃើញអ្នកបួសផ្លាស់ទឹកមុខ. ឱនក្បាលចុះនៅនឹងថ្កល់មិនមានឆ្លើយថាដូចម្ដេច ត្រឡប់ជានៅស្ងៀមឈឹង ។ ឃើញដូច្នោះ ព្រះអង្គម្ចាស់ក៏មានព្រះបន្ទូលទៀតថា: "លោកតា. ខ្ញុំស្មានហាក់ដូចជា លោកតាបានស្ដាប់ខ្ញុំឮដែរ សូមលោកតាប្រាប់ខ្ញុំមក បើសិនជាលោកតាដឹងឬក៏ពុំដឹងប្រយោជន៍កុំឱ្យខ្ញុំខាតពេល ហើយខ្ញុំនឹងអាចទៅរកសួរគេនៅកន្លែងដទៃទៀត" ។

ទីបំផុត អ្នកបួសក៏ឆ្លើយថា : "លោកម្ចាស់. ផ្លូវដែលលោកម្ចាស់សួរនោះ ខ្ញុំស្គាល់ ប៉ុន្តែ សេចក្ដីរាប់អានដែលខ្ញុំទើបតែនឹងមាន

ជាមួយលោកចាប់តាំងពីកាលខ្ញុំបានឃើញលោកមក. ហើយសេចក្ដីរាប់អាននេះធំជាងកិច្ចដែលលោកម្ចាស់បានធ្វើដល់ខ្ញុំទៀត. បានធ្វើឱ្យខ្ញុំនៅស្ងៀមពុំដឹងថា តើខ្ញុំត្រូវតែបំពេញចិត្តលោកម្ចាស់តាមសេចក្ដីប្រាថ្នារបស់លោកម្ចាស់ឬក៏យ៉ាងណា" ។

តើមានហេតុអ្វីដែលបណ្ដាលឱ្យលោកតារុញរាក្នុងចិត្តដូច្នេះ ឬក៏លោកតាមានឧបសគ្គអ្វីក្នុងការដែលត្រូវប្រាប់ខ្ញុំនេះ. ព្រះអង្គម្ចាស់បាម៉ានទ្រង់សួរ ។

- ខ្ញុំនឹងនិយាយជម្រាបលោកម្ចាស់. អ្នកបួសឆ្លើយ. គឺដោយហេតុមកពីខ្ញុំសម្លឹងឃើញមានគ្រោះថ្នាក់ដែលលោកត្រូវទទួល ហើយលោកនឹងមិនព្រមជឿតាមខ្ញុំ ។ មានពួកអភិជនជាច្រើនដែលមានសេចក្ដីអង់អាចក្លាហានមិនខុសពីលោកម្ចាស់ទេ បានទទួលគ្រោះថ្នាក់នោះរួចមកហើយ ។ ពួកអភិជនទាំងនោះបានធ្វើដំណើរមកតាមនេះហើយបានធ្វើសំនួមពរនេះដល់ខ្ញុំដូចជាលោកម្ចាស់ដែរ ។ ហើយខ្ញុំឥតមានធ្វេសប្រហែសនឹងនិយាយពន្យល់ណែនាំអស់លោកទាំងនោះឱ្យបោះបង់សេចក្ដីប្រាថ្នា ហើយយាងទៅរកអ្វីនៅកន្លែងដទៃទៀតទៅប៉ុន្តែគេឥតព្រមជឿខ្ញុំសោះ ។ នៅទីបំផុតខ្ញុំក៏ព្រមប្រាប់ផ្លូវ តាមការអង្វររបស់គេ ប៉ុន្តែខ្ញុំសូមបញ្ជាក់ជូនលោកម្ចាស់ឱ្យជ្រាបថា ជនទាំងនោះឥតបានសម្រេចតាមបំណងសោះ ហើយខ្ញុំឥតឃើញសូម្បីតែម្នាក់ត្រឡប់មកវិញឡើយ ហេតុនេះ. ទោះលោកម្ចាស់ស្រឡាញ់ជីវិតលោក

ម្ចាស់តែបន្តិចបន្តួចក្តី ហើយបើលោកព្រមជឿតាមដំបូន្មានខ្ញុំ សូមលោកម្ចាស់កុំអញ្ជើញទៅឆ្ងាយទៀត ហើយយាងត្រឡប់ទៅគេហស្ថានលោកម្ចាស់វិញទៅប្រសើរជាង" ។

ទោះបីអ្នកបួសបាននិយាយទូលយ៉ាងនេះក៏ដោយ ព្រះអង្គម្ចាស់បាម៉ានក៏នៅតែទទូចចង់ធ្វើតាមព្រះរាជបំណងព្រះអង្គ មិនព្រមជឿតាមអ្នកបួសសោះ ហើយក៏មានព្រះបន្ទូលទៅកាន់អ្នកបួសថា : "ខ្ញុំព្រមជឿថាដំបូន្មានរបស់លោកតានេះស្មោះត្រង់មែន ហើយខ្ញុំត្រូវដឹងគុណលោកតាឥតភ្លេចចំពោះសញ្ញាមិត្តភាព ដែលលោកតាបានតឿនដល់ខ្ញុំនេះ, ប៉ុន្តែទោះជាគ្រោះថ្នាក់ដែលលោកតាបានមានប្រសាសន៍នោះ មានសណ្ឋានយ៉ាងណាក៏ដោយ គ្មានអ្វីអាចធ្វើឱ្យខ្ញុំផ្លាស់គោលបំណងនេះបានឡើយ" ។ បើសិនជាមាននរណាមួយហ៊ានវាយប្រហារខ្ញុំ ក៏ខ្ញុំមានគ្រឿងសាស្ត្រាវុធយ៉ាងសំខាន់នឹងការពារខ្លួនដែរ. ហើយអ្នកនោះឯងក៏មិនមែនក្លាហានខ្លាំងពូកែជាងខ្ញុំប៉ុន្មានដែរ ។

- ចុះបើសិនជាអ្នកដែលវាយប្រហារលោកម្ចាស់, អ្នកបួសបញ្ជាក់, មិនបង្ហាញរូបឱ្យលោកម្ចាស់ឃើញ ហើយវាមានគ្នាច្រើនណាស់ តើលោកម្ចាស់អាចការពារខ្លួនលោកម្ចាស់ទៅនឹងមនុស្សដែលលោកម្ចាស់មើលខ្លួនពុំឃើញនោះម្តេចបាន?

- អ្វីក៏ដោយ, ព្រះអង្គម្ចាស់ទ្រង់មានព្រះបន្ទូលឆ្លើយយ៉ាងរន្ថើន, ហើយទោះជាលោកតាចេះមានប្រសាសន៍ដូចម្តេចក៏ដោយ, ក៏

មិនអាចឱ្យខ្ញុំឈប់បំពេញករណីយកិច្ចនេះបានដែរ ។ ដូច្នេះខ្ញុំសូមអង្វរលោកតាម្តងទៀត សុំឱ្យលោកតាប្រាប់ខ្ញុំភ្លាមមក ហើយសុំកុំប្រកែកនឹងសេចក្តីអង្វរខ្ញុំនេះទៀតឱ្យសោះ ។

អ្នកបួសកាលបើសម្គាល់ឃើញថា គាត់ពុំអាចរាំងរាបំណងព្រះអង្គម្ចាស់បានទេ ព្រោះព្រះអង្គនៅតែចចេសរឹងចង់តែយាងទៅកន្លែងនោះ ថ្វីបើគាត់ខំឱ្យដំបូន្មានដែលអាចជួយស្រោចស្រង់ជីវិតបានក៏ដោយ, ក៏លូកដៃយកដុំមូលមួយនៅក្នុងថង់ជិតគាត់នោះ ហើយថ្វាយទៅព្រះអង្គម្ចាស់បាម៉ានដោយពោលដូច្នេះថា : “ព្រោះខ្ញុំពុំអាចនិយាយឃាត់លោកម្ចាស់បាន, សូមលោកម្ចាស់ចាំស្តាប់ខ្ញុំ ហើយទាញយកប្រយោជន៍ពីដំបូន្មានខ្ញុំនេះចុះ សូមលោកម្ចាស់កាន់ដុំមូលនេះឡើង រួចកាលបើលោកម្ចាស់ឡើងជិះលើសេះរួចហើយ, សូមបោះដុំមូលនេះទៅមុខលោកម្ចាស់ ហើយបរសេះតាមរបស់នេះឱ្យជាប់ លុះ-ត្រាទៅដល់ជើងភ្នំមួយដែលវាត្រូវឈប់” ។ កាលបើដុំនេះឈប់ហើយសូមលោកម្ចាស់ចុះពីខ្នងសេះ ហើយទុកសេះនៅទីនោះចុះ គ្រាន់តែត្រូវយកខ្សែបង្ហៀដាក់លើកវាប៉ុណ្ណោះ សេះនេះនឹងឥតដើរទៅណាបានឡើយ វានឹងនៅឈរចាំលុះត្រាលោកម្ចាស់ត្រឡប់មកវិញ ។ នៅពេលដែលលោកម្ចាស់ដើរឡើងភ្នំនោះទៅ លោកម្ចាស់នឹងបានឃើញនៅខាងស្តាំនិងខាងឆ្វេងដៃ ដុំថ្មពណ៌ខ្មៅជាច្រើនអនេក, ហើយលោកម្ចាស់នឹងបានឮសម្លេងទ្រហឹងអឺងកងច្របូកច្របល់គ្នាពីគ្រប់ទិសទី

អ្នកបួសបាននិយាយ ជុំមូលនៅក៏ឈប់ស្ងៀម ។ ព្រះអង្គម្ចាស់ក៏យាង ចុះពីខ្នងសេះ យកខ្សែបង្ហៀដាក់ទៅលើកវា សេះក៏ឥតមានដើរទៅណាចោលកន្លែងឡើយ ។ បន្ទាប់ពីបានពិនិត្យមើលភ្នំ. នឹងសម្គាល់ឃើញដុំថ្មខ្មៅៗនោះ ហើយព្រះអង្គម្ចាស់ក៏ចាប់យាងឡើងទៅលើភ្នំ។ ទ្រង់យាងឡើងពុំទាន់តែបានគ្រប់បួនជំហានផង. សម្លេងដែលអ្នកបួសបាននិយាយនោះ បានលាន់ឮឡើងរំពងអឹងកង តែឥតឃើញមានមនុស្សម្នាណាម្នាក់ ។ អ្នកខ្លះពោលថា : "តើមនុស្សពញ្ញើនេះទៅណាមកណា? វាចង់បានអ្វី? ចូរកុំឱ្យវាទៅ" ។ ខ្លះទៀតពោលដូច្នេះ : "ចាប់វាឱ្យជាប់. យកវាមក. សម្លាប់វាចោលទៅ" ខ្លះស្រែកឮដូចផ្គរ-លាន់ : "ចោរ ! មនុស្សឃាដ ! មនុស្សធ្វើអំពើឃាដកម្ម !" ខ្លះផ្ទុយទៅវិញស្រែកចំអកឡកឡឺយថា: "ទេ. កុំធ្វើបាបគាត់. បើកផ្លូវឱ្យបងកំលោះគាត់ទៅផង គឺគាត់នេះហើយដែលគេត្រូវទុកទ្រុងនឹងបក្សាជូន !" ។

ថ្វីបើឮសម្រែកបៀតបៀនរំខានដូច្នោះក៏ដោយ. ក៏ព្រះអង្គម្ចាស់បាម៉ាន នៅតែខំយាងឡើងទៅបានមួយសន្ទុះ ដោយសភាពនឹងនួនយ៉ាងអង់អាច ប៉ុន្តែសម្លេងចេះតែផ្ទួនឡើងៗលាន់សូរជាខ្លាំង. ហើយនៅជិតៗព្រះអង្គម្ចាស់ផង ខ្លះពីមុខខ្លះពីក្រោយ លុះត្រាតែព្រះអង្គកើតសេចក្ដីខ្លាចឡើងញ័រព្រះហស្ដព្រះបាទទាំងអស់. ទើបទ្រង់មានដំណើរទៅជាទ្រេតទ្រោត ។ រួចកាលបើព្រះអង្គម្ចាស់យល់ថា.

ខ្ញុំសូមជម្រាបម្តងទៀតថា. ទាន់ឱកាសនៅមាននឹងពិចារណា សូមលោកម្ចាស់មេត្តាសញ្ជឹងត្រិះរិះឱ្យមែនទែន ព្រោះការបាត់បង់ជីវិតនេះគ្មានអ្វីជួសជុលបានទេ ហើយស្ថិតនៅជាប់នឹងលក្ខខណ្ឌដែលគេប្រព្រឹត្តល្មើស ឬក៏ការធ្វេសប្រហែស. សូមលោកម្ចាស់យល់ឱ្យច្បាស់ ។

ព្រះអង្គម្ចាស់បាម៉ាន ក្រោយពីបានទទួលដុំមូលពីអ្នកបួសហើយ ក៏មានព្រះបន្ទូលថា : "ចំពោះដំបូន្មានដែលលោកតាបានទូន្មានហើយទូន្មានទៀតនេះ ហើយដែលខ្ញុំត្រូវតែនឹកគុណលោកតាឥតភ្លេចនោះ. ខ្ញុំពុំអាចធ្វើតាមបានទេ. ប៉ុន្តែខ្ញុំនឹងខិតខំឆ្លៀតយកប្រយោជន៍អំពីដំបូន្មានដែលលោកតាបានហាមខ្ញុំកុំឱ្យងាកក្រោយ នៅពេលដើរឡើងទៅ ហើយខ្ញុំសង្ឃឹមថា មិនយូរប៉ុន្មានលោកនឹងឃើញខ្ញុំត្រឡប់មកវិញ ហើយមកសម្តែងអំណរគុណដ៏ជ្រាលជ្រៅដល់លោកតា ដោយបានទាំងរបស់នោះមកជាមួយផង" ។ កាលបើមានព្រះបន្ទូលដូច្នេះចប់កាលណា ព្រះអង្គម្ចាស់ក៏ឡើងគង់សេះជម្រាបលាអ្នកបួស ដោយអោនព្រះកេសគោរពយ៉ាងគួរសមបំផុត រួចក៏បោះដុំមូលនោះទៅមុខព្រះអង្គ ។

ដុំមូលនោះបានរមៀល ហើយចេះតែរមៀលទៅមុខជានិច្ចដោយល្បឿនដដែល តាមល្បឿនដើមដែលព្រះអង្គម្ចាស់បានបោះទៅ ។ ដូច្នេះ ព្រះអង្គម្ចាស់បរសេះតាមនៃល្បឿន. ឱ្យត្រូវនឹងល្បឿនដុំមូលនោះ ដើម្បីកុំឱ្យបាត់ព្រះនេត្រពីដុំមូល ។ កាលបើទៅដល់ជើងភ្នំដែល

មក ព្រះអង្គម្ចាស់ប៉ៃរិសមានព្រះបន្ទូលថា : "ម្ចាស់ក្សត្រីអូន, សូមម្ចាស់អូនហូតកាំបិតមើល ហើយយើងនឹងបានដំណឹងយ៉ាងណាទៀត"។ ព្រះអង្គម្ចាស់ក្សត្រីក៏បានហូតកាំបិតចេញមក, ហើយទាំងពីរព្រះអង្គទ្រង់ទតទៅឃើញស្រក់ឈាមនៅចុងកាំបិត។ ទើបព្រះអង្គម្ចាស់ក្សត្រីយល់នូវភេរវកម្មនិងការឈឺចាប់ដូច្នេះ ក៏គ្រវែងកាំបិតនោះចោល រួចទ្រង់ស្រែកយ៉ាងភ្លាត់សម្លេងថា : "អីយ៉ា ! ម្ចាស់ព្រះរៀម, ម្ចាស់ព្រះរៀមចាកចោលម្ចាស់អូនហើយឬ ចាកចោលម្ចាស់អូនបណ្ដាលមកពីកំហុសម្ចាស់អូន ! ម្ចាស់អូនខានឃើញព្រះភក្ត្រព្រះរៀមទៀតហើយ! តើខ្ញុំជាមនុស្សកំណាចយ៉ាងណាទៅ? ហេតុអ្វីក៏ខ្ញុំនិយាយរឿងបក្សាចេះនិយាយ, ដើមឈើចេះច្រៀង និងទឹកពណ៌លឿងប្រាប់ព្រះអង្គ ។ ហើយម្យ៉ាងទៀត តើហេតុអ្វីបានជាខ្ញុំចាំបាច់ត្រូវការសួរស្រីអ្នកកាន់សាសនាអ៊ីស្លាមថាផ្ទះនេះល្អឬអាក្រក់ មានវត្ថុតាំងគ្រប់គ្រាន់ហើយឬនៅ? ឱទេវតាអើយ ចុះហេតុអ្វីក៏គាត់មិនប្រាប់ពីរឿងគ្រោះថ្នាក់នេះផង ! ស្រីលាក់ពុត ស្រីឆបោក ម្ដេចក៏អ្នកមិននឹកដល់គុណដែលខ្ញុំបានធ្វើបដិសណ្ឋារកិច្ចដល់អ្នកផង? ហេតុអ្វីក៏អ្នកបាននិយាយប្រាប់ខ្ញុំអំពីបក្សា អំពីដើមឈើ, អំពីទឹក ដែលជារបស់មាននៅតែក្នុងមនោគតិហើយធ្វើឱ្យខ្ញុំជឿ លុះត្រាតែត្រូវស្លាប់បងជាទីស្នេហារបស់ខ្ញុំបាត់ទៅដូច្នេះ ហើយរបស់ទាំងនោះនៅតែមករំខានខួរក្បាលខ្ញុំឱ្យគិតនឹកដល់ដោយសារអំពើស្នេហ៍របស់អ្នក?" ។

ទ្រង់អស់កម្លាំងកាន់តែខ្លាំងណាស់ហើយ ទ្រង់ក៏ភ្លេចនឹកដល់បណ្តាំអ្នកបួសឈឹង. ហើយទ្រង់ងាកបែរទៅក្រោយដើម្បីរត់ចុះទៅវិញ ប៉ុន្តែពុទ្ធោអើយមួយរំពេចនោះ ព្រះអង្គម្ចាស់ទ្រង់ក្លាយទៅជាថ្មខ្មៅភ្លាម ការផ្លាស់រូបរាងនេះ បានកើតមានឡើងដល់ជនជាច្រើនមុនព្រះអង្គដែលមានបំណងដូចគ្នានេះ ។ មិនតែប៉ុណ្ណោះ សត្វសេះក៏ត្រូវទទួលការផ្លាស់ជាតិនេះដែរ ។

ចាប់តាំងពីព្រះអង្គម្ចាស់បាម៉ានបានធ្វើដំណើរយាងចេញទៅ ព្រះអង្គម្ចាស់ក្សត្រីប៉ារីសាដ ឥតដែលខាននឹងហូតកាំបិត ដែលព្រះអង្គម្ចាស់ព្រះវៀមបានទុកថ្វាយមើលក្នុងមួយថ្ងៃៗជាច្រើនដង ប្រយោជន៍ឱ្យបានដឹងថា តើព្រះវៀមមានព្រះជន្មគង់នៅទេ ឬក៏អស់ព្រះជន្មហើយ ។ ព្រះនាងបានចងកាំបិតនេះជាប់នឹងខ្សែក្រវាត់ព្រះនាងជាមួយនឹងស្រោម ។ អាស្រ័យដោយហេតុដូច្នេះ. ព្រះនាងក៏បានស្រោកស្រាន្តទុក្ខម្តងៗ ដោយបានដឹងថាព្រះវៀមទ្រង់សុខសប្បាយព្រះអង្គទេ ហើយព្រះនាងតែងបានយករឿងព្រះអង្គម្ចាស់ព្រះវៀមមកសន្ទនាជាញឹកញយជាមួយនឹងព្រះអង្គម្ចាស់ប៉ែវិស ដែលទ្រង់តែងបានសួរព្រះនាងជាញយៗដែរ អំពីដំណើរព្រះអង្គម្ចាស់ព្រះវៀម ។

លុះមកដល់ថ្ងៃចង្រៃដែលព្រះអង្គម្ចាស់ព្រះវៀមត្រូវក្លាយព្រះអង្គទៅជាថ្មខ្មៅ. នៅវេលាល្ងាចព្រះអង្គម្ចាស់ក្សត្រីនឹងព្រះអង្គម្ចាស់ប៉ែវិសទ្រង់បានសន្ទនាគ្នាពីរឿងព្រះអង្គម្ចាស់ព្រះវៀមតាមទម្លាប់រៀង

យើង បណ្ដាលមកពីកំហុសគាត់ ឬក៏បណ្ដាលមកពីគ្រោះថ្នាក់ផ្សេងៗ ដែលយើងពុំអាចស្មានបាន? ដូច្នេះ ម្ចាស់ក្សត្រីអូន ដោយការសោយទិវង្គតរបស់ព្រះរៀមឥតជាឧបសគ្គអ្វីដល់ខ្ញុំនឹងបន្តការស្វែងរករបស់ម្ចាស់អូនទេនោះៗ ខ្ញុំសុំខ្លួនចេញធ្វើដំណើរស្វែងរកនេះស្នងព្រះរៀម. ខ្ញុំក៏មានបំណងដូចជាព្រះអង្គដែរ ទោះបីព្រះអង្គបានទទួលទុក្ខជាគំរូមកដូច្នេះក៏ដោយ. ក៏ខ្ញុំឥតផ្លាស់មនោសញ្ចេតនាឡើយ. ដូច្នេះនៅថ្ងៃស្អែកនេះ ខ្ញុំនឹងចេញដំណើរទៅហើយ" ។

ព្រះអង្គម្ចាស់ក្សត្រីបានខំរករឿងនិយាយឃាត់ព្រះអង្គម្ចាស់ប៉ែរិសណាស់ ព្រមទាំងបានអង្វរព្រះអង្គកុំឱ្យយាងទៅរងគ្រោះថ្នាក់ក្រែងមិនសុគតតែមួយព្រះអង្គទៅជាពីរព្រះអង្គទៅវិញ ប៉ុន្តែព្រះអង្គម្ចាស់មិនព្រមតាមឡើយ ថ្វីបើព្រះនាងបានបំភ្លឺដូច្នេះក៏ដោយ ។ មុននឹងធ្វើដំណើរយាងចេញទៅ. ព្រះអង្គម្ចាស់បានថ្វាយចង្កោមគជ់មួយមាន ១០០ គ្រាប់ទៅព្រះនាង ប្រយោជន៍ឱ្យព្រះនាងអាចជ្រាបដំណឹងអំពីលទ្ធផលនៃដំណើររបស់ព្រះអង្គ ដូចជាកាំបិតដែលព្រះអង្គម្ចាស់ព្រះរៀមបានទុកថ្វាយព្រះនាងដែរ នៅពេលដែលព្រះអង្គយាងចេញទៅ ។ នៅពេលថ្វាយចង្កោមគជ់នេះទៅព្រះនាង ព្រះអង្គម្ចាស់ប៉ែរិសទ្រង់មានព្រះបន្ទូលថា : "នៅពេលដែលខ្ញុំមិននៅ សូមម្ចាស់អូននិយាយសួរទៅចង្កោមគជ់នេះ ដើម្បីឱ្យដឹងដំណឹងពីខ្ញុំ។ កាលបើនិយាយទៅហើយ. ឃើញគ្រាប់គជ់នោះឈប់ស្ងៀមហាក់ដូចជាផ្សារជាប់គ្នា

ព្រះអង្គម្ចាស់ប៉ៃរិស ក៏ទ្រង់កើតទុក្ខជាពន់ប្រមាណក្នុងរឿង នេះ ដូចជាព្រះអនុជក្សត្រីដែរ ប៉ុន្តែព្រះអង្គឥតនៅបង្អង់ឱ្យខាតពេល វល់តែកើតទុក្ខសោកស្តាយឥតអំពើនោះទេ ដោយហេតុថា ព្រះអង្គម្ចាស់ទ្រង់យល់នូវព្រះទ័យម្ចាស់អូននៅតែលោភលន់ពន់ប្រមាណ ចង់បានបក្សាចេះនិយាយ ដើមឈើចេះច្រៀងនិងទឹកពណ៌លឿង ព្រះអង្គម្ចាស់ក៏មានព្រះបន្ទូលឡើងថា : "ម្ចាស់ក្សត្រីអូន, យើងនឹងនៅស្រណោះអាឡោះសោកស្តាយម្ចាស់ព្រះរៀមយើងដូច្នេះ ក៏ជាការឥតអំពើដែរ ។ សេចក្តីត្អូញត្អែរ កើតទុក្ខរៀបរាប់របស់យើងនេះមិនអាចញុំាងឱ្យម្ចាស់ព្រះរៀមមានព្រះជន្មាយុឡើងវិញទេ គឺជាឆន្ទៈព្រះអាទិទេព ។ យើងត្រូវតែចុះចូលធ្វើតាមឆន្ទៈនេះ ហើយគោរពតាមសេចក្តីសម្រេចចិត្តរបស់ព្រះអង្គ មិនត្រូវមានចិត្តចង់ជ្រៀតជ្រែកចូលក្នុងរឿងនោះឡើយ ។ ចុះហេតុអ្វីបានជាអម្បាញ់មិញ ម្ចាស់អូនមិនចង់ជឿតាមសម្តីអ្នកស្រីកាន់សាសនាអ៊ីស្លាម បន្ទាប់ពីម្ចាស់អូនបានសម្គាល់យ៉ាងម៉ឺងម៉ាត់ក្នុងចិត្តថា ជាការពិតហើយច្បាស់ណាស់នោះ? ម្ចាស់អូនស្មានថា តើគាត់អាចនិយាយប្រាប់ម្ចាស់អូនអំពីរបស់បីយ៉ាងនោះបានទេ, បើសិនជារបស់នោះគ្មានសោះ ហើយគាត់ទើបតែនឹងប្រឌិតឡើងដោយចេតនា ដើម្បីនឹងបញ្ឆោតម្ចាស់អូនដែលបានធ្វើបដិសណ្ឋារកិច្ចទទួលគាត់ ដោយរីករាយនិងដោយសប្បុរស? មួយចំណែកទៀត តើយើងអាចជឿថា ការសោយទីវង្គតនៃម្ចាស់ព្រះរៀម

មកវិញសោះ ។ ការនោះគ្មានសង្ស័យទេ គឺបុរសនោះត្រូវទទួលវាសនាដូចជាជនមុនៗដែរ ។

ព្រះអង្គម្ចាស់ប៉ែរិសក៏មានព្រះបន្ទូលថា : "ជម្រាបអ្នកបួស. ខ្ញុំស្គាល់ហើយជនដែលអ្នកបានពោលនេះ គឺជាបងប្រុសច្បងបង្អស់របស់ខ្ញុំ ហើយខ្ញុំបានដឹងយ៉ាងពិតប្រាកដថាគាត់ស្លាប់ហើយ ប៉ុន្តែខ្ញុំពុំដឹងថា តើគាត់ស្លាប់ទៅកើតជាអ្វី" ។

- ខ្ញុំអាចជម្រាបលោកបាន. អ្នកបួសឆ្លើយ. គាត់បានផ្លាស់ជាតិទៅជាថ្មខ្មៅ ដូចជនឯទៀតដែលខ្ញុំបាននិយាយជម្រាបលោកដែរ ហើយលោកក៏ប្រហែលជានឹងត្រូវទទួលការផ្លាស់ជាតិដូចគ្នានេះដែរ ខណៈណាលោកមិនបានពិនិត្យឱ្យម៉ត់ចត់នូវដំបូន្មានទាំងឡាយ ដែលខ្ញុំបានប្រាប់លោកពីមុនៗមក ហើយបើលោកនៅតែទទូចមិនព្រមលះបង់សេចក្ដីសម្រេចចិត្តរបស់លោកនេះ, ខ្ញុំសុំរំលឹកលោកម្ដងទៀតចុះ ។

- ជម្រាបអ្នកបួស. ព្រះអង្គម្ចាស់ប៉ែរិសទ្រង់ទទូចទទែ. ខ្ញុំពុំដឹងជាត្រូវជំពាក់គុណអ្នកប៉ុន្មានទេ ដែលអ្នកខំខ្នះខ្នែងជួយរក្សាការពារជីវិតខ្ញុំនេះ ដែលជាជនដែលអ្នកមិនទាំងស្គាល់សោះ ហើយគ្មានទាំងបានធ្វើអ្វីជាអំពើគាប់ប្រសើរសមនឹងត្រូវទទួលចិត្តប្រណីនេះផង ។ ប៉ុន្តែខ្ញុំសូមនិយាយនឹងអ្នកថា មុននឹងខ្ញុំសម្រេចចិត្តយ៉ាងណា. ខ្ញុំត្រូវការទៅឱ្យដល់កន្លែងនោះសិន ខ្ញុំពុំអាចបោះបង់គោលបំណងតែម្ដង

ទាល់តែម្ចាស់អូនពុំអាចធ្វើឱ្យកំរើកឬធ្វើឱ្យរមៀលតាមគ្នាបាន. សញ្ញានោះប្រាប់ឱ្យដឹងថា ខ្ញុំត្រូវបានទទួលវាសនាដូចជាម្ចាស់ព្រះរៀមដែរ ។ ប៉ុន្តែ សូមយើងសង្ឃឹមថា ការនេះនឹងឥតកើតមានឡើយ ហើយខ្ញុំប្រាកដជាមានវាសនាបានមកឃើញម្ចាស់អូនវិញ ដោយសេចក្តីរីករាយដែលយើងខំរង់ចាំមក" ។

ព្រះអង្គម្ចាស់បែរៃវិសក៏យាងចេញទៅ ហើយនៅថ្ងៃទីម្ភៃមួយព្រះអង្គក៏បានជួបនឹងអ្នកបួសដដែលនោះ នៅកន្លែងតែមួយដែលព្រះអង្គម្ចាស់បាម៉ានទ្រង់បានជួបពីមុន។ ព្រះអង្គម្ចាស់ក៏យាងចូលទៅជិតគាត់ គំនាប់គាត់គួរសមគាត់រួចហើយអង្វរសុំឱ្យគាត់បង្ហាញកន្លែង. បើសិនជាគាត់ដឹង. គឺកន្លែងបក្សាចេះនិយាយ. ដើមឈើចេះច្រៀង និងទឹកពណ៌លឿង ។ អ្នកបួសក៏មិនព្រមប្រាប់ព្រះអង្គសោះ ហើយគាត់បាននិយាយបំភ្លឺព្រះអង្គតាមហេតុផ្សេង ដូចជាគាត់បាននិយាយទូលព្រះអង្គម្ចាស់បាម៉ានដូច្នោះដែរ រហូតដល់ទៅនិយាយថា ទើបតែមិនយូរប៉ុន្មានផងនេះ មានអ្នកជិះសេះកំលោះម្នាក់ដែលមានទម្រង់រាងរៅស្រដៀងនឹងព្រះអង្គដែរនោះ បានមកសុំឱ្យគាត់បង្ហាញផ្លូវដូច្នេះដែរ ។ លុះចាញ់ចំណេះនិយាយហាមជននោះកុំឱ្យប្រាថ្នាដូច្នោះពុំស្តាប់សោះ. គាត់ក៏ព្រមបង្ហាញផ្លូវ. ឱ្យដុំមូលមួយសម្រាប់ធ្វើជាអ្នកមគ្គុទ្ទេសក៍ នឹងប្រាប់អំពីកិច្ចការផ្សេងៗដែលត្រូវកត់ចំណាំ ដើម្បីធ្វើការឱ្យបានសម្រេចតាមបំណង ។ ប៉ុន្តែ គាត់ឥតបានឃើញជននោះត្រឡប់

ព្រះអង្គម្ចាស់ប៉ៃរិសក៏សម្ដែងអំណរគុណដល់អ្នកបួសយាងឡើងគង់លើសេះ. បោះដុំមូលទៅខាងមុខនោះ រួចទ្រង់បរសេះតាមដុំមូលនោះ ។ នៅទីបំផុត ព្រះអង្គម្ចាស់ក៏បានយាងទៅដល់ជើងភ្នំ រួចទ្រង់ឃើញដុំមូលនោះឈប់វិល. ព្រះអង្គក៏យាងចុះពីខ្នងសេះ ។ មុននឹងព្រះអង្គចាប់ឈានជំហានដំបូងឡើងទៅលើភ្នំ ព្រះអង្គទ្រង់គង់ឈរនៅកន្លែងដដែលមួយសន្ទុះ ដើម្បីទ្រង់កត់ត្រាឱ្យចាំនូវបម្រាមទាំងឡាយដែលអ្នកបួសបានប្រាប់ ។ រួចទ្រង់ក៏ខំតាំងចិត្តឱ្យក្លាហានឡើង ទើបយាងឡើងទៅសម្រេចព្រះទ័យថា នឹងទៅដល់កំពូលភ្នំ ។ លុះព្រះអង្គម្ចាស់យាងបានប្រហែលជាប្រាំមួយជំហាន ស្រាប់តែឮសម្លេងមួយលេចចេញមកពីក្រោយព្រះអង្គហាក់ដូចជានៅជិតណាស់ ឮដូចជាមាត់មនុស្សស្រែកជេរដូច្នោះថា “ហៃ៎ឈប់សិនអ្នកក្លាហានហួសប្រមាណចាំខ្ញុំធ្វើទណ្ឌកម្មមួយជូនសិន !” ។

កាលបើព្រះអង្គម្ចាស់ ទ្រង់ព្រះសណ្ដាប់ឮនូវការប្រមាថយ៉ាងធ្ងន់ដូច្នេះ. ព្រះអង្គក៏ភ្លេចនូវបម្រាមអ្នកបួស. ព្រះអង្គទ្រង់យកព្រះហស្តចាប់កាន់កាំបិតស្នៀតទ្រង់ងាកបែរទៅក្រោយដើម្បីសងសឹក. ប៉ុន្តែពេលនោះព្រះអង្គម្ចាស់ព្រមទាំងសេះព្រះអង្គក៏ក្លាយទៅជាថ្មខ្មៅទាំងអស់មួយរំពេច ។

ចាប់តាំងពីពេលព្រះអង្គម្ចាស់ប៉ៃរិសបានធ្វើដំណើរចេញទៅ. ព្រះអង្គម្ចាស់ក្សត្រីប៉ារីសាដ ជារាល់ថ្ងៃតែងយកចង្កោមគជ់ ដែលព្រះ

បានទេ ។ ដូច្នេះ ខ្ញុំសូមអង្វរអ្នកឱ្យមេត្តាអនុគ្រោះប្រាប់ផ្លូវដល់ខ្ញុំ ដូចជាអ្នកបានធ្វើសេចក្ដីអនុគ្រោះដល់បងខ្ញុំផង ។ ខ្ញុំនឹងប្រហែលជាប្រព្រឹត្តធ្វើតាមព័តិមានអ្នកបានប្រសើរជាងបងខ្ញុំ ។

- ព្រោះខ្ញុំពុំអាចហាមឃាត់លោកដូចម្ដេចបាន, អ្នកបួសពោល, ដើម្បីឱ្យលោកជឿ ហើយយល់ព្រមបោះបង់គំនិត ដែលលោកបានសម្រេចមក, បើសិនជាខ្ញុំកុំមានវ័យចាស់ជរាដូច្នេះ ហើយបើសិនជាខ្ញុំអាចឡើងឈរបាន, នោះខ្ញុំនឹងក្រោកឡើងភ្លាមមួយរំពេច ដើម្បីហុចដុំមូលដែលខ្ញុំមាននេះជូនទៅអ្នកភ្លែត សម្រាប់ឱ្យអ្នកប្រើការធ្វើជាមគ្គុទ្ទេសក៍ ។

ដោយឥតបណ្ដោយឱ្យអ្នកបួសមានប្រសាសន៍ទៅទៀត, ព្រះអង្គម្ចាស់ប៉ៃវិសក៏យាងចុះពីខ្នងសេះ ហើយយាងចូលទៅជិតអ្នកបួស១ក៏ថ្វាយដុំមូលមួយ បណ្ដាដុំមូលដែលគាត់នៅមានជាច្រើនទៀតមកព្រះអង្គម្ចាស់ ហើយនិយាយទូលព្រះអង្គពីរបៀបដែលត្រូវប្រើ នឹងកិច្ចដែលត្រូវធ្វើ ដូចជាគាត់បាននិយាយទូលព្រះអង្គម្ចាស់បាម៉ានដូច្នោះដែរ។ ហើយបន្ទាប់ពីគាត់បានរំលឹកព្រះអង្គម្ចាស់កុំឱ្យខ្លាចនឹងសម្រែកដែលព្រះអង្គនឹងបានឮ ហើយឥតឃើញមនុស្ស ទោះជាសម្រែកគំហកកំហែងយ៉ាងណាក៏ដោយ ព្រោះវាគ្មានធ្វើអ្វីបានក្រៅពីរាំងរា កុំឱ្យព្រះអង្គយាងឡើងទៅឃើញទ្រុងនិងសត្វ, អ្នកបួសក៏អនុញ្ញាតឱ្យព្រះអង្គម្ចាស់យាងទៅ ។

យាងគង់លើសេះធ្វើដំណើរចេញទៅតាមផ្លូវតែមួយ ដែលព្រះរៀម ទាំងពីរមុនបានយាងទៅដែរ ។

ព្រះអង្គម្ចាស់ក្សត្រីបារីសាដ. ដែលទ្រង់ធ្លាប់ជិះសេះបរបាញ់ ម្រឹគម្រឹគាស្រាប់ ក៏ទ្រាំទ្រនឹងការអស់ព្រះកាយពលបានគ្រាន់បើជាង ស្ត្រីភេទឯទៀត ។ លុះយាងធ្វើដំណើរបានគ្រប់ចំនួនថ្ងៃហើយ. ព្រះ នាងក៏បានជួបនឹងអ្នកបួសដដែលនោះនៅថ្ងៃទីម្ភៃមួយ ។ កាលបើព្រះ នាងបានយាងទៅដល់ជិតគាត់ ព្រះនាងក៏យាងចុះពីខ្នងសេះ ព្រះហស្ត ម្ខាងកាន់សេះ ហើយយាងចូលទៅគង់ជិតអ្នកបួសតំនាប់គាត់ គួរសម គាត់តាមធម្មតា រួចព្រះនាងត្រាស់សួរទៅគាត់ថា: “អ្នកបួសដ៏ចម្រើន. សូមអ្នកមេត្តាឱ្យខ្ញុំឈប់សម្រាកក្បែរអ្នកបន្តិច ហើយសូមអ្នកមេត្តា និយាយប្រាប់ខ្ញុំថា តើអ្នកមានបានឮគេនិយាយទេថា នៅទីជិតៗក្នុង ភូមិនេះ. មានកន្លែងមួយដែលមានសត្វចេះនិយាយ ដើមឈើចេះច្រៀង និងទឹកពណ៌លឿង” ។

អ្នកបួសក៏ឆ្លើយថា: “អ្នកស្រី. ដោយហេតុតែសំឡេងអ្នកធ្វើ ឱ្យខ្ញុំស្គាល់ថា អ្នកជាភេទអ្វីភ្លាម ទោះអ្នកស្រីស្លៀកពាក់ក្លែងក្លាយជា មនុស្សប្រុសក៏ដោយ. បានជាខ្ញុំហៅអ្នកដូច្នេះ ។ ខ្ញុំសូមសម្តែងអំណរ គុណនឹងសេចក្តីគួរសមរបស់អ្នកស្រីហើយៗខ្ញុំមានសេចក្តីរីករាយក្រៃ លែង ដោយបានទទួលកិត្តិយសបានត្រូវអ្នកស្រីសួរខ្ញុំនេះ ។ ខ្ញុំសូម ជម្រាបថា ខ្ញុំស្គាល់ច្បាស់ណាស់កន្លែងដែលអ្នកស្រីសួររកនោះ ប៉ុន្តែ តើអ្នកស្រីមានបំណងយ៉ាងណាក្នុងការសួរខ្ញុំនេះ?

នាងបានទទួលពីព្រះអង្គម្ចាស់ប៉ែរិសមកពាក់នឹងព្រះហស្ត ហើយកាលបើព្រះនាងគ្មានការអ្វីនឹងបំពេញ, ព្រះនាងតែងយកគជ់នោះមកដាក់រមៀលលេងក្នុងបាតព្រះហស្ត ។ ទោះបីនៅវេលាយប់ក៏ព្រះនាងឥតដែលដាក់ចង្កោមគជ់នោះឆ្ងាយពីព្រះអង្គដែរ ។ នៅវេលាយប់, ព្រះនាងទ្រង់យកចង្កោមគជ់នោះមកពាក់នឹងព្រះសុរង, ហើយនៅវេលាព្រឹក កាលបើព្រះនាងទ្រង់តើនឡើង, ព្រះនាងតែងយកព្រះហស្តទៅស្ទាបមើលដើម្បីចង់ដឹងមើលថា តើគជ់នោះនៅតែរត់តាមគ្នាទេ ។ ទីបំផុត នៅថ្ងៃដែលព្រះអង្គម្ចាស់ប៉ែរិសត្រូវទទួលវាសនាក្លាយទៅជាថ្មខ្មៅ ដូចជាព្រះអង្គម្ចាស់ព្រះរៀមដែរនោះ ព្រះនាងបានមានព្រះបន្ទូលទៅកាន់ចង្កោមគជ់ ដែលព្រះនាងពាក់នៅនឹងព្រះអង្គនោះ ប៉ុន្តែមួយរំពេចនោះ ព្រះនាងក៏សង្កេតឃើញគជ់ទាំងឡាយឈប់ស្តាប់បង្គាប់ព្រះនាងទៀត ជាសញ្ញាឱ្យដឹងថា ព្រះអង្គម្ចាស់ប៉ែរិសទ្រង់សោយទីវង្គតយ៉ាងពិតប្រាកដហើយ ។ ដោយហេតុព្រះនាងបានសម្រេចព្រះទ័យទុកជាមុនស្រេចទៅហើយថា កាលបើរឿងដូច្នេះកើតមានឡើង ព្រះនាងនឹងយាងចេញទៅបំពេញកិច្ចនេះដោយខ្លួនឯងផ្ទាល់ម្តង ។ ដូច្នេះព្រះនាងក៏មានសេចក្តីឈឺចាប់ជាខ្លាំង លុះស្នែកឡើងបន្ទាប់ពីបានស្លៀកពាក់ក្លែងព្រះអង្គធ្វើជាមនុស្សប្រុស និងរៀបចំគ្រឿងអាវុធនិងបរិក្ខារផ្សេងៗរួច និងក្រោយពីមានព្រះសវនីយ៍ប្រាប់បរិវារព្រះនាងថា ព្រះនាងនឹងយាងត្រឡប់មកវិញក្នុងពេលពីរបីថ្ងៃ ព្រះនាងក៏ទ្រង់

នៅពេលនោះ, អ្នកបួសក៏និយាយទូលព្រះអង្គម្ចាស់ក្សត្រីអំពីឧបសគ្គដែលត្រូវឡើងឱ្យបានទៅដល់លើកំពូលភ្នំ ដែលជាលំនៅនៃបក្សាចេះនិយាយ ។ កាលបើយកបក្សានោះបានហើយ វានឹងនិយាយប្រាប់អំពីកន្លែងដើមឈើចេះច្រៀង និងទឹកពណ៌លឿង។ តមកទៀតអ្នកបួសបាននិយាយទូលព្រះនាង អំពីសំឡេងអ៊ូអរសម្លុតគួរឱ្យញាប់ញ័រ សំឡេងនេះលាន់ឮចេញមកពីគ្រប់ទិស តែឥតឃើញតួមនុស្សទេ។ នៅទីបំផុតអ្នកបួសបានទូលអំពីថ្មខ្មៅៗជាច្រើន ដែលជាវត្ថុតែមួយអាចធ្វើឱ្យព្រះនាងនិងអ្នកឯទៀតភិតភ័យជាខ្លាំង កាលបើព្រះនាងទ្រង់បានជ្រាបថា ដុំថ្មទាំងឡាយនេះគឺជាខ្មោចអ្នកជិះសេះយ៉ាងក្លាហានៗ ដែលបានផ្លាស់ជាតិពីមនុស្សទៅ ដោយហេតុពុំបានប្រតិបត្តិតាមលក្ខខណ្ឌសំខាន់ៗ ដើម្បីឱ្យបានសម្រេចតាមបំណង គឺកុំឱ្យបែរខ្លួនងាកមើលក្រោយមុននឹងយកបានទ្រុងសត្វសិន ។

កាលបើអ្នកបួសនិយាយចប់ហើយ, ព្រះអង្គម្ចាស់ក្សត្រីក៏មានព្រះសវនីយ៍ថា : « បើតាមខ្ញុំបានស្តាប់សម្តីរបស់អ្នក ខ្ញុំក៏បានដឹងថាឧបសគ្គធំៗ ដើម្បីចេញទៅប្រតិបត្តិការឱ្យបានសម្រេចនោះ ទីមួយគឺត្រូវឡើងឱ្យបានទៅដល់ទ្រុងសត្វនោះ កុំឱ្យកោតញញើតនឹងសម្រែកអ៊ូអរ ដែលគេបានស្តាប់ឮតែឥតឃើញតួមនុស្សអ្នកនិយាយ, ទីពីរគឺកុំឱ្យងាកបែរក្រោយ ។ ចំពោះលក្ខខណ្ឌខាងក្រោយនេះ, ខ្ញុំសង្ឃឹមថាខ្ញុំនឹងអាចធ្វើជាចៅហ្វាយលើចិត្តខ្ញុំបានល្មមគ្រប់គ្រាន់ ។ រីឯចំពោះ

- សូមជម្រាបអ្នកបួស, ព្រះអង្គម្ចាស់ក្សត្រីមានព្រះសវនីយ៍, គេបាននិយាយរឿងនេះប្រាប់ខ្ញុំហើយ ខ្ញុំមានសេចក្តីអន្ទះអន្ទែងចង់បានរបស់នោះជាពន់ប្រមាណ ។

- អ្នកបួសក៏ឆ្លើយថា: “អ្នកស្រី, គេបាននិយាយការពិតជម្រាបអ្នកស្រីមែន, របស់នោះចម្លែកអស្ចារ្យក្រៃលែងដូចគេបានជម្រាប ប៉ុន្តែគេឥតបានជម្រាបអ្នកស្រីទេ អំពីឧបសគ្គទាំងឡាយដែលគេត្រូវពុះពារ ដើម្បីនឹងបានរបស់នោះ ។ បើសិនជាគេបាននិយាយជម្រាបអ្នកស្រីផង ប្រហែលជាអ្នកស្រីមុខជាមិនដាច់ចិត្តចេញធ្វើដំណើរស្វះស្វែងដូច្នេះឡើយ ” ។ សូមអ្នកស្រីជឿខ្ញុំ ហើយឈប់ប្រាថ្នាយ៉ាងនេះទៅ សូមអញ្ជើញត្រឡប់ទៅវិញ ហើយសូមកុំយល់ថាខ្ញុំនេះធ្វើឱ្យអ្នកស្រីខាតលាភនោះ ។

ព្រះអង្គម្ចាស់ក្សត្រីក៏មានព្រះសវនីយ៍តបថា : “លោកឪពុក, ខ្ញុំមកពីឆ្ងាយណាស់ ហើយខ្ញុំនឹងតូចចិត្តនឹងខ្លួនខ្ញុំជាពុំខាន បើខ្ញុំព្រមត្រឡប់ទៅវិញ ដោយពុំទាន់បានបំពេញកិច្ចតាមបំណង ។ អ្នកបាននិយាយប្រាប់ខ្ញុំ អំពីឧបសគ្គនិងអំពីគ្រោះថ្នាក់បណ្តាលឱ្យស្លាប់ជីវិត ប៉ុន្តែអ្នកឥតបាននិយាយប្រាប់ខ្ញុំ តើឧបសគ្គនោះយ៉ាងណាខ្លះ ហើយតើគ្រោះថ្នាក់នោះបណ្តាលមកពីអ្វី ការទាំងនេះហើយដែលខ្ញុំចង់ដឹងណាស់ ដើម្បីខ្ញុំនឹងបានយកទៅពិគ្រោះសួរខ្លួនឯងនិងពិចារណាមើលថា តើខ្ញុំត្រូវជឿឬពុំត្រូវជឿលើសេចក្តីសម្រេចចិត្ត, លើសេចក្តីក្លាហាន, នឹងលើកម្លាំងរបស់ខ្ញុំ” ។

គ្មានរណាម្នាក់បានស្នើសួរខ្ញុំដូចជាអ្នកស្រីនេះសោះ ហើយអ្នកទាំងនោះត្រូវស្លាប់តែហោងអស់ ។ បើសិនជាអ្នកស្រីនៅតែទទូចធ្វើតាមបំណងអ្នកស្រីនេះ, នោះអ្នកស្រីអាចធ្វើល្បងមើលទៅ ប៉ុន្តែសូមអ្នកស្រីជ្រាបថា ខ្ញុំមិនមែនដឹកនាំអ្នកស្រីឱ្យទៅរកបាបគ្រោះទេ ។

- លោកឪពុក, ព្រះអង្គម្ចាស់ក្សត្រីមានព្រះសវនីយ៍, គ្មានអ្វីអាចរាំងរាមិនឱ្យខ្ញុំទទូចធ្វើតាមបំណងខ្ញុំនេះទេ? បេះដូងខ្ញុំបាននិយាយប្រាប់ខ្ញុំថា ការប៉ុនប្រសប់អាចជួយឱ្យខ្ញុំសម្រេចការតាមបំណងបាន, ហើយខ្ញុំបានសម្រេចចិត្តជាស្រេចថា នឹងយកការប៉ុនប្រសប់នេះមកប្រើ ។ ដូច្នេះ ខ្ញុំនៅពុំទាន់ស្គាល់តែផ្លូវដែលខ្ញុំត្រូវធ្វើដំណើរទៅទេ ។ គឺជាសេចក្ដីអនុគ្រោះដែលខ្ញុំត្រូវអង្វរសុំពីអ្នក សូមអ្នកមេត្តាប្រាប់ខ្ញុំកុំប្រកែក ។

អ្នកបួសក៏បានក្រើនរំលឹកព្រះអង្គម្ចាស់ក្សត្រីជាលើកក្រោយបង្អស់ សូមឱ្យព្រះនាងទ្រង់ពិគ្រោះនឹងខ្លួនឯងឱ្យមែនទែន ។ លុះអ្នកបួសសង្កេតឃើញថា គាត់ពុំអាចធ្វើឱ្យព្រះអង្គម្ចាស់ក្សត្រីផ្លាស់ប្ដូរព្រះទ័យបាន, គាត់ក៏លូកយកដុំមូលថ្វាយទៅព្រះនាងរួចពោលថា : “សូមអ្នកស្រីយកដុំមូលនេះទៅ, រួចអញ្ជើញឡើងជិះសេះចុះ ហើយកាលបើអ្នកស្រីបោះដុំមូលនេះទៅមុខអ្នកស្រី សូមអ្នកស្រីបរសេះតាមឱ្យជាប់ ដុំមូលនឹងរមៀលរហូតទៅដល់ភ្នំដែលជាកន្លែងដែលអ្នកស្រីត្រូវការរក ហើយជាកន្លែងដែលវាត្រូវឈប់ ។ កាលបើដុំនេះឈប់រមៀល

លក្ខខណ្ឌទីមួយវិញ ខ្ញុំសូមបញ្ជាក់ថា សម្រែកផ្សេងៗទាំងឡាយ ដូចដែលអ្នកបានពោលបំភ្លឺខ្ញុំនោះ អាចបន្លាចទោះបីអ្នកអង់អាចយ៉ាងណា ក៏ឱ្យទៅជាខ្លាចបានដែរ ប៉ុន្តែនៅគ្រប់ការចាប់ផ្តើមធ្វើទាំងឡាយដែលមានការលំបាកនឹងភយន្តរាយ គេឥតហាមឃាត់មិនឱ្យប្រើការប៉ិនប្រសប់ដែលខ្លួនមាននោះទេ ដូច្នេះខ្ញុំសុំសួរអ្នកថា តើក្នុងរឿងដែលខ្ញុំយល់ថាមានប្រយោជន៏នេះ, គេអាចយកការប៉ិនប្រសប់មកប្រើបានទេ?

- តើការប៉ិនប្រសប់ដូចម្តេចដែលអ្នកចង់យកមកប្រើនេះ? អ្នកបួសសួរ ។

- ខ្ញុំយល់ថា, ព្រះនាងឆ្លើយ, បើសិនជាខ្ញុំយកសំឡីចុកត្រចៀកឱ្យជិត, ត្រចៀកនោះនឹងពុំសូវមានការចាប់អារម្មណ៏ប៉ុន្មាន ទោះបីសម្រែកឮខ្លាំង ហើយគួរឱ្យព្រឺព្រួចយ៉ាងណាក៏ដោយ ។ កាលបើត្រ-ចៀកស្តាប់ពុំឮហើយ, សម្រែកនោះក៏គ្មានអានុភាពមកលើមនោគតិខ្ញុំប៉ុន្មានដែរ ខួរក្បាលខ្ញុំនឹងបានស្ថិតនៅជាសេរី ប្រយោជន៏កុំឱ្យវង្វេងវង្វាន់ស្មារតីលុះត្រាបាត់ការប្រើវិចារណញ្ញាណនេះ ។

- អ្នកស្រី, អ្នកបួសឆ្លើយ, ចាប់តាំងពីដើមរហូតមកទល់ឥឡូវនេះ មានជនជាច្រើនបានសួរមកខ្ញុំដើម្បីចង់ដឹងផ្លូវដែលអ្នកស្រីបានសួរខ្ញុំនេះ, ប៉ុន្តែខ្ញុំពុំបានដឹងថា តើមានជនណាមួយបានប្រើការប៉ិនប្រសប់ ដែលអ្នកស្រីបាននិយាយប្រាប់ខ្ញុំនោះទេ ការដែលខ្ញុំដឹង គឺថា

ទាំងអស់ ។ គឺជាសម្លេងស្រែកជេរប្រទេចផ្ដាសាលោកម្ចាស់ឱ្យលោកម្ចាស់នឿយណាយធុញទ្រាន់ ខូចទឹកចិត្ត កុំឱ្យលោកម្ចាស់ឡើងទៅដល់លើកំពូលភ្នំបាន ។ ប៉ុន្តែសូមលោកម្ចាស់ប្រយ័ត្នឱ្យមែនទែន កុំខ្លាចឱ្យសោះហើយជាពិសេសគឺកុំងាកបែរមើលក្រោយ ។ បើសិនជាលោកម្ចាស់ងាកបែរមើលក្រោយ. នោះលោកម្ចាស់នឹងក្លាយទៅជាថ្មខ្មៅមួយរំពេច ដូចជាពួកសេដ្ឋីឬអភិជនឯទៀត ដែលលោកម្ចាស់បានឃើញនោះ ព្រោះដុំថ្មខ្មៅទាំងនោះជាពួកអភិជនដូចជាលោកម្ចាស់ដែរ ដែលប្រតិបត្តិការណ៍ពុំបានសម្រេចដូចបំណង ដូចខ្ញុំបាននិយាយជម្រាបលោកម្ចាស់រួចមកហើយ ។ បើសិនជាលោកម្ចាស់អាចជៀសគ្រោះថ្នាក់ ដែលខ្ញុំគ្រាន់តែបាននិយាយជម្រាបសើ១ប៉ុណ្ណេះបាន ដើម្បីឱ្យលោកម្ចាស់ទ្រង់ពិចារណាមើល ។ កាលបើលោកម្ចាស់បានឡើងទៅដល់លើកំពូលភ្នំ លោកម្ចាស់នឹងបានឃើញទ្រុងមួយនៅទីនោះ គឺនៅក្នុងទ្រុងនោះហើយ ដែលគេដាក់បក្សាចេះនិយាយ ។ ដោយហេតុថា សត្វបក្សានោះចេះនិយាយ សូមលោកម្ចាស់សួរវាទៅ អំពីទឹកន្លែងដើមឈើចេះច្រៀង និងទឹកពណ៌លឿង. វានឹងប្រាប់លោកម្ចាស់ពុំខានខ្ញុំគ្មានអ្វីនឹងជម្រាបលោកម្ចាស់ក្រៅពីនេះទៀតទេ។ នេះហើយជាកិច្ចដែលលោកម្ចាស់ត្រូវធ្វើ និងនេះហើយជាការដែលលោកម្ចាស់ត្រូវជៀសវាង ។ ប៉ុន្តែបើសិនជាលោកម្ចាស់ជឿតាមខ្ញុំ ហើយធ្វើតាមដំបូន្មានខ្ញុំនេះ. នោះលោកម្ចាស់ឥតបារម្ភនឹងក្ស័យជីវិតឡើយ។ ដូច្នេះ

ហើយ. សូមអ្នកស្រីឈប់នៅត្រង់នោះដែរ អញ្ជើញចុះពីសេះភ្លាម. រួចអញ្ជើញឡើងទៅលើភ្នំទៅ ។ ដូច្នេះ សូមអ្នកស្រីអញ្ជើញចុះ អ្នកស្រីនឹងបានជ្រាបការតទៅទៀត. តែសូមកុំភ្លេចទាញយកប្រយោជន៍ពីការធ្វើដំណើរនេះឱ្យបាន" ។

ព្រះអង្គម្ចាស់ក្សត្រីប៉ារីសាដ ក្រោយពីបានមានព្រះសវនីយ៍អរគុណនឹងជម្រាបលាអ្នកបួសនោះ ក៏យាងឡើងជិះសេះ បោះដុំមូលនោះទៅមុខ រួចទ្រង់បរសេះតាមផ្លូវដែលដុំមូលបានរមៀល ។ ដុំមូលនោះចេះតែរមៀលឥតឈប់ ។ លុះដល់ទីបំផុត, ដុំមូលនោះក៏បានទៅឈប់នៅជើងភ្នំ ។ ព្រះអង្គម្ចាស់បានយាងចុះពីខ្នងសេះ, ទ្រង់យកសំឡីចុកព្រះកាណ៌ រួចក៏យាងឡើងមួយៗ តាមផ្លូវទៅតាមកំពូលភ្នំដោយសេចក្ដីអង់អាច ។ ព្រះនាងក៏បានឮសូរសម្រែក ប៉ុន្តែ សំឡីអាចធ្វើជាជំនួយដល់ព្រះនាងយ៉ាងសំខាន់ ។ ហើយដរាបណាព្រះនាងបានយាងទៅមុខបន្តិច ដរាបនោះសម្រែកក៏កាន់តែឮខ្លាំង ប៉ុន្តែមិនមែនដល់ទៅជាកើតការរំភើបបណ្ដាលឱ្យព្រះនាងឡប់ស្មារតីនោះទេ។ ព្រះនាងបានទ្រង់ព្រះសណ្ដាប់សម្រែកជេរជាច្រើនយ៉ាង និងការសើចចំអកផ្សេងៗ គួរឱ្យឈឺចាប់ណាស់ ចំពោះភេទជាស្ត្រីដូចព្រះនាងនោះ ប៉ុន្តែព្រះនាងឥតមានញញើតបន្តិច ទ្រង់បែរជាមានព្រះសម្រួល ហើយមានសវនីយ៍តែម្នាក់ឯងថា : "ខ្ញុំឥតខឹងនឹងពាក្យជេរប្រទេចឬពាក្យចំអកឡកឡឺយរបស់អ្នកនេះទេ ។ ចូរអ្នកនិយាយឱ្យអាក្រក់ជាងនេះទៅ

ទៀតទៅ ខ្ញុំក៏ឥតឈឺក្បាលអ្វីឡើយ ហើយអ្នកមិនអាចរាំងរាខ្ញុំមិនឱ្យធ្វើដំណើរតទៅមុខបានទៀតទេ" ។ នៅទីបំផុត, ព្រះនាងក៏ទ្រង់បានយាងឡើងទៅដល់ទីខ្ពស់ ហើយបានឃើញទ្រុងនិងបក្សា ។ ឯបក្សានោះដោយចូលរួមគំនិតនិងសម្រែកបានខំស្រែកសម្លុតព្រះនាងឮសូរសម្លេងលាន់រំពង ទោះបីមានមាឌតូចដូច្នោះក៏ដោយ ។ បក្សានោះស្រែកឱ្យព្រះនាងថា : "ប៉ៃស្រីឆ្កួត, ថយចេញឱ្យឆាប់ កុំចូលមកជិតឱ្យសោះ !" ។

ព្រះអង្គម្ចាស់ក្សត្រីសប្បាយព្រះទ័យនឹងឃើញវត្ថុនោះ ក៏បោះជំហានយ៉ាងវែងៗ ។ នៅពេលដែលព្រះនាងបានយាងជិតទៅដល់ទីបំផុតនៃបំណងហើយ, ព្រះនាងក៏បានយាងទៅដល់លើខ្នងភ្នំ ដែលមានផែនដីលាតរាបស្មើធេង ។ ព្រះនាងទ្រង់រត់យ៉ាងលឿនតម្រង់ទៅទ្រុង ហើយក៏យកព្រះហស្តដាក់ពីលើទ្រុង មានព្រះសវនីយ៍ទៅកាន់បក្សាថា : "បក្សាខ្ញុំត្រូវការមកយកឯង ហើយឯងមិនត្រូវគេចទៅណាឱ្យសោះ" ។

នៅពេលដែលព្រះអង្គម្ចាស់ក្សត្រី ទាញយកសំឡីចេញពីព្រះកាណ៌, បក្សាក៏និយាយមកកាន់ព្រះនាងថា : "អ្នកស្រីដ៏ក្លាហាន, សូមអ្នកស្រីកុំខឹងនឹងខ្ញុំឱ្យសោះ ចំពោះការដែលខ្ញុំបានចូលរួមនឹងសម្រែកឯទៀត ដែលបានស្រែកជេរអ្នកស្រីជាច្រើនក្រៃលែង ដើម្បីជួយរក្សាសេរីភាពរបស់ខ្ញុំ ។ ពិតមែនតែខ្ញុំជាប់នៅក្នុងទ្រុង, ក៏ខ្ញុំសប្បាយចិត្ត

នឹងវាសនាខ្ញុំណាស់ ប៉ុន្តែដោយខ្ញុំកើតមកសម្រាប់ធ្វើជាទាសាអ្នកណាមួយដែលមកយកទ្រុងនេះបាន។ ដូច្នេះខ្ញុំនេះជាទាសាអ្នកស្រីហើយព្រោះអ្នកស្រីបានដណ្ដើមយកខ្ញុំដោយសេចក្ដីក្លាហាន និងថ្លៃថ្នូរជាងមនុស្សឯទៀតទាំងអស់ក្នុងលោក ។ ហើយចាប់តាំងពីពេលនេះទៅ ខ្ញុំសូមសម្ដែងភក្ដីភាពដែលខ្ញុំពុំអាចប្រព្រឹត្តល្មើសបានចំពោះអ្នកស្រី ព្រមទាំងការទទួលខ្លួនធ្វើតាមសេចក្ដីបង្គាប់របស់អ្នកស្រីទាំងអស់ ។ ខ្ញុំស្គាល់ហើយថាអ្នកស្រីជានរណា ហើយខ្ញុំនឹងជម្រាបអ្នកស្រីថា អ្នកស្រីឥតស្គាល់ខ្លួនអ្នកស្រីថាជានរណាទេ ។ ប៉ុន្តែថ្ងៃមួយខ្ញុំនឹងជម្រាបអ្នកស្រីឱ្យបានដឹង ហើយខ្ញុំសង្ឃឹមថាអ្នកស្រីនឹងដឹងគុណខ្ញុំជាច្រើនពុំខាន។ ឥឡូវនេះ ដើម្បីជាការចាប់ផ្ដើមឱ្យឃើញនូវសញ្ញាស្មោះត្រង់ ដែលខ្ញុំត្រូវមានចំពោះអ្នកស្រី សូមអ្នកស្រីប្រាប់ខ្ញុំឱ្យដឹងមក អំពីបំណងអ្នកស្រីយ៉ាងណាខ្លះ. ខ្ញុំប្រុងខ្លួនតែនឹងធ្វើជូនហើយ" ។

ព្រះអង្គម្ចាស់ក្សត្រី ពោរពេញទៅដោយសេចក្ដីសប្បាយរក ប្រៀបពុំបាន ក៏មានព្រះសវនីយ៍ទៅកាន់បក្សាថា : "បក្សា, ខ្ញុំប្រាថ្នា ចង់បានវត្ថុច្រើនណាស់ដែលសុទ្ធតែជារបស់សំខាន់ៗជាទីបំផុត ហើយ ខ្ញុំមានសេចក្ដីត្រេកអរជាពន់ពេក ដោយបានឮអ្នកសម្ដែងសុឆន្ទៈចំពោះ មកខ្ញុំ ។ បក្សា, ជាដំបូង ខ្ញុំបានដឹងថា នៅទីនេះមានទឹកពណ៌លឿង ដែលអាចមានគុណភាពយ៉ាងអស្ចារ្យ សូមអ្នកប្រាប់កន្លែងរបស់នេះឱ្យ ខ្ញុំដឹងមុនរបស់ឯទៀតទាំងអស់" ។ បក្សាក៏ប្រាប់កន្លែងរបស់នោះដល់ ព្រះនាង ដែលនៅមិនឆ្ងាយពីទីនោះប៉ុន្មាន ។ ព្រះអង្គម្ចាស់ក្សត្រីក៏ យាងទៅកាន់កន្លែងនោះ, ហើយយកដបប្រាក់តូចមួយដែលព្រះនាង បានដាក់ជាប់ទៅជាមួយ ទៅដងទឹកនោះដាក់ពេញ ។ ព្រះនាងក៏យាង ត្រឡប់មកកាន់បក្សាវិញ ហើយមានព្រះសវនីយ៍ជាថ្មីទៀតថា: "បក្សា, ប៉ុណ្ណឹងពុំទាន់គ្រប់គ្រាន់ទេ, ខ្ញុំត្រូវការរកដើមឈើចេះច្រៀងទៀត, ប្រាប់ខ្ញុំមក តើដើមឈើនោះនៅឯណា?" ។ បក្សាក៏ទូលថា : "សូម អ្នកស្រីត្រឡប់ទៅក្រោយ, អ្នកស្រីនឹងឃើញព្រៃឈើមួយ ដែលនៅ ក្នុងទីនោះមានដើមឈើចេះច្រៀង?" ដោយប្រពៃឈើឥតនៅឆ្ងាយ

ប៉ុន្មានទេ. ព្រះអង្គម្ចាស់ក្សត្រីក៏បានយាងទៅដល់ទីនោះ ហើយក៏ទ្រង់បាន ឮចម្រៀងយ៉ាងពីរោះក៏លេចចេញពីចន្លោះដើមឈើឯទៀត ជាសញ្ញាឱ្យដឹងថាគឺជាដើមឈើដែលព្រះនាងត្រូវការរក ប៉ុន្តែដើមឈើនោះធំហើយខ្ពស់ណាស់ ។ ព្រះនាងក៏ត្រឡប់មកវិញ ហើយមានព្រះសវនីយ៍ទៅកាន់បក្សាថា: "បក្សា, ខ្ញុំបានឃើញដើមឈើចេះច្រៀងហើយ, ប៉ុន្តែខ្ញុំពុំអាចដកឬយកមកបាន" ។

- អ្នកស្រីពុំចាំបាច់ដកឬសវាទេ. អ្នកស្រីគ្រាន់តែកាច់យកមែកវាតូចមួយមក ដើម្បីយកទៅដាំក្នុងសួនអ្នកស្រី ។ មែកនេះនឹងដុះចាក់ឬសភ្លាម កាលបើគេដោតវាចូលទៅក្នុងដី ហើយមិនយូរប៉ុន្មាន. អ្នកស្រីនឹងបានឃើញមែកនេះទៅជាដើមឈើមួយដើមយ៉ាងល្អដូចជាដើមឈើដែលអ្នកស្រីទើបតែនឹងបានឃើញនេះដែរ ។

កាលបើព្រះអង្គម្ចាស់ក្សត្រីបារីសាដបានរបស់ទាំងបីមុខ ដូចដែលស្រីអ្នកកាន់សាសនាអ៊ិស្លាមបាននិយាយទូលព្រះនាង ហើយធ្វើឱ្យព្រះនាងកើតព្រះទ័យចង់បានជាពន់ប្រមាណមកកាន់នៅនឹងព្រះហស្ថហើយ. ព្រះនាងក៏មានសវនីយ៍ទៅកាន់បក្សាទៀតថា : "បក្សា. ការដែលអ្នកបានបំពេញបំណងខ្ញុំទាំងប៉ុន្មាននេះ ពុំទាន់គ្រប់គ្រាន់ទេ. អ្នកនេះជាដើមហេតុនៃមរណភាពនៃបងប្រុសខ្ញុំពីរនាក់. ដែលក្លាយទៅជាថ្មខ្មៅទាំងឡាយ ដែលខ្ញុំបានឃើញកាលពេលខ្ញុំឡើងមក ។ ខ្ញុំប្រាថ្នាចង់បានគាត់ត្រឡប់ទៅស្រុកវិញជាមួយនឹងខ្ញុំ" ។

នៅពេលនោះ គេសង្កេតឃើញបក្សាហាក់ដូចជាមិនចង់បំពេញកិច្ចជូនព្រះនាងតាមបំណង ។ វាធ្វើហាក់ដូចជាច្រិមច្រុម ទើបព្រះនាងទ្រង់សួរបញ្ជាក់បន្ថែមថា : "បក្សា. ឯងនឹកឃើញទេថា ឯងទើបនឹងនិយាយប្រាប់ខ្ញុំថា ឯងជាទាសាខ្ញុំ. ដូច្នេះឯងប្រាកដជាទាសាខ្ញុំហើយៗជីវិតឯងក៏នៅក្នុងអំណាចខ្ញុំដែរ" ។

- ខ្ញុំមិនអាចប្រកែកនឹងការពិតនោះទេ. បក្សាឆ្លើយ ទោះបីការដែលលោកស្រីសុំឱ្យខ្ញុំធ្វើជាការមានឧបសគ្គធំសម្បើមណាស់ក៏ដោយ ក៏ខ្ញុំត្រូវតែធ្វើបំពេញចិត្តអ្នកស្រីឱ្យបានដែរ ។ សូមអ្នកស្រីក្រឡេកមើលជុំវិញទីនេះ ក្រែងអ្នកស្រីបានប្រទះឃើញក្អមទឹកមួយ ។

- ព្រះនាងក៏ឆ្លើយថា ខ្ញុំឃើញក្អមមួយហើយ ។

- សូមអ្នកស្រីយកក្អមនោះមក. បក្សាពោលបន្ថែម ហើយនៅពេលចុះពីខ្នងភ្នំនេះទៅ សូមអ្នកស្រីយកក្អមដែលមានទឹកពេញនេះ ប្រួចទៅលើគ្រប់ថ្មខ្មៅទាំងអស់. គឺជាមធ្យោបាយសម្លាប់រកបងប្រុសអ្នកស្រីទាំងពីរឱ្យបានឃើញដូចចិត្ត ។

ព្រះអង្គម្ចាស់ក្សត្រីប៉ារីសាដក៏យកក្អមទឹក. ទ្រុងនិងបក្សា. ដបទឹកព្រមទាំងដើមឈើយាងចុះមក ។ លុះយាងមកដល់ក្រោម. ព្រះនាងក៏យកក្អមទឹកនោះ ទៅចាក់លើគ្រប់ថ្មខ្មៅទាំងអស់ដែលព្រះនាងបានឃើញ ហើយថ្មខ្មៅនីមួយៗ ក៏បានប្រែក្លាយទៅជាមនុស្សម្នាក់ៗដែរ ។ ដោយព្រះនាងឥតមានភ្លេចស្រោចទឹកលើថ្មណាមួយ

សោះឡើយ សេះទាំងឡាយ, ព្រះអង្គម្ចាស់ព្រះរៀមទាំងពីរ និងពួកសេដ្ឋីអភិជនឯទៀតក៏បានរស់ឡើងទាំងអស់ ហើយព្រះនាងក៏បានស្គាល់ព្រះអង្គម្ចាស់បាម៉ាននឹងព្រះអង្គម្ចាស់ប៉ែរិស ។ ព្រះអង្គម្ចាស់ទាំងពីរ ក៏បានស្គាល់ព្រះនាងដែរ ហើយយាងចុះមកឱបព្រះនាងសម្ដែងសេចក្ដីនឹករលឹក ។ ព្រះនាងក៏មានសវនីយ៍សួរថា : "ម្ចាស់ព្រះរៀមជាទិស្នេហា, តើព្រះអង្គធ្វើអ្វីនៅទីនេះ?" ។ ដោយព្រះអង្គម្ចាស់ទាំងពីរបានឆ្លើយថា ព្រះអង្គទើបតែនឹងតើនពីផ្ទំ ព្រះនាងក៏មានសវ-នីយ៍ឆ្លើយកាត់ឡើងភ្លាមថា : "ចាំ មែនហើយ, តែបើកុំបានម្ចាស់អូនមកជួយយកអាសាទេ ម្ល៉ោះសមម្ចាស់បងប្រហែលពុំទាន់អស់ងុយទេនៅតែផ្ទំទៅទៀតរហូតដល់ថ្ងៃគេជំនុំជម្រះខ្លួន ។ ម្ចាស់ព្រះរៀមឥតទ្រង់បាននឹកឃើញទេឬថា ម្ចាស់ព្រះរៀមយាងមកទីនេះដើម្បីរកបក្សាចេះនិយាយ, ដើមឈើចេះច្រៀងនិងទឹកពណ៌លឿង ហើយលុះយាងមកដល់ទីនេះ ម្ចាស់ព្រះរៀមក៏បានឃើញថ្មខ្មៅជាច្រើនមែនឬទេ? ឥឡូវសូមម្ចាស់ព្រះរៀមក្រឡេកមើល តើមាននៅសល់មួយទេ ។ អស់លោកទាំងឡាយដែលឈរជុំវិញយើងនេះ ពីមុនគឺជាដុំថ្មខ្មៅទាំងនោះ ។ មិនតែប៉ុណ្ណោះសោះ ម្ចាស់ព្រះរៀមដែលបានក្លាយទៅជាថ្មខ្មៅដែរនោះ ឥឡូវបានប្រែជាតិកំណើតមកវិញអស់ហើយ ។ ហេតុនេះបើសិនជាម្ចាស់ព្រះរៀមត្រូវការចង់ជ្រាបថា តើការអស្ចារ្យនោះយ៉ាងណាទៅ នោះម្ចាស់អូនសូមទូលថា គឺដោយសារគុណធម៌នៃទឹកនៅ

ក្នុងក្អមនេះ ដែលខ្ញុំបានយកទៅច្រូចលើថ្មនីមួយៗ ទើបកើតការអស្ចារ្យនេះឡើង ។ ក្អមទឹកនោះម្ចាស់ក្សត្រីបានដាក់ចោលនៅជើងភ្នំ ព្រោះអស់ត្រូវការយកមកប្រើធ្វើអ្វីទៀតហើយ ។ ក្រោយពីបានដណ្ដើមយកបក្សា ដែលម្ចាស់ព្រះរៀមទតឃើញនៅក្នុងទ្រុងនេះ. មកធ្វើជាទាសាកាលណា. ម្ចាស់អូនក៏រកឃើញដើមឈើចេះច្រៀង និងទឹកពណ៌លឿងទៀត ដែលម្ចាស់អូនកាន់នេះ តែម្ចាស់អូនពុំអាចដាច់ចិត្តត្រឡប់ទៅស្រុកវិញ ដោយឥតបាននាំព្រះរៀមទៅជាមួយផង. ទើបម្ចាស់អូនប្រើអំណាចដែលម្ចាស់អូនត្រូវមានទៅលើបក្សានេះ ឱ្យបក្សាប្រាប់មធ្យោបាយ ។ បក្សាក៏បានប្រាប់ម្ចាស់អូនអំពីកន្លែងក្អមទឹក និងអំពីការប្រើប្រាស់ទឹកក្អមនេះ" ។

ព្រះអង្គម្ចាស់បាម៉ាននិងប៉ែរិស កាលបើទ្រង់បានព្រះសណ្ដាប់ព្រះសវនីយ៍ព្រះនាងដូច្នេះហើយ. ក៏ទ្រង់យល់ថា ព្រះអង្គត្រូវជំពាក់គុណព្រះនាងច្រើនណាស់ ។ ចំណែកពួកសេដ្ឋីគហបតីទាំងឡាយ ដែលឈរកកកុញនៅជុំវិញទីនោះ ហើយដែលបានស្ដាប់ឮព្រះរាជសាសន៍ព្រះអង្គម្ចាស់ក្សត្រីដូច្នោះ ក៏បានសម្ដែងអំណរគុណនឹងសេចក្ដីដឹងគុណជាច្រើនបំផុតដល់ព្រះនាង ដែលបានជួយស្រោចស្រង់ខ្លួនឱ្យមានជីវិតរស់ជាមនុស្សឡើងវិញ ដោយប្រកាសខ្លួនទាំងអស់គ្នាធ្វើជាទាសាព្រះនាង ហើយប្រុងខ្លួនតែនឹងធ្វើតាមបង្គាប់ព្រះនាង ឥតមានចិត្តនឹកច្រណែននឹងព្រះនាងដែលដណ្ដើមយកបានរបស់ដែលខ្លួនប្រាថ្នាចង់បានដែរនោះទេ ។

ព្រះអង្គម្ចាស់ក្សត្រីក៏មានព្រះសវនីយ៍ជាថ្មីឡើងទៀតថា: "អស់លោកទាំងឡាយ, បើសិនជាអស់លោកបានយកចិត្តទុកដាក់ស្តាប់ខ្ញុំ, នោះអស់លោកអាចសង្កេតឃើញថា ខ្ញុំគ្មានបំណងអ្វីដទៃក្រៅអំពីរកបងខ្ញុំឱ្យឃើញនេះទេ, ដូច្នេះ បើសិនជាការនេះមានអត្ថប្រយោជន៍ទៅលើអស់លោកដែរ, អស់លោកក៏ឥតត្រូវជំពាក់គុណខ្ញុំដែរ តែខ្ញុំសូមទទួលយ៉ាងរីករាយនូវសេចក្តីស្មោះត្រង់ ដែលអស់លោកប្រុងនឹងសម្តែងឱ្យឃើញជាក់ច្បាស់ ចំពោះរូបខ្ញុំ ហើយខ្ញុំសូមអរគុណនឹងអស់លោកវិញដែរ ។ មួយចំណែកទៀត, ខ្ញុំយល់ថា ឥឡូវនេះអស់លោកទាំងអស់បានត្រឡប់មកជាមនុស្សសេរី ចាកផុតពីក្តីអភ័ព្វហើយៗ ខ្ញុំក៏សុំចូលរួមសប្បាយជាមួយសុភមង្គលអស់លោក ដែលកើតមានក្នុងពេលជួនគ្នាជាមួយនឹងខ្ញុំនេះ។ ប៉ុន្តែ យើងមិនត្រូវនៅកន្លែងនេះតទៅទៀត ដែលជាកន្លែងគ្មានអ្វីត្រូវការឱ្យយើងឈប់នៅយូរទៀតសោះ។ សូមយើងឡើងជិះសេះត្រឡប់ទៅនគររៀងៗខ្លួនវិញ" ។

ដើម្បីជាគំរូ ព្រះអង្គម្ចាស់ក្សត្រីបានយាងមុនគេទៅ យកសេះនៅកន្លែងដែលព្រះនាងបានលែងចោល ។ មុននឹងព្រះនាងឡើងគង់សេះ, ព្រះអង្គម្ចាស់បាម៉ាន ដោយចង់ជួយសម្រាលព្រះនាង, បានអង្វរព្រះនាងសូមឱ្យព្រះអង្គជួយកាន់ទ្រុងសត្វ ។ ព្រះអង្គម្ចាស់ក្សត្រីក៏មានសវនីយ៍ថា : "ម្ចាស់ព្រះរៀម, បក្សានេះជាទាសាខ្ញុំ, ខ្ញុំចង់កាន់ខ្លួនខ្ញុំផ្ទាល់, ប៉ុន្តែបើព្រះរៀមចង់កាន់មែកឈើនៃដើមឈើចេះច្រៀង,

សូមព្រះរៀមអញ្ជើញយកទៅ ។ ប៉ុន្តែសូមព្រះរៀមជួយកាន់ទ្រុងសត្វខ្ញុំបន្តិច, ហើយឱ្យទៅខ្ញុំវិញ នៅពេលខ្ញុំបានឡើងជិះសេះស្រួលបួល" ។ កាលបើព្រះនាងបានឡើងគង់សេះស្រួលបួលហើយៗ ព្រះអង្គម្ចាស់ព្រះរៀមក៏បានថ្វាយទ្រុងសត្វនោះទៅ ព្រះនាងក៏ទ្រង់ងាកតម្រង់ទៅទិស ដែលព្រះអង្គម្ចាស់ប៉ែរិសកំពុងគង់ ហើយមានសវនីយ៍ថា: "ម្ចាស់ព្រះរៀមប៉ែរិស, នេះដបដាក់ទឹកពណ៌លឿង ខ្ញុំសូមថ្វាយទុកនឹងព្រះរៀមបើព្រះរៀមមិនមានការលំបាកទេ" ។ ព្រះអង្គម្ចាស់ប៉ែរិសក៏ទទួលយកដបទឹកដោយព្រះទ័យរីករាយ ។

កាលបើព្រះអង្គម្ចាស់បាម៉ាន ព្រះអង្គម្ចាស់ប៉ែរិសមួយអន្លើដោយពួកសេដ្ឋីគហបតី បានឡើងគង់និងជិះសេះគ្រប់គ្នាអស់ហើយ, ព្រះអង្គម្ចាស់ក្សត្រីបង្គង់ចាំឱ្យនរណាម្នាក់បរសេះនាំផ្លូវចេញទៅមុខគេ ។ ព្រះអង្គម្ចាស់ទាំងពីរ ចង់ទុកកិត្តិយសនេះជូនដល់ពួកសេដ្ឋី, ឯពួកសេដ្ឋីវិញក៏ចង់ថ្វាយកិត្តិយសនេះចំពោះព្រះនាង ។ លុះព្រះនាងសង្កេតឃើញថា គ្មានជនណាមួយព្រមបរសេះទៅមុខគេសោះ ព្រោះចង់ទុកកិត្តិយសថ្វាយព្រះនាង, ទើបព្រះនាងមានព្រះសវនីយ៍ទៅកាន់អស់លោកទាំងអស់ថា : "អស់លោកទាំងឡាយ, ខ្ញុំចាំឱ្យអស់លោកទាំងឡាយទៅមុន" ។ ជនម្នាក់ដែលនៅក្បែរព្រះនាងជាងគេក៏ឆ្លើយតាងនាមមិត្តខ្លួនទាំងអស់ថា : "អ្នកស្រី, បន្ទាប់ពីយើងខ្ញុំបានដឹងថាយើងខ្ញុំត្រូវជំពាក់គុណអ្នកស្រីច្រើនណាស់នោះៗ គ្មានកិត្តិយសឯណា

ដែលយើងត្រូវធ្វើចំពោះអ្នកស្រីក្រៅពីពេលនេះទេ. ថ្វីបើអ្នកស្រីមិនព្រមឱ្យធ្វើ យើងខ្ញុំអង្វរអ្នកស្រីសុំដើរដង្ហែតាមក្រោយអ្នកស្រីដែរ" ។

ព្រះអង្គម្ចាស់ក្សត្រីក៏មានសវនីយ៍ថា: "អស់លោកជាទីគោរព. ខ្ញុំមិនសមនឹងទទួលកិត្តិយសដែលអស់លោកបម្រុងនឹងធ្វើចំពោះរូបខ្ញុំនេះទេ. ហើយបើសិនជាខ្ញុំព្រមទទួល ក៏ព្រោះតែអស់លោកប្រាថ្នាឱ្យខ្ញុំទទួលដែរ ។ នៅពេលនោះ. ព្រះនាងក៏បរសេះយាងចេញទៅមុនគេ. ហើយព្រះអង្គម្ចាស់និងអស់លោកឯទៀត ក៏បរសេះតាមក្រោយជាមួយគ្នាឥតគិតប្រកាន់ពីឋានៈអ្វីឡើយ ។ នៅពេលយាងត្រឡប់មកវិញនោះ. ព្រះអង្គម្ចាស់. ព្រះអង្គម្ចាស់ក្សត្រី. អស់លោកទាំងអស់បម្រុងចូលទៅជួបអ្នកបួស ដើម្បីសម្តែងអំណរគុណដល់គាត់ ចំពោះបដិសណ្ឋារកិច្ចដ៏ប្រសើរដែលគាត់បានធ្វើដល់បរជនទាំងឡាយ នឹងចំពោះដំបូន្មានរបស់គាត់ដែលអាចជួយស្រោចស្រង់ជីវិតខ្លួនបាន បើសិនជាខ្លួនព្រមជឿហើយគោរពប្រតិបត្តិធ្វើតាម ប៉ុន្តែគាត់ទទួលអនិច្ចកម្មបាត់ទៅហើយ ហើយគេពុំអាចដឹងបានថា តើគាត់ស្លាប់ដោយជរាភាព ឬក៏គាត់ស្លាប់ពីព្រោះតែគាត់អស់ត្រូវការនឹងនៅចាំបង្ហាញផ្លូវដល់ជនឯទៀត ដែលត្រូវការទៅដណ្តើមយកវត្ថុបីយ៉ាង ដែលព្រះអង្គម្ចាស់ក្សត្រីប៉ារីសាដទើបតែនឹងមានជ័យជំនះ ។

ដូច្នេះ អ្នកដំណើរទាំងឡាយក៏ធ្វើដំណើរតទៅទៀត ប៉ុន្តែចេះតែរលោះគ្នាមួយថ្ងៃបន្តិចៗ ដោយមកពីពួកសេដ្ឋីឬអភិជនទាំងឡាយ

ដែលបានអញ្ជើញមកពីប្រទេសនានា កាលបើធ្វើដំណើរមកដល់ផ្លូវទៅកាន់ប្រទេសខ្លួន ក៏ថ្វាយបង្គំលាព្រះអង្គម្ចាស់ក្សត្រីនឹងព្រះអង្គម្ចាស់ទាំងពីរជាបន្តបន្ទាប់គ្នា ។ ព្រះអង្គម្ចាស់ក្សត្រី, ព្រះអង្គម្ចាស់បាម៉ាននឹងព្រះអង្គម្ចាស់ប៉ែវិស ទ្រង់បានខំធ្វើដំណើរតាមផ្លូវតម្រង់មកគេហស្ថានព្រះអង្គ លុះត្រាបានដល់ដោយសុវត្ថិភាព ។

ដំបូងបង្អស់ ព្រះអង្គម្ចាស់ក្សត្រីបានដាក់ទ្រុងបក្សានោះនៅក្នុងបន្ទប់ទទួលភ្ញៀវ ដែលយើងបានពោលរួចមកហើយ ។ ដោយហេតុថា, បន្ទប់ទទួលភ្ញៀវបែរមុខទៅទិសសួនច្បារ, កាលបើបក្សានោះស្រែកយំឡើងសត្វឯទៀតដូចជាចាប, ក្រួចអ៊ឹត, ពពេច, ដូនតា, ល្វាចេក, ហើយនិងសត្វដទៃទៀតច្រើនរាប់ពុំអស់ បានហើរមកទំយំបន្ទរតាមសម្លេងបក្សាចេះនិយាយ ។ ចំណែកឯមែកឈើវិញ, ព្រះនាងបានឱ្យគេយកទៅដាំនៅចំពោះព្រះភក្ត្រព្រះនាង នៅក្នុងកន្លែងសួនច្បារសម្រាប់ដាំផ្កាឆ្ងាយពីផ្ទះបន្តិច ។ មែកឈើនោះបានដុះចាក់ឫសហើយមិនយូប៉ុន្មានក៏ទៅជាដើមឈើមួយធំ, ដែលមានស្លឹកចេះច្រៀងនិងប្រគុំកើតជាតន្ត្រីយ៉ាងពិរោះ ដូចជាដើមឈើដែលព្រះនាងបានកាច់មែកយកមកនេះដែរ ។ ចំពោះទឹកពណ៌លឿង, ព្រះនាងបានឱ្យគេរៀបធ្វើអាងមួយនៅកណ្តាលសួនបុប្ផា, កាលបើអាងនោះធ្វើហើយស្រេចព្រះនាងក៏យកទឹកនោះទាំងអស់ចាក់ចូលទៅ ។ មួយរំពេចនោះទឹកក៏រីកទំហំឡើង ។ លុះឡើងមកដល់ជិតមាត់អាងស្រាប់តែលេចជា

កណ្ដាប់ស្រូវមួយ យ៉ាងធំចេញពីចំពាក់កណ្ដាលអាងកម្ពស់ប្រហែល ម្ភៃជំហាន (០,៣២៤៨ម) ហើយហូរធ្លាក់ចុះមកវិញជានិច្ច ឥតធ្វើឱ្យទឹកអាងនោះហៀរចេញបន្តិចបានឡើយ ។

ដំណឹងនៃវត្ថុអស្ចារ្យនេះបានលេចឮរន្ទឺទៅដល់ទីជិតខាង ហើយដោយហេតុថា ទ្វារផ្ទះក៏ដូចជាទ្វារសួនតែងបើកចំហជានិច្ច, មិនយូរប៉ុន្មានប្រជាជនជាច្រើនកកកុញនៅជិតខាងបានចូលមកមើលត្រេបត្រា ។ ចំនួនពីរបីថ្ងៃកន្លងមក ព្រះអង្គម្ចាស់បាម៉ាននឹងប៉ែរិស កាលបើព្រះកាយពលស្រួលបួលហើយ, ក៏ចាប់ប្រកបរបររស់នៅតទៅទៀត។ ហើយដោយការបរបាញ់សត្វជាការកំសាន្តធម្មតារបស់ព្រះអង្គម្ចាស់, ព្រះអង្គម្ចាស់ក៏ឡើងគង់សេះ រួចក៏យាងចេញទៅបរបាញ់ជាលើកដំបូងបង្អស់ បន្ទាប់ពីពេលទ្រង់បានយាងត្រឡប់មកពីធ្វើដំណើរផ្សងព្រេងវិញ នៅទីដទៃក្រៅពីទីក្រោលសត្វដែលបិតាចិញ្ចឹមបានធ្វើទុកថ្វាយចម្ងាយប្រហែលពីរបីលីយើ (១លីយើ=៤គ.ម.) ពីគេហស្ថានព្រះអង្គ។ នៅពេលដែលព្រះអង្គម្ចាស់កំពុងតែដេញបាញ់ម្រឹគីម្រិគានោះ, ស្រាប់តែលេចព្រះបាទស៊ុលតង់យាងតម្រង់មកទីនោះ កំពុងតែដេញបាញ់សត្វដែរ។ កាលបើព្រះអង្គម្ចាស់ទាំងពីរទតឃើញថា ព្រះបាទស៊ុលតង់នឹងយាងមកដល់ឆាប់ៗ ព្រោះមានពួកទាហានសេះជាច្រើនបានលេចចេញមកពីគ្រប់ទិស ព្រះអង្គក៏ឈប់បាញ់ ហើយយាងថយចេញពីទីនេះ, ដើម្បីកុំឱ្យជួបព្រះរាជា។ ប៉ុន្តែនៅចំតាមផ្លូវដែលព្រះអង្គម្ចាស់

យាងថយចេញនោះ ព្រះអង្គម្ចាស់ក៏បានជួបនឹងព្រះបាទស៊ុលតង់ ត្រង់កន្លែងមួយយ៉ាងចង្អៀតរកតែគេចថយក្រោយកុំឱ្យព្រះអង្គទតឃើញពុំបាន ។ នៅក្នុងខណៈភ្ញាក់ភាន់ភាំងនោះ ព្រះអង្គម្ចាស់ទាំងពីរមានពេលគ្រប់គ្រាន់តែយាងចុះពីខ្នងសេះ ហើយអោនលុតជង្គង់នៅមុខព្រះបាទស៊ុលតង់. ព្រះនលាដ៏ទៀបទៅនឹងដីគ្មានងើបព្រះសិរសាមើលព្រះអង្គឡើយ ។ ប៉ុន្តែព្រះបាទស៊ុលតង់ទ្រង់សង្កេតឃើញព្រះអង្គម្ចាស់គង់សេះយ៉ាងសម. ស្លៀកពាក់យ៉ាងស្អាតបាក់ ដូចជាជនជាប់ព្រះញាតិវង្សនឹងព្រះរាជវាំង. ក៏ចង់ទតព្រះភក្ត្រព្រះអង្គទាំងពីរ ទើបព្រះអង្គទាញសេះឱ្យឈប់ហើយមានព្រះរាជឱង្ការឱ្យព្រះអង្គម្ចាស់ងើបព្រះភក្ត្រឡើង ។

ព្រះអង្គម្ចាស់ទាំងពីរក៏ទ្រង់ងើបឡើង ហើយគង់ឈរនៅមុខព្រះបាទស៊ុលតង់ ប្រកបដោយទឹកមុខស្រឡះស្រស់ស្រាយនិងឫកពាសុភាពរាបសា ។ ព្រះបាទស៊ុលតង់ទ្រង់សម្លឹងមើលព្រះអង្គម្ចាស់មួយសន្ទុះចាប់តាំងពីព្រះសិរសារហូតដល់ចុងព្រះបាទ ឥតមានព្រះបន្ទូលថាដូចម្ដេចឡើយ ។ បន្ទាប់ពីព្រះអង្គបាននឹកស្ងើចសរសើរអាការៈនិងទឹកព្រះភក្ត្រជាទីរីករាយ នៃព្រះអង្គម្ចាស់ហើយ ព្រះអង្គក៏ទ្រង់ត្រាស់សួរថា តើព្រះអង្គម្ចាស់ទាំងពីរជានរណាហើយនៅឯណា? ។

ព្រះអង្គម្ចាស់បាម៉ានក៏មានព្រះបន្ទូលឡើងថា : "បពិត្រលម្អធូលីព្រះបាទ ទូលព្រះបង្គំយើងខ្ញុំជាបុត្រនាយតម្រួតសួនរបស់ព្រះរាជា

ដែលឥឡូវគាត់ស្លាប់បាត់ទៅហើយ ហើយសព្វថ្ងៃទូលព្រះបង្គំយើងខ្ញុំនៅក្នុងផ្ទះដែលគាត់បានសង់ទុកឱ្យមុនពេលគាត់ស្លាប់បន្តិច ប្រយោជន៍ឱ្យទូលព្រះបង្គំយើងខ្ញុំបានជ្រកនៅបណ្ដោះអាសន្នសិន ទម្រាំទូលព្រះបង្គំយើងខ្ញុំមានវ័យគ្រប់ការល្មមបម្រើព្រះអង្គបាន ហើយនឹងបានចូលសុំការព្រះអង្គធ្វើដើម្បីនឹងចិញ្ចឹមជីវិត កាលបើឱកាសល្អបានផ្ដល់ឱ្យ។

- តាមដែលយើងបានឃើញ ព្រះបាទស៊ុលតង់មានព្រះបន្ទូល, គឺអ្នកទាំងពីរចូលចិត្តបរបាញ់សត្វមែនទេ? ។

- បពិត្រព្រះករុណាថ្លៃវិសេសព្រះអង្គម្ចាស់បាម៉ានមានបន្ទូលគឺជាមុខរបរចម្បងតារបស់ទូលព្រះបង្គំ ដូចជាមុខរបរនៃជននៅក្រោមអំណាចព្រះអង្គដែលបានស្ម័គ្រចិត្តចូលកាន់អាវុធនៅក្នុងកងទ័ពព្រះអង្គ ហើយមិនត្រូវធ្វេសប្រហែសនឹងករណីយកិច្ចខ្លួនដូច្នោះដែរ ដើម្បីឱ្យស្របទៅតាមទម្លាប់បុរាណ ក្នុងព្រះរាជអាណាចក្រនេះ" ។ ព្រះបាទស៊ុលតង់ទ្រង់ស្ងប់ស្ងែងនឹងចម្លើយប្រកបដោយគតិបណ្ឌិតនេះ ក៏មានព្រះរាជឱង្ការទៅកាន់ព្រះអង្គម្ចាស់ទាំងពីរថា : "ព្រោះការបរបាញ់នេះជាមុខរបរចម្បងតារបស់អ្នកហើយ ខ្ញុំសប្បាយចិត្តនឹងចង់ឃើញអ្នកបាញ់ណាស់ ដូច្នេះចូរអ្នកមកជាមួយខ្ញុំ យើងបើកឱ្យអ្នករើសតាមចិត្តអ្នកស្ម័គ្រ តើអ្នកចូលចិត្តបាញ់សត្វអ្វីជាងគេ" ។

ព្រះអង្គម្ចាស់ក៏យាងឡើងគង់សេះ, បរតាមព្រះបាទស៊ុលតង់។ លុះបរសេះចេញទៅមិនបានឆ្ងាយប៉ុន្មាន ព្រះអង្គម្ចាស់ក៏ស្រាប់តែ

ឃើញសត្វជាច្រើនតែម្តង ។ ព្រះអង្គម្ចាស់បាម៉ានក៏រើសយកសិង្ហ, ព្រះអង្គម្ចាស់ប៉ៃរិសខ្លាឃ្មុំ ។ រួចក៏បំផាយសេះចេញទៅភ្លែតដំណាល គ្នាដោយសេចក្តីអង់អាច ធ្វើឱ្យព្រះបាទស៊ុលតង់ភ្ញាក់ជាខ្លាំង ។ ព្រះអង្គម្ចាស់បានដេញតាមសត្វរៀងៗព្រះអង្គ ហើយក៏បានចោលលំពែង យ៉ាងត្រង់បំផុតទៅត្រូវមុតជាប់នឹងខ្លួនសត្វទាំងនោះ ។ ព្រះអង្គម្ចាស់បាម៉ានចោលត្រូវសិង្ហព្រះអង្គម្ចាស់ប៉ៃរិសត្រូវខ្លាឃ្មុំ ហើយក្រោយបន្តិចមកព្រះបាទស៊ុលតង់ក៏ទ្រង់ទតឃើញសត្វនោះដួលមួយម្តងៗ បោលទៅមុខលែងរួច។ គ្មានទ្រង់ឈប់នៅស្ងៀម, ព្រះអង្គម្ចាស់បាម៉ាន ក៏ដេញតាមខ្លាឃ្មុំមួយទៀត, ព្រះអង្គម្ចាស់ប៉ៃរិសក៏ដេញតាមសិង្ហ មួយទៀតដែរ, ហើយមិនយូរប៉ុន្មានព្រះអង្គម្ចាស់ក៏បានចោលលំពែង ត្រូវសត្វនោះស្លាប់ផ្ងារជើងទាំងពីរ ។ ព្រះអង្គម្ចាស់បម្រុងនឹងបន្តការ បរបាញ់ទៅទៀត តែព្រះបាទស៊ុលតង់មិនទ្រង់អនុញ្ញាត, ព្រះអង្គបាន មានព្រះរាជឱង្ការហៅត្រឡប់មកវិញ ។ លុះព្រះអង្គម្ចាស់យាងមក ដល់ជិតព្រះអង្គហើយ, ព្រះបាទស៊ុលតង់ក៏មានព្រះបន្ទូលថា: "បើសិន ជាខ្ញុំបណ្តោយឱ្យអ្នកបាញ់តទៅទៀត, អ្នកនឹងបំផ្លាញកន្លែងប្រមាញ់ខ្ញុំ ខ្ទេចខ្ទីអស់មួយរំពេច ។ ខ្ញុំមិនមែនចង់សំចៃសត្វខ្ញុំទេ តែខ្ញុំមានចិត្ត ប្រណីខ្លួនអ្នកដែលខ្ញុំត្រូវតែទទួលស្គាល់ក្នុងពេលឥឡូវនេះ" ។

ព្រះបាទស៊ុលតង់កួរូសា ក៏កើតព្រះទ័យទោរទន់ស្រឡាញ់ព្រះ អង្គម្ចាស់ទាំងពីរព្រះអង្គនោះជាពន់ប្រមាណ។ ហើយព្រះអង្គក៏អញ្ជើញ

ព្រះអង្គម្ចាស់ឱ្យទៅតាមព្រះអង្គក្នុងពេលឥឡូវនេះ ។ ប៉ុន្តែព្រះអង្គម្ចាស់បាម៉ានទ្រង់មានព្រះបន្ទូលឆ្លើយថា : "បពិត្រល្អងធូលីព្រះបាទ, ទូលព្រះបង្គំយើងខ្ញុំមិនសមនឹងទទួលកិត្តិយសដែលព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យព្រះរាជទាននេះទេ ហើយទូលព្រះបង្គំយើងខ្ញុំ សូមអង្វរព្រះអង្គ សូមព្រះរាជទានអនុញ្ញាតកុំឱ្យទូលព្រះបង្គំយើងខ្ញុំទៅតាមព្រះអង្គធ្វើអ្វី" ។

ព្រះបាទស៊ុលតង់ទ្រង់ពុំយល់ថា តើដោយហេតុអ្វីបានជាព្រះអង្គម្ចាស់ទាំងពីរមិនព្រមទទួលសេចក្តីអនុគ្រោះនេះ ទើបព្រះអង្គទ្រង់មានព្រះរាជឱង្ការសួរបង្គំឱ្យព្រះអង្គម្ចាស់ឆ្លើយបំភ្លឺព្រះអង្គ។ ព្រះអង្គម្ចាស់បាម៉ានក៏មានព្រះបន្ទូលឆ្លើយថា : "បពិត្រព្រះករុណាថ្លៃវិសេស, ទូលព្រះបង្គំយើងខ្ញុំមានប្អូនស្រីមួយជាប្អូនពៅបង្អស់ ។ ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នាបានរស់នៅជាមួយគ្នាជាប់ជានិច្ច ហើយទូលព្រះបង្គំយើងខ្ញុំពុំដែលទទួលធ្វើ ឬធ្វើអ្វីមុនបានសួរយោបល់នាងឡើយ ចំណែកនាងវិញក៏ដូច្នោះដែរ, នាងពុំដែលហ៊ានសម្រេចធ្វើអ្វីដោយពុំទាន់បានសួរយោបល់ទូលព្រះបង្គំយើងខ្ញុំជាមុនឡើយ" ។

ព្រះបាទស៊ុលតង់ក៏មានព្រះបន្ទូលតបថា : "ខ្ញុំសូមសរសើរជាច្រើនចំពោះការរស់នៅរួមគ្នាជាភាតរភាពនេះ។ ដូច្នេះ សូមអ្នកប្រឹក្សានឹងប្អូនស្រីអ្នកមើល ហើយនៅថ្ងៃស្អែក នៅពេលត្រឡប់មកបរបាញ់ជាមួយខ្ញុំ សូមអ្នកយកចម្លើយនោះមកប្រាប់ខ្ញុំកុំខាន" ។

ព្រះអង្គម្ចាស់ទាំងពីរក៏យាងត្រឡប់ទៅលំនៅវិញ ប៉ុន្តែទាំងពីរព្រះអង្គឥតមាននឹកឃើញ មិនត្រឹមតែពីរឿងដែលព្រះអង្គម្ចាស់បានជួបនឹងព្រះបាទស៊ុលតង់ ហើយបានទទួលកិត្តិយសបរបាញ់ជាមួយព្រះអង្គប៉ុណ្ណោះទេ, ប៉ុន្តែទ្រង់ថែមទាំងភ្លេចពុំបាននិយាយទូលព្រះអង្គម្ចាស់ក្សត្រីអំពីរឿងដែលព្រះបាទស៊ុលតង់បានមានព្រះបន្ទូលជាមួយព្រះអង្គម្ចាស់ ហើយព្រះអង្គទ្រង់មានបំណងនឹងនាំព្រះអង្គម្ចាស់ទៅជាមួយនឹងព្រះអង្គទៀតផង ។ លុះថ្ងៃស្អែកឡើង នៅពេលដែលព្រះអង្គម្ចាស់បានយាងទៅដល់ជិតព្រះអង្គ នៅកន្លែងប្រមាញ់ ព្រះបាទស៊ុលតង់ក៏មានព្រះបន្ទូលសួរថា : "ម្តេចទៅ, អ្នកមាននិយាយប្រាប់ប្អូនស្រីអ្នកទេ? នាងយល់ព្រមឱ្យអ្នកទៅលេងនឹងខ្ញុំទេ?" ។ ព្រះអង្គម្ចាស់ទាំងពីរក៏ងាកមើលព្រះភក្ត្រគ្នាភ្លឹះៗ រួចព្រះអង្គម្ចាស់បាម៉ានក៏មានព្រះបន្ទូលថា: "ទូលព្រះបង្គំយើងខ្ញុំសូមអង្វរព្រះអង្គសូមព្រះរាជទានអភ័យទោស, ប្អូនទូលព្រះបង្គំក្តី ទូលព្រះបង្គំក្តីឥតមាននឹកឃើញរឿងនេះបន្តិចសោះឡើយ ។ ដូច្នេះ ចូរអ្នកនឹកកុំភ្លេចក្នុងថ្ងៃនេះ, ហើយថ្ងៃស្អែកនាំចម្លើយមកប្រាប់ខ្ញុំ, ព្រះបាទស៊ុលតង់មានព្រះបន្ទូល"

ជាលើកទីពីរ, ព្រះអង្គម្ចាស់បានភ្លេចរឿងនេះទៀត ហើយព្រះបាទស៊ុលតង់ក៏ឥតទ្រង់ក្រោធនឹងការធ្វេសប្រហែសនេះដែរ ផ្ទុយទៅវិញព្រះអង្គបានលូកយកដុំមាសបីដុំចេញពីក្នុងថង់ព្រះអង្គ ហើយទ្រង់ដាក់ទៅក្នុងថ្នក់អាវព្រះអង្គម្ចាស់បាម៉ាន ទើបមានព្រះបន្ទូល

ដោយញញឹមថា ៖ "ដុំមូលនេះជួយការពារកុំឱ្យអ្នកភ្លេចរឿងដែលខ្ញុំត្រូវការចង់ដឹងនេះទៀត ។ នៅល្ងាចនេះ ដុំមាសនេះនឹងធ្លាក់ចេញពីខ្សែក្រវាត់អ្នក ហើយពួសូរសម្លេងអាចឱ្យអ្នកនឹកឃើញដល់រឿងនេះភ្លាម ដែលអ្នកពុំបាននឹកឃើញនៅពេលមុន ។

រឿងនេះបានកើតឡើងដូចព្រះបាទស៊ុលតង់ទ្រង់បានព្រមានមែន បើអត់មានដុំមាសបីនេះ. ព្រះអង្គម្ចាស់ទាំងពីរប្រាកដជាភ្លេចមានបន្ទូលពីរឿងខាងលើនេះ ទូលព្រះអង្គម្ចាស់ក្សត្រីបារីសាដទៀត ។ ដុំមាសបានធ្លាក់ចេញពីខ្សែក្រវាត់ព្រះអង្គម្ចាស់បាម៉ាន នៅពេលដែលព្រះអង្គម្ចាស់ដោះខ្សែក្រវាត់ចេញរៀបនឹងចូលផ្ទំ ។ មួយរំពេចនោះព្រះអង្គម្ចាស់ក៏យាងទៅជួបព្រះអង្គម្ចាស់ប៉ែវិស. រួចយាងទៅកាន់បន្ទប់ព្រះអង្គម្ចាស់ក្សត្រីទាំងពីរព្រះអង្គ ។ ព្រះអង្គម្ចាស់ក្សត្រីក៏ពុំទាន់ផ្ទំនៅឡើយដែរ ។ ព្រះអង្គម្ចាស់ព្រះរៀមក៏មានបន្ទូលសុំទោសព្រះនាងអំពីការដែលទ្រង់មករំខានព្រះនាងក្នុងកាលមិនគួរ រួចក៏មានបន្ទូលអំពីរឿងនោះទូលព្រះនាង និងអំពីពេលបានជួបព្រះបាទស៊ុល-តង់ ។

ព្រះអង្គម្ចាស់ក្សត្រីបារីសាដទ្រង់ភ័យនឹងដំណឹងនេះ ទើបមានព្រះសវនីយ៍ថា ៖ "ការដែលម្ចាស់ព្រះរៀមបានជួបនឹងព្រះបាទស៊ុល-តង់ ជាការមួយសប្បាយហើយប្រកបដោយកិត្តិយសមួយធំណាស់ ហើយតទៅមុខ ការជួបនេះរឹតតែបណ្តាលឱ្យព្រះរៀមសប្បាយទៀត ។

ប៉ុន្តែចំពោះខ្ញុំម្ចាស់ជាប្អូន ការជួបនេះជាការនាំឱ្យរំខាន ហើយឱ្យព្រួយចិត្តផង ។ ម្ចាស់អូនយល់ច្បាស់ថា ដោយសារតែសេចក្តីរាប់អានចំពោះម្ចាស់អូនហើយ បានជាព្រះវៀមហ៊ានប្រកែកមិនព្រមធ្វើតាមបំណងព្រះបាទស៊ុលតង់ ។ ខ្ញុំសូមដឹងគុណម្ចាស់បងទាំងពីរដ៏ជ្រាលជ្រៅ ម្ចាស់អូនស្គាល់ច្បាស់ហើយមេត្រីភាពរបស់ម្ចាស់បង ចំពោះមកលើរូបម្ចាស់អូនដូចជាមេត្រីភាពម្ចាស់អូនមានទៅលើម្ចាស់បងដែរ ។ ម្ចាស់ព្រះវៀមសុខចិត្តប្រព្រឹត្តអំពើពុំគួរសម ចំពោះព្រះបាទស៊ុលតង់ ដោយហ៊ានប្រកែកត្រង់ៗនឹងព្រះអង្គ កុំឱ្យតែបាត់ការរស់នៅជាភាតរភាពដែលយើងបានប្តេជ្ញានឹងគ្នាមកហើយ ។ ម្ចាស់ព្រះវៀមបានពិចារណាយ៉ាងត្រូវថា បើសិនជាម្ចាស់ព្រះវៀមបានព្រមទៅជាមួយព្រះអង្គទៅហើយ. នោះម្ចាស់ព្រះវៀមនឹងត្រូវឃ្លាតពីប្អូនបន្តិចម្តងៗ លុះត្រាតែត្រូវទៅនៅបម្រើព្រះអង្គរហូត ។ ប៉ុន្តែម្ចាស់ព្រះវៀមស្មានថា ជាការប្រពៃឬ ដែលយើងហ៊ានប្រកែកជាដាច់ខាត នឹងព្រះរាជបំណងព្រះមហាក្សត្រ? សេចក្តីប្រាថ្នារបស់ព្រះបាទស៊ុលតង់ គឺជាឆន្ទៈទាំងឡាយដែលអាចនាំឱ្យមានគ្រោះ បើសិនជាគេប្រកែកពុំធ្វើតាម ។ ដូច្នេះបើសិនជាម្ចាស់អូននឹងឃាត់ព្រះវៀមកុំឱ្យធ្វើតាមបំណងព្រះអង្គទៅ នោះឃើញថា ម្ចាស់អូននឹងរឹតតែធ្វើឱ្យម្ចាស់ព្រះវៀមទទួលរងគំនុំថ្មីពីព្រះអង្គទៀត ហើយនឹងបណ្តាលឱ្យម្ចាស់អូនវេទនាជាមួយនឹងព្រះវៀមផង ។ ម្ចាស់ព្រះវៀមឃើញទេ តើខ្ញុំមានមនោសញ្ចេតនាយ៉ាងណា ។

ដូច្នេះមុននឹងយើងត្រូវឆ្លើយយ៉ាងណា១នោះ ត្រូវយើងពិគ្រោះសួរបក្សាចេះនិយាយសិន ហើយយើងចាំមើលតើបក្សានឹងឱ្យដំបូន្មានយើងយ៉ាងណា បក្សាមានបញ្ញាឈ្លាសវៃ ហើយចេះប្រមាណការអ្វី១ដឹងជាមុន ហើយបក្សាតែងជួយយើងនៅពេលមានការលំបាកផ្សេង១ដែលធ្វើឱ្យយើងទាល់គំនិត" ។

ព្រះអង្គម្ចាស់ក្សត្រីក៏យកទ្រុងសត្វចេញមក ហើយបន្ទាប់ពីព្រះនាងបានស្នើរឿងនោះដល់បក្សាហើយ នៅចំពោះព្រះភក្ត្រព្រះអង្គម្ចាស់. ព្រះនាងក៏សួរទៅបក្សាថា តើឱ្យព្រះអង្គម្ចាស់ធ្វើយ៉ាងណា នៅក្នុងភាពអល់ឯកនេះ ។ បក្សាក៏ឆ្លើយថា : "ត្រូវតែព្រះអង្គម្ចាស់ព្រះរៀម ព្រមទាំងអ្នកស្រីធ្វើស្របតាមឆន្ទៈព្រះបាទស៊ុលតង់ ហើយត្រូវសុំយាងព្រះអង្គមកលេងផ្ទះអ្នកស្រីដែរ ។

- ប៉ុន្តែ. បក្សា. (ព្រះនាងមានសវនីយ៍) យើងស្រឡាញ់បងប្អូនយើងរកអ្វីប្រៀបគ្មាន ។ តើមេត្រីភាពរបស់យើងមិនបែកបាក់ទេឬដោយដំណើរនេះ ។

- គ្មានអ្វីទាំងអស់. (បក្សាឆ្លើយ) មានរឹតតែពីប្រសើរឡើង ។

- ដូច្នេះ. ព្រះបាទស៊ុលតង់នឹងឃើញរូបខ្ញុំហើយ (ព្រះនាងមានព្រះសវនីយ៍) ។ បក្សាក៏ឆ្លើយថា ជាការចាំបាច់ត្រូវតែឱ្យព្រះអង្គឃើញអ្នកស្រីហើយការទាំងអស់នឹងប្រព្រឹត្តទៅយ៉ាងប្រពៃ ។

នៅថ្ងៃស្អែកឡើង ព្រះអង្គម្ចាស់បាម៉ាននិងប៉ែវិសក៏យាងត្រ-

ឡប់ទៅបរបាញ់សត្វវិញ. ហើយព្រះបាទស៊ុលតង់ក៏ទ្រង់ត្រាស់សួរថា តើព្រះអង្គម្ចាស់មានបាននឹកឃើញស្មើរឿងនោះ ដល់ព្រះអនុជក្សត្រីទេ ។ ព្រះអង្គម្ចាស់បាម៉ានក៏យាងចូលទៅជិតព្រះបាទស៊ុលតង់ ហើយមានព្រះបន្ទូលថា: “បពិត្រព្រះករុណាថ្លៃវិសេស. លួងធូលីអាចតម្រូវរូបទូលព្រះបង្គំយើងខ្ញុំបានតាមព្រះរាជបំណង ហើយទូលព្រះបង្គំយើងខ្ញុំបានបម្រុងខ្លួននឹងធ្វើតាមបង្គាប់ព្រះអង្គ ព្រោះថាទូលព្រះបង្គំយើងខ្ញុំមិនត្រឹមតែបានទទួលសេចក្ដីយល់ព្រម ពីប្អូនស្រីទូលព្រះបង្គំយ៉ាងងាយប៉ុណ្ណោះទេ គឺនាងថែមទាំងឱ្យយោបល់ថា ទូលព្រះបង្គំយើងខ្ញុំមិនដឹងចាំបាច់សួរយោបល់នាងធ្វើអ្វីទេ ដោយហេតុថារឿងនេះជាករណីយកិច្ចរបស់ទូលព្រះបង្គំយើងខ្ញុំ ដែលត្រូវមានចំពោះព្រះអង្គ ។ ដូច្នេះបពិត្រព្រះនរបតីទូលព្រះបង្គំយើងខ្ញុំ សូមព្រះអង្គព្រះរាជទានអភ័យទោសដល់ទូលព្រះបង្គំផង ចំពោះរឿងនេះ” ។

ព្រះបាទស៊ុលតង់មានព្រះបន្ទូលឆ្លើយថា : “ការនេះសូមឯងកុំព្រួយឱ្យសោះ. យើងយល់ព្រមយ៉ាងរីករាយបំផុត ហើយយើងសង្ឃឹមថា ឯងនឹងត្រូវមានការគួរសមនឹងយើងតែត្រឹមប៉ុណ្ណឹងដដែលបានហើយ” ។ ព្រះអង្គម្ចាស់ទាំងពីរអៀនខ្មាសនឹងសេចក្ដីត្រាប្រណីហួសប្រមាណនេះ ក៏គ្មានមានព្រះបន្ទូលឆ្លើយយ៉ាងណា ក្រៅពីឯកព្រះសិរសាសម្ដែងសេចក្ដីគោរពយ៉ាងជ្រាលជ្រៅចំពោះព្រះអង្គ ។

នៅថ្ងៃនោះ ព្រះបាទស៊ុលតង់ទ្រង់ឆាប់ឈប់បរបាញ់ ខុសពី

ព្រះរាជទម្លាប់មក ដោយហេតុតែព្រះអង្គទ្រង់ពិចារណាឃើញថា ព្រះអង្គម្ចាស់ទាំងពីរប្រកបដោយបញ្ញាឈ្លាសវៃ និងសេចក្ដីអង់អាចណាស់ ព្រះអង្គក៏ទ្រង់មានព្រះទ័យអន្ទះអន្ទែងចង់សន្ទនា ដោយសេរីជាមួយព្រះអង្គម្ចាស់ ទើបព្រះអង្គប្រញាប់យាងត្រឡប់ទៅព្រះបរមរាជវាំងវិញដូច្នេះ ។ នៅពេលធ្វើដំណើរយាងចេញទៅព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យអនុញ្ញាតឱ្យព្រះអង្គម្ចាស់ទាំងពីរបរសេះទន្ទឹមសង្ខាងព្រះអង្គ គឺជាកិត្តិយសដែលបណ្ដាលឱ្យកើតសេចក្ដីច្រណែន. មិនត្រឹមតែពីពួកមន្ត្រីធំៗក្នុងព្រះរាជវាំងទេ. សូម្បីតែលោកនាយករដ្ឋមន្ត្រីក៏មានសេចក្ដីអន់ចិត្តដែរ កាលបើឃើញព្រះអង្គម្ចាស់ទាំងពីរបានទទួលកិត្តិយសយ៉ាងមុខលោកដូច្នោះ ។

កាលបើព្រះបាទស៊ុលតង់យាងចូលទៅដល់ក្នុងព្រះរាជធានីហើយ. ប្រជាពលរដ្ឋដែលស្ថិតនៅសង្ខាងវិថី បានខំសម្លឹងមើលតែព្រះអង្គម្ចាស់បាម៉ានិងព្រះអង្គម្ចាស់ប៉ែរិស ដោយចង់ដឹងថា តើព្រះអង្គម្ចាស់ទាំងពីរនោះជានរណា ជាជនបរទេស ឬក៏ជាជនក្នុងនគរនោះទេ ។ អ្នកខ្លះក៏បានពោលថា : “ទោះជាយ៉ាងណាក៏ដោយ. សូមឱ្យព្រះអាទិទេពមេត្តាដាក់ទានឱ្យព្រះបាទស៊ុលតង់ មានព្រះរាជបុត្រពីរព្រះអង្គ ហើយមានព្រះរូបល្អឥតខ្ចោះប្រកបដោយទឹកព្រះភក្ត្ររីករាយដូច្នេះកុំខាន បើសិនជាព្រះនាងស៊ុលតានបានប្រសូតបុត្រមកដូចប្រក្រតីធម្មតា. នោះព្រះរាជបុត្រព្រះអង្គប្រហែលជាមានព្រះជន្មធំប៉ុនៗនេះទៅហើយ” ។

វត្ថុទីមួយដែលព្រះបាទស៊ុលតង់ទ្រង់បានធ្វើដល់ព្រះអង្គម្ចាស់ នៅពេលយាងទៅដល់ព្រះបរមរាជវាំង គឺព្រះអង្គទ្រង់បាននាំព្រះអង្គម្ចាស់ទតមើលបន្ទប់ទាំងឡាយក្នុងប្រាសាទ ហើយព្រះអង្គម្ចាស់ក៏ទ្រង់ស្ងើចសរសើរលម្អគ្រឿងសង្ហារិម, ភាពឆើតឆាយ, ក្បាច់រចនាផ្សេងៗនិងសទិសសណ្ឋាន ។ នៅទីបំផុតគេក៏រៀបចំអាហារភោជនយ៉ាងល្អបំផុតថ្វាយព្រះអង្គម្ចាស់សោយ, ព្រះបាទស៊ុលតង់ក៏អញ្ជើញព្រះអង្គម្ចាស់គង់តុសោយក្រយាព្រះស្ងោយជាមួយព្រះអង្គ ។ ព្រះអង្គម្ចាស់ទាំងពីរបម្រុងប្រកែកដែរ ប៉ុន្តែព្រះអង្គម្ចាស់ទ្រង់យល់ព្រមតាមវិញ កាលបើព្រះបាទស៊ុលតង់មានព្រះបន្ទូលថា គឺជាឆន្ទៈព្រះអង្គ ។

ព្រះបាទស៊ុលតង់ជាក្សត្រទ្រង់ប្រកបដោយបញ្ញាខ្ពង់ខ្ពស់ ហើយទ្រង់មានការយល់យ៉ាងជ្រៅជ្រះខាងវិទ្យាសាស្ត្រ ពិសេសគឺខាងប្រវត្តិសាស្ត្រ ។ ដូច្នេះ ព្រះអង្គបានទ្រង់ចិន្តាទុកជាមុនថា នឹងផ្ដើមរករឿងមានព្រះបន្ទូលមុនព្រះអង្គម្ចាស់, មិនទុកឱ្យព្រះអង្គម្ចាស់មានព្រះបន្ទូលមុនព្រះអង្គបានឡើយ ។ ដោយហេតុនេះ ព្រះអង្គក៏ចាប់មានព្រះបន្ទូលមុន រួចជាបន្តបន្ទាប់មកការសន្ទនាក៏ចេះតែមានហូរហែក្នុងពេលសោយក្រយាព្រះស្ងោយ ។ ប៉ុន្តែនៅគ្រប់រឿងនៃការសន្ទនានោះព្រះអង្គម្ចាស់ទ្រង់មានព្រះបន្ទូលប្រកបដោយការចេះដឹង, ការឈ្លាសវៃ, ការវិនិច្ឆ័យនិងការស្គាល់ខុសស្គាល់ត្រូវជាដរាប ដែលជាហេតុនាំឱ្យព្រះបាទស៊ុលតង់ទ្រង់ស្ងើចសរសើរជាទីបំផុត ។ ទើបព្រះអង្គទ្រង់

ព្រះចិន្តាក្នុងព្រះទ័យថា : "បើសិនជាកុមារទាំងពីរនេះ ដែលប្រកបដោយបញ្ញាយ៉ាងនេះស្រាប់ហើយ បានទៅជាបុត្ររបស់ខ្ញុំ ហើយទោះបីខ្ញុំនឹងអប់រំវាដោយខ្លួនខ្ញុំផ្ទាល់ទៀតក៏ដោយ, ក៏យុវជននេះគ្មានចេះអ្វីឱ្យលើសពីនេះទៅទៀតបានដែរ" ។ បន្ទាប់ពីការសន្ទនាយ៉ាងវែងជាមួយព្រះអង្គម្ចាស់នៅនឹងតុក្រយាព្រះស្ងោយមក, ព្រះអង្គក៏ទ្រង់អញ្ជើញព្រះអង្គម្ចាស់ទៅសន្ទនានៅក្នុងការិយាល័យព្រះអង្គទៀត ។ នៅទីបំផុត ព្រះអង្គក៏មានព្រះបន្ទូលថា : "ខ្ញុំពុំបាននឹកស្មានថា នៅទីដំបន់ជនបទមានអភិជនក្មេងៗ ដូច្នោះដែលជាកូនចៅខ្ញុំ, មានការអប់រំយ៉ាងខ្ពង់ខ្ពស់, មានចំណេះបញ្ញាប៉ិនប្រសប់ជ្រៅជ្រះដូច្នេះសោះ ។ តាំងពីខ្ញុំកើតមក, ខ្ញុំពុំដែលបានសន្ទនាអ្វីឱ្យបានសប្បាយដូចជាបានសន្ទនាជាមួយនឹងឯងនេះទេ។ ប៉ុន្តែប៉ុណ្ណេះគ្រប់គ្រាន់ល្មមហើយ ព្រោះដល់ពេលអ្នកត្រូវឈប់សម្រាកលម្ហែកាយមើលការរាំច្រៀងផ្សេងៗនៅក្នុងព្រះបរមរាជវាំងខ្ញុំនេះ ។ ប៉ុន្តែដោយគ្មានល្បែងអ្វី ដែលអាចឱ្យឯងបាត់អផ្សុកបានក្រៅពីភ្លេងនោះ សូមឯងអញ្ជើញទៅស្ដាប់តូរ្យ-តន្ត្រីដែលគេកំពុងលេងនោះទៅ" ។

កាលបើព្រះបាទស៊ុលតង់ទ្រង់មានព្រះបន្ទូលចប់ភ្លាម អ្នកភ្លេងដែលបានទទួលបង្គាប់ក៏ចូលមកសម្ដែងវិជ្ជាខ្លួនយ៉ាងប៉ិនប្រសប់ ។ ពួកអ្នកក្រមាច់យ៉ាងល្បីៗឈ្មោះក៏ឡើងកំប្លែងបន្ទរនឹងភ្លេង, នាដករនាដការីទាំងឡាយបានឡើងរាំបញ្ចប់ការសប្បាយយ៉ាងល្អមើលណាស់

ព្រះអង្គម្ចាស់ទាំងពីរ កាលបើយល់ថា ពេលកាន់តែល្ងាចជិតយប់ហើយ ក៏ឱនលុតជង្គង់ថ្វាយបង្គំសុំលាព្រះបាទស៊ុលតង់ ក្រោយពីបានសម្ដែងអំណរគុណព្រះអង្គចំពោះព្រះទ័យសប្បុរសនឹងកិត្តិយសដែលព្រះអង្គទ្រង់បានធ្វើមកលើខ្លួន ។ ព្រះបាទស៊ុលតង់ក៏ទ្រង់យល់ព្រម ហើយមានព្រះបន្ទូលថា: "យើងអនុញ្ញាតឱ្យឯងទៅហើយៗសូមឯងនឹកថា យើងបាននាំអ្នកមកកាន់ព្រះរាជវាំងយើងដោយផ្ទាល់ខ្លួនយើងដូច្នេះ ដើម្បីឱ្យឯងស្គាល់ផ្លូវប្រយោជន៍ដល់ថ្ងៃក្រោយ ឯងមកលេងផ្ទាល់ខ្លួនឯងតែម្ដង ។ ឯងនឹងត្រូវបានគេទទួលដោយរីករាយហើយដរាបណាឯងបានមកលេងនឹងយើងញឹកញយ ដរាបនោះឯងក៏បានធ្វើឱ្យយើងសប្បាយច្រើនដែរ" ។

មុននឹងថ្វាយបង្គំលាព្រះរាជាចេញពីព្រះរាជវាំងទៅ ព្រះអង្គម្ចាស់បាម៉ានទ្រង់មានព្រះបន្ទូលថា : "បពិត្រព្រះនរបតីជាម្ចាស់ជីវិតលើត្បូង, ទូលព្រះបង្គំយើងខ្ញុំសូមអង្វរព្រះករុណាថ្លៃវិសេស សូមព្រះអង្គទ្រង់មេត្តាអនុគ្រោះដល់ទូលព្រះបង្គំនឹងដល់ប្អូនស្រីទូលព្រះបង្គំផង គឺសូមព្រះអង្គទ្រង់យាងកាត់តាមផ្លូវផ្ទះទូលព្រះបង្គំ ហើយយាងចូលសម្រាកព្រះកាយក្នុងគេហស្ថានទូលព្រះបង្គំ តាមពេលដ៏គួរ, នៅពេលណាមួយដែលព្រះអង្គទ្រង់បានយាងទៅកំសាន្តបរបាញ់សត្វនៅទីជិតៗនោះ ។ ពិតមែនហើយតែកន្លែងនោះមិនសមនឹងព្រះអង្គយាងចូលទេ ប៉ុន្តែនៅពេលខ្លះ, ព្រះរាជាក៏ទ្រង់សព្វព្រះរាជហឫទ័យនឹង

ចូលសម្រាកព្រះកាយពលនៅក្នុងផ្ទះខ្ញុំដែរ"។ ព្រះបាទស៊ុលតង់ក៏ទ្រង់មានព្រះបន្ទូលតបថា : "គេហស្ថានរបស់អធិជនទាំងឡាយដូចជារូបឯងនេះ ជាគេហស្ថានល្អហើយសមនឹងកិត្តិយសឯងណាស់ ។ យើងនឹងមានសេចក្តីសោមនស្សនឹងទៅមើលណាស់ សោមនស្សដោយបានឃើញឯងនឹងប្អូនស្រីឯង ដែលយើងមានសេចក្តីរីករាយជាមុន១ ដែលយើងបានទៅឃើញនាងធ្វើជាម្ចាស់ផ្ទះនោះ ព្រោះយើងបានស្គាល់គុណសម្បត្តិរបស់នាងតាមដំណើរ ដែលឯងបាននិយាយប្រាប់យើងខ្លះមកហើយ ។ ដូច្នេះយើងនឹងទៅលេងផ្ទះឯងនៅពេលឆាប់១ មិនហួសពីថ្ងៃខានស្អែកនេះឡើយ ។ នៅពេលព្រលឹមធំ. យើងនឹងដល់កន្លែងដែលយើងបានជួបនឹងឯងពីថ្ងៃមុន សូមឯងនៅចាំយើងត្រង់កន្លែងនោះពុំខាន ដើម្បីនាំផ្លូវយើងទៅកាន់ផ្ទះឯង" ។

នៅថ្ងៃដដែលនោះ ព្រះអង្គម្ចាស់បាម៉ាននិងប៉ែវិសក៏បានយាងត្រឡប់ទៅដល់គេហស្ថានវិញ ។ លុះយាងទៅដល់ ព្រះអង្គម្ចាស់ក៏មានព្រះបន្ទូលប្រាប់ព្រះអង្គម្ចាស់ក្សត្រីអំពីបដិសណ្ឋារកិច្ចដ៏ខ្ពង់ខ្ពស់បំផុត ដែលទ្រង់បានទទួលពីព្រះបាទស៊ុលតង់ ហើយព្រះអង្គម្ចាស់បានបញ្ជាក់ថា ព្រះអង្គទ្រង់យល់ប្រមសម្រេចថានឹងយាងមកលេងផ្ទះយើងនៅថ្ងៃខានស្អែកនេះ ។

ព្រះអង្គម្ចាស់ក្សត្រីក៏មានព្រះសវនីយ៍ថា: "បើសិនជាការនេះដូច្នេះមែន. ត្រូវយើងគិតរៀបចំក្រយាព្រះស្ងោយយ៉ាងណាឱ្យសមនឹង

ថាន:ព្រះអង្គ ។ ប៉ុន្តែជាការប្រពៃត្រូវយើងពិគ្រោះយោបល់បក្សាចេះនិយាយសិន ។

បក្សាប្រហែលជានឹងប្រាប់ម្ហូបឆ្ងាញ់ៗឱ្យយើងធ្វើ ឱ្យបានសមនឹងពោធិបារមីព្រះមហាក្សត្រា ។ ព្រះអង្គម្ចាស់ព្រះរៀមទាំងពីរក៏យល់ព្រម រួចនៅពេលព្រះអង្គម្ចាស់ព្រះរៀមយាងថយចេញទៅ. ព្រះនាងក៏នៅពិគ្រោះនឹងបក្សាតែមួយព្រះអង្គឯង ។ ព្រះនាងមានព្រះសវនីយ៍ថា : "បក្សាព្រះបាទស៊ុលតង់ទ្រង់សព្វព្រះរាជហឫទ័យយាងមកលេងផ្ទះយើងនេះ ហើយយើងត្រូវតែរៀបចំក្រយាព្រះស្ងោយទទួលព្រះអង្គ ។ ដូច្នេះសូមឯងនិយាយប្រាប់ខ្ញុំមក. តើឱ្យខ្ញុំរៀបចំធ្វើម្ហូបអាហារយ៉ាងម៉េច ដើម្បីឱ្យបានសព្វព្រះទ័យព្រះអង្គ" ។

បក្សាក៏ឆ្លើយថា: "អ្នកស្រីជាចៅហ្វាយដ៏ប្រសើររបស់ខ្ញុំ. អ្នកស្រីមានចុងភៅយ៉ាងចំណានៗជាច្រើន សូមឱ្យចុងភៅទាំងនេះ ធ្វើម្ហូបណាដែលខ្លួនយល់ថាប្រសើរជាងគេទាំងអស់ ប៉ុន្តែសំខាន់បំផុត. សុំឱ្យចុងភៅធ្វើម្ហូបត្រសក់ញាត់ទិមគជ់មួយចាន ។ ម្ហូបត្រសក់នេះ សូមអ្នកស្រីលើកយកទៅថ្វាយព្រះរាជាសោយមុនគេបង្អស់ ព្រោះជារបស់ប្រសើរជាងគេ" ។

- ត្រសក់ញាត់ទិមគជ់ ! ព្រះអង្គម្ចាស់ក្សត្រីទ្រង់ស្រែកទ្រហោដោយសេចក្តីងឿងឆ្ងល់ ។ បក្សា. អ្នកឥតនឹកឃើញទេឬ គឺជាម្ហូបដែលគេពុំដែលឮសោះ ។ ព្រះបាទស៊ុលតង់ទ្រង់នឹងសរសើរពុំខាន



ថាជារបស់ឆើតឆាយរុងរឿងឧត្តុង្គឧត្តម ប៉ុន្តែត្រូវដឹងថា ព្រះអង្គទ្រង់គង់នៅនឹងតុ ដើម្បីសោយក្រយា មិនមែនព្រះអង្គទ្រង់សរសើរគជ់ទេ។ ក្រៅពីនេះ, កាលបើខ្ញុំយកគជ់ខ្ញុំមកប្រើការដូច្នេះមែន ក៏ខ្ញុំគ្មានគ្រប់គ្រាន់សម្រាប់ធ្វើទឹមញាត់ត្រសក់នេះដែរ ។

- អ្នកស្រី, បក្សាឆ្លើយ, សូមអ្នកស្រីធ្វើតែតាមខ្ញុំជម្រាបទៅហើយសូមកុំព្រួយក្រែងមានកើតរឿងហេតុអ្វីឱ្យសោះ មានតែអំពើល្អទេដែលអាចកើតមានបាន ។ ចំណែកឯគជ់វិញ, ស្អែកនេះនៅពេលពីព្រលឹមបំផុត, សូមអ្នកស្រីអញ្ជើញទៅកាន់គល់ឈើក្នុងសួនអ្នកស្រីដែលដុះនៅដើមគេបង្អស់ ហើយនៅខាងស្តាំដៃ, រួចសុំឱ្យគេជីកត្រង់គល់ឈើនោះ អ្នកស្រីនឹងបានឃើញគជ់លើសចំនួនដែលអ្នកស្រីត្រូវការទៅទៀត ។

ចាប់តាំងពីល្ងាចនៃថ្ងៃនោះម្ល៉េះ, ព្រះអង្គម្ចាស់ក្សត្រីបារីសាដបានទ្រង់ប្រាប់អ្នកថែរក្សាសួន ឱ្យប្រុងប្រៀបខ្លួនឱ្យស្រេច។ លុះស្អែកឡើង នៅពេលពីព្រលឹម ព្រះនាងក៏នាំអ្នកថែរក្សាសួនទៅកាន់ដើមឈើ ដែលបក្សាបានប្រាប់ រួចក៏ទ្រង់បង្គាប់ឱ្យអ្នកថែរក្សាសួនជីកត្រង់គល់ឈើនោះ ។ កាលបើអ្នកថែសួនច្បារជីកបានជ្រៅបន្តិចទៅ គាត់ក៏ហាក់ដូចជាជីកលែងមុតទៅទៀត, រួចគាត់ក៏សម្លឹងទៅឃើញប្រអប់តូចមួយ ធ្វើអំពីមាសមានរាងបួនជ្រុងស្មើ មួយជ្រុង១ប្រវែងមួយជំហាន (០.៣២៤៨ម) ។ គាត់ក៏ចង្អុលបង្ហាញព្រះអង្គម្ចាស់ក្សត្រី១ក៏

មានសវនីយ៍ថា : "គឺអាស្រ័យហេតុនេះហើយបានជាខ្ញុំនាំឯងមក. ចូរឯងជីកតទៅទៀត ហើយប្រយ័ត្នកុំឱ្យប៉ះនឹងផ្លែចប" ។

នៅទីបំផុត. អ្នកថែសួនច្បារក៏ជីកយកបានប្រអប់នោះថ្វាយទៅព្រះអង្គម្ចាស់ក្សត្រី ។ ដោយហេតុថា ប្រអប់នោះបិទភ្ជិតដោយស្រយូវយ៉ាងតូចស្អាត. ព្រះអង្គម្ចាស់ក្សត្រីក៏បើកបានហើយទតឃើញសុទ្ធតែគជ់. មានទំហំដ៏តូច ប៉ុន្តែស្អាតហើយសមនឹងយកមកប្រើតាមសេចក្តីត្រូវការណាស់ ។ បន្ទាប់ពីបានបិទប្រអប់នោះទៅវិញ. ព្រះនាងក៏កាន់ប្រអប់នោះយាងត្រឡប់មកលំនៅ ប្រកបដោយសេចក្តីសោមនស្សជាពន់ប្រមាណ ទុកអ្នកថែសួនឱ្យនៅលុបដីត្រង់កន្លែងនោះឱ្យរាបស្មើដូចពីដើមវិញ ។

ព្រះអង្គម្ចាស់បាម៉ាននិងប៉ៃវិស ដោយទ្រង់បានទតឃើញព្រះអង្គម្ចាស់ក្សត្រីជាព្រះអនុជ នៅក្នុងសួនច្បារទាំងព្រលឹមខុសពីទម្លាប់ធម្មតាមកដូច្នេះ ក៏យាងចុះពីដំណាក់ព្រះអង្គរៀង១ខ្លួនតម្រង់ឆ្ពោះទៅរកព្រះនាង នៅពេលដែលព្រះអង្គទ្រង់ស្លៀកពាក់តែងព្រះកាយរួច ។ ព្រះអង្គម្ចាស់ទាំងពីរ ក៏បានយាងទៅជួបព្រះនាងនៅត្រង់ពាក់កណ្តាលសួនច្បារ ហើយដោយព្រះអង្គម្ចាស់ទតពីចម្ងាយ ឃើញព្រះនាងមានកាន់របស់អ្វីនៅនឹងព្រះហស្ត. លុះយាងទៅដល់ជិតទៅ. ព្រះអង្គម្ចាស់ក៏បានស្គាល់ថាជាប្រអប់មាសតូចមួយ. ទើបទ្រង់កើតសេចក្តីងឿងឆ្ងល់ជាពន់ប្រមាណ ។ ព្រះអង្គម្ចាស់បាម៉ានក៏ត្រាស់សួរទៅព្រះ

នាងភ្លាមថា : “ម្ចាស់អូន, កាលម្ចាស់អូនយាងទៅជាមួយអ្នកថែសួន, ម្ចាស់បងឥតឃើញមានកាន់អ្វីសោះ, ឥឡូវលុះម្ចាស់អូនយាងត្រឡប់មកវិញ ក៏ស្រាប់តែឃើញកាន់ប្រអប់មាសនេះ។ តើរបស់នេះជាកំណប់ដែលអ្នកថែសួនច្បារបានឃើញ ហើយមកប្រាប់ម្ចាស់អូនឬ?”

- ម្ចាស់ព្រះរៀម, ព្រះអង្គម្ចាស់ក្សត្រីមានសវនីយ៍ គឺជាការយល់ផ្ទុយទាំងអស់ គឺខ្លួនម្ចាស់អូននេះទេ ដែលបាននាំអ្នកថែសួនទៅប្រាប់កន្លែងប្រអប់នេះ, ហើយអ្នកថែសួនច្បារក៏បានជីកយកប្រអប់នេះបានឱ្យម្ចាស់អូន។ ម្ចាស់ព្រះរៀមរឹតតែត្រេអរនឹងសេចក្ដីដ៏ប្រសើរនេះណាស់ កាលបើម្ចាស់ព្រះរៀមបានទតឃើញរបស់នៅក្នុងប្រអប់នេះទៀត ។

ព្រះអង្គម្ចាស់ក្សត្រីក៏បើកប្រអប់នោះឡើង, ព្រះអង្គម្ចាស់ក៏បានឃើញសុទ្ធតែគជ់ មានទំហំមិនជាសម្បើមប៉ុន្មានទេ ប៉ុន្តែ ជារបស់មានតម្លៃក្រៃលែង បើប្រៀបទៅនឹងភាពល្អឥតខ្ចោះនឹងចំនួននៃគជ់នោះ ។ ដូច្នេះ ព្រះអង្គម្ចាស់ក៏ទ្រង់ត្រាស់សួរទៅព្រះនាងថា តើដោយដំណើរយ៉ាងណាបានជាព្រះនាងបានដឹងកន្លែងកំណប់នេះ ។ ព្រះនាងក៏ទ្រង់ឆ្លើយថា : “ម្ចាស់ព្រះរៀម, បើសិនជាម្ចាស់ព្រះរៀមគ្មានការប្រញាប់ពេកណាស់ទេ, សូមម្ចាស់ព្រះរៀមមកជាមួយម្ចាស់អូនៗនឹងរៀបរាប់ទូល” ។ ព្រះអង្គម្ចាស់ប៉ៃរិសក៏មានព្រះបន្ទូលតបថា : “គ្មានការប្រញាប់ឯណាដែលអាចធ្វើឱ្យយើងខានដឹងរឿងនេះទេ ។ យើងគ្មានការអ្វីទៀតក្រៅពីមកជួបនឹងម្ចាស់អូនទេ” ។

នៅពេលនោះ ព្រះអង្គម្ចាស់ក្សត្រីបារីសាដទ្រង់យាងត្រឡប់ទៅលំនៅបណ្តើរ. មានសវនីយ៍ទូលម្ចាស់ព្រះរៀមបណ្តើរអំពីរឿងដែលព្រះនាងបានពិគ្រោះជាមួយបក្សា។ បន្ទាប់ពីម្ចាស់ព្រះរៀមបានយល់ព្រមផង, ដើម្បីរៀបធ្វើម្ហូបថ្វាយព្រះរាជា, អំពីការដែលព្រះនាងបានឆ្លើយជំទាស់នឹងបក្សា អំពីរឿងធ្វើម្ហូបត្រសក់ញាត់ទឹមគុជហើយនិងអំពីមធ្យោបាយដែលបក្សាបានប្រាប់កន្លែងលាក់គជ់ ដែលម្ចាស់អូនទើបនឹងយកបានមកនេះ ដើម្បីប្រើការធ្វើម្ហូបតាមសម្តីបក្សាព្រះអង្គម្ចាស់និងព្រះអង្គម្ចាស់ក្សត្រីបានទ្រង់ប្តូរយោបល់គ្នាជាច្រើនដើម្បីឱ្យបានយល់បំណងបក្សា. ដែលចង់ឱ្យគេធ្វើម្ហូបយ៉ាងនេះ ថ្វាយព្រះបាទស៊ុលតង់ ព្រមទាំងជួយប្រាប់មធ្យោបាយ ដើម្បីធ្វើម្ហូបនោះឱ្យទាល់តែកើតផង ។ ប៉ុន្តែនៅទីបំផុត, ព្រះអង្គម្ចាស់ទាំងឡាយពុំអាចយល់ដូចម្តេចបានឡើយ ប៉ុន្តែទ្រង់ក៏បានមូលមតិថា ត្រូវតែធ្វើតាមដំបូន្មានបក្សាកុំបីខ្វះកន្លែងណាឱ្យសោះឡើយ ។

លុះចូលទៅដល់ក្នុងផ្ទះ ព្រះនាងក៏ទ្រង់មានព្រះរាជឱង្ការឱ្យគេទៅហៅនាយចុងភៅមកជួបនឹងព្រះនាងនៅក្នុងបន្ទប់ព្រះនាង ។ រួចក្រោយពីព្រះនាងបានបង្គាប់ដល់នាយចុងភៅឱ្យប្រុងប្រៀបរៀបចំធ្វើក្រយាព្រះស្ងោយដើម្បីជប់លៀងព្រះបាទស៊ុលតង់ ព្រះនាងទ្រង់មានព្រះសវនីយ៍បន្ថែមដូច្នេះថា : "ក្រៅពីការដែលខ្ញុំទើបនឹងបាននិយាយប្រាប់អ្នកនេះ, ចូរអ្នកធ្វើម្ហូបមួយមុខតាមបង្គាប់ខ្ញុំ ដើម្បីថ្វាយ

ព្រះរាជាសោយ ហើយអ្នកមិនត្រូវបណ្តោយអ្នកណាឱ្យធ្វើក្រៅពីដៃអ្នកផ្ទាល់ឡើយ ។ ម្ហូបនោះគឺត្រសក់ញាត់ទឹម, ប៉ុន្តែទឹមនោះត្រូវយកគជ់នេះទៅធ្វើ" ។ នៅពេលនោះ, ព្រះនាងក៏បើកប្រអប់ឡើងបង្ហាញគជ់ឱ្យនាយចុងភៅមើល ។

នាយចុងភៅ ដែលពុំធ្លាប់បានឮគេពោលពីទឹមដូច្នេះសោះ, ក៏ដើរថយក្រោយពីរជំហាន, ធ្វើមុខស្មឿកសម្តែងនូវការងឿងឆ្ងល់ ។ ព្រះអង្គម្ចាស់ក្សត្រីយល់នូវអាកប្បកិរិយាដូច្នេះ ក៏មានព្រះសវនីយ៍ថា: "ខ្ញុំដឹងច្បាស់ណាស់ថា អ្នកមុខជាទុកខ្ញុំជាមនុស្សវិកលចរិកហើយ, បានជាបង្គាប់អ្នកឱ្យធ្វើម្ហូប ដែលអ្នកពុំដែលឮគេនិយាយម្តងណាសោះ ហើយដែលគេអាចពោលយ៉ាងប្រាកដថា គ្មាននរណាគេដែលធ្វើម្ហូបដូច្នេះទេ ។ ការនេះពិតដូច្នេះមែន ខ្ញុំក៏ដឹងដូចជាអ្នកដែរ ប៉ុន្តែខ្ញុំឥតឆ្កួតទេ គឺខ្ញុំប្រកបដោយសុភវិនិច្ឆ័យបរិបូណ៌ ដែលខ្ញុំបង្គាប់ឱ្យអ្នកធ្វើនេះ ។ ហេតុនេះ ចូរអ្នកត្រឡប់ទៅវិញ ប្រឌិតធ្វើឡើងតាមការប៉ិនប្រសប់របស់អ្នក ។ ដូច្នេះចូរអ្នកយកប្រអប់គជ់នេះទៅ រួចយកប្រអប់និងគជ់នៅសល់មកឱ្យខ្ញុំវិញ បើសិនជាគជ់នេះប្រើការមិនអស់" ។ នាងចុងភៅគ្មានអ្វីឆ្លើយឆ្លងនឹងព្រះនាងទៀត ក៏កណ្តៀតយកប្រអប់នោះទៅ ។ នៅថ្ងៃដដែលនោះ ព្រះអង្គម្ចាស់ក្សត្រីបារីសាដបានទ្រង់បង្គាប់ឱ្យគេរៀបចំបោសសម្អាតជូតលាងរបស់អ្វីៗឱ្យបានស្អាត ហើយឱ្យមានរបៀបរៀបរយទាំងអស់, ទាំងខាងក្នុងផ្ទះក៏ដូចជានៅក្នុងសួន

ដើម្បីទទួលព្រះបាទស៊ុលតង់ឱ្យបានថ្លៃថ្នូរ, សមរម្យនឹងព្រះរាជឋានៈព្រះអង្គ ។

លុះស្អែកឡើង នៅពេលដែលព្រះបាទស៊ុលតង់ប្រទេសពែរ្ស៊ីយាងមកដល់កន្លែងបរបាញ់សត្វ, ព្រះអង្គម្ចាស់ព្រះរៀមទាំងពីរបានយាងទៅគង់រង់ចាំ ទទួលព្រះអង្គនៅត្រង់កន្លែងនោះជាមុនស្រេចទៅហើយ ។ ព្រះបាទស៊ុលតង់ក៏ទ្រង់ចាប់បរបាញ់សត្វ រហូតដល់ពេលទៀបថ្ងៃត្រង់ទើបទ្រង់ឈប់ ។ នៅពេលនោះ, ព្រះអង្គម្ចាស់បាម៉ានបានគង់នៅជិតព្រះអង្គដើម្បីដង្ហែព្រះអង្គ ចំណែកឯព្រះអង្គម្ចាស់ប៉ែវិស ក៏បរសេះយាងចេញទៅមុខក្បួន ដើម្បីបង្ហាញផ្លូវ ។ លុះយាងទៅដល់ទីមើលទៅឃើញផ្ទះ ព្រះអង្គម្ចាស់ប៉ែវិសក៏បំផាយសេះយ៉ាងលឿងទៅមុន ដើម្បីទូលព្រះនាងឱ្យដឹងថា ព្រះបាទស៊ុលតង់យាងមកជិតដល់ហើយ ។ ប៉ុន្តែដោយពួកអ្នកបម្រើ ដែលព្រះនាងបានបង្គាប់ឱ្យឈរអមសង្ខាងរុក្ខវិថី បានទូលព្រះនាងមុននេះរួចទៅហើយ. ព្រះអង្គម្ចាស់ក៏បានឃើញព្រះនាងរៀបចំព្រះកាយជាស្រេច បម្រុងចាំទទួលព្រះរាជា ។

- ព្រះបាទស៊ុលតង់ក៏យាងទៅដល់ ចូលកាត់តាមទីធ្លា រួចក៏យាងចុះពីខ្នងសេះនៅត្រង់ទីខាងមុខល្វែងក្រៅនៃផ្ទះ ។ ព្រះអង្គម្ចាស់ក្សត្រីប៉ារីសាដ ក៏យាងចេញមកអោនថ្វាយបង្គំព្រះអង្គ ។ ព្រះអង្គម្ចាស់ព្រះរៀមដែលគង់នៅជិតនោះ ក៏ទូលព្រះបាទស៊ុលតង់ភ្លាមថា នេះគឺ

ព្រះអនុជក្សត្រីរបស់ទ្រង់ ។ ព្រះបាទស៊ុលតង់ក៏ទ្រង់ឱនទាញព្រះហស្ត ព្រះនាងឱ្យទ្រង់ងើបឡើង។ រួចក្រោយពីព្រះអង្គបានគង់សរសើររូបសម្បត្តិ. ឫកពាចរិយា ព្រមទាំងទឹកព្រះភក្ត្រដ៏ស្រស់ស្រាយរបស់ព្រះនាងអស់ពេលមួយសន្ទុះហើយ. ព្រះអង្គក៏មានព្រះបន្ទូលថា : "បងទាំងពីរសែនដូចប្អូន. ឯប្អូនក៏សែនដូចបងអីម្ល៉េះ ហើយបើតាមខ្ញុំពិចារណាមើលចិត្តគំនិតបងទាំងពីរនេះទៅ. ខ្ញុំយល់ថាបងទាំងពីរនេះពុំដែលហ៊ានសម្រេចធ្វើអ្វីមុនបានសួរយោបល់ប្អូនឡើយ ។ ប៉ុន្តែខ្ញុំសង្ឃឹមថា ខ្ញុំនឹងដឹងរឿងនេះច្បាស់ទៅទៀត កាលបើខ្ញុំបានមើលផ្ទះនេះរួចហើយសិន" ។

នៅពេលនោះ ព្រះអង្គម្ចាស់ក្សត្រីក៏មានព្រះសវនីយ៍ថា : "បពិតព្រះករុណាថ្លៃវិសេស គឺជាផ្ទះនៅស្រុកស្រែ ។ ផ្ទះនេះសមតែនឹងឋានៈមនុស្សដូចជាខ្ញុំម្ចាស់នេះ ដែលប្រកបការរស់នៅឆ្ងាយដាច់ពីចំណោមមហាជន ។ ផ្ទះនេះគ្មានកន្លែងត្រង់ណាអាចឱ្យប្រៀបប្រដូចបានទៅនឹងផ្ទះនៅក្នុងទីក្រុងធំៗទេ. ហើយបើប្រៀបទៅនឹងប្រាសាទដ៏ល្អដែលគេសាងទុកថ្វាយតែព្រះមហាក្សត្រទាំងឡាយគង់នោះ. ឃើញថាផ្ទះនេះរឹតតែអន់ថយណាស់ទៅទៀតទៅហើយ" ។

- ខ្ញុំពុំព្រមជឿតាមសម្ដីនាងទាំងអស់បានទេ ព្រះរាជាមានព្រះបន្ទូល? តាមដែលខ្ញុំបានឃើញខ្លះមកហើយនោះៗខ្ញុំហាក់ដូចជាសង្ស័យនឹងសុវាចានាងនេះណាស់ ។ ដូច្នេះ ខ្ញុំនឹងវិនិច្ឆ័យក្នុងចិត្តថា

ដូចម្ដេចបាន កាលបើនាងនាំខ្ញុំមើលផ្ទះនេះសិន ។ ដូច្នេះ សូមនាងអញ្ជើញទៅមុខនាំផ្លូវខ្ញុំ ។

ព្រះអង្គម្ចាស់ក្សត្រី ក៏នាំព្រះបាទស៊ុលតង់ទតមើលបន្ទប់ពីមួយទៅមួយគ្រប់ទាំងអស់ លើកលែងតែបន្ទប់ទទួលភ្ញៀវមួយចេញ។ ព្រះបាទស៊ុលតង់ក្រោយពីបានពិនិត្យមើលបន្ទប់គ្រប់កន្លែងទាំងអស់ នឹងក្រោយពីបានសរសើរនូវភាពផ្សេងៗពីគ្នា ក៏មានព្រះបន្ទូលទៅកាន់ព្រះអង្គម្ចាស់ក្សត្រីថា : "នាងក្រមុំ, នាងឱ្យឈ្មោះផ្ទះនេះថា ជាផ្ទះនៅជនបទឬ? ទីក្រុងយ៉ាងល្អៗ ហើយយ៉ាងធំៗផងនឹងទៅជាកន្លែងគ្មានមនុស្សនៅទៅហើយ បើសិនជាផ្ទះទាំងឡាយនៅស្រុកស្រែល្អដូចជាផ្ទះនាងនេះ ។ ខ្ញុំឥតឆ្ងល់ទៀតឡើយ នាងសប្បាយចិត្តនឹងរស់នៅទីនេះណាស់ ហើយនាងប្រហែលជាស្អប់ខ្ពើមទីក្រុងហើយ ។ សុំនាំខ្ញុំទៅមើលសួនច្បារផង ខ្ញុំសង្ឃឹមថា សួនច្បារនោះនឹងល្អសមគ្នានឹងផ្ទះពុំខាន" ។

ព្រះអង្គម្ចាស់ក្សត្រីក៏បើកទ្វារផ្លូវទៅកាន់សួនច្បារ ហើយរបស់ដែលធ្វើឱ្យព្រះអង្គចាប់ចក្ខុជាងគេ គឺទឹកផុសជាកណ្ដាប់ស្រូវ, មានពណ៌លឿងដូចជាមាស ។ ព្រះអង្គក៏ទ្រង់គង់ទតទស្សនីយភាពចម្លែកនេះដោយសេចក្ដីងឿងឆ្ងល់នឹងស្ញប់ស្ញែង រួចក៏មានព្រះបន្ទូលថា : "ទឹកអស្ចារ្យគួរឱ្យគយគន់យ៉ាងសប្បាយនេះចេញមកពីណា? តើដើមទឹកនៅឯណា? ហើយដោយវិជ្ជាសិល្បអ្វី បានជាគេអាចធ្វើឱ្យខ្សែទឹក

បាញ់ចេញឡើងដូច្នេះបាន ហើយដែលខ្ញុំយល់ថានៅក្នុងលោកយើងនេះ គ្មានរបស់យ៉ាងនេះមកប្រដូចបានឡើយ? ខ្ញុំចង់មើលរបស់អស្ចារ្យនេះឱ្យបានជិតបំផុត" មានព្រះបន្ទូលដូច្នេះបណ្ដើរ, ព្រះអង្គក៏យាងចូលទៅជិតបណ្ដើរដែរ ។ បន្ទាប់ពីនោះមក, ព្រះអង្គម្ចាស់ក្សត្រីក៏បាននាំព្រះអង្គទៅទតមើលឈើចេះច្រៀងទៀត ។

លុះយាងទៅដល់ជិតកន្លែងនោះ, ព្រះបាទស៊ុលតង់ទ្រង់ព្រះសណ្ដាប់ឮសម្លេងតន្ត្រីយ៉ាងប្លែកខុសពីតន្ត្រី ដែលព្រះអង្គទ្រង់បានព្រះសណ្ដាប់មក, ព្រះអង្គក៏ឈប់គង់នៅស្ងៀម ហើយទ្រង់ក៏ខំងាករកមើល តើពួកភ្លេងនៅឯណា ។ លុះព្រះអង្គឥតទតឃើញនរណាម្នាក់ទោះនៅទីជិតក្ដីឆ្ងាយក្ដី ក៏ប៉ុន្តែព្រះអង្គនៅតែព្រះសណ្ដាប់ឮតន្ត្រីផ្សេងៗគ្នា ទើបព្រះអង្គទ្រង់ត្រាស់សួរទៅ ព្រះអង្គម្ចាស់ក្សត្រីបារីសាដថា : "នាងក្រមុំ ចុះពួកអ្នកភ្លេងដែលខ្ញុំឮសូរលេងនេះ នៅឯណា? អ្នកទាំងនោះនៅក្នុងដី ឬអ្នកទាំងនោះបំបាំងខ្លួនក្នុងអាកាសឬ?"

បើតាមសម្លេងលេងដ៏សែនពិរោះគួរឱ្យចាប់ចិត្តនេះ អ្នកភ្លេងទាំងនោះ គួរណាស់តែបង្ហាញខ្លួនឱ្យឃើញផង ព្រោះពួកអ្នកភ្លេងទាំងនោះបានធ្វើឱ្យកើតការសប្បាយ ។

- បពិត្រព្រះករុណាថ្លៃវិសេស, ព្រះអង្គម្ចាស់ក្សត្រីទ្រង់ឆ្លើយតបដោយញញឹមថា, មិនមែនមនុស្សទេដែលបានប្រគុំតន្ត្រីលាន់ឮទ្រហឹងនេះ, គឺជាដើមឈើដែលព្រះអង្គទតឃើញនៅខាងមុខព្រះអង្គ

នេះ. ហើយបើសិនជាព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យយាងចូលទៅមុខចំនួនមួយជំហានទៀត. នោះព្រះអង្គនឹងទ្រង់អស់សង្ស័យ ហើយសម្លេងនឹងឮកាន់តែច្បាស់ឡើង ។

ព្រះបាទស៊ុលតង់ក៏យាងចូលទៅមុខ ហើយព្រះអង្គហាក់ដូចជាត្រូវស្នេហ៍នឹងភ្លេងដ៏ពិរោះនោះ ប៉ុន្តែព្រះអង្គមិនបានបណ្ដែតអារម្មណ៍ឱ្យលង់ទៅតាមសូរភ្លេងនោះទេ ទើបទ្រង់ត្រាស់សួរទៅព្រះអង្គម្ចាស់ក្សត្រីថា : "នាងក្រមុំខ្ញុំសូមអង្វរ. តើដើមឈើគួរស្ងើចនេះដុះឡើងឯង១ក្នុងសួននាងឬ? ឬមួយក៏ជាអំណោយដែលគេបានធ្វើដល់នាងឬក៏នាងបាននាំយកមកពីប្រទេសណាមួយដ៏ឆ្ងាយ? តាមខ្ញុំស្មានដើមឈើ នេះត្រូវស្ថិតនៅទីឆ្ងាយណាស់ បើសិនជាមិនដូច្នេះទេ នោះខ្ញុំប្រាកដជាបានឮគេដំណាលពុំខាន ព្រោះខ្ញុំជាអ្នកចូលចិត្តចង់ឃើញរបស់កម្រ១ ដែលកើតពីធម្មជាតិណាស់ ។ ចុះនាងហៅឈ្មោះដើមឈើនេះដូចម្ដេចទៅ?"

-បពិត្រព្រះករុណាថ្លៃវិសេស. ព្រះនាងមានព្រះសវនីយ៍ ដើមឈើនេះបានទទួលឈ្មោះថា ដើមឈើចេះច្រៀង ហើយដើមឈើនេះឥតដុះនៅក្នុងប្រទេសនេះទេ ។ គេត្រូវការពេលច្រើនណាស់ ដើម្បីនិយាយរៀបរាប់ឱ្យបានសព្វគ្រប់ថា តើដោយរឿងហេតុយ៉ាងណា បានជាដើមឈើនេះបានមកនៅក្នុងទីនេះ ។ គឺជារឿងដែលទាក់ទងទៅនឹងទឹកពណ៌លឿងនឹងបក្សាចេះនិយាយ ព្រោះដើមឈើនេះបានមក

ជាមួយគ្នានឹងវត្ថុពីរមុខនេះដែរ ។ ប៉ុន្តែបើព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យចង់ដឹង, ខ្ញុំម្ចាស់ក៏មានសេចក្ដីរីករាយនឹងនិយាយថ្វាយដែរ បន្ទាប់ពីពេលព្រះអង្គទ្រង់សម្រាក មានព្រះកាយពលស្រួលបួលឡើងវិញ ក្រែងព្រះអង្គទ្រង់នឿយហត់នឹងការប្រមាញ់កណ្ដាលកំដៅព្រះអាទិត្យ ។

- នាងក្រមុំ, ព្រះបាទស៊ុលតង់មានព្រះបន្ទូល ខ្ញុំឥតមាននឿយហត់នឹងស្ដាប់រឿងនាងសោះ ព្រោះរឿងនាងមានផលប្រយោជន៍ច្រើនដល់ខ្ញុំ ។ សូមនាងកុំបារម្ភក្រែងខ្ញុំធុញទ្រាន់អស់កម្លាំង នឹងទ្រាំស្ដាប់រឿងនាងឱ្យសោះ ។ ដូច្នេះ, សូមយើងទៅមើលទឹកពណ៌លឿងឱ្យហើយសិន ហើយខ្ញុំមានសេចក្ដីអន្ទះអន្ទែងពន់ប្រមាណចង់មើលបក្សាចេះនិយាយទៀត ។

កាលបើព្រះបាទស៊ុលតង់ ទ្រង់យាងទៅដល់កន្លែងទឹកពណ៌លឿង, ព្រះអង្គក៏ទ្រង់ខំសម្លឹងមើលខ្សែទឹក ដែលបាញ់ចេញឡើងពីអាងកើតទៅជាកណ្ដាប់ស្រូវ។ ខ្សែទឹកនេះបាញ់ឡើងខ្ពស់ ហើយធ្លាក់ចុះមកក្នុងអាងវិញគ្មានឈប់ឈរសោះ។ ព្រះអង្គអត់ទ្រាំពុំបានក៏មានព្រះបន្ទូលសួរទៅព្រះអង្គម្ចាស់ក្សត្រីថា : "បើតាមនាងពោលទឹកនេះគ្មានប្រភពទេ, ហើយទឹកនេះគ្មានបំពង់បង្ហូរមកពីទីជិតខាង ឬក៏មកពីក្រោមដីនេះទេ ។ តែខ្ញុំអាចយល់បានខ្លះថា ទឹកនេះជារបស់ចម្លែកអស្ចារ្យ ដូចជាដើមឈើចេះច្រៀងដែរ" ។

- បពិត្រព្រះនរបតី, ព្រះអង្គម្ចាស់ក្សត្រីមានសវនីយ៍ រឿងនេះដូចជាព្រះអង្គមានព្រះបន្ទូលមែន ។ ហើយជាភស្តុតាងពិតប្រាកដថា ទឹកនេះឥតហូរមកពីណាទេនោះ គឺដោយអាងនេះមានតែមួយបន្ទប់ប៉ុណ្ណោះ ។ ដូច្នេះទឹកក៏មិនអាចហូរចូលពីខាង ឬពីក្រោមបានឡើយ ។ ឯការដែលទឹកនេះកើតទៅជារបស់អស្ចារ្យ ដល់ចក្ខុព្រះអង្គនោះ គឺបណ្ដាលមកពីទឹកមួយដបតូច ដែលខ្ញុំម្ចាស់បានចាក់ទៅក្នុងអាង រួចទឹកមួយដបនោះក៏រីកទំហំឡើងពេញអាង ដោយគុណធម៌ពិសេសរបស់វា ដូចដែលព្រះអង្គទ្រង់ទតឃើញស្រាប់នេះ» ។ តមក, ព្រះបាទស៊ុលតង់ក៏យាងថយចេញឆ្ងាយពីអាងទឹក ព្រមទាំងមានព្រះបន្ទូលថា: «ចំពោះការទស្សនារបស់ខ្ញុំលើកដំបូងនេះ ប៉ុណ្ណេះឃើញថាល្មមគ្រប់គ្រាន់ហើយ ព្រោះខ្ញុំសន្យាក្នុងចិត្តថា នឹងមកមើលកន្លែងនេះឱ្យបានញឹកញយ ។ ឥឡូវសូមនាំខ្ញុំទៅមើលបក្សាចេះនិយាយទៀត» ។

បន្ទាប់ពីនោះមក, ព្រះបាទស៊ុលតង់ក៏យាងត្រឡប់ទៅកាន់លំនៅព្រះអង្គម្ចាស់ក្សត្រីវិញ ។ លុះព្រះអង្គយាងចូលទៅជិតបន្ទប់ទទួលភ្ញៀវ ព្រះអង្គក៏ទតឃើញបក្សាបក្សីជាច្រើនរាប់ពុំអស់ ទំនៅលើដើមរុក្ខាលតាវល្លិ៍នានាកំពុងស្រែកយំរៀងៗខ្លួន លាន់សូរកកែកករទ្រហឹងអឹងកង ។ ព្រះរាជាក៏ទ្រង់ត្រាស់សួរថា ចុះហេតុអ្វីបានជាបក្សាទាំងនេះ បានបបួលគ្នាមកទំកុះករនៅទីនេះ ម្ដេចមិនទៅទំដើមឈើឯទៀតក្នុងសួន ព្រោះនៅទីនោះព្រះអង្គពុំដែលឃើញ ឬឮសត្វអ្វីយំ

សោះឡើយ ។ ព្រះអង្គម្ចាស់ក្សត្រីក៏ទ្រង់ឆ្លើយទូលថា បក្សាទាំងឡាយបានហើរមកពីទីជិតខាងនេះ ដើម្បីយំបន្តតាមសម្លេងបក្សាចេះនិយាយ ។ ព្រះករុណានឹងអាចទតឃើញបក្សាចេះនិយាយនោះ នៅក្នុងទ្រុងដាក់លើមាត់បង្អួចបន្ទប់ ដែលព្រះអង្គនឹងយាងចូលទៅនេះ ។ ហើយបើសិនជាព្រះអង្គទ្រង់យកព្រះទ័យផ្ទៀងស្តាប់បន្តិច, នោះព្រះអង្គនឹងបានជ្រាបថា បក្សានេះមានសម្លេងឮជាងសម្លេងបក្សាឯទៀតទាំងអស់, សូម្បីតែសត្វចាបម្យ៉ាងដែលល្បីឈ្មោះខាងយំនោះ ក៏ពុំអាចយំឮជាងបក្សានេះដែរ ។

ព្រះបាទស៊ុលតង់ក៏បានយាងចូលទៅដល់ក្នុងបន្ទប់ទទួលភ្ញៀវ ។ ហើយដោយបក្សាកំពុងតែស្រែកយំ ព្រះអង្គម្ចាស់ក្សត្រីក៏មានព្រះសវនីយ៍ទៅកាន់បក្សាថា : “បក្សា, នេះជាព្រះបាទស៊ុលតង់, ចូរអ្នកសម្តែងអភិវន្ទនាការចំពោះព្រះអង្គ” ។ បក្សាចេះនិយាយព្រមទាំងបក្សាឯទៀតក៏ឈប់យំមួយរំពេច ហើយបក្សាអស្ចារ្យក៏និយាយថា : “សូមឱ្យព្រះបាទស៊ុលតង់បានប្រកបតែដោយសេចក្តីរីករាយ សូមឱ្យព្រះអាទិទេពជួយចម្រុងចម្រើនព្រះអង្គ ឱ្យប្រកបតែនឹងភាពរុងរឿង-ថ្កុំថ្កើង, និងសូមឱ្យព្រះអាទិទេពជួយបង្កើនព្រះជន្មព្រះអង្គឱ្យបានវែងឆ្នាំតទៅទៀត” ។

ដោយម្ហូបម្ហាក្រយាព្រះស្ងោយបានរៀបចំតម្កល់ទុកជាស្រេចនៅលើកៅអីទំរេត ក្បែរបង្អួចដែលគេដាក់ទ្រុងបក្សានោះ ព្រះអង្គក៏

ទ្រង់គង់សោយក្រយាព្រះស្ងោយ ដោយមានព្រះបន្ទូលថា : “បក្សា, យើងអរគុណនឹងសេចក្ដីគួរសមរបស់ឯងណាស់ ហើយយើងសប្បាយចិត្តនឹងបានឃើញឯងដូចជាព្រះបាទស៊ុលតង់ និងជាស្ដេចនៃបក្សាទាំងអស់” ។

ព្រះបាទស៊ុលតង់ កាលបើទ្រង់ទតឃើញម្ហូបត្រសក់នៅមុខព្រះអង្គ ហើយដែលព្រះអង្គយល់ថាជាត្រសក់ញាត់ទឹមធម្មតា ក៏ទ្រង់លូកព្រះហស្តទៅចាប់សោយ ប៉ុន្តែព្រះអង្គស្រាប់តែកើតសេចក្ដីងឿងឆ្ងល់ជាក្រៃលែង ដោយទតឃើញទឹមនោះធ្វើអំពីគជ់ទៅវិញ, ទើបព្រះអង្គមានព្រះបន្ទូលថា : “ចុះអ្វីក៏ប្លែកម្ល៉េះ ! គេនឹកឃើញយ៉ាងណាបានជាគេធ្វើទឹមអំពីគជ់ដូច្នេះ? គជ់គេឥតបរិភោគទេ” ។ ព្រះអង្គក៏ទ្រង់សម្លឹងមើលទៅព្រះអង្គម្ចាស់ទាំងពីរ និងព្រះអង្គម្ចាស់ក្សត្រីដើម្បីចង់ដឹងថា តើរបស់នោះមានន័យដូចម្ដេច, ប៉ុន្តែបក្សាក៏បានឆ្លើយជូសព្រះអង្គម្ចាស់ទាំងឡាយថា : “បពិត្រព្រះរាជាដ៏ចម្រើន, ព្រះអង្គទ្រង់ចេះកើតសេចក្ដីងឿងឆ្ងល់ជាពន្លឹកភ្លាម នឹងទឹមធ្វើអំពីគជ់ដែលព្រះអង្គទ្រង់ទតឃើញផ្ទាល់នឹងចក្ខុព្រះអង្គនេះ, ចុះហេតុអ្វីក៏ព្រះអង្គមិនទ្រង់ងឿងឆ្ងល់ភ្លាមផង ម្ដេចក៏ទ្រង់ឆាប់ជឿគេអ្វីម្ល៉េះអំពីការដែលស្រីឆ្មបក្រាបទូលថា ព្រះនាងស៊ុលតានប្រសូតបុត្រមកជាសត្វឆ្កែ, សត្វឆ្មា នឹងជាដុំឈើនោះ?

- បានជាខ្ញុំជឿ, ព្រះបាទស៊ុលតង់មានព្រះឱង្ការ, ព្រោះស្រីឆ្មបបានប្រាប់ខ្ញុំ ។

- ព្រះករុណាទ្រង់ជ្រាបទេថា, បក្សាពោល, ស្រីឆ្មបទាំងនោះជាបងស្រីបង្កើតរបស់ព្រះនាងស៊ុលតាន ប៉ុន្តែជាបងស្រីអាក្រក់ក្រៃក្រលែងមានចិត្តច្រណែនឫស្យាឈ្នានិះតែនឹងប្អូនឯង ដោយឃើញព្រះអង្គទ្រង់សព្វព្រះទ័យស្រឡាញ់ព្រះនាងយកធ្វើជាមហេសី មិនឯស្រឡាញ់វាឯណោះវិញ ។ ហើយដើម្បីបំពេញការចងគំនុំរបស់វា, វាបាននាំគ្នាពោលបំភ័ន្តព្រះអង្គ ។ ស្រីទាំងនោះនឹងឆ្លើយទទួលសារភាពខ្លួនពុំខាន, បើសិនជាព្រះអង្គហៅវាមកសួរចម្លើយ ។ បងប្អូនប្រុសពីរនាក់និងនាងស្រីជាប្អូននេះ គឺជាព្រះរាជបុត្រាបុត្រីព្រះអង្គហើយ ដែលត្រូវស្រីឆ្មបដាក់ក្នុងកញ្ជ្រែងបណ្តែតបំបរបង់ចោលតាមប្រឡាយទឹក ប៉ុន្តែដោយហេតុតែកុសលផលបុណ្យលោកជួយ, ព្រះអង្គម្ចាស់នឹងព្រះអង្គម្ចាស់ក្សត្រីក៏ត្រូវសពលោកនាយតម្រួតសួន រើសយកមកចិញ្ចឹមបីបមថ្នមថ្នាក់ហាក់ដូចជាបុត្រចេញមកពីឈាមលោកបង្កើត ។

សម្តីរបស់បក្សានេះជាសម្ភារៈមួយយ៉ាងចំណាន ជួយបំភ្លឺការវិនិច្ឆ័យរបស់ព្រះបាទស៊ុលតង់ឱ្យកាន់តែច្បាស់ឡើងមួយរំពេច ទើបព្រះអង្គទ្រង់លាន់ព្រះឱស្ឋយ៉ាងខ្លាំងថា : “បក្សា, យើងឥតមានអល់ឯកក្នុងចិត្តនិងព្រមជឿតាមការពិត ដែលឯងបានពោលបំផុសឡើងនិងបានប្រាប់យើងឱ្យដឹងនេះទេ ។ អំពើទន់ភ្លន់និងពាក្យផ្អែមល្ហែមរបស់យុវជន ដែលធ្វើឱ្យយើងមានសេចក្តីស្នេហាមកជាច្រើនណាស់ហើយនោះ, បានប្រាប់យើងច្បាស់ណាស់ទៅហើយថា យុវជនយុវតីទាំងនេះប្រាកដជាញាតិសារលោហិតរបស់យើង ។ ដូច្នេះបុត្រាបុត្រី

ទាំងឡាយ ចូរឯងចូលមកជិតបិតា. បិតានឹងឱបរឹតឯង ដើម្បីសម្តែងសញ្ញានៃសេចក្តីស្នេហារបស់បិតាជាលើកដំបូងបំផុត ចំពោះឯងរាល់គ្នា" ។ ព្រះបាទស៊ុលតង់ក៏ទ្រង់ងើបឈរឡើង ចូលទៅចាប់ត្រកងឱបរឹតព្រះអង្គម្ចាស់និងព្រះអង្គម្ចាស់ក្សត្រីជាបន្តបន្ទាប់គ្នា ហើយក៏ទ្រង់ព្រះកន្សែងជាមួយនឹងព្រះរាជបុត្រាបុត្រីទាំងនោះយ៉ាងយូរ ។ បន្ទាប់មកព្រះអង្គក៏មានព្រះបន្ទូលថា : "ប៉ុណ្ណេះមិនទាន់គ្រប់គ្រាន់ទេកូនប្រុសកូនស្រីបិតាអើយ ! សូមកូនទាំងឡាយឱបរឹតគ្នាទាំងបីនាក់ឡើង ក្នុងឋានៈជាកូនបិតា កើតចេញមកពីព្រះលោហិតស្តេចប្រទេសពែរ្ស៊ែ. ដែលមានឯងរាល់គ្នានេះហើយ ត្រូវរក្សាកិត្តិគុណរបស់ប្រទេស. មិនមែនឱបរឹតគ្នា ក្នុងឋានៈជាបុត្រលោកនាយតម្រួតសួនទេ ដែលបិតាត្រូវតែដឹងគុណលោកឥតភ្លេចសោះឡើយ ព្រោះលោកបានជួយស្រោចស្រង់អ្នក. ឱ្យមានជីវិតរស់ឡើងជាមនុស្សនឹងគេ ម្ល៉េះសមបិតាខានបានឃើញមុខកូនឯង ហើយកូនឯងក៏ខានបានឃើញព្រះភក្ត្របិតាដែរ" ។

បន្ទាប់ពីព្រះអង្គម្ចាស់និងព្រះអង្គម្ចាស់ក្សត្រីបានឱបរឹតគ្នាដោយសេចក្តីស្នេហាជាទីបំផុត និងដោយសេចក្តីសប្បាយមួយថ្មីតាមបំណងព្រះបាទស៊ុលតង់ហើយ. ព្រះបាទស៊ុលតង់ក៏ទ្រង់ចាប់សោយក្រយាព្រះស្ងោយជាមួយនឹងបុត្រាបុត្រីព្រះអង្គដោយសេចក្តីរីករាយរកអ្វីប្រៀបគ្មាន ។ ប៉ុន្តែ ព្រះអង្គទ្រង់សោយយ៉ាងប្រញិបប្រញាប់ជាទីបំផុត ។ លុះសោយហើយភ្លាម ទ្រង់ក៏មានព្រះបន្ទូលថា : "កូនទាំង

ឡាយ. ឯងរាល់គ្នាបានស្គាល់រូបបិតាហើយ ស្អែកនេះបិតានឹងនាំមាតាឯងមកឱ្យឯងស្គាល់ទៀត សូមកូនរៀបចំខ្លួនចាំទទួលមាតាឯងចុះ" ។

ព្រះបាទស៊ុលតង់ក៏យាងឡើងគង់លើសេះត្រឡប់ទៅរាជធានីវិញយ៉ាងលឿងក្រៃលែង ។ លុះព្រះអង្គយាងទៅដល់មហាប្រាសាទភ្លាម, ការដែលព្រះអង្គត្រូវធ្វើជាដំបូងបង្អស់ គឺទ្រង់ត្រាស់បង្គាប់ទៅលោកនាយករដ្ឋមន្ត្រីឱ្យទៅកោះហៅបងស្រីព្រះនាងស៊ុលតានទាំងពីរនាក់ ឱ្យចូលមកគាល់ព្រះអង្គជាប្រញាប់ ។ គេក៏បានទៅចាប់នាំខ្លួនស្រីពីរនាក់នោះមកសួរចម្លើយម្នាក់ម្តងៗ ឃើញថាបានប្រព្រឹត្តអំពើលាមកមែន, ហើយក៏ផ្តន្ទាទោសតាមកំហុស ដោយត្រូវយកដៃជើងទាំងបួនទៅចងជាប់នឹងសត្វសេះបួនដែរ ហើយវាយសេះនោះឱ្យបោលទៅទីផ្សេងគ្នា, ប្រទាញប្រទង់ខ្លួនមនុស្សទោសលុះត្រាដាច់ជាបួនកំណាត់ ។

នៅពេលនោះ ព្រះបាទស៊ុលតង់កូរូសា ដោយមានព្រះរាជបរិពារក្នុងព្រះបរមរាជវាំងហែហមផង ក៏យាងផ្ទាល់ព្រះបាទលុះត្រាទៅដល់មាត់ទ្វារនៃព្រះវិហារអ៊ីស្លាមដែលធំជាងគេ ។ រួច, បន្ទាប់ពីព្រះអង្គបានយាងចូលទៅផ្ទាល់ព្រះអង្គនាំព្រះនាងស៊ុលតានពីទីគុកដ៏តូច ដែលជាកន្លែងដែលព្រះនាងបានត្រូវគេដាក់ឃុំឃាំងឱ្យនៅសង្រោកសង្រេង សោយទុក្ខសោយទោសពន់ប្រមាណជាច្រើនឆ្នាំមកហើយ ។ ចេញផុតមកខាងក្រៅហើយ, ព្រះអង្គក៏ឱបរឹតព្រះនាង ហើយទ្រង់ព្រះកន្សែងរអាក់រអួលប្រកបដោយទឹកព្រះនេត្រាហូរចេញមកយ៉ាង

សស្រាក់ឥតឈប់ឈរ ដោយព្រះអង្គទតឃើញព្រះនាងមានភាពគួរឱ្យអាណិតអាសូរជាពន់ពេកណាស់. ទើបព្រះអង្គខំប្រឹងមានព្រះបន្ទូលដូច្នេះថា : "ម្ចាស់អូន. ខ្ញុំមកនេះ ដើម្បីសូមទោសម្ចាស់អូន ចំពោះអំពើអយុត្តិធម៌ដែលខ្ញុំបានប្រព្រឹត្តដោយអចេតនាទៅលើរូបអូន. ហើយនិងដើម្បីសូមជួសជុលជំងឺចិត្តអូន ការណ៍នេះខ្ញុំបានធ្វើរួចខ្លះទៅហើយ គឺខ្ញុំបានផ្តន្ទាទោសអ្នកដែលបាននាំខ្ញុំឱ្យធ្វើខុស ដោយកិច្ចបោកបញ្ឆោតខ្ញុំយ៉ាងអប្រិយ៍ ហើយខ្ញុំសង្ឃឹមថាម្ចាស់អូននឹងយល់ថា ការជួសជុលផ្លូវចិត្តនោះល្មមគ្រប់គ្រាន់ណាស់ហើយ កាលបើខ្ញុំនឹងធ្វើអំណោយព្រះអង្គម្ចាស់ពីរព្រះអង្គយ៉ាងប្រសើរ, និងព្រះអង្គម្ចាស់ក្សត្រីមួយព្រះអង្គជាទីស្នេហានេះ ព្រោះព្រះអង្គម្ចាស់. ព្រះអង្គម្ចាស់ក្សត្រីទាំងនេះ គឺជាបុត្រាបុត្រីម្ចាស់អូនឯង នឹងជាបុត្រាបុត្រីយើងទាំងអស់គ្នា។ ដូច្នេះ សូមយាងម្ចាស់អូន. ហើយសូមម្ចាស់អូនទទួលឋានៈព្រមទាំងកិត្តិយសទាំងឡាយ ដែលម្ចាស់អុនត្រូវមានដូចពីដើមវិញ" ។

ការសុំទោសនេះ បានធ្វើឡើងនៅចំពោះមុខប្រជាជនជាច្រើនអនេក ដែលបានរត់ទាំងហ្វូងៗមកពីគ្រប់ទិស នៅពេលដែលបានឮពីដំណឹងនេះភ្លាម ។ ដំណឹងនេះបានផ្សាយពាសពេញទីក្រុងក្នុងពេលដ៏ឆាប់បំផុត ។

ស្អែកឡើង នៅពេលពីព្រលឹមធំ. ព្រះបាទស៊ុលតង់នឹងព្រះនាងស៊ុលតាន. ដោយមានព្រះរាជបរិពារជាច្រើនហែហមផង. ក៏ទ្រង់យាងធ្វើដំណើរទៅកាន់គេហស្ថានព្រះអង្គម្ចាស់នឹងព្រះអង្គម្ចាស់ក្សត្រី ។

លុះយាងទៅដល់ បន្ទាប់ពីទ្រង់យាងចុះពីរាជអាជានេយ្យមក ព្រះបាទស៊ុលតង់ ក៏ទ្រង់បង្ហាញព្រះនាងស៊ុលតាន ឱ្យព្រះអង្គម្ចាស់បាម៉ាន ព្រះអង្គម្ចាស់ប៉ែរិស នឹងព្រះអង្គម្ចាស់ក្សត្រីប៉ារីសាដបានស្គាល់. រួចព្រះអង្គក៏មានព្រះបន្ទូលថា : "ម្ចាស់អូន. ព្រះអង្គម្ចាស់ទាំងពីរនេះជាព្រះរាជបុត្រាអូន. ឯព្រះអង្គម្ចាស់ក្សត្រីនេះជាព្រះរាជបុត្រី ។ សូមម្ចាស់អូនឱបរឹតបុត្រាបុត្រីយើងដូចជាខ្ញុំបានឱបរឹតរួចមកហើយដែរ ។ ព្រះអង្គម្ចាស់ព្រះអង្គម្ចាស់ក្សត្រីទាំងបីព្រះអង្គនេះ សមជាបុត្រាបុត្រីយើងណាស់" ។ នៅក្នុងការឱបរឹតដ៏រំភើបចិត្តនោះ ព្រះជលនេត្របានហូរចេញមកជាច្រើនបំផុត ពិសេសគឺព្រះនាងស៊ុលតាន ព្រោះជាធម្មតារបស់មាតា ដែលបានបែកមុខបុត្រធីតាអស់ពេលជាច្រើនឆ្នាំដោយក្រៀមក្រំ ហើយដែលគ្មានសង្ឃឹមថានឹងបានជួបវិញផង ហើយស្រាប់តែបានជួបមុខកូនកម្សត់វិញយ៉ាងនេះ ។

ព្រះអង្គម្ចាស់ទាំងពីរព្រះអង្គ. និងព្រះអង្គម្ចាស់ក្សត្រីបានខំខ្នះខ្នែងរៀបចំអាហារភោជន ថ្វាយព្រះបាទស៊ុលតង់ និងព្រះនាងស៊ុលតានសោយ ព្រមទាំងមន្ត្រីអ្នករាជការទាំងអស់ ដែលបានហែហមព្រះអង្គទៅបរិភោគទាំងអស់គ្នា ។ លុះក្រោយពេលបាយរួចមក. ព្រះបាទស៊ុលតង់ក៏នាំព្រះនាងស៊ុលតានទៅក្នុងសួនច្បារ. បង្ហាញព្រះនាងឱ្យទតដើមឈើចេះច្រៀង. ទឹកពណ៌លឿង ។ ចំណែកឯបក្សាព្រះនាងបានទតនៅក្នុងទ្រុងហើយៗព្រះអង្គក៏ពោលសរសើរប្រាប់ព្រះនាងសព្វគ្រប់អំពីរឿងបក្សានោះ នៅពេលកំពុងសោយក្រយាព្រះស្ងោយ លុះ

អស់មានការអ្វីដែលត្រូវការឱ្យព្រះអង្គគង់នៅទីនោះតទៅទៀតហើយ ព្រះអង្គក៏ទ្រង់ឡើងគង់ព្រះរាជអាជានេយ្យ ធ្វើព្រះរាជដំណើរចេញទៅព្រះបរមរាជវាំងវិញ ។ ព្រះអង្គម្ចាស់បាម៉ានគង់សេះនៅពីខាងស្តាំព្រះអង្គ, ព្រះអង្គម្ចាស់ប៉ែវិសពីខាងឆ្វេង ព្រះនាងស៊ុលតាននឹងព្រះអង្គម្ចាស់ក្សត្រីពីខាងដែរ តែយាងពីក្រោយព្រះបាទស៊ុលតង់, បន្ទាប់មកទើបពួកមន្ត្រីក្នុងព្រះបរមរាជវាំងអញ្ជើញបន្តបន្ទាប់គ្នាតាមឋានៈយសសក្តិ ។ លុះក្បួនដង្ហែបានទៅដល់ជិតទីក្រុង ពួកប្រជាជនដែលបានទៅដល់មុនក៏រត់ចេញពីផ្ទះមកប្រសាចឈរចាំមើលក្បួន ។ អ្នកទាំងនោះបានខំសម្លឹងមើលព្រះនាងស៊ុលតាន និងព្រះអង្គម្ចាស់ទាំងពីរព្រមទាំងព្រះអង្គម្ចាស់ក្សត្រីច្រើនជាងគេបំផុត ដោយមានការស្រែកទះដៃអបអរសាទផង ព្រោះគេសប្បាយនឹងបានឃើញព្រះនាងស៊ុលតាន បានរួចអំពីអំពើទារុណកម្មយ៉ាងវេទនា ។ ក្រៅពីនេះ, ប្រជាជនបានខំសម្លឹងមើលបក្សាក្នុងទ្រុង ដែលព្រះនាងប៉ារីសាដបានដាក់នៅមុខព្រះនាង ។ អ្នកទាំងនោះបានសរសើរដល់សម្រែកបក្សា ដែលចេះហៅបក្សាឯទៀតឱ្យហើរតាម ដោយទំលើដើមឈើនានាក្នុងស្រុកស្រែ និងនៅលើដំបូលផ្ទះតាមវិថីនៃរាជធានី ។

នៅទីបំផុត ព្រះអង្គម្ចាស់បាម៉ាន, ប៉ែវិសនិងព្រះអង្គម្ចាស់ក្សត្រីប៉ារីសាដក៏បានយាងទៅដល់ព្រះបរមរាជវាំង ដោយសេចក្តីរុងរឿងជាទីបំផុត ។ ហើយនៅល្ងាចនោះ គេបានរៀបចំអុជប្រទីបជ្វាលាភ្លឺព្រោងព្រាតដូចជាថ្ងៃ ព្រមទាំងមានលេងល្បែងកំសាន្តផ្សេងៗទាំង

នៅខាងក្នុងព្រះរាជវាំង និងនៅក្នុងទីក្រុងទាំងមូល ។ ពិធីនេះបាន បន្តទៅជាយូរថ្ងៃទើបឈប់ ។

កាលបើទ្រង់ព្រះសណ្ដាប់រឿងមកដល់ត្រង់កន្លែងនេះ ព្រះចៅស៊ុលតង់ប្រទេសឥណ្ឌា ក៏ទ្រង់អត់ទ្រាំពុំសរសើរបញ្ញាដ៏ខ្ពង់ខ្ពស់របស់ព្រះនាងស៊ុលតាន ជាមហេសីព្រះអង្គពុំបាន ដែលចេះរករឿងយ៉ាងប្លែកៗពិរោះៗនិយាយថ្វាយព្រះអង្គទ្រង់ព្រះសណ្ដាប់កំសាន្តជារាល់រាត្រីឥតដែលខានសោះឡើយ ។

រឿងមួយពាន់មួយយប់ក៏សន្មតថា ចប់សព្វគ្រប់នៅកណ្ដាលការសប្បាយទាំងនោះ ។ គឺរឿងមួយពាន់មួយយប់នេះឯងហើយ ដែលបានជួយបន្ថយការប្រមាណខុសរបស់ព្រះបាទស៊ុលតង់ទៅលើភក្ដីភាពនៃស្ត្រីទាំងអស់ ។ ព្រះអង្គក៏ទ្រង់បានត្រជាក់ព្រះទ័យឡើងវិញ ហើយព្រះអង្គទ្រង់ជឿជាក់ដល់គុណូបការៈ និងគតិបណ្ឌិតដ៏ទូលំទូលាយរបស់ព្រះនាងសេហេរ៉ាសាដ ។ ព្រះអង្គទ្រង់ព្រះចិន្ដាឃើញដល់សេចក្ដីក្លាហានរបស់ព្រះនាង ដែលព្រះនាងបានសុំខ្លួនដោយស្ម័គ្រចិត្តមកធ្វើជាមហេសីព្រះអង្គ គ្មានខ្លាចស្លាប់សោះ ព្រោះព្រះនាងក៏ដឹងខ្លួនឯងថា ព្រះនាងនឹងត្រូវគេយកទៅសម្លាប់ចោលនៅថ្ងៃស្អែកបន្ទាប់ពីយប់ដែលនាងត្រូវមកនៅរួមរក្សស្មោះស្ម័គ្រមេត្រីជាមួយព្រះអង្គ. ដូចជានារីមុនៗឯទៀតដែរ ។

ការពិចារណាឱ្យឃើញដូច្នេះ រួមជាមួយនឹងគុណសម្បត្តិដ៏ល្អជាច្រើនដែលព្រះអង្គទ្រង់ធ្លាប់មានមក ក៏បានញុំាងព្រះទ័យព្រះអង្គថា

ត្រូវតែលើកលែងទោសព្រះនាង ទើបព្រះអង្គមានព្រះបន្ទូលថា : "សេ-ហេរ៉ាសាដជាទីស្នេហា, ខ្ញុំយល់ច្បាស់ហើយថា នាងមិនខ្វះរឿងនិយាយប្រាប់ខ្ញុំទេ, ប៉ុន្តែអស់ពេលជាយូរដែរណាស់មកហើយ ដែលនាងបានធ្វើឱ្យខ្ញុំសប្បាយចិត្ត គឺនាងជួយសម្រាលកំហឹងខ្ញុំ ។ ដូច្នេះ, ខ្ញុំសូមបោះបង់ចោលដោយរីករាយ ដើម្បីជាការអនុគ្រោះដល់នាងនូវច្បាប់ដ៏ឃោរឃៅឥតមេត្តា ដែលខ្ញុំបានបង្កើតដោយខ្លួនឯង ។ ដូច្នេះខ្ញុំសូមលើកលែងទោសនាងពីត្រឹមពេលនេះ ហើយសូមនាងសម្គាល់ក្នុងចិត្តថា គឺនាងនេះហើយដែលជាអ្នកជួយដោះទុក្ខនារីទាំងអស់ ដែលត្រូវគេសម្លាប់ចោលតាមគំនុំរបស់ខ្ញុំ" ។ ព្រះនាងសេហេរ៉ាសាដក៏ស្ទុះទៅឱបព្រះបាទព្រះអង្គ, សម្តែងអំណរគុណដ៏ជ្រាលជ្រៅក្រៃលែងចំពោះព្រះអង្គ ។ លោកនាយករដ្ឋមន្ត្រីបានទទួលដំណឹងល្អនេះមុនគេ ផ្ទាល់ពីព្រះឱស្ឋព្រះបាទស៊ុលតង់ហើយមិនយូរប៉ុន្មានដំណឹងលើកលែងទោសនេះ ក៏បានផ្សាយពាសពេញទីក្រុងនិងអាណាខេត្ត ។ ប្រជាជនទាំងអស់នៅក្នុងព្រះរាជាណាចក្រឥណ្ឌាបានប្រសិទ្ធពរថ្វាយព្រះបាទស៊ុលតង់ជាច្រើន និងជាពិសេសពោលសរសើរនឹកដល់គុណព្រះនាងសេហេរ៉ាសាដជាច្រើនអនេកក្រៃលែងរកអ្វីប្រៀបគ្មានឡើយ ។

**រឿងមួយពាន់មួយយប់**
**បានបញ្ចប់ដោយបរិបូណ៌**


ឯកសហស្សរាត្រី
មួយពាន់មួយយប់